# គំរូបែបបទផែនការបន្តការសិក្សា និងការចូលរៀន (2020–21)

ការណែនាំសម្រាប់ការបំពេញផែនការបន្តការសិក្សា និងការចូលរៀន មានផ្តល់ជូនតាមរយៈ: https://www.cde.ca.gov/re/lc/documents/lrngcntntyatndncpln-instructions.docx.

| ឈ្មោះទីភ្នាក់ងារអប់រំតាមមូលដ្ឋាន (LEA) | ឈ្មោះបុគ្គលិកដែលត្រូវទំនាក់ទំនង និងតួនាទី | អ៊ីម៉ែល និងទូរសព្ទ |
|---|---|---|
| មណ្ឌលសិក្សាធិការរួបរួមស្តុកតុន (Stockton Unified School District) | Connor Sloan បណ្ឌិតផ្នែកអប់រំ នាយក LCAP | csloan@stocktonusd.net 1-209-933-7040 |

# ព័ត៌មានទូទៅ

[ការពិពណ៌នាអំពីផលប៉ះពាល់ដែលជំងឺរាតត្បាត COVID-19 មានទៅលើទីភ្នាក់ងារ LEA និងសហគមន៍របស់ខ្លួន។]

ជំងឺរាតត្បាត COVID-19 បានប៉ះពាល់ដោយផ្ទាល់ទៅលើមណ្ឌលសិក្សាធិការរួបរួមស្តុកតុន (Stockton Unified School District, SUSD) ទាំងមូល និងបានប៉ះពាល់ទៅលើជីវិតរស់នៅរបស់សិស្ស បុគ្គលិក ក្រុមគ្រួសារ និងសហគមន៍សាលារៀនរបស់យើង។ ដោយសារតែផលប៉ះពាល់នៃជំងឺរាតត្បាត COVID-19 មណ្ឌលសិក្សាធិការរួបរួមស្តុកតុន (Stockton Unified School District,SUSD) ត្រូវបានបង្ខំចិត្តបិទលែងដំណើរការរាល់អគារសិក្សា ការិយាល័យ និងសម្ភារៈបរិក្ខារទាំងអស់សម្រាប់សាធារណជន ដោយចាប់ផ្តើមនៅថ្ងៃទី17 ខែមីនា ឆ្នាំ2020 ដើម្បីធានានូវសុវត្ថិភាព និងសុខុមាលភាពរបស់សិស្ស បុគ្គលិក និងក្រុមគ្រួសារ។ ជំងឺរាតត្បាត COVID-19 បានប៉ះពាល់ដាលក្ខណៈប្រព័ន្ធដល់ផ្នែកឡូជីសស្ទិកនៃការបង្រៀន និងកិច្ចដំណើរការ នៅទូទាំងមណ្ឌលសិក្សាធិការ SUSD និងបាននាំមកនូវបញ្ហាប្រឈមនានាដល់សិស្ស និងក្រុមគ្រួសារក្នុងការទទួលបានសេវាជាមូលដ្ឋាន។ នៅអំឡុងពេលនៃជំងឺរាតត្បាតនេះ មណ្ឌលសិក្សាធិការ SUSD បានបន្តផ្តល់ជូនការសិក្សាពីចម្ងាយ ការផ្តល់អាហារដល់សិស្ស និងការអភិវឌ្ឍជំនាញវិជ្ជាជីវៈ និងសេវាកម្ម សុខភាពផ្លូវចិត្ត សុខុមាលភាពចិត្តសង្គម និងរាងកាយទៅដល់សិស្ស បុគ្គលិក និងក្រុមគ្រួសារ។ ដោយសារតែបទប្បញ្ញត្តិស្តីពីសុខភាព និងសុវត្ថិភាព ដែលបានកំណត់ដោយរដ្ឋកាលីហ្វ័រញ៉ា ដូច្នេះ មណ្ឌលសិក្សាធិការ SUSD បានផ្តល់ជូននូវរាល់បទពិសោធន៍សិក្សានារដូវក្តៅទាំងអស់ និងការអភិវឌ្ឍជំនាញវិជ្ជាជីវៈ តាមរយៈប្រព័ន្ធកម្មវិធីសិក្សាពីចម្ងាយ និងបានចាប់ផ្តើមនៅឆ្នាំសិក្សា2020-2021 ជាមួយនឹងការផ្តល់ជូនការសិក្សាពីចម្ងាយទៅដល់សិស្សដែលបានចុះឈ្មោះចូលរៀនទាំងអស់ ទន្ទឹមគ្នានឹងការផ្តល់ជូនអាហារដល់សិស្សដែលបានចូលរៀនទាំងអស់ ជាមួយនឹងឱកាសក្នុងការទទួល យកអាហារពេលព្រឹក អាហារពេលថ្ងៃត្រង់ និងអាហារពេលល្ងាច ពីទីតាំងសាលារៀនទាំង 28 កន្លែង ដែលស្ថិតនៅពេញទូទាំងព្រំប្រទល់មណ្ឌលសិក្សា ធិការដែលត្រូវចូលរៀន។ គ្រប់ទីតាំងសាលារៀនទាំងអស់ មានបុគ្គលិកប្រចាំការនៅអំឡុងពេលក្នុងសប្តាហ៍ដើម្បីដោះស្រាយបញ្ហាតម្រូវការរបស់ សិស្ស និងក្រុមគ្រួសារ តាមរយៈការណាត់ជួប និងការអនុវត្តតាមការណែនាំ និងពិធីសារស្តីពីសុវត្ថិភាព និងសុខភាព។ រាល់ការរំខានដែលបង្កឡើងដោយជំងឺរាតត្បាត COVID-19 បានបង្កើតនូវបទពិសោធន៍គួរឲ្យតក់ស្លុតពាក់ព័ន្ធនឹងការញែកឲ្យនៅដាច់ដោយឡែកពីគ្នា ដោយនាំមកនូវការកើនឡើង នៃចំនួនបុគ្គលិក សិស្ស និងក្រុមគ្រួសារដែលជួបប្រទះភាពថប់បារម្ភ និងការតក់ស្លុត បណ្តាលមកពីការដាក់ឲ្យនៅដាច់ដោយឡែក និងការផ្តាច់ទំនាក់ទំនង ព្រមជាមួយនឹងការឃ្លាតឆ្ងាយពីគ្នារវាងសាលារៀន និងសហគមន៍នៅអំឡុងពេលនៃជំងឺរាតត្បាតទូទាំងសកលនេះ។

ជាការឆ្លើយតបទៅនឹងការបិទអគារសិក្សា លេខខ្សែទូរសព្ទបន្ទាន់ មានផ្តល់ជូន ដើម្បីឲ្យភាគីពាក់ព័ន្ធអាចចូលរួមពិភាក្សាដោយផ្ទាល់ ឬផ្ញើសារសម្រាប់ការគាំទ្រផ្នែកបច្ចេកវិទ្យា ជំនួយសិក្សាពីចម្ងាយ គិលានុបដ្ឋាកប្រចាំមណ្ឌលសិក្សា អ្នកពិគ្រោះយោបល់នៅបឋមសិក្សា និងវិទ្យាល័យ គ្រូពេទ្យគ្លីនិកផ្នែកជំងឺផ្លូវចិត្ត និង

បុគ្គលិកផ្នែកសុខុមាលភាព និងការចូលរៀនរបស់កុមារ។ ជំងឺ COVID-19 បានប៉ះពាល់យ៉ាងខ្លាំងដល់កាលវេលានៃការទទួល និងការផ្តល់ធនធានចាំបាច់នានា (ឧ.ទា. សម្ភារៈការពារផ្ទាល់ខ្លួន (PPE) កុំព្យូទ័រយួរដៃ វ៉ាយហ្វាយហតស្ប៉ត (WiFi hot spot) សម្ភារៈផ្គត់ផ្គង់ការបង្រៀន កម្មវិធីរៀបចំផែនការស្ថាប័នសម្រាប់សិស្ស ជញ្ជាំងខណ្ឌកញ្ចក់ផ្លិកស៊ី)។ មណ្ឌលសិក្សាធិការ បន្តផ្តល់ឱកាសឲ្យភាគីពាក់ព័ន្ធផ្តល់យោបល់ត្រឡប់ និងមតិចូលរួមទៅលើតម្រូវការ និងឆ្លើយតបទៅកាន់តម្រូវការទាំងអស់ឲ្យបានឆាប់ និងប្រកបដោយភាពច្នៃប្រឌិតតាមដែលអាចធ្វើបាន នៅក្នុងទិដ្ឋភាព "ពិតថ្មីមួយ" ដែលជំងឺ COVID-19 បានបង្កើតឡើងសម្រាប់យើងគ្រប់គ្នាដែលត្រូវរស់នៅ។ បុគ្គលិកបង្រៀនដែលសហការគ្នាធ្វើការងារនៅក្នុងការបង្កើតកាលវិភាគបង្រៀន-រៀនពីចម្ងាយ ប្រព័ន្ធបទពិសោធន៍សិក្សាក្នុងពេលតែមួយ និងក្នុងពេលផ្សេងគ្នា កម្មវិធីប្រមូលសិស្សចូលរៀនវិញតាមបណ្តាញអ៊ីនធឺណិត (Back To School Nights) និងត្រូវបានផ្តល់ជូនជាមួយនឹងការអភិវឌ្ឍជំនាញវិជ្ជាជីវៈដែលផ្តោតទៅលើការជំរុញសិស្សឲ្យចូលរួមជាមួយការសិក្សាពីចម្ងាយយ៉ាងតឹងរឹងប្រកបដោយគុណភាពខ្ពស់ ទន្ទឹមគ្នានឹងការធានាថាសិស្ស និងគ្រួសាររបស់ពួកគេទទួលបានកម្មវិធីសិក្សាស្របតាម ស្តង់ដាតាមអនឡាញ និងទទួលបានសៀវភៅសិក្សាគោលជាក់ស្តែងរបស់ពួកគេ និងសៀវភៅកិច្ចសម្រាប់ការសិក្សាដែលអាចប្រើប្រាស់បាន។ ការផ្លាស់ប្តូរកម្មវិធី និងការបិទអគារមណ្ឌលសិក្សាធិការដើម្បីដោះស្រាយបញ្ហាគ្រោះអាសន្ននៃជំងឺ COVID-19 បានបង្ហាញឲ្យឃើញនូវផលប៉ះពាល់ធំៗទៅលើសិស្ស បុគ្គលិក និងក្រុមគ្រួសារ។

ផ្តល់ផលប៉ះពាល់ធ្ងន់ធ្ងរបំផុតមួយចំនួននៃការបិទអគារសិក្សា គឺជាបញ្ហាប្រឈមនៃការធានាថា៖ រាល់កង្វះស្បៀងអាហារដែលកំពុងប្រឈម ត្រូវបានផ្តល់ជូនជាមួយនឹងអាហារ/ចំណីអាហារ សិស្សទាំងអស់មានកុំព្យូទ័រ/កុំព្យូទ័រយួរដៃប្រើប្រាស់ និងលទ្ធភាពក្នុងការប្រើប្រាស់អ៊ីនធឺណិត ការផ្តល់សេវាពិគ្រោះយោបល់ជាលក្ខណៈបុគ្គល និងជាក្រុម និងសេវាសុខភាពផ្លូវចិត្ត រក្សាទំនាក់ទំនង និងការផ្តល់សេវាកម្មដោយផ្ទាល់ដល់ក្រុមគ្រួសារដែលឪពុក

ម្តាយទើបលែងលះថ្មីៗ ដែលទីតាំង និងលេខទូរសព្ទ ទំនាក់ទំនងរបស់ពួកគេ បានផ្លាស់ប្តូរជាញឹកញាប់ និងជាមួយសិស្សដែលតម្រូវឲ្យមានទំនាក់ទំនង និងបានទទួលការទាក់ទងផ្ទាល់ជាមួយមនុស្សពេញវ័យ សម្រាប់សេវាកម្មនានាដូចជា ការព្យាបាលដោយចលនា និងការព្យាបាលមុខងារវិជ្ជាជីវៈ ការ ព្យាបាលផ្នែកសម្តី និងចល័តភាព និងការគាំទ្រផ្នែករាងកាយសម្រាប់សិស្សដែលមិនអាចល័តចុះឡើងបាន។ ផលប៉ះពាល់នៃទីជម្រកដែលមានស្រាប់សម្រាប់សុវត្ថិភាព ការសិក្សាពីចម្ងាយ និងការមិនមានលទ្ធភាពជួបជុំជាមួយមិត្តរួមថ្នាក់ និងអ្នករួមការងារជាមួយគ្នាដោយផ្ទាល់ បទពិសោធន៍សិក្សា តាមរយៈទំនាក់ទំនងពីចម្ងាយ និងការចូលរួមក្នុងកម្មវិធីដំណាច់ឆ្នាំសិក្សា ឬកម្មវិធីបើកបវេសនកាលឆ្នាំសិក្សាថ្មី ការឡើងថ្នាក់ ការបញ្ចប់ការសិក្សាតាមបណ្តាញអ៊ីនធឺណិត ទាំងអស់នេះ បានបង្ហាញឲ្យឃើញនូវផលប៉ះពាល់ផ្លូវចិត្តសង្គម និងផលប៉ះពាលសុខភាពផ្លូវចិត្ត ដែលយើងមិនដែលធ្លាប់ឆ្លងកាត់រួមគ្នាពីមុនមក ក្នុងនាមជាប្រព័ន្ធសាលារៀន និងសហគមន៍មួយ។ ផលប៉ះពាល់ផ្ទាល់មួយនៃជំងឺរាតត្បាត COVID-19 រួមមាន៖ ការបង្រៀនដោយផ្ទាល់ និងការសិក្សារៀនសូត្ររបស់សិស្សដែលប្រព្រឹត្តទៅក្នុងទីកន្លែងស្នាក់នៅរបស់សិស្សនៅទុលមុខកញ្ចក់អេក្រង់កុំព្យូទ័រ ជាមួយនឹងការរៀន-បង្រៀន និងការគាំទ្រភាគច្រើនដែលប្រព្រឹត្តទៅតាមរយៈប្រព័ន្ធកម្មវិធីពីចម្ងាយ និងនៅឆ្ងាយពីគ្នា ការអង្កេតមើលជាប្រព័ន្ធទៅលើតម្រូវការកាន់តែច្រើនឡើងសម្រាប់ការទទួលបានការអនុវត្តការយល់ដឹងអំពីការប៉ះទង្គិច និងការអនុវត្តការកែលម្អឡើងវិញសម្រាប់សិស្សទាំងអស់ តួនាទីនៃការគ្រប់គ្រង និងការជំរុញទាំងមនុស្សពេញវ័យ និងសិស្សឲ្យចូលរួមនៅក្នុង "ទិដ្ឋភាពពិតថ្មីមួយ" ដែលបង្ហាញឲ្យឃើញតាមរយៈជំងឺរាតត្បាត COVID-19 ការអនុញ្ញាតឲ្យសិស្សដែលគ្មានលទ្ធភាពស្ថិតនៅក្នុងថ្នាក់រៀនជាក់ស្តែងជាមួយគ្រូបង្រៀនរបស់ពួកគេ និងដែលមាននៅក្នុងកន្លែងស្នាក់នៅរបស់ពួកគេពីថ្ងៃចន្ទដល់ថ្ងៃសុក្រ អំឡុងម៉ោងសិក្សាពីមុនមក ការសិក្សាដែលផ្តោតលើការប្រើប្រាស់ពិភពសិក្សាពីចម្ងាយតាមប្រព័ន្ធកុំព្យូទ័រអនឡាញ សិស្ស និងមនុស្សពេញវ័យដែលស្ថិតនៅមុខកញ្ចក់អេក្រង់កុំព្យូទ័រក្នុងរយៈពេលវែងជាប្រចាំ ឪពុកម្តាយ និងអាណាព្យាបាលដែលធ្វើកិច្ចការរបស់ពួកគេយ៉ាងអស់ពីលទ្ធភាពដើម្បីគាំទ្រដល់ការសិក្សាកូនៗរបស់ពួកគេ នៅក្នុងកន្លែងស្នាក់នៅរបស់ពួកគេ តម្រូវការច្រើនឡើងសម្រាប់ការយល់ដឹងអំពីការប៉ះទង្គិច និងការបង្រៀន និងរៀនដែលឆ្លើយតបតាមវប្បធម៌ និងភាសា និងការដោះស្រាយរាល់ឧបសគ្គផ្នែកហិរញ្ញវត្ថុ សុខភាព ផ្លូវចិត្ត មនោសញ្ចេតនា និងសង្គម ដែលមានការផ្សារភ្ជាប់ជាមួយនឹងជំងឺរាតត្បាត COVID-19 និងស្របជាមួយនឹងបទពិសោធន៍នៃការស្នាក់នៅពីមុនមក ក្នុងរយៈពេលវែង។ ការកម្រើកឡើងនៃផលប៉ះពាល់នៃជំងឺរាតត្បាត COVID-19 ទៅលើសហគមន៍ មានទំហំធំធេង និងបង្ហាញឲ្យឃើញនូវភាពអាសន្នជារួមនៅក្នុងការដោះ ស្រាយបញ្ហាតម្រូវការចិត្តសង្គម និងតម្រូវការសិក្សារៀនសូត្ររបស់សិស្ស បុគ្គលិក និងក្រុមគ្រួសារ។

មណ្ឌលសិក្សាធិការ SUSD អំឡុងការសិក្សានារដូវផ្ការីក និងរដូវក្តៅឆ្នាំ2020 បានសហការជាមួយភាគីពាក់ព័ន្ធ បានផ្តល់ឱកាសឲ្យភាគីពាក់ព័ន្ធធ្វើការផ្តល់មតិយោបល់ ដោយប្រាថ្នាចង់ឲ្យសិស្សទទួលបានការសិក្សាតាមរយៈគំរូនៃការបង្រៀនប្រកបដោយសុវត្ថិភាព និងសុខភាព នៅក្នុងកន្លែងសិក្សា ជាក់ស្តែង និង/ឬ

ការសិក្សាពីចម្ងាយ ទន្ទឹមគ្នានឹងការធ្វើ ផែនការសម្រាប់ប្រព័ន្ធសិក្សាជាយុទ្ធសាស្ត្រ និងអន្តរាគមន៍នានាដែលចាំបាច់ត្រូវផ្តល់ជូនដល់ សិស្ស ដើម្បីជួយអភិវឌ្ឍជំនាញតាមស្តង់ដាកម្រិតថ្នាក់ដោយផ្ទាល់ សុខភាពផ្លូវចិត្ត ការគាំទ្រសុខុមាលភាពចិត្តសង្គម ដើម្បីដោះស្រាយបញ្ហាប្រឈមដែលបានជួបប្រទះ តាមរយៈការទទួលបានការសិក្សានៅអំឡុងរដូវផ្ការីក និងអំឡុងរដូវក្តៅ ដោយសារតែផលប៉ះពាល់នៃជំងឺរាតត្បាត COVID-19។ ក្នុងនាមជា

មណ្ឌលសិក្សាធិការ យើងឲ្យតម្លៃលើតម្រូវការដើម្បីដោះស្រាយបញ្ហាគោលដៅសិក្សា និងការលូតលាស់ផ្លូវចិត្តសង្គមរបស់សិស្ស ជាមួយនឹងគោលវិធីប្រកបដោយសមធម៌ដែលបានផ្តោតនៅក្នុងការបំពេញតម្រូវការនៃយុវជនក្រោមការថែទាំរបស់ឪពុកម្តាយចិញ្ចឹម អ្នកសិក្សាភាសាអង់គ្លេស ក្រុមគ្រួសារដែលឪពុកម្តាយទើបលែងលះ ក្រុមអ្នកដែលមានប្រាក់ចំណូលទាប និងក្រុមសិស្សអប់រំពិសេស។ នៅក្នុងការផ្តល់ជូនសេវាសិក្សារៀនសូត្រ អាហារូបត្ថម្ភ សុខុមាលភាពផ្លូវចិត្ត និងចិត្តសង្គមដែលចាំបាច់នានា ផែនការបន្តការសិក្សា និងការចូលរៀនរបស់យើង គឺមានភាពស្របគ្នាទៅនឹងការ រំពឹងទុកនៃរាល់បទបញ្ជាសុខភាពសាធារណៈរបស់រដ្ឋ និងខោនធីទាំងអស់ ដើម្បីធានាថាក្នុងនាមជាមណ្ឌលសិក្សាធិការ យើងកំពុងបំពេញតម្រូវការរបស់សិស្ស យើងដោយសុវត្ថិភាពតាមរយៈការផ្តល់ជូនដំណាក់កាលបង្រៀនគ្រប់យ៉ាងដែលអាចផ្តល់ជូនបាន នៅពេលយើងបន្តសម្របសម្រួលតាមទិដ្ឋភាពពិតថ្មីដែលបានបង្ហាញឲ្យឃើញតាមរយៈផលប៉ះពាល់នៃជំងឺ COVID-19 និងទទួលស្គាល់ការផ្លាស់ប្តូរ និងលក្ខណៈខ្លាំងក្លានៃជំងឺរាតត្បាតនេះ។

# ការចូលរួមរបស់ភាគីពាក់ព័ន្ធ

[ការពិពណ៌នាអំពីការខិតខំប្រឹងប្រែងដែលបានធ្វើឡើងដើម្បីស្នើសុំមតិយោបល់របស់ភាគីពាក់ព័ន្ធ។]

កិច្ចដំណើរការ និងកិច្ចខិតខំប្រឹងប្រែងចូលរួមរបស់ភាគីពាក់ព័ន្ធទាំងអស់ដែលមណ្ឌលសិក្សាធិការរូបរួមស្តុកតុន (Stockton Unified School District, SUSD) បានធ្វើឡើង នៅក្នុងការផ្តល់ឱកាសសម្រាប់យោបល់ត្រឡប់របស់ភាគីពាក់ព័ន្ធ សម្រាប់អ្នកដែលទទួលបាន ឬមិនទទួលបានការស្ទង់មតិដែលពាក់ព័ន្ធនឹងការប្រើប្រាស់អ៊ីនធឺណិត ការស្ទង់ប្រជាមតិតាមទូរសព្ទ ការសន្ទនារបស់សហគមន៍លើមតិយោបល់ត្រឡប់តាមអនឡាញ និងតាមការហៅទូរសព្ទចូលរួមលើបណ្តាញអ៊ីនធឺណិត ការហៅទូរសព្ទដោយផ្ទាល់ទៅកាន់គ្រួសារ កិច្ចប្រជុំសហការថ្នាក់ក្រសួងស្តីពីការផ្សព្វផ្សាយជាយុទ្ធសាស្ត្រដល់ក្រុមគ្រួសារដែលប្រឈមជាមួយភាពលំបាកក្នុងការតភ្ជាប់បណ្តាញ ការផ្សព្វផ្សាយតាមបណ្តាញព័ត៌មានសង្គម កិច្ចប្រជុំគណៈកម្មាធិការប្រឹក្សាយោបល់ឪពុកម្តាយ/អាណាព្យាបាលតាមមណ្ឌលសិក្សាធិការ ខិត្តប័ណ្ណ និងឯកសារផ្តល់ព័ត៌មានដែលបានចែកចាយនៅតាមហាងទំនិញរបស់ សហគមន៍ ការផ្សព្វផ្សាយរបស់បុគ្គលិកជាយុទ្ធសាស្ត្រតាមរយៈការចុះសួរសុខទុក្ខតាមផ្ទះ ការហៅទូរសព្ទទៅកាន់ក្រុមគ្រួសារដែលប្រឈមនឹងបញ្ហា លំបាកក្នុងការតភ្ជាប់បណ្តាញ និងលទ្ធភាពទទួលបានទំនាក់ទំនង ភាពជាដៃគូជាមួយអង្គការស្ថាប័ននៅក្នុងកិច្ចខំប្រឹងប្រែងផ្សព្វផ្សាយ និងចូលរួម សម្រាប់ក្រុមគ្រួសារ និងការពិភាក្សាបែបសហការជាមួយអ្នកដឹកនាំសហជីព និងស្ថាប័ននៃមណ្ឌលសិក្សាធិការ SUSD។ មណ្ឌលសិក្សាធិការ SUSD បានផ្តល់ឱកាសតាមរយៈប្រព័ន្ធកម្មវិធីពីចម្ងាយ/ឆ្ងាយពីគ្នាសម្រាប់កិច្ចពិភាក្សាបែបសហការស្តីពីគំរូបង្រៀន/រៀនផ្សេងៗដែលបានស្នើឡើងដើម្បី អនុវត្ត ដែលអាចផ្តល់ជូនបាននៅក្នុងដំណាក់កាលនៃការបង្រៀនទៅលើសុខភាពពាក់ព័ននឹងជំងឺរាតត្បាតផ្សេងៗ ដែលអ្នកចូលរួមអាចជ្រើសរើសឡូកចូលបានតាមរយៈការភ្ជាប់តាមកុំព្យូទ័រ ទូរសព្ទ ឬផ្ញើមតិយោបល់ និងសំណួររបស់ពួកគេទៅកាន់មណ្ឌលសិក្សាធិការជាលាយលក្ខណ៍អក្សរ។ សេវាបកប្រែឯកសារ/បកប្រែផ្ទាល់មាត់ ត្រូវបានផ្តល់ជូន និងផ្តល់ឲ្យនៅអំឡុងពេលកិច្ចសន្ទនាស្តីពីការចូលរួមរបស់ភាគីពាក់ព័ន្ធ ហើយការស្ទង់មតិនេះ ត្រូវបានផ្តល់ជូនជាចម្រុះភាសា។ វេទិកាចូលរួមរបស់សិស្ស ត្រូវបានសម្របសម្រួលដោយក្រុមវាគ្មិនសិស្សដែលបានផ្តល់ឱកាសឲ្យសិស្សានុសិស្សចែករំលែកការយល់ឃើញ និងតម្រូវការដែលស្របតាមការសិក្សាពីចម្ងាយ និងការចូលទៅប្រើប្រាស់ធនធានសុខភាពចិត្តសង្គម និងផ្លូវចិត្ត។ មណ្ឌលសិក្សាធិការ SUSD បានផ្តល់ឱកាសដល់គណៈកម្មាធិការពិគ្រោះយោបល់សហគមន៍ (Community Advisory Committee, CAC), គណៈកម្មាធិការពិគ្រោះយោបល់អ្នកសិក្សាភាសាអង់គ្លេសមណ្ឌលសិក្សាធិការ (District English Learner Advisory Committee, DELAC) និងគណៈកម្មាធិការពិគ្រោះយោបល់ឪពុកម្តាយ (Parent Advisory Committee, PAC) ដើម្បីចែករំលែកនូវតម្រូវការ មតិយោបល់ និងទស្សនៈដែលគាំទ្រដល់ការអភិវឌ្ឍផែនការបន្តការសិក្សា និងការចូលរៀន។ សាលាក្រុង ម៉ោងចូលរួមស្តាប់ និងម៉ោងសិក្សាសម្រាប់ក្រុមប្រឹក្សាពិសេស ត្រូវបានរៀបចំឡើងតាមប្រព័ន្ធអ៊ីនធឺណិតដោយផ្តល់ឱកាសឲ្យភាគីពាក់ព័ន្ធធ្វើការចែករំលែកមតិយោបល់ដែលបានប្រើប្រាស់ដើម្បីផ្តល់ព័ត៌មានអំពីផែនការបន្តការសិក្សា និងការ ចូលរៀន។ កិច្ចខិតខំប្រឹងប្រែងទាំងនេះ ត្រូវបានធ្វើឡើងក្នុងពេលតែមួយនៅពេលដែលការស្ទង់មតិ និងការស្ទង់ប្រជាមតិតាមទូរសព្ទត្រូវបានផ្តល់ ជូនជាទម្រង់នៃឱកាសផ្សព្វផ្សាយការចូលរួមសម្រាប់ភាគីពាក់ព័ន្ធនៅក្នុងការផ្តល់ការចូលរួមមតិដ៏មានតម្លៃ ដែលបានយកទៅប្រើប្រាស់ដើម្បីផ្តល់ ព័ត៌មានអំពីកិច្ចដំណើរការរៀបចំផែនការរបស់មណ្ឌលសិក្សាធិការ SUSD នៅក្នុងការដោះស្រាយបញ្ហាធ្វើផែនការយុទ្ធសាស្ត្រដែលផ្តោតទៅលើការសិក្សារៀនសូត្រ ការចូលរៀន ការចូលរួមរបស់ឪពុកម្តាយ និងសិស្ស សុខភាពផ្លូវចិត្ត និងសុខុមាលភាពចិត្តសង្គម វប្បធម៌

និងសមភាព សេវាអាហា រូបត្ថម្ភ និងសេវាសុខភាព និងឡជីសស្ទិកសិក្សាពីចម្ងាយ។ សៀវភៅណែនាំស្តីពីការសិក្សាពីចម្ងាយ ត្រូវបានបង្កើតឡើងដោយរួមសហការ ជាមួយការរួមចំណែក និងការចូលរួមមតិយោបល់របស់បុគ្គលិក និងក្រុមគ្រួសារ ហើយសៀវភៅណែនាំនេះ ត្រូវបានផ្តល់ជូនដល់ក្រុមគ្រួសារ និងបានបកប្រែជាចម្រុះភាសា។ ការចូលរួម យោបល់ត្រលប់ និងមតិចូលរួមរបស់ភាគីពាក់ព័ន្ធ ត្រូវបានយកមកវិភាគ ទិន្នន័យវិភាគនេះ ត្រូវបានប្រើប្រាស់ដើម្បីកំណត់ ពីទំនោរកើតចេញមកពីយោបល់ត្រលប់ ដែលទទួលបានពីភាគីពាក់ព័ន្ធ តម្រូវការរបស់សិស្ស បុគ្គលិក និងគ្រួសារ ត្រូវបានកំណត់ ហើយសុខភាព សុវត្ថិភាព និងឡជីសស្ទិកបង្រៀនសម្រាប់ផ្តល់ជូនការបង្រៀនហ្មត់ចត់ប្រកបដោយគុណភាពខ្ពស់ ត្រូវបានយកមកពិចារណា សវនាការសាធារណៈ ត្រូវបានរៀបចំធ្វើឡើងដោយផ្តល់ឱកាសឲ្យមានការផ្តល់យោបល់ត្រលប់របស់ភាគីពាក់ព័ន្ធទៅលើវិធានការជាក់លាក់ និងការចំណាយដែលបានស្នើ ដែលត្រូវរួមបញ្ចូលទៅក្នុងផែនការបន្តសិក្សា និងការចូលរៀន (Learning Continuity & Attendance Plan, LCP) និងត្រូវបានបង្ហោះនៅលើគេហទំព័ររបស់មណ្ឌលសិក្សាធិការ SUSD ជាមួយនឹងសំណៅចម្លងដែលអាចស្វែងរកបាននៅការិយាល័យមណ្ឌលសិក្សាធិការ ប្រធានគ្រប់គ្រង បានឆ្លើយតបជាលាយលក្ខណ៍អក្សរទៅកាន់សំណួរដែលបានបិទផ្សាយនៅកិច្ចប្រជុំ CAC, DELAC, និង PAC, ហើយសវនាការសាធារណៈស្តីពីផែនការនេះ ត្រូវ បានរៀបចំឡើងនៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សាភិបាលថ្ងៃទី15 ខែកញ្ញា មុនពេលសម្រេចបញ្ចប់ និងអនុម័តលើផែនការបន្តការសិក្សា និងការចូលរៀន (Learning Continuity and Attendance Plan, LCP) នេះ នៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សាភិបាលមណ្ឌលសិក្សាធិការ SUSD ដែលបានរៀបចំឡើងនៅថ្ងៃទី22 ខែកញ្ញា ឆ្នាំ2020។ មណ្ឌលសិក្សាធិការ SUSD បានចាប់ផ្តើមជំរុញឲ្យភាគីពាក់ព័ន្ធចូលរួមនៅរដូវផ្ការីកឆ្នាំ 2020 នៅក្នុងកិច្ចដំណើរការធ្វើផែនការដើម្បីបំពេញតម្រូវការរបស់សិស្ស ក្រុមគ្រួសារ និងបុគ្គលិក តាមរយៈកិច្ចដំណើរការអភិវឌ្ឍបែបសហការ។

[ការពិពណ៌នាអំពីជម្រើសដែលផ្តល់ជូនសម្រាប់ការចូលរួមពីចម្ងាយនៅក្នុងកិច្ចប្រជុំសាធារណៈ និងការធ្វើសវនាការសាធារណៈ។]

មណ្ឌលសិក្សាធិការ SUSD បានលើកកម្ពស់ការចូលរួមរបស់ភាគីពាក់ព័ន្ធតាមរយៈការហៅទូរសព្ទ សារជាអក្សរ ជម្រើសអ៊ីម៉ែល ការផ្សព្វផ្សាយបន្តតាមបណ្តាញព័តមានសង្គម ទំនាក់ទំនងជាមួយឪពុកម្តាយនៅក្នុងទីតាំងសាលារៀន កិច្ចប្រជុំគណៈកម្មការមាតាបិតា/ក្រុមគ្រួសារ ដែលចែករំលែកពីកាលបរិច្ឆេទ និងមធ្យោបាយផ្សេងៗដើម្បីភ្ជាប់ទំនាក់ទំនង និងចូលរួមនៅក្នុងកិច្ចប្រជុំសាធារណៈ ឱកាសក្នុងការផ្តល់យោបល់ត្រឡប់ និងការស្នើសុំជាលាយលក្ខណ៍អក្សរទៅដល់ការិយាល័យមណ្ឌលសិក្សាធិការ និងគេហទំព័រដែលបង្ហោះផ្សាយព័ត៌មានសំខាន់ៗ និងការចូលប្រើប្រាស់ធនធានដែល គាំទ្រដល់ផែនការបន្តការសិក្សា និងការចូលរៀន។ ការហៅចូលតាមទូរសព្ទ និង/ឬភ្ជាប់ទំនាក់ទំនងតាមមធ្យោបាយជម្រើសពីចម្ងាយ នៃឧបករណ៍កុំព្យូទ័រ និងការផ្ញើមតិយោបល់ជាលាយលក្ខណ៍អក្សរ ត្រូវបានផ្តល់ជូនសម្រាប់ការចូលរួមនៅក្នុងកិច្ចប្រជុំសាធារណៈ និងសវនាការសាធារណៈដែល គាំទ្រដល់ផែនការបន្តការសិក្សា និងការចូលរៀន (Learning Continuity and Attendance Plan, LCP)។ រាល់កិច្ចប្រជុំសាធារណៈ ទាំងអស់អាចចូលរួមបានដោយភាគីពាក់ព័ន្ធដែលជ្រើសរើសភ្ជាប់ទំនាក់ទំនងតាមការហៅទូរសព្ទ ឬតាមប្រព័ន្ធអេឡិចត្រូនិកផ្សេងទៀត ដើម្បីអង្កេតតាមដាន និងបង្ហាញ ប្រាប់ដល់ក្រុមប្រឹក្សានាយកនៃមណ្ឌលសិក្សាធិការរួបរួមស្តុកតុន (Stockton Unified School District, SUSD)។ អ៊ីម៉ែល សារជាអក្សរ និងការហៅ ទូរសព្ទ ត្រូវបានផ្ញើជូន ព្រមជាមួយនឹងបញ្ជីរាយនាមសិស្សដែលបានចុះឈ្មោះចូលរៀនរបស់មណ្ឌលសិក្សាធិការ ដើម្បីផ្តល់ដំណឹងដល់ភាគីពាក់ព័ន្ធ ឲ្យបានជ្រាបអំពីកិច្ចប្រជុំសាធារណៈ និងការណែនាំអំពីរបៀបចូលទៅកាន់កិច្ចប្រជុំក្រុមប្រឹក្សាមណ្ឌលសិក្សាធិការ SUSD និងសេវាកម្មបកប្រែសម្រាប់ កិច្ចប្រជុំសាធារណៈ។ កិច្ចប្រជុំផ្តោតលើប្រធានបទគាំទ្រដល់ផែនការបន្តការសិក្សា និងការចូលរៀន ត្រូវបាន បង្ហាញប្រាប់ទៅដល់ភាគីពាក់ព័ន្ធតាម អ៊ីម៉ែល ការហៅទូរសព្ទ/សារជាអក្សរ ការបង្ហោះផ្សាយតាមគេហទំព័រ និងការផ្សព្វផ្សាយតាមបណ្តាញព័ត៍មានសង្គម។

[សេចក្តីសង្ខេបនៃយោបល់ត្រឡប់ដែលផ្តល់ដោយក្រុមភាគីពាក់ព័ន្ធ។]

គំនិត និងទំនោរដែលកើតចេញពីការការវិភាគលើយោបល់ត្រលប់ បានមកពីភាគីពាក់ព័ន្ធ ដែលផ្តោតជាចម្បងទៅលើ៖ តម្រូវការសម្រាប់ឲ្យសិស្សទទួលបានកុំព្យូទ័រយួរដៃ និងវ៉ាយហ្វាយហតស្ប៉ត (WiFi hot spot) ដើម្បីធានាបាននូវការតភ្ជាប់បណ្តាញនៅក្នុងទីកន្លែងស្នាក់នៅរបស់ពួកគេ តម្រូវ ការសម្រាប់ការពិគ្រោះយោបល់ និងសេវាសុខភាពផ្លូវចិត្តដែលមានផ្តល់ជូនរួចជាស្រេចទៅដល់សិស្ស និងនៅក្នុងការគាំទ្រដល់សុខុមាលភាពបុគ្គលិក និងគ្រួសារដែលមានជាប់ទាក់ទងទៅនឹងផលប៉ះទង្គិចនៃជំងឺរាតត្បាត COVID-19 មេរៀនសិក្សាផ្នែកចិត្តសង្គមដែលបានបង្រៀន និងផ្តល់ ជូនក្នុងក្របខណ្ឌនៃការសិក្សាពីចម្ងាយ និងការអភិវឌ្ឍជំនាញវិជ្ជាជីវៈសម្រាប់បុគ្គលិកបង្រៀនទៅលើការជំរុញឲ្យសិស្សចូលរួម តាមរយៈការប្រើប្រាស់ប្រព័ន្ធកម្ម វិធីសិក្សាពីចម្ងាយ និងមធ្យោបាយបង្រៀនតាមអ៊ីនធឺណិត សិក្ខាសាលា និងការបណ្តុះបណ្តាលសម្រាប់គ្រួសារទៅលើរបៀបប្រើប្រាស់កុំព្យូទ័រ និងការគាំទ្រដល់កូនៗរបស់ពួកគេដែលប្រើប្រាស់ធនធានសិក្សាពីចម្ងាយ សិស្សដែលចូលជួបដោយផ្ទាល់ជាមួយគ្រូ ហើយផ្តោតថាការសិក្សាពីចម្ងាយ គឺជាបញ្ហាប្រឈមមួយ ជាពិសេសសម្រាប់សិស្សថ្នាក់បឋមសិក្សា និងអ្នកដែលមានតម្រូវការពិសេស ការទទួលបានជំនួយការបង្រៀន និងកិច្ចការលំហាត់សម្រាប់សិស្ស និងការដោះស្រាយបញ្ហាតម្រូវថែទាំកុមាររបស់បុគ្គលិកសំខាន់ៗ។ គំនិត និង

ទំនោរមួយចំនួនផ្សេងទៀត ដែលកើតចេញពីតម្រូវការសម្រាប់ឲ្យសិស្សទទួលបាននូវមជ្ឈដ្ឋានប្រើប្រាស់អ៊ីនធឺណិត/ពីចម្ងាយដើម្បីមានទំនាក់ទំនងសង្គម ជជែកជាមួយសិស្សដទៃទៀត និងបង្កើតមិត្តភាព នៅក្រៅម៉ោងសិក្សា ការបណ្តុះបណ្តាលបុគ្គលិកសម្រាប់សេវាកម្មវិធីអប់រំសម្រាប់បុគ្គល (IEP) ពីចម្ងាយ មេរៀនដែល បានថតទុកដើម្បីឲ្យសិស្ស និងគ្រួសារអាចចូលប្រើប្រាស់ពួកវាសម្រាប់ការសិក្សា និងការគាំទ្រជាបន្ត និងការប្រាថ្នាចង់ឲ្យសាលាផ្តល់ជូនការបង្រៀន ដោយផ្ទាល់សម្រាប់សិស្ស ប្រសិន បើអាចផ្តល់ជូនបាន។

សិស្ស និងគ្រួសារផ្តល់ជាយោបល់ថាការបន្តភ្ជាប់ទៅកាន់ការបង្រៀនឡាយផ្ទាល់ គឺជាបញ្ហាលំបាកមួយនៅពេលខ្លះ ដោយសារតែសិស្ស ឬគ្រូ អាចនឹងបាត់បង់ការភ្ជាប់ទៅកាន់ការបង្រៀនឡាយផ្ទាល់ និងចាកចេញពីក្រុមសិក្សានៅក្នុងថ្នាក់រៀន ហើយអាចឡូកចូលមកម្តងទៀត។ មូលបទនៃយោបល់ត្រលប់នៅក្នុងចំណោមគ្រួសារគឺថា ភាពអត់ធ្មត់ និងការយល់ដឹងអំពីបញ្ហាអ៊ីនធឺណិត និងការភ្ជាប់ជាមួយនឹងការបង្រៀនក្នុងថ្នាក់រៀន ឡាយផ្ទាល់អាចនឹងទទួលបានការផ្តល់តម្លៃខ្ពស់ ដោយសារតែមនុស្សគ្រប់គ្នាកំពុងព្យាយាមអស់ពីលទ្ធភាពក្នុងការធ្វើឲ្យស្ថានភាពបច្ចុប្បន្ននេះប្រព្រឹត ទៅមានប្រសិទ្ធភាព។ សិស្សផ្តល់យោបល់ថា ពួកគេបានផ្តល់តម្លៃខ្ពស់ដល់ភាពចាំបាច់សម្រាប់ភាពអត់ធ្មត់ និងការអធ្យាស្រ័យដល់ពួកគេដែល មិនអាចបើកកាម៉េរ៉ារបស់ពួក គេបានគ្រប់ពេល ដោយសារតែបញ្ហាកម្រិតរលកហ្វ្រេកង់ និងមិនអាចបើកម៉ៃក្រូហ្វូនបានគ្រប់ពេល ដោយសារតែសំឡេងរំខានដែលកើតមានជុំវិញខ្លួនពួកគេនៅអំឡុងពេលសិក្សាពីចម្ងាយ។ មូលបទរួមជាមួយនឹងយោបល់ត្រឡប់ដែលបុគ្គលិកបានបញ្ជាក់ និងបានកំណត់គឺថា មានកម្រិតវឌ្ឍនភាព នៃការសិក្សាលឿន និងឆាប់រហ័សដែលបានរំពឹងទុកនៅក្នុងការសម្របសម្រួលទៅតាមទម្រង់នៃការសិក្សាពីចម្ងាយ និងប្រព័ន្ធកម្មវិធីផ្សេងៗ និងសារៈសំខាន់នៃការរក្សាបាននូវភាពឥតប្រែប្រួលនៅក្នុងកាលវិភាគបវេសនាកាលនៃការសិក្សាពីចម្ងាយ នៅក្នុងកម្រិតមួយដែលអាចធ្វើទៅបាន ដើម្បីផ្តល់ឲ្យសិស្ស និងក្រុមគ្រួសារនូវការរំពឹងឥតប្រែប្រួលទៅលើរបៀបនៃការសិក្សាតាមសាលា នៅអំឡុងពេលនៃការសិក្សាពីចម្ងាយ។ ការស្នើសុំការបណ្តុះ បណ្តាលនៅក្នុងការប្រើប្រាស់មធ្យោបាយឌីជីថលដើម្បីធានាថា សិស្សទទួលបានការសិក្សារៀនសូត្រ និងជំរុញឲ្យសិស្សចូលរួមទៅក្នុងការសិក្សា គឺ ត្រូវបានបុគ្គលិកផ្តល់យោបល់ចូលរួម។ គ្រួសារ និងបុគ្គលិក បានចែករំលែកនូវមូលបទរួមនៅក្នុងយោបល់ត្រលប់របស់ពួកគេថា ក្រុមគ្រួសារ និងសិស្ស ត្រូវការការបណ្តុះបណ្តាលស្តីពីរបៀបចូលប្រើប្រាស់មធ្យោបាយសិក្សាតាមអនឡាញ និងឡូកចូលទៅក្នុងថ្នាក់រៀនតាមប្រព័ន្ធអ៊ីនធឺណិតដោយមាន ការគាំទ្របន្ថែមពីសិស្សដែលមានការលំបាកនៅក្នុងការចូលរួមក្នុងការសិក្សាតាម ថ្នាក់រៀន ទាំងវគ្គសិក្សាពីចម្ងាយ និងវគ្គបង្រៀនដោយផ្ទាល់។ ក្រុមគ្រួសារ បានចែករំលែកនូវមូលបទជាពិសេសនៅក្នុងយោបល់ត្រឡប់ថាការ ពិនិត្យផ្ទៀងផ្ទាត់ផ្ទាល់មួយទល់នឹងមួយដោយបុគ្គលិក ជាមួយនឹងសិស្សដែលមានបញ្ហាលំបាកនៅក្នុងការសិក្សាពីចម្ងាយ ដើម្បីបានដឹងថាតើសិស្ស មានការយល់ដឹងអំពីកិច្ចការលំហាត់ ការគាំទ្រការបង្រៀនតាមតម្រូវ ការ និងរបៀបដែលពួកគេគិតនៅអំឡុងជំងឺរាតត្បាត COVID-19 ដែរឬអត់នោះ គឺជាអ្វីដែលពួកគេចង់បាន។ រាល់យោបល់ត្រលប់របស់ភាគីពាក់ព័ន្ធបាន ពង្រឹងការអនុវត្តមូលបទដែលថា ការសិក្សាពីចម្ងាយ អាចនឹងបង្ហាញនូវបញ្ហាប្រឈមសម្រាប់សិស្សដែលមិនមែនជាអ្នកសិក្សាតាមគំហើញចក្ខុ និងមានអារម្មណ៍ថាទទួលបានការគាំទ្រតាមរយៈទំនាក់ទំនងសង្គម ហើយ ថាជម្រើសនៃការសិក្សាជាក្រុមតូចៗ និងឱកាសសម្រាប់ឲ្យសិស្សឆ្លើយសំណួរ និងទទួលបានជំនួយពីគ្រូ គឺពិតជាចាំបាច់នៅអំឡុងពេលសិក្សាពី ចម្ងាយ។ សម្រាប់ក្រុមភាគីពាក់ព័ន្ធទាំងអស់ មូលបទជារួមដែលបានចែករំលែកនៅក្នុងយោបល់ត្រលប់ គឺជាតម្រូវការសម្រាប់ការទទួលបានកុំព្យូទ័រយួរដៃ និងការតភ្ជាប់បណ្តាញសម្រាប់សិស្ស និងបុគ្គលិក សេវាសុខភាពផ្លូវចិត្ត និងសេវាចិត្តសង្គមដែលបានផ្តល់ជូនដល់សិស្សអំឡុងពេល សិក្សាពីចម្ងាយ គឺត្រូវការចាំបាច់ សម្ភារៈសម្អាត និងសម្លាប់មេរោគ មានផ្តល់ជូនរួចជាស្រេចដល់បុគ្គលិកទាំងអស់ដែលកំពុងធ្វើការងារនៅលើ តាមទីតាំងដោយផ្ទាល់ សិក្ខាសាលាសម្រាប់គ្រួសារដែលគាំទ្រការសិក្សាពីចម្ងាយ និងវីដេអូដែលបង្ហាញពីរបៀបដែលក្រុមគ្រួសារ និងសិស្សអាចចូលទៅប្រើប្រាស់ធនធានមណ្ឌលសិក្សាធិការ និងឱកាសជាច្រើនទៀតសម្រាប់សិស្សនៅក្នុងការប្រាស្រ័យទាក់ទងជាមួយមិត្តរួមថ្នាក់តាមប្រព័ន្ធអ៊ីនធឺណិតក្រៅការសិក្សា រហូតដល់ពេលមានសុវត្ថិភាពក្នុងការត្រលប់ចូលទៅកាន់វគ្គបង្រៀនដោយ ផ្ទាល់វិញ។

[ការពិពណ៌នាអំពីទិដ្ឋភាពនៃផែនការបន្តការសិក្សា និងការចូលរៀនដែលទទួលឥទ្ធិពលតាមរយៈមតិចូលរួមរបស់ភាគីពាក់ព័ន្ធជាក់លាក់។]

មតិចូលរួមរបស់ភាគីពាក់ព័ន្ធជាក់លាក់ដែលទទួលបានពីការចូលរួម ការរួមចំណែក ឱកាសសម្រាប់យោបល់ត្រលប់នៅក្នុងខែសិក្សានារដូវផ្ការីក និងរដូវក្តៅ និងនៅអំឡុងពេលចាប់ផ្តើមនៃឆ្នាំសិក្សា2020-2021 បានផ្តល់នូវការណែនាំអំពីតម្រូវការសម្រាប់ការអភិវឌ្ឍផែនការនៅក្នុងការផ្តោតទៅ សុខភាព និងសុវត្ថិភាព សិស្ស បុគ្គលិក និងក្រុមគ្រួសារ ការចូលទៅប្រើប្រាស់បច្ចេកវិទ្យាបង្រៀន និងវ៉ាយហ្វាយហតស្ប៉ត (WiFi hot spot) ដើម្បីធានាបាននូវការតភ្ជាប់បណ្តាញ ការផ្តល់ជម្រើសទទួលបានចំណីអាហារសម្រាប់សិស្សនៅក្នុងព្រំដែនមណ្ឌលសិក្សាធិការទាំងមូល ដែលចូលរៀន និងការធានាថាសិស្សត្រូវទទួលបានការបង្រៀនឡាយផ្ទាល់ប្រចាំថ្ងៃ និងការប្រាស្រ័យទាក់ទងជាមួយគ្រូរបស់ពួកគេ ដោយមានការផ្តល់ការគាំទ្រដល់ឪពុកម្តាយ/អាណាព្យាបាលដើម្បីគាំទ្រដល់កូនៗពួកគេនៅអំឡុង

ពេលសិក្សាពីចម្ងាយ។ ការសម្រេចចិត្តទៅលើរបៀបដែលសាលារៀនគប្បីត្រូវបើកដំណើរ ការសាឡើងវិញ ត្រូវបានធ្វើឡើងតាមរយៈការរួមបញ្ចូលគ្នានៃមតិចូលរួមរបស់
ខោនធី និងសហគមន៍។ មណ្ឌលសិក្សាធិការ SUSD បានទទួលនូវមតិ ចូលរួមរបស់សហគមន៍តាមរយៈការស្ទង់ប្រជាមតិ ការស្ទង់មតិទៅលើភាគីពាក់ព័ន្ធ និងកិច្ចប្រជុំ
បែប សហការជាមួយគ្រួសារ និងអង្គភាពសហជីព ការងារ។ ដោយសារតែកម្រិតខ្ពស់បំផុតតាមទិន្នន័យនៅក្នុងជំងឺ COVID-19 នៅក្នុងទីក្រុង និងខោនធីរបស់យើង
និងការណែនាំដែលផ្ដល់ជូនពីរដ្ឋាភិបាល មូលដ្ឋាន និងរដ្ឋ ទើបមណ្ឌលសិក្សាធិការ SUSD បានរកឃើញនៅក្នុងយោបល់ត្រលប់របស់ ភាគីពាក់ព័ន្ធដែលបានវិភាគលើ
ការកើនឡើងនៃក្ដីប្រាថ្នាចង់ឲ្យការសិក្សាពីចម្ងាយពេញលេញក្លាយទៅជាវគ្គបង្រៀន និងជាជម្រើសមួយដែលបន្តផ្ដល់ជូនគ្រួសារដែលបន្តមានក្ដីបារម្ភអំពីសុខភាព
និងសុវត្ថិភាព ស្របគ្នាជាមួយនឹងជំងឺរាតត្បាត COVID-19 នៅក្នុងឆ្នាំសិក្សា2020-2021 ទាំងមូល។ ផ្នែកទីមួយដែលស្របគ្នាជាមួយនឹងការបន្តការសិក្សាដែលទទួល
ឥទ្ធិពលតាមរយៈយោបល់ត្រលប់ជុំវិញក្ដីកង្វល់អំពីសុខភាព និងសុវត្ថិភាព ស្របគ្នាជាមួយនឹងជំងឺ COVID-19 គឺជាតម្រូវការក្នុងការអនុវត្តសេវាសុខភាពប្រចាំថ្ងៃ
ការប្រព្រឹត្តទៅនៃជំងឺ COVID-19 ការពិនិត្យសីតុណ្ហភាពប្រចាំថ្ងៃ និងការតាមដានអ្នកប៉ះពាល់ផ្ទាល់ និងប្រព័ន្ធតាមដានដែលមានស្រាប់ ដើម្បីអនុវត្តនៅក្នុងករណី
ហេតុការណ៍ដែលបុគ្គលមានជំងឺ COVID-19 បង្ហាញខ្លួន នៅកន្លែងណាមួយ នៅក្នុងមណ្ឌលសិក្សាធិការ SUSD ទាំងមូល។ កិច្ចដំណើរ ការចូលរួមរបស់ភាគីពាក់ព័ន្ធ
បានជះឥទ្ធិពលទៅលើជម្រើសនៃរចនា សម្ព័ន្ធដែលបានធ្វើផែនការសម្រាប់វគ្គបង្រៀនដោយផ្ទាល់ទៅលើការបង្កើតកាល វិភាគបង្រៀនបែបចម្រុះរួមបញ្ចូលគ្នា
ដែលនៅក្នុងនោះ សិស្សអាចនឹងចូលរៀននៅសាលាក្នុងជំនាន់សិក្សាក្នុងរយៈពេលពីរថ្ងៃជាប់ៗគ្នា និងទទួលបាន ការសិក្សាពីចម្ងាយក្នុងរយៈពេលបីថ្ងៃដែលពួកគេ
មិនស្ថិត នៅក្នុងអគារសិក្សាជាក់ស្ដែងដែលកំពុងតែបានផ្ដល់ជូនសម្រាប់ការបង្រៀនផ្ទាល់ ជាមួយនឹង ភាពបត់បែនសម្រាប់សិស្សដែលមានតម្រូវការពិសេស ដែល
អាចទទួលបានបទពិសោធន៍នៃការសិក្សាដោយផ្ទាល់កាន់តែច្រើនឡើងនៅតាមទីតាំង។ តាមរយៈលទ្ធផលនៃការស្ទង់មតិយោបល់ត្រលប់របស់ភាគីពាក់ព័ន្ធ និងកិច្ច
ប្រជុំសហការជាមួយអ្នកដឹកនាំអង្គភាពសហជីពការងាររបស់មណ្ឌលសិក្សា ធិការ SUSD ដូច្នេះ គេបានកំណត់ថា វគ្គបង្រៀនផ្ទាល់សមស្របបំផុត ដែលអាចដោះស្រាយ
បញ្ហាសិក្សារបស់សិស្ស ទន្ទឹមគ្នានឹងការផ្ដល់លទ្ធភាពឲ្យទីតាំងសាលារៀនអនុវត្តពិធីសារ និងនីតិវិធីស្ដីពីសុខភាព និងសុវត្ថិភាព អាចនឹងក្លាយជាគំរូសិក្សាបែបចម្រុះ
រួមបញ្ចូលគ្នា ដោយពិចារណាទៅលើ បញ្ហាប្រឈម និងបំណងប្រាថ្នាដែល ផ្ដល់ជូនដោយភាគីពាក់ព័ន្ធ។ ដោយមានភាគីពាក់ព័ន្ធជាច្រើនបានបង្ហាញនូវក្ដីបារម្ភ
អំពីសុខភាព និងសុវត្ថិភាព ស្របគ្នាជាមួយនឹងជំងឺរាតត្បាត COVID-19 ជាមួយនឹងការផ្ដោតទៅលើការបន្តសិក្សាផងនោះ ដូច្នេះ មណ្ឌលសិក្សាធិការ បានសម្រេច
ខិតខំស្វែងរក លទ្ធភាពក្នុងការផ្ដល់ជូនការ សិក្សាពីចម្ងាយជាបន្តបន្ទាប់ដល់សិស្ស សូម្បីតែនៅពេលការបង្រៀនផ្ទាល់ត្រូវបន្តអនុវត្តជាធម្មតាឡើងវិញក៏ដោយ ដើម្បី
ដោះស្រាយក្ដីកង្វល់ដែលបានចែករំលែកដោយក្រុមគ្រួសារ និងបុគ្គលិក។ គំនិតសំខាន់បានមកពីមតិចូលរួមរបស់ភាគីពាក់ព័ន្ធ ដែលបានជះឥទ្ធិពលលើការអភិវឌ្ឍ
ផែនការនេះ គឺជាតម្រូវការសម្រាប់ការអភិវឌ្ឍការណែនាំច្បាស់លាស់ដែលរៀបរាប់អំពីការបង្រៀនឡាយផ្ទាល់ប្រចាំថ្ងៃសម្រាប់សិស្សទាំងអស់ ជារៀងរាល់ថ្ងៃ
រួមមានប្រព័ន្ធដាក់ពិន្ទុ និងចំនួននាទីបង្រៀនអប្បបរមាក្នុងមួយថ្ងៃ។ យោបល់ត្រលប់ជាក់លាក់នេះ ជួយសម្រួលដល់មណ្ឌលសិក្សា ធិការក្នុងការបង្កើតទាំង
សៀវភៅណែនាំអំពីការបង្រៀនពីចម្ងាយ និងទំព័រគេហទំព័រដែលបានរកឃើញដោយការចុចលើរូបអាយខុន (icon) ដៃនៅ លើគេហទំព័រដើម ដែលផ្ដល់ព័ត៌មាន និង
តំណភ្ជាប់តាមអ៊ីនធឺណិតទៅកាន់ធនធានទាំងអស់ដែលក្រុមគ្រួសារបង្ហាញការចាប់អារម្មណ៍ក្នុងការចូល ប្រើប្រាស់ និងមានចំណេះដឹងពាក់ព័ន្ធនៅក្នុងមតិចូលរួម
និងយោបល់ត្រឡប់ដែលបានផ្ដល់ជូននៅក្នុងកិច្ចដំណើរការអភិវឌ្ឍផែនការទាំងមូល។

ទំនោរសំខាន់បំផុតរបស់យោបល់ត្រឡប់ដែលបានជះឥទ្ធិពលទៅលើផែនការនោះ គឺការចូលទៅប្រើប្រាស់ឧបករណ៍ និងតម្រូវការតភ្ជាប់បណ្ដាញរបស់សិស្ស និង
បុគ្គលិក។ ក្នុងការដោះស្រាយបញ្ហាតម្រូវការទាំងនេះ មណ្ឌលសិក្សាធិការ ចាំបាច់ត្រូវទទួលរងឥទ្ធិពលតាមរយៈយោបល់ត្រលប់សម្រាប់ការប្រើប្រាស់វ៉ាយហ្វាយ (WiFi)
ដោយការបញ្ជាទិញកុំព្យូទ័រយួរដៃ ដើម្បីធានាថាសិស្ស និងបុគ្គលិកបង្រៀនមានកុំព្យូទ័រដំណើរការអាច ប្រើប្រាស់បានដោយប្រើកាម៉េរ៉ា និងការបញ្ជាទិញវ៉ាយហ្វាយ
ហតស្ប៉ត (WiFi hot spot) សម្រាប់សិស្សដែលបានចុះឈ្មោះ និងខ្លះទៀតសម្រាប់គ្រូ និង បុគ្គលិកគាំទ្រការបង្រៀនដែលបានផ្ដល់មតិយោបល់នៅក្នុង
លទ្ធផលស្ទង់មតិ ដែលពួកគេត្រូវការគាំទ្រជាមួយនឹងបញ្ហាតភ្ជាប់បណ្ដាញនៅក្នុងកន្លែងស្នាក់នៅរបស់ពួកគេ ដោយសារតែកត្តាផ្សេងៗ។ ដោយមាន
បុគ្គលិកសំខាន់ៗរបស់មណ្ឌលសិក្សាធិការ SUSD មានការផ្ដល់មតិយោបល់ថា ពួកគេបានត្រូវការការគាំទ្រកូន ដូច្នេះ មណ្ឌលសិក្សាធិការ SUSD បានធ្វើការងារជាដៃគូ
ជាមួយទីភ្នាក់ងារខាងក្រៅ ដើម្បីផ្ដល់ជូនជំរំប្រមូលផ្ដុំកុមារនៅពេលថ្ងៃ រយៈពេលប្រាំថ្ងៃក្នុងមួយសប្ដាហ៍ នៅក្នុងបរិវេណសាលារៀន សម្រាប់បុគ្គលិកមណ្ឌលសិក្សា SUSD
កុមារដែលគ្រប់អាយុចូលរៀនថ្នាក់មត្តេយ្យ ឆ្លងភូមិសិក្សាដល់ថ្នាក់ទី8 (TK-8) គឺមិនមានបង់ប្រាក់ទេ ព្រមគ្នាជាមួយនឹងការជះឥទ្ធិពលនៃការផ្ដល់គំរូសិក្សាពីចម្ងាយ
ពេញលេញ ទៅលើបុគ្គលិក សំខាន់ៗ។ ដោយមានសិស្ស និងក្រុមគ្រួសារជាច្រើនបង្ហាញនូវតម្រូវការក្នុងការទទួលបានការគាំទ្រផ្នែកសិក្សារៀនសូត្រ និងពេលវេលា
បង្រៀនបន្ថែម ដើម្បីដោះស្រាយបញ្ហាលំបាកក្នុងការយល់អំពីខ្លឹមសារនៅក្នុងការសិក្សាពីចម្ងាយ ដូច្នេះ មណ្ឌលសិក្សាធិការ USD បានផ្ដោតលើការដោះស្រាយបញ្ហា
លំបាកក្នុងការបាត់បង់ការសិក្សា តាមរយៈការបង្កើនជម្រើសនៃការបង្រៀនដែលបានផ្ដល់ជូនដល់សិស្ស និងការ ផ្ដល់ការគាំទ្រលើការបង្រៀនតាមរយៈ
បុគ្គលិកមណ្ឌលសិក្សាធិការ និងភាពជាដៃគូជាមួយទីភ្នាក់ងារខាងក្រៅ ដើម្បីបង្កើនការចូលរួមរបស់សិស្ស បានបង្កើនកាលវេលា និងចំនួនម៉ោងដែល ក្រុមគ្រួសារ

អាចភ្ជាប់ទំនាក់ទំនងជាមួយបុគ្គលិកដើម្បីឆ្លើយសំណួររបស់ពួកគេ និងជួយបំពេញតម្រូវការសិក្សាពីចម្ងាយ បានផ្តល់ការចូលប្រើប្រាស់កម្មវិធីសិក្សាបំពេញក្រេឌីតដល់សិស្សវិទ្យាល័យទាំងអស់ និងបានបង្កើនការចូលប្រើប្រាស់កម្មវិធី អន្តរាគមន៍អំណានសម្រាប់សិស្សដែលមានតម្រូវការពិសេស។

នៅក្នុងការដោះស្រាយបញ្ហាដែលភាគីពាក់ព័ន្ធបានផ្តល់មតិយោបល់ តម្រូវការពាក់ព័ន្ធនឹងការទទួលបានការគាំទ្រក្នុងក្របខណ្ឌនៃការសិក្សាពីចម្ងាយ ដែលផ្តោតលើការគាំទ្របច្ចេកទេស ធនធានគាំទ្រដល់សិស្សក្រុមគ្រួសារ និងបុគ្គលិក ត្រូវបានបង្កើតឡើងនៅក្នុងមណ្ឌលសិក្សាធិការ SUSD ទាំងមូល ដើម្បីធានាថាភាគីពាក់ព័ន្ធអាចទទួលបានការគាំទ្រដោយងាយជាចម្រុះភាសា។ បច្ចេកវិទ្យា និងការមានអ៊ីនធឺណិតប្រើប្រាស់ និងការគាំទ្ររបស់កុំព្យូទ័រ Chromebook សេវាគាំទ្រសុខភាពផ្លូវចិត្ត និងអាកប្បកិរិយា សិក្ខាសាលាឡាយផ្ទាល់ និងបានថតទុក និងឱកាសបណ្តុះបណ្តាល ត្រូវបានបង្កើត ឡើងយ៉ាងជាក់លាក់ដើម្បីដោះស្រាយបញ្ហាតម្រូវការដែលបានបង្ហាញប្រាប់នៅក្នុងមតិចូលរួមដែលបានចែករំលែក។ ជាពិសេស តាមរយៈការចូលរួមរបស់គ្រួសារនៅក្នុងការសិក្សាពីចម្ងាយ ទីតាំងសាលារៀនផ្តល់ជូនការប្រើប្រាស់ម៉ោងធ្វើការដល់បុគ្គលិកនៅចុងម៉ោង នាពេលល្ងាច ដើម្បីបង្កើនការចូលប្រើប្រាស់ ដើម្បីឲ្យក្រុមគ្រួសារធ្វើការ មានឱកាសទទួលបានការឆ្លើយតបទៅកាន់សំណួររបស់ពួកគេ និងដោះស្រាយបញ្ហាដែលពាក់ព័ន្ធ នឹងការសិក្សាពីចម្ងាយ។ បុគ្គលិកការិយាល័យអភិវឌ្ឍកម្មវិធីសិក្សា និងភាសា បានផ្តល់ជំនួយទូទៅនៅអំឡុងពេលសិក្សាពីចម្ងាយ ហើយឯកសារណែនាំ នានា ត្រូវបានបង្កើតឡើងសម្រាប់បុគ្គលិក និងគ្រួសារ ដោយមានធនធានតាមតំណភ្ជាប់ដែលមានភ្ជាប់មកជាមួយនៅក្នុងឯកសារ ដើម្បីជួយជំរុញឲ្យចូលទៅប្រើប្រាស់ធនធាន និងព័ត៌មានសម្រាប់បុគ្គលិក និងគ្រួសារ (ឧ.ទា. ការគាំទ្របច្ចេកវិទ្យា ការគាំទ្រកម្មវិធីសិក្សា ព័ត៌មាន សុខភាព និងសុវត្ថិភាព កុមារ ការណែនាំ និងការគាំទ្រដល់ការចូលរៀន ការគាំទ្រសុខភាពផ្លូវចិត្ត និងសេវាពិគ្រោះយោបល់)។

ជាការឆ្លើយតបទៅនឹងតម្រូវការរបស់ភាគីពាក់ព័ន្ធស្របទៅតាមអាហារូបត្ថម្ភ និងការទទួលបានអាហារនៅសាលាសម្រាប់សិស្ស មណ្ឌលសិក្សាធិការ SUSD បានផ្តល់ជូនអាហារពេលព្រឹក អាហារថ្ងៃត្រង់ និងអាហារពេលល្ងាចនៅតាមទីតាំងសាលារៀនចំនួន 28 កន្លែងជាយុទ្ធសាស្ត្រនៅ ទូទាំងព្រំប្រទល់មណ្ឌលសិក្សាធិការដែលត្រូវចូលរៀន នៅថ្ងៃចន្ទ ពុធ និងសុក្រ (អាហារពីរពេល ត្រូវបានផ្តល់ជូនរៀងរាល់ថ្ងៃ) និងនៅតាមវិទ្យាល័យដែលបានកំណត់ដើម្បីបំពេញតម្រូវការនៃកាលវិភាគសិក្សាពីចម្ងាយ ការផ្តល់អាហារ ប្រព្រឹត្តទៅពីរដងក្នុងមួយថ្ងៃ ម៉ោង 6:45-7:30 ព្រឹក និងម៉ោង 10:30 ថ្ងៃត្រង់ នៅថ្ងៃចែកអាហារដើម្បីសម្របតាមតម្រូវការដែលបានបង្ហាញប្រាប់តាមរយៈសិស្ស គ្រួសារ និងបុគ្គលិក ដើម្បីទទួលបានអាហារនៅអំឡុងពេលដែលមិនប៉ះពាល់ដល់កាលវិភាគសិក្សាពីចម្ងាយសម្រាប់សិស្សនៅតាមវិទ្យាល័យ។ ជំរំប្រមូលផ្តុំពេលថ្ងៃសម្រាប់កូនៗរបស់បុគ្គលិកសំខាន់ៗ ស្ថិតនៅតាមទីតាំងចែកចំណីអាហារ ដើម្បីធានាថាកុមារដែលចូលរួមនៅក្នុងជំរំប្រមូលផ្តុំ ទទួលបានអាហារសម្រន់ផងដែរ ក្រៅពីអាហារតាមសាលាប្រចាំថ្ងៃរបស់ពួកគេ។ ក្នុងការទទួលស្គាល់តម្រូវការក្នុងការគាំទ្រដែលផ្តោតលើការ ឆ្លើយតបចំពោះបញ្ហាលំបាកនៃការសិក្សាពីចម្ងាយជាបន្ត និងការទទួលបានសេវា ចិត្តសង្គម និងសេវាសុខភាពផ្លូវចិត្ត ដើម្បីដោះស្រាយបញ្ហាតម្រូវការយល់ដឹងពីផលប៉ះទង្គិចរបស់សិស្ស ដូច្នេះ កិច្ចដំណើរការចូលរួមរបស់ភាគីពាក់ព័ន្ធ បានជះឥទ្ធិពលទៅលើឱកាស និងសេវាកម្មកាន់តែច្រើនឡើង ដែលបានផ្តល់ជូនសិស្ស គ្រួសារ និងបុគ្គលិកនៅក្នុងផ្នែកប្រើប្រាស់ និងគាំទ្របច្ចេកវិទ្យា ជំនួយលើការបង្រៀន និងកិច្ចការលំហាត់នៅផ្ទះការពិគ្រោះយោបល់លើការគាំទ្រ និងការធ្វើផែនការណែនាំផ្នែកសិក្សារៀនសូត្រ ម៉ោងជួបប្រជុំក្រុមសុខភាពផ្លូវចិត្ត និងសិក្ខាសាលាសម្រាប់សិស្ស គ្រួសារ និងបុគ្គលិក និងកម្មវិធីសិក្សាចិត្តសង្គមដែលបានរួមបញ្ចូលទៅក្នុងបទពិសោធន៍សិក្សាពីចម្ងាយសម្រាប់សិស្ស។

# ការបន្តការសិក្សា

## ការផ្តល់ជូនការសិក្សាដោយផ្ទាល់

[ការពិពណ៌នាអំពីសកម្មភាពដែល LEA នឹងអនុវត្ត ដើម្បីផ្តល់ការបង្រៀនតាមថ្នាក់រៀន នៅពេលដែលអាចធ្វើបាន ជាពិសេសសម្រាប់សិស្សដែលមានការបាត់បង់ការសិក្សាសំខាន់ៗ ដោយសារតែការបិទសាលានៅក្នុងឆ្នាំសិក្សា2019–2020 ឬអាចមានហានិភ័យប្រឈមនឹងការបិទសាលានាពេលអនាគត។]

នៅក្នុងខែមិថុនា ឆ្នាំ2020 មណ្ឌលសិក្សាធិការ បានជំរុញឲ្យភាគីពាក់ព័ន្ធចូលរួមនៅក្នុងកិច្ចដំណើរការ ដែលអាចជាការផ្តល់ជូនការបង្រៀនដោយផ្ទាល់សមស្រប និងមានប្រសិទ្ធភាពបំផុត ដែលត្រូវផ្តល់ជូនសម្រាប់ការបើកដំណើរការឆ្នាំសិក្សា2020។ ដោយសារតែការផ្លាស់ប្តូរទិន្នន័យជាវិជ្ជមានអំពីជំងឺ COVID-19 នៅក្នុងខោនធីទាំងមូល ដូច្នេះ មណ្ឌលសិក្សាធិការ បានផ្លាស់ប្តូរមកផ្តោតការយកចិត្តទុកដាក់លើការចាប់ផ្តើមបើកដំណើរការឆ្នាំសិក្សាថ្មីនៅក្នុងក្របខណ្ឌនៃការផ្តល់ជូន

ការសិក្សាពីចម្ងាយពេញលេញ។ បុគ្គលិកមណ្ឌលសិក្សាធិការរួបរួមស្តុកតុន (Stockton Unified School District, SUSD) បន្តរក្សាការផ្តោតយកចិត្តទុកដាក់ទៅលើការធានាថា ការបើកដំណើរការសាឡើងវិញនៃអគារសិក្សាសម្រាប់ការផ្តល់ជូនការបង្រៀនដោយផ្ទាល់ ត្រូវបានផ្តោតជាចម្បងទៅលើសុវត្ថិភាព និងផ្តល់ជូនការបង្រៀនដែលផ្តល់អាទិភាពច្បងលើគុណភាពខ្ពស់ទៅដល់សិស្សរបស់យើង។ នៅពេលដែលស្ថានភាពសុខភាពបច្ចុប្បន្ន និងការកំណត់លើតារាងត្រួតពិនិត្យជំងឺ COVID-19 របស់រដ្ឋ មិនអនុញ្ញាតឲ្យផ្តល់ជូនការបង្រៀនដោយផ្ទាល់ជាលក្ខណៈប្រព័ន្ធបាន ពេលនោះមណ្ឌលសិក្សា ត្រូវបន្តមានកិច្ចដំណើរការធ្វើផែនការយុទ្ធសាស្ត្រដែលត្រៀមរួចជាស្រេចសម្រាប់គំរូសិក្សាបែបចម្រុះរួមបញ្ចូលគ្នា ដើម្បីឲ្យមណ្ឌលសិក្សាធិការ SUSD ត្រៀមរៀបចំផ្តល់ជូនការបង្រៀនដោយផ្ទាល់ដល់សិស្សនៅពេលណាដែលមន្ត្រីសុខាភិបាលរបស់រដ្ឋនិងខោនធី ផ្តល់ការណែនាំថាមានសុវត្ថិភាពក្នុងការអនុវត្តបែបនេះ។ មិនថាយើងស្ថិតនៅក្នុងដំណាក់កាលបង្រៀនបែបណានោះទេ មណ្ឌលសិក្សាធិការ SUSD ប្តេជ្ញាចិត្តក្នុងការធានាថា បុគ្គលិកនិងសិស្សានុសិស្សគ្រប់រូប មានសម្ភារៈការពារផ្ទាល់ខ្លួន (Personal Protection Equipment, PPE) ដែលចាំបាច់សម្រាប់ផ្តល់ជូនការបង្រៀន និងចូលទៅសិក្សារៀនសូត្រ ស្របទៅតាមការណែនាំស្តីពីសុខភាព និងសុវត្ថិភាពដែលផ្តល់ជូនដោយមន្ត្រីថ្នាក់មូលដ្ឋាន និងថ្នាក់រដ្ឋ។

ខណៈពេលដែលយើងកំពុងកែលម្អ និងកែសម្រួលផែនការរបស់យើង ក្នុងកិច្ចសហការជាមួយផ្នែកសុខភាពសាធារណៈខោនធីសានចូឃីន (San Joaquin County Public Health) និងការិយាល័យអប់រំប្រចាំខោនធីយើង ក្នុងនាមមណ្ឌលសិក្សាធិការ យើងនឹងបន្តប្រើប្រាស់រាល់វិធានការដែលយើងអាចអនុវត្តបាន ដើម្បីគ្រប់គ្រងទៅលើបញ្ហាប្រឈមដែលបណ្តាលមកពីជំងឺ COVID-19 ដោយផ្តោតទៅលើការផ្តល់ទៅឲ្យមជ្ឈដ្ឋានសិក្សារៀនសូត្រនូវសុវត្ថិភាពអតិបរមាសម្រាប់សិស្ស និងបុគ្គលិកគ្រប់រូប ខណៈពេលកំពុងបន្តបេសកកម្មណែនាំរបស់ពួកយើងក្នុងការផ្តល់ឲ្យសិស្សគ្រប់រូបនូវការរៀបចំខ្លួនសម្រាប់ការសិក្សានៅមហាវិទ្យាល័យ ជំនាញអាជីព និងសហគមន៍។  ដោយមានការផ្តោតទៅលើតម្រូវការសុខភាព សុវត្ថិភាព និងការសិក្សារៀនសូត្ររបស់សិស្ស មណ្ឌលសិក្សាធិការ SUSD កំពុងធ្វើផែនការស្តីពីការផ្តល់ជូនលំនាំគំរូនៃការបង្រៀនចំនួនពីរបែបសម្រាប់ក្រុមគ្រួសារនៅក្នុងការជ្រើសរើស នៅពេលណាការផ្តល់ជូនការបង្រៀន អាចផ្តល់ជូនបាន។ ទាំងនេះនឹងរួមបញ្ចូលនូវជម្រើសសិក្សាពីចម្ងាយ 100% និងគំរូសិក្សាចម្រុះរួមបញ្ចូលគ្នា ដោយមានកាលវិភាគរៀបចំផ្សេងៗសម្រាប់ផ្នែកនៃការសិក្សាដោយផ្ទាល់ និងការសិក្សាពីចម្ងាយត្រូវបានផ្តល់ជូនដល់សិស្សទៅតាមជំនាន់សិក្សានីមួយ។ នៅពេលផ្ទេរចូលទៅក្នុងការផ្តល់ជូនការសិក្សាដោយផ្ទាល់ តាមដែលអាចផ្តល់ជូនបានតាមរយៈអភិបាលកិច្ចថ្នាក់មូលដ្ឋាន និងថ្នាក់រដ្ឋ មណ្ឌលសិក្សាធិការ SUSD នឹងផ្តល់ជូនក្នុងដំណាក់កាលទីពីរនូវគំរូនៃការបង្រៀនដែលបានរៀបចំតាមបែបចម្រុះរួមបញ្ចូលគ្នា ដោយជំរុញឲ្យសិស្សចូលរៀនដោយផ្ទាល់នៅក្នុងក្រុមសិស្សតាមជំនាន់ ដែលបានគាំទ្រដោយបទពិសោធន៍សិក្សាពីចម្ងាយ នៅថ្ងៃដែលក្រុមសិស្សតាមជំនាន់ មិនទទួលបានការបង្រៀនដោយផ្ទាល់នៅក្នុងបរិវេណសាលាពីគ្រូរបស់ពួកគេ។ មណ្ឌលសិក្សាធិការ SUSD នឹងបន្តផ្តល់ជូនជម្រើសនៃការសិក្សាពីចម្ងាយពេញលេញសម្រាប់ក្រុមគ្រួសារទាំងឡាយដែលពេញចិត្តលើការបន្តការសិក្សាពីចម្ងាយ 100%។ ការផ្លាស់ប្តូរការផ្តល់ជូនការបង្រៀនដោយផ្ទាល់ គឺផ្តោតទៅលើការផ្តល់ការចូលរួមនៅក្នុងការបង្រៀនដែលផ្តោតលើគុណភាពខ្ពស់ជាចម្បងទៅដល់សិស្ស។ នៅក្នុងការផ្តល់ការសិក្សាទាំងពីនេះ មណ្ឌលសិក្សាធិការ SUSD បានផ្តល់ទៅលើការផ្តល់ឱកាសសម្រាប់សិស្សក្នុងការចូលរួមនៅក្នុងការបង្រៀនផ្សាយបន្តផ្ទាល់ក្នុងពេលតែមួយទាំងក្នុងទីកន្លែងស្នាក់នៅរបស់ពួកគេ និងនៅក្នុងថ្នាក់រៀនជាក់ស្តែង តាមរយៈការគាំទ្របច្ចេកវិទ្យាផ្សេងៗ ដោយមានកិច្ចសហការជាមួយប្រព័ន្ធគ្រប់គ្រងការសិក្សាដូចជាកម្មវិធី  Google Classroom ជាដើម ម្លោះហើយ នឹងនាំមកនូវការផ្តល់ឱកាសសម្រាប់ឲ្យសិស្សចូលរួមនៅក្នុងវគ្គសិក្សាពីចម្ងាយ និងការសិក្សាផ្ទាល់ ដើម្បីរួមសហការជាមួយមិត្តរួមថ្នាក់ និងមានការចូលរួមទៅក្នុងការបង្រៀនដែលផ្តោតលើគុណភាពខ្ពស់ជាចម្បងផ្តល់ជូនដោយបុគ្គលិកបង្រៀន។ ដោយមានការផ្លាស់ប្តូរវគ្គបង្រៀនដោយផ្ទាល់ ការផ្តោតជាចម្បង នឹងផ្តោតទៅលើវិធានការសុខភាព និងសុវត្ថិភាព ហេតុដូច្នេះ កិច្ចខិតខំប្រឹងប្រែងក្នុងការចុះតាមដានប្រកបដោយប្រសិទ្ធភាពទៅលើទំនាក់ទំនងរួមជាមួយនឹងផ្នែកសុខភាពសាធារណៈរបស់ខោនធីសានជូឃីន (San Joaquin County Public Health) នោះ សិស្សនឹងទទួលបានការរៀបចំបញ្ចូលទៅក្នុងក្រុមតាមជំនាន់សិក្សា ក្រុមសិស្សដែលបានចាត់តាំង ដែលនឹងត្រូវចូលទៅក្នុងការផ្តល់ជូនការបង្រៀនដោយផ្ទាល់រួមគ្នា នៅថ្ងៃតែមួយ រៀងរាល់សប្តាហ៍ ឲ្យបានច្រើនតាមដែលអាចធ្វើបាន។ អំឡុងពេលនៃកិច្ចដំណើរការនេះ រាល់សេចក្តីណែនាំរបស់មណ្ឌសិក្សាធិការ រដ្ឋ និងខោនធី នឹងត្រូវតាមដានដើម្បីធានានូវសុខភាព និងសុវត្ថិភាពសិស្ស បុគ្គលិក និងក្រុមគ្រួសារ។ មណ្ឌលសិក្សាធិការ SUSD នឹងធ្វើការរួមគ្នាជាមួយបុគ្គលិកនាយកដ្ឋាន និងអ្នកដឹកនាំសហជីព នៅក្នុងការអភិវឌ្ឍប្រព័ន្ធនានាសម្រាប់ការបង្កើតមេរៀនបង្រៀនដោយលោក-គ្រូអ្នកគ្រូដែលត្រូវបានកត់ត្រាទុក ការបង្កើតបណ្ណាល័យឯកសារបង្រៀនសម្រាប់សិស្ស និងក្រុមគ្រួសារដែលអនុញ្ញាតឲ្យមានការទទួលបានការបង្រៀនដោយផ្ទាល់តាមស្តង់ដាកាន់តែច្រើនឡើង និងកាន់តែល្អប្រសើរឡើង និងការពន្យល់អំពីបញ្ញត្តិ និងកិច្ចការដែលគ្រូបានផ្តល់ឲ្យ។ ធនធានទាំងនេះ នឹងអនុញ្ញាតឲ្យក្រុមគ្រួសារដែលកំពុងធ្វើការ មានលទ្ធភាពអាចបត់បែនបាន នៅក្នុងការគាំទ្រដល់តម្រូវការសិក្សារៀនសូត្ររបស់កូនៗពួកគេ និងគាំទ្រដល់សិស្សដែលមានតម្រូវការពិសេស និង/ឬ អាចនឹងទទួលបានអត្ថប្រយោជន៍ពីមេរៀនបង្រៀន

សាចុះសាឡើងដែលបង្រៀនដោយគ្រូនៅក្នុងកម្រិតថ្នាក់របស់ពួកគេ។ នៅអំឡុងពេលដែលសិស្សទាំងអស់ចូលរួមនៅក្នុងការសិក្សាពីចម្ងាយនៅក្នុងគំរូនៃការផ្តល់ជូនការបង្រៀនដោយផ្ទាល់ បុគ្គលិកសិក្សា នឹងគាំទ្រដល់ការចូលរួមរបស់សិស្សតាមរយៈការផ្តល់ជូនការប្រាស្រ័យទាក់ទងតាមការរំពឹងទុកទៅលើកម្មវិធី Google Classroom តំណភ្ជាប់ទៅកាន់កិច្ចការ ធនធានគាំទ្រការសិក្សា សហការជាមួយគ្រូបង្រៀនដោយប្រើប្រាស់ទិន្នន័យរបស់សិស្សដើម្បីណែនាំការធ្វើផែនការបង្រៀន ផ្តល់ម៉ោងធ្វើការដល់សិស្ស និងក្រុមគ្រួសារដើម្បីចូលរួម និងការគាំទ្រជាក្រុមតូចៗ និងជាលក្ខណៈបុគ្គលដល់សិស្សដែលមានតម្រូវការពិសេស។

គម្រូសិក្សាបែបចម្រុះ នឹងរួមបញ្ចូលនូវការបង្រៀនឃើញមុខគ្នាផ្ទាល់តាមរយៈការសិក្សាតាមអនឡាញ ដូច្នេះនាំឲ្យមានការកាត់បន្ថយចំនួនសិស្សនៅក្នុងអគារសិក្សាសម្រាប់ការរក្សាគម្លាតឆ្ងាយពីគ្នា តាមរយៈការផ្លាស់ប្តូរការផ្តល់វគ្គសិក្សាមួយចំនួន ជាមួយនឹងកាលវិភាគដោយផ្ទាល់ដែលបានរៀបចំខុសៗគ្នា។ នៅក្នុងគំរូបង្រៀន-រៀនតាមបែបចម្រុះបញ្ចូលគ្នា ចំនួនសិស្សក្នុងថ្នាក់ នឹងត្រូវបានកាត់បន្ថយ ហើយគ្រឿងបរិក្ខារត្រូវបានរៀបចំក្នុងទីតាំងជាយុទ្ធសាស្ត្រនៅក្នុងមជ្ឈដ្ឋានសិក្សាដោយផ្ទាល់ ដើម្បីធានាឲ្យមានការបង្កើតឡើងនូវបរិយាកាសសិក្សាដែលរក្សាគម្លាតឆ្ងាយពីគ្នា។ សម្ភារៈការពារផ្ទាល់ខ្លួន (Personal Protective Equipment, PPE) នឹងត្រូវផ្តល់ជូនដល់បុគ្គលិកនិងសិស្សនៅតាមទីតាំង សាប៊ូនឹងត្រូវបានស្តុកទុករួចជាស្រេចគ្រប់ពេលវេលា ហើយកន្លែងទឹកលាងដៃ នឹងត្រូវបានដាក់ដំឡើងនៅខាងមុខសាលាទាំងអស់។ កាលវិភាគម៉ោងចេញលេង ការអប់រំកាយ (PE) និងពេលអាហារថ្ងៃត្រង់ នឹងត្រូវបានបង្កើតឡើងជាយុទ្ធសាស្ត្រដើម្បីដោះស្រាយបញ្ហាណែនាំអំពីសុខភាព និងសុវត្ថិភាពស្តីពីការជំរុញឲ្យសិស្ស និងបុគ្គលិកនៅក្នុងទីតាំងសាលា។ ផែនការតាមទីតាំងសាលា នឹងត្រូវបានបង្កើតឡើងនៅក្នុងសាលានីមួយៗ ដើម្បីកាត់បន្ថយស្ថានភាពប្រមូលផ្តុំ និងការជួបជុំគ្នាច្រើនដែលអាចនឹងមិនស្របតាមពិធីសាររក្សាគម្លាតឆ្ងាយពីគ្នា និងការរួមបញ្ចូលគ្នានៃជំនាន់សិក្សារបស់សិស្ស។ រយៈពេលសម្រួលឥរិយាបថសម្រាប់សិស្សនៅអនុវិទ្យាល័យ និងវិទ្យាល័យ អាចនឹងត្រូវកាត់បន្ថយជាអប្បបរមា និងរៀបចំតាមលំដាប់ជាយុទ្ធសាស្ត្រនូវពិធីសារបម្លាស់ទីតាមទិសដៅនៅក្នុងទីតាំង ដើម្បីដោះស្រាយបញ្ហាពិធីសាស្តីពីការបង្កើនសុខភាព និងសុវត្ថិភាព។ ការផ្តល់បុគ្គលិកអំឡុងដំណាក់កាលបង្រៀនទីបី នឹងត្រូវដោះស្រាយបញ្ហាតម្រូវការផ្នែកឡូជីសស្ទិកនៃការទទួលបានការផ្តល់ជូនការបង្រៀនដោយផ្ទាល់ប្រចាំសប្តាហ៍របស់សិស្ស ជាមួយនឹងកម្មវិធីក្រោយការសិក្សានៅសាលាដោយផ្ទាល់ដែលបានផ្តល់ជូន និងដែលរក្សាបាននូវជម្រើសសិក្សាពីចម្ងាយសម្រាប់ក្រុមគ្រួសារ។ នៅគ្រប់ការផ្តល់ជូនការបង្រៀនដោយផ្ទាល់ទាំងអស់ រាល់ពិធីសារសុវត្ថិភាព និងសុខភាពប្រចាំថ្ងៃទាំងអស់ នឹងត្រូវបានអនុវត្ត និងតាមដានស្របតាមការណែនាំរបស់អ្នកជំនាញផ្នែកសុខភាពថ្នាក់មូលដ្ឋាន និងថ្នាក់រដ្ឋ។ នៅក្នុងបរិវេណសាលា ការបម្លាស់ទីរបស់សិស្ស និងបុគ្គលិក នឹងត្រូវបានបង្កើតឡើងក្នុងរបៀបមួយដែលការបម្លាស់ទីនោះត្រូវបានកំណត់នៅក្នុងលំហូរទៅមកដែលអនុញ្ញាតឲ្យមានកាត់បន្ថយការជួបមុខគ្នាដោយផ្ទាល់ និងការបម្លាស់ទីដែលផ្តោតលើបញ្ហាសុខភាពសម្រាប់មនុស្សគ្រប់រូបនៅក្នុងបរិវេណសាលា។ គំរូកាលវិភាគបង្រៀនតាមថ្នាក់រៀន នឹងធានាបាននូវការអភិវឌ្ឍការសិក្សា និងបំណិនសមត្ថភាពរបស់សិស្ស តាមរយៈការផ្តល់ជូនចំនួននាទីបង្រៀនដែលចាំបាច់ ការវាយតម្លៃកែលម្អទូទៅផ្អែកតាមកម្មវិធីសិក្សាសម្រាប់គ្រូតាមកម្រិតថ្នាក់ ដើម្បីប្រើប្រាស់នៅក្នុងពេលវេលានៃកិច្ចសហការ និងការរៀបចំផែនការបង្រៀន និងគម្រូផ្ទេរការសិក្សាទៅក្នុងការបង្រៀនដោយផ្ទាល់ដែលផ្តល់ជូននូវចំនួនសិស្សក្នុងថ្នាក់តិចជាងមុននៅក្នុងគំរូសិក្សាសិក្សាបែបចម្រុះរួមបញ្ចូលគ្នា ដើម្បីដោះស្រាយបញ្ហាតម្រូវការសុខភាព និងសុវត្ថិភាព ស្របតាមកម្រិតជីវិតរស់នៅរបស់សិស្សនៅក្នុងថ្នាក់រៀន។ កាលវិភាគវាយតម្លៃរបស់មណ្ឌលសិក្សាធិការ នឹងយកមកអនុវត្តរួមគ្នាជាមួយនឹងពេលវេលានៃកិច្ចសហការរបស់គ្រូ ដែលផ្តោតទៅលើទិន្នន័យសិស្សនៅក្នុងការវាយតម្លៃកែលម្អ និងការវាយតម្លៃបញ្ចប់ ដែលនឹងត្រូវបានប្រើប្រាស់ដើម្បីបង្កើតការគាំទ្រការបង្រៀនដើម្បីដោះស្រាយបញ្ហាប្រឈមផ្នែកសិក្សារៀនសូត្រដែលសិស្សជួបប្រទះ ដោយសារតែផលប៉ះពាល់នៃជំងឺ COVID-19 និងការអនុវត្តអន្តរាគមន៍នានាដើម្បីផ្តល់ជូននូវវិធីសាស្ត្រប្រព័ន្ធគាំទ្រច្រើនដំណាក់កាល (Multi-Tiered System of Supports, MTSS) ដើម្បីបំពេញតាមតម្រូវការសិក្សា និងតម្រូវការចិត្តសង្គមផ្សេងៗគ្នារបស់សិស្ស។

អំឡុងពេលផ្តល់ការបង្រៀនដោយផ្ទាល់ទាំងអស់ សិស្សនិងបុគ្គលិកគ្រប់រូបដែលស្ថិតនៅក្នុងបរិវេណសាលា នឹងត្រូវចូលរួមនៅក្នុងកិច្ចដំណើរការស្វ័យត្រួតពិនិត្យសម្រាប់សេវាសុខភាពលើជំងឺ COVID-19 ប្រចាំថ្ងៃ ពិនិត្យសីតុណ្ហភាព លាង និង/ឬ សម្អាតអនាម័យដៃរបស់ពួកគេ មុនពេលចូលមកកាន់បរិវេណសាលា ហើយពិធីសាររក្សាគម្លាតឆ្ងាយពីគ្នា នឹងត្រូវគោរពតាម។ ការបង្កើនការលាង និងសម្អាតអនាម័យឲ្យបានស្អាតប្រចាំថ្ងៃទៅលើទីតាំងរួម និងទីតាំងដែលប៉ះត្រូវរាងកាយ (ឧ.ទា. ដៃទ្វារ តុ ឡាប្ញ ឧបករណ៍នៅកន្លែងក្មេងលេងជាដើម) នឹងប្រព្រឹត្តទៅ ដោយមិនអនុញ្ញាតឲ្យប្រើប្រាស់កន្លែងបាញ់ទឹករួមឡើយ ហើយនឹងត្រូវអនុវត្តទម្លាប់ប្រចាំថ្ងៃផ្នែកសុខភាពនិងសុវត្ថិភាពសម្រាប់ពេលចេញលេញ ការអប់រំកាយ និងពេលញ៉ាំអាហារថ្ងៃត្រង់។ រាល់យានយន្តដឹកជញ្ជូនរបស់មណ្ឌលសិក្សាធិការ SUSD ទាំងអស់ នឹងត្រូវសម្អាតអនាម័យ និងលាងសម្អាត មុនពេលសិស្សចូលទៅក្នុងយានយន្ត ហើយនៅពេលសិស្សត្រូវបានដាក់នៅតាមសាលាសម្រាប់ជើងធ្វើដំណើរពេលព្រឹក យានយន្ត នឹងត្រូវបានលាងសម្អាតអនាម័យ និងដោយគ្មាននរណាម្នាក់ជិះឡើយក្នុងរយៈពេល 30 នាទី មុនពេលប្រើប្រាស់ដើម្បីធ្វើការដឹកជញ្ជូនពីសាលារៀនទៅកាន់ចំណតរថយន្តក្រុងដែលនៅជិតលំនៅដ្ឋានរបស់សិស្សបំផុត។  ជាមួយនឹងជំងឺរាតត្បាត COVID-19 ដែលបង្ហាញឲ្យឃើញពីការការផ្លាស់ប្តូរជាបន្តបន្ទាប់ និងបម្រែបម្រួលយ៉ាងខ្លាំងនៅក្នុងលទ្ធភាពសម្រាប់មណ្ឌលសិក្សាធិការ SUSD ដើម្បីអាចផ្តល់ជូនវគ្គបង្រៀនដោយផ្ទាល់ ដូច្នេះ មណ្ឌលសិក្សាធិការ នឹងបន្តធ្វើការងារដោយសហការជាដៃគូជាមួយមន្ត្រីសុខាភិបាលថ្នាក់មូលដ្ឋាន និងថ្នាក់រដ្ឋ និងនាយកដ្ឋាននានា និងអនុវត្តតាមការណែនាំ និងការកំណត់ជាមួយនឹងវគ្គបង្រៀនដោយផ្តល់ដែលអាចផ្តល់ជូនបាននៅក្នុងឆ្នាំសិក្សា2020-2021 ទាំងមូល។  នៅក្នុងនីតិវិធីសម្លាប់មេរោគទាំងមូល នឹងត្រូវបានអនុវត្តដោយមានការសម្លាប់មេរោគប្រចាំថ្ងៃទៅលើទីកន្លែងដែលប៉ះញឹកញាប់ច្រើនពេញមួយថ្ងៃ និងការសម្អាតថ្នាក់រៀន ទីតាំងរួម និងផ្ទៃដែលប៉ះញឹកញាប់ឲ្យបានស្អាតជាប្រចាំ។ បុគ្គលិក និងសិស្ស នឹងត្រូវបានលើកទឹកចិត្ត និងទទួលបានការណែនាំឲ្យការពិនិត្យដោយខ្លួនឯងសម្រាប់ការរកមើលរោគសញ្ញានៅតាមផ្ទះ ដោយប្រើនីតិវិធីសមស្របសម្រាប់អ្នកប្រើប្រាស់ដែលអាចប្រើប្រាស់តាមកុំព្យូទ័រ ឬទូរសព្ទបាន។ កាលវិភាគសម្រាប់វគ្គបង្រៀនដោយផ្ទាល់ នឹងផ្តល់ជូននូវជម្រើសក្នុងកម្រិតមួយដែលអាចធ្វើបាន ទៅដល់ក្រុមគ្រួសារពាក់ព័ន្ធនឹងកិច្ចដំណើរការដែលកូនរបស់ពួកគេមកកាន់បរិវេណសាលារៀន (ថ្ងៃណាមួយដែលស្របតាមកាលវិភាគជាមួយបងប្អូន ឬនៅក្នុងទីកន្លែងរបស់មិត្តរួមថ្នាក់ដែលស្នាក់នៅជាមួយ)  និងការបង្កើតកាលវិភាគសិក្សាបែបចម្រុះដែលដោះស្រាយបញ្ហាតម្រូវការនៃចំនួនសិស្សជារួមដែលមានតម្រូវការពិសេស និងចាំបាច់បំផុត ខណៈពេលដែលកំពុងបង្កើតឱកាសជាបន្តសម្រាប់ការតភ្ជាប់ និងទំនាក់ទំនងតាមអនឡាញសម្រាប់ការសិក្សាពីចម្ងាយ។ វគ្គបង្រៀនដោយផ្ទាល់ នឹងពិចារណាទៅលើតម្រូវការសម្រាប់សិស្សក្នុងការបង្រៀនក្នុងពេលតែមួយនៅតាមសាលា និងនៅតាមផ្ទះ។ ដោយមានការឆ្លាស់វេនពីរថ្ងៃ សិស្សនឹងត្រូវបានដាក់បញ្ចូលទៅក្នុងជំនាន់/ក្រុមសិក្សា ដែលក្រុមនីមួយៗគឺស្ថិតនៅក្នុងបរិវេណសាលារយៈពេលពីរថ្ងៃក្នុងមួយសប្តាហ៍ ហើយការសិក្សាពីចម្ងាយក្នុងរយៈពេលបីថ្ងៃផ្សេងទៀត។ ចំនួនសិស្សទាំងអស់ដែលមានតម្រូវការខ្ពស់ នឹងត្រូវផ្តល់ជូនជាយុទ្ធសាស្ត្រនូវការចូលរួម និងឱកាសកាន់តែច្រើនឡើងដើម្បីចូលរយមទៅក្នុងវគ្គបង្រៀនដោយផ្ទាល់។ ការវាយតម្លៃលើកម្មវិធីសិក្សា ការវាយតម្លៃបណ្តោះអាសន្ន និងការវាយតម្លៃបូកសរុប នឹងត្រូវបានប្រើប្រាស់ដើម្បីផ្តល់អាទិភាពដល់តម្រូវការអក្សរកម្ម និងគណិតវិទ្យា យល់ដឹងអំពីផ្នែកទូលំទូលាយនៃផ្នែកដែលជាក្តីកង្វល់លើការសិក្សាតាមស្តង់ដា និងយល់ដឹងអំពីផលប៉ះពាល់នៃការសិក្សាពីចម្ងាយ ខណៈពេលកំពុងរៀបចំផែនការជាយុទ្ធសាស្ត្រលើគោលវិធីរៀននិងបង្រៀន ដើម្បីដោះស្រាយបញ្ហាតម្រូវការសិក្សាសម្រាប់បុគ្គល និងសម្រាប់សិស្សក្នុងថ្នាក់ទាំងមូល។ សវនកម្មទិន្នន័យទៅលើតម្រូវការរបស់សិស្សដែលស្របជាមួយនឹងក្រុមសិស្សដែលមានតម្រូវការពិសេស នឹងត្រូវបានអនុវត្តដើម្បីផ្តល់ការចូលរួម និងគាំទ្រឲ្យបានច្រើនដូចជាការបង្រៀនជាក្រុមតូចៗ មិត្តអប់រំមិត្ត និងការពិគ្រោះយោបល់លើការណែនាំនិងគាំទ្រផ្នែកសិក្សារៀនសូត្រ ការអប់រំសម្រាប់គ្រួសារ និងការផ្សព្វផ្សាយរបស់ការិយាល័យទំនាក់ទំនងនៅក្នុងការគាំទ្រដល់ការបង្កើនសមត្ថភាពសម្រាប់ក្រុមគ្រួសារដើម្បីជួយគាំទ្រផ្នែកសិក្សាដល់សិស្ស ការគាំទ្រការបង្រៀនក្រោយម៉ោងសិក្សានៅសាលានិងកិច្ចការលំហាត់ផ្ទះ កម្មវិធីអន្តរាគមន៍អំណាន និងកម្មវិធីសិក្សាបំពេញក្រេឌីតសម្រាប់សិស្សវិទ្យាល័យ។ ពេលវេលាកិច្ចសហការបង្រៀន នឹងមានផ្តល់ជូនយ៉ាងហោចណាស់ពីរដងក្នុងមួយខែទៅដល់បុគ្គលិកបង្រៀន សម្រាប់ពេលវេលាក្នុងគោលបំណងជាលាក់ដែលបានចំណាយទៅលើការត្រួតពិនិត្យទិន្នន័យសិស្ស និងការអភិវឌ្ឍផែនការបង្រៀនជាយុទ្ធសាស្ត្រ និងសកម្មភាពនានា ដើម្បីដោះស្រាយបញ្ហាតម្រូវសិក្សារៀនសូត្រ និងការអភិវឌ្ឍចិត្តសង្គមរបស់សិស្ស។

សុខុមាលភាពចិត្តសង្គមរបស់សិស្ស នឹងត្រូវបានគាំទ្រតាមរយៈមេរៀនសិក្សាផ្នែកផ្លូវចិត្តសង្គមដែលបានផ្តល់ជូន អ្នកពិគ្រោះយោបល់ គ្រូពេទ្យគ្លីនិកផ្នែកសុខភាពផ្លូវចិត្ត និងអ្នកផ្តល់ជំនួយផ្នែកអាកប្បកិរិយាដែលធ្វើការងាររួមសហការគ្នាជាមួយគ្រូបង្រៀន និងដែលផ្តល់សេវាកម្មដោយផ្ទាល់សិស្ស បុគ្គលិក និងក្រុមគ្រួសារ។ អន្តរាគមន៍អាកប្បកិរិយាវិជ្ជមាន និងការគាំទ្រ (Positive Behavior Interventions & Supports) នឹងត្រូវបានអនុវត្តនៅក្នុងមណ្ឌលសិក្សាទាំងមូល ហើយការអភិវឌ្ឍវិជ្ជាជីវៈ នឹងធ្វើការដោះស្រាយជាបន្តបន្ទាប់លើបញ្ហាយល់ដឹងអំពីផលប៉ះពាល់នៃការប៉ះទង្គិច (trauma-informed care) និងការអនុវត្តការប្រតិបត្តស្តាឡើងវិញនៃយុទ្ធសាស្ត្រនៅក្នុងការគាំទ្រដល់ការបង្កើតបរិយាកាសសិក្សាប្រកបដោយសមធម៌សម្រាប់សិស្សគ្រប់រូប។ ប្រសិនបើអាចធ្វើបាននៅក្នុងវគ្គបង្រៀនដោយផ្ទាល់ សេវាកម្មបន្ថែម នឹងត្រូវបានផ្តល់ជូនជាចម្បងដោយដោះស្រាយតម្រូវការរបស់យុវជនជាកូនចិញ្ចឹម អ្នកសិក្សាភាសាអង់គ្លេស គ្រួសារទើបលែងលះថ្មីៗ សិស្ស

ដែលមានពិការភាព និងក្រុមសិស្សមានអត្តសញ្ញាណផ្សេងទៀត ដែលទិន្នន័យផ្តល់ការគាំទ្រដល់តម្រូវការសម្រាប់ការផ្តល់ជូនការគាំទ្រផ្នែកផ្លូវចិត្តសង្គម និងការសិក្សារៀនសូត្រ។ មណ្ឌលសិក្សាធិការ SUSD នឹងបន្តប្រាស្រ័យទាក់ទង និងមានទំនាក់ទំនងជាមួយភាគីពាក់ព័ន្ធនានាពាក់ព័ន្ធនឹងផែនការ និងការប្រើប្រាស់មតិយោបល់ចូលរួមដែលបានផ្តល់ជូនដើម្បីបន្តកែសម្រួលលំនាំគំរូនៃការបង្រៀន ដើម្បីបំពេញតាមត្រូវការរបស់សិស្សយ៉ាងល្អបំផុត។

## វិធានការពាក់ព័ន្ធនឹងវគ្គបង្រៀនដោយផ្ទាល់ [តារាងជួរផ្ដេក និងវិធានការបន្ថែម អាចនឹងត្រូវបានដាក់បន្ថែមទៀត ទៅតាមការចាំបាច់]

| ពិពណ៌នា | មូលនិធិសរុប | ការបែងចែក |
|---|---|---|
| ពិធីសារបង្កើនសុខភាព និងអនាម័យស្របជាមួយនឹងការផ្ដល់មធ្យោបាយធ្វើដំណើរដល់សិស្ស។ (IPI-1) | $100,000 | ទេ |
| ស្លាកសញ្ញា ផ្ទាំងផូស្ទ័រ និងផ្ទាំងសញ្ញារូបភាពសម្គាល់បិតលើកម្រាលឥដ្ឋនៅក្នុងទីតាំងសាលារៀនទាំងមូល ដើម្បីបង្កើនការរក្សាគម្លាតឆ្ងាយពីគ្នាជាអតិបរមា។ សញ្ញាសម្គាល់ នឹងជួយបង្ហាញផ្លូវលំហូរចរាចរណ៍ កាត់បន្ថយទំនាក់ទំនងរវាងក្រុមគ្រួសារនានា និងកំណត់សម្គាល់ទីកន្លែងច្រកចេញ/ចូលជាក់លាក់។ រូបភាព ក៏នឹងជួយពង្រឹងការអនុវត្តពិធីសាស្ត្រពីការប្រើម៉ាស់ និងការលាង/សម្អាតអនាម័យដៃផងដែរ។ (IPI-2) | $20,000 | ទេ |
| បន្តផ្ដល់បុគ្គលិកឃ្លាំមើល/ថែទាំនៅតាមទីតាំង ដើម្បីឲ្យគ្រឿងបរិក្ខារនានាត្រូវបានសម្លាប់មេរោគជាប្រចាំ (បន្ថែមពីលើការថែទាំ និងសម្អាតតាមស្តង់ដា) នៅក្នុងទីកន្លែងដែលប៉ះពាល់ញឹកញាប់។ (IPI-3) | $2,100,000 | ទេ |
| កញ្ចក់ផ្លិកស៊ី (Plexiglass) ផ្ដល់របាំងការពារ នៅពេលដែលការប៉ះពាល់ដោយផ្ទាល់អាចនឹងប្រព្រឹត្តទៅ និងមិនអនុញ្ញាតឲ្យមានការរក្សាគម្លាតឆ្ងាយពីគ្នាចម្ងាយ 6 ហ្វីតបាន ដូចជាតុការិយាល័យជួរមុខជាដើម។ (IPI-4) | $37,775 | ទេ |
| ការផ្ដល់សម្ភារៈបង្រៀនជាលក្ខណៈបុគ្គលដើម្បីកំណត់ចំនួនបុគ្គលដែលប្រើប្រាស់វត្ថុរួមគ្នាឲ្យនៅត្រឹមចំនួនតិចតួច និងធានាឲ្យសិស្សមានសម្ភារៈដែលពួកគេត្រូវការចាំបាច់ដើម្បីចូលរួមឲ្យបានពេញលេញនៅក្នុងកិច្ចដំណើរការសិក្សា។ (IPI-5) | $433,282 | ទេ |
| ការគាំទ្រការបង្រៀនសម្រាប់គ្រូបង្រៀនថ្មីដែលផ្ដោតលើការផ្ដល់ការបណ្ដុះបណ្ដាល សិក្ខាសាលា និងធនធាននានានៅក្នុងការផ្ដល់ជូនវគ្គបង្រៀនដោយផ្ទាល់។ (IPI-6) | $400,000 | ទេ |
| ហ្វីលទ័រ HVAC ៖ ទីតាំងអគារ នឹងបង្កើនចំនួនដែលពួកគេត្រូវផ្លាស់ប្ដូរហ្វីលទ័រ HVAC នៅតាមទីតាំងសាលារៀន និងអគារមណ្ឌលសិក្សាធិការ ដូចដែលបានណែនាំតាមសេចក្ដីណែនាំស្ដីពីសុខភាព និងសុវត្ថិភាពនាពេលបច្ចុប្បន្ន។ (IPI-7) | $253,000 | ទេ |

| ពិពណ៌នា | មូលនិធិសរុប | ការបែងចែក |
| --- | --- | --- |
| សម្ភារៈការពារផ្ទាល់ខ្លួន (Personal Protective Equipment, PPE)៖ ក្រណាត់ម៉ាស់ (ម៉ាស់ និងរបាំងមុខ ប្រសិនបើសមស្រប) ដើម្បីធានាថាសិស្ស បុគ្គលិក និងគ្រួសារដែលចូលទៅក្នុងទីតាំងសាលារៀន និងបុគ្គលិកដែលធ្វើការនៅក្នុងសហគមន៍ នឹងកាត់បន្ថយជាអប្បបរមានៃការរីកសាយភាយនៃចំហាយភាគល្អិតតាមផ្លូវដង្ហើម នៅពេលស្ថិតនៅក្នុងបរិវេណសាលា។ បង្កើនការផ្គត់ផ្គង់សាប៊ូ និងទឹកលាងដៃ និងទែម៉ូម៉ែត្រដើម្បីពិនិត្យមើលសីតុណ្ហភាពសិស្ស និងសម្ភារៈផ្គត់ផ្គង់បន្ថែមទៀតដើម្បីឆ្លើយតបចំពោះសិស្សដែលបង្ហាញរោគសញ្ញានៃជំងឺ៖ (IPI-8) | $4,180,277 | ទេ |
| កម្មវិធីសហ្វវែរតាមដានអ្នកដែលប៉ះពាល់ផ្ទាល់ និងត្រួតពិនិត្យរោគសញ្ញានៃជំងឺនឹងជំងឺ COVID-19 របស់ក្រុមហ៊ុន Qualtrics សម្រាប់សិស្ស បុគ្គលិក និងគ្រួសារគ្រប់រូបដើម្បីប្រើប្រាស់សម្រាប់ជាមូលដ្ឋានទិន្នន័យ និងកម្មវិធីសុវត្ថិភាពសម្រាប់សុខភាពនិងសុខុមាលភាពនៃការផ្តល់ជូនវគ្គបង្រៀនដោយផ្ទាល់ នៅក្នុងការឆ្លើយតបទៅនឹងជំងឺរាតត្បាត COVID-19។ (IPI-9) | $50,427 | ទេ |

# កម្មវិធីសិក្សាពីចម្ងាយ

## ការបន្តការបង្រៀន

[ការពិពណ៌នាអំពីរបៀបដែលភ្នាក់ងារ LEA នឹងផ្តល់ជូនការបន្តការបង្រៀននៅអំឡុងឆ្នាំសិក្សានេះ ដើម្បីធានាឲ្យសិស្សទទួលបានកម្មវិធីសិក្សា ពេញលេញដែលមានគុណភាពប្រហាក់ប្រហែលគ្នាខ្លាំងពាក់ព័ន្ធនឹងវិធីសាស្ត្រនៃការផ្តល់ជូន រួមទាំងផែនការសម្រាប់កម្មវិធីសិក្សា និងធនធានបង្រៀនរបស់ភ្នាក់ងារ LEA ដែលនឹងធានាបាននូវការបន្តការបង្រៀនសម្រាប់សិស្ស ប្រសិនបើការផ្ទេររវាងការសិក្សាដោយផ្ទាល់ និងការបង្រៀនពីចម្ងាយមានការចាំបាច់។]

មណ្ឌលសិក្សាធិការរួបរួមស្តុកតុន (Stockton Unified School District, SUSD) ប្តេជ្ញាចិត្តផ្តល់ការបង្រៀនពីចម្ងាយប្រកបដោយគុណភាពខ្ពស់ដែលជំរុញបន្ថែមតាមរយៈឯកសារសិក្សាបង្កើតឡើងដោយមណ្ឌលសិក្សាធិការទៅតាមស្តង់ដា ផ្តោតលើខ្លឹមសាតាមកម្រិតថ្នាក់ ទន្ទឹមគ្នានឹងការផ្តល់ជូនឱកាសសិក្សាផ្នែកចិត្តសង្គមដែលដោះស្រាយបញ្ហាសុខុមាលភាពចិត្តសង្គមរបស់សិស្សគ្រប់រូប។ ឯកសារដំណភ្ជាប់ឆាប់រហ័សមួយ ត្រូវបានបង្កើតឡើងសម្រាប់ការចូលទៅប្រើប្រាស់បានដោយងាយសម្រាប់ឪពុកម្តាយ និងសិស្សដើម្បីតភ្ជាប់ទៅកាន់សម្ភារៈឧបទេសសិក្សាដែលបង្កើតឡើងដោយមណ្ឌលសិក្សាធិការតាមអនឡាញ ហើយការណែនាំធនធានបច្ចេកវិទ្យាសម្រាប់ឪពុកម្តាយនិងសិស្ស បានបង្កើតឡើងជាចម្រុះភាសា ដើម្បីជួយគាំទ្រដល់ការចូលទៅប្រើប្រាស់ធនធាន និងព័ត៌មានបានកាន់តែច្រើន និងកាន់តែល្អប្រសើរឡើង។ ផ្នែកកម្មវិធីសិក្សា និងការបង្រៀន បានបង្កើតឯកសារនានាសម្រាប់សិស្ស និងក្រុមគ្រួសារ ដែលផ្តល់ជូននូវការចូលទៅប្រើប្រាស់ឯកសារសិក្សាបង្កើតឡើងដោយមណ្ឌលសិក្សាធិការទាំងស្រុង (ហៅថា កម្មវិធីសិក្សា) ហើយនិងឯកសារណែនាំសម្រាប់គ្រូនិងបុគ្គលិកសម្រាប់ផ្តល់ជូនការបន្តសេវាអប់រំនៅអំឡុងពេលនៃការសិក្សាពីចម្ងាយ ដោយផ្តោតលើខ្លឹមសារបង្រៀន កាលវេលាវាយតម្លៃនិងពិធីសារនានា ជំនាញមូលដ្ឋានគ្រឹះដែលត្រូវបង្រៀនជាប្រព័ន្ធ និងដោយផ្ទាល់ដោយមានការគាំទ្រដោយពេលវេលាអនុវត្តជាក្រុមតូចៗ ការវាយតម្លៃកែលម្អដើម្បីណែនាំការកែសម្រួលការបង្រៀន បង្ហាញអំពីស្តង់ដាស្នូលរួមរបស់រដ្ឋ (Common Core State Standards, CCSS) និងការគាំទ្រការបង្រៀនសម្រាប់អ្នកសិក្សាភាសាអង់គ្លេស ទាំងក្នុងក្របខណ្ឌអភិវឌ្ឍភាសាអង់គ្លេស (English Language Development, ELD) ដែលបានកំណត់ និងដែលបានដាក់បញ្ចូលគ្នា។ មណ្ឌលសិក្សាធិការ SUSD បានបង្កើតការណែនាំស្តីពីផែនការបន្តការអប់រំសម្រាប់ឲ្យបុគ្គលិកមណ្ឌលសិក្សាធិការប្រើប្រាស់ជាធនធានសម្រាប់ការត្រៀមខ្លួនជាមូលដ្ឋាន ការត្រៀមខ្លួនរយៈពេលខ្លី និងការត្រៀមខ្លួនរយៈពេលវែង នៅក្នុងការ

ផ្តល់សេវាអប់រំនៅក្នុងពេលជំងឺរាតត្បាត COVID-19។

នៅតាមកម្រិតទីតាំង ផ្នែករដ្ឋបាលទីតាំង នឹងដឹកនាំការធ្វើផែនការ និងកំណត់ពេលកិច្ចដំណើរការសម្រាប់ចែកចាយឯកសារសិក្សាសម្រាប់សិស្ស និងសហការធ្វើការងារជាមួយគ្រូ ក្រុមការងារតាមកម្រិតថ្នាក់ និងក្រុមការតាមមុខវិជ្ជា ទៅលើចរនាសម្ព័ន្ធនៃការផ្តល់ជូនហ្វូលឌ័រឯកសារតាមទីតាំងសម្រាប់កិច្ចសហការ និងចែករំលែកធនធានដែលត្រូវបានប្រើប្រាស់រួមគ្នាជាមួយសិស្សក្នុងថ្នាក់ (ដ្រាយស្តុកទិន្នន័យរួម (shared drive) កម្មវិធី Google Classroom គេហទំព័រសាលា/ថ្នាក់រៀនជាដើម)។ កាលវិភាគជួងផ្តល់សញ្ញាប្រចាំថ្ងៃសម្រាប់ការបង្រៀន និងប្រព័ន្ធកំណត់សម្គាល់សម្រាប់មេរៀន និងធនធានដែលត្រូវប្រមូលនៅក្នុងទីតាំងហ្វូលឌ័រឯកសាររួមក្នុងទីតាំង ត្រូវបានបង្កើតឡើងនៅក្នុងការគាំទ្រដល់ការសិក្សាពីចម្ងាយ។ អ្នករដ្ឋបាលតាមទីតាំង នឹងបង្កើត និងប្រាស្រ័យទាក់ទងប្រាប់ព័ត៌មានទំនាក់ទំនងសម្រាប់ការវិភាគនិងដោះស្រាយបញ្ហាទៅដល់ក្រុមគ្រួសារ និងបុគ្គលិកសម្រាប់ការគាំទ្រផ្នែកបច្ចេកវិទ្យា ការគាំទ្រកម្មវិធីសិក្សា និងសុខភាពនិងសុវត្ថិភាពរបស់កុមារ បញ្ជារវត្តមាន កាលបរិច្ឆេទប្រជុំនិងសិក្ខាសាលា និងព័ត៌មានសំខាន់ៗផ្សេងទៀត។ គ្រូបង្រៀន នឹងផ្តល់ទំនាក់ទំនងឡាយផ្ទាល់ប្រចាំថ្ងៃសម្រាប់គោលបំណងនៃការបង្រៀន ការគ្រប់គ្រងវឌ្ឍនភាព និងការថែរក្សាការផ្សារភ្ជាប់ទំនាក់ទំនងសាលារៀនតាមរយៈទម្រង់នៃការផ្តល់ជូនក្នុងពេលតែមួយ និងក្នុងពេលផ្សេងគ្នា។ សម្រាប់ថ្នាក់មត្តេយ្យដល់ថ្នាក់ទី12 (K-12) ការវាយតម្លៃ នឹងប្រព្រឹតទៅទូទាំងឆ្នាំសិក្សា ស្របតាមការរំពឹងទុករបស់មណ្ឌលសិក្សាធិការ SUSD សម្រាប់ការវាយតម្លៃដែលបានកំណត់សម្រាប់ត្រីមាស (សិស្សថ្នាក់មត្តេយ្យដល់ថ្នាកទី8) និងចន្លោះពេលបីខែ/ត្រីមាស (សិស្សថ្នាក់ទី9 ដល់ទី12)។ គ្រូអប់រំទូទៅ និងអ្នកជំនាញផ្នែកអប់រំពិសេស នឹងសហការគ្នាប្រើប្រាស់ពេលវេលាធ្វើផែនការរួមគ្នាដើម្បីដោះស្រាយបញ្ហាប្រើប្រាស់បច្ចេកទេសបង្រៀនពិសេសសម្រាប់សិស្សទាំងអស់ដែលត្រូវកាជំនួយពិសេសនៅក្នុងការវាយតម្លៃ។ ការសិក្សាពីចម្ងាយសម្រាប់ការអប់រំពិសេស នឹងប្រព្រឹតទៅជាទម្រង់នៃការបង្រៀនតាមរយៈការប្រើប្រាស់បច្ចេកវិទ្យាចម្រុះច្រើនប្រភេទដើម្បីដោះស្រាយបញ្ហាទំនាក់ទំនងគ្រូ-សិស្ស និងទំនាក់ទំនងសិស្ស-គ្រូ។ គ្រូនឹងចែករំលែកឯកសារសិក្សាប្រចាំថ្ងៃ ហើយនឹងរក្សាការប្រាស្រ័យទាក់ទងជាប្រចាំជាមួយគ្រូសារជាមួយឪពុកម្តាយ តាមរយៈការហៅទូរសព្ទត្រួតពិនិត្យដោយផ្ទាល់ អ៊ីម៉ែល សារជាអក្សរ កម្មវិធី Google Classroom កម្មវិធី SeeSaw កម្មវិធី Classdojo កម្មវិធី Reminds កម្មវិធី Padlet កម្មវិធី Kami កម្មវិធី Zoom ម៉ោងធ្វើការធម្មតា និងប្រព័ន្ធកម្មវិធីតាមអនឡាញផ្សេងទៀត។

មណ្ឌលសិក្សាធិការ SUSD នឹងគ្រប់គ្រងស្តង់ដាកម្រិតថ្នាក់ ផ្អែកលើការវាយតម្លៃពិនិត្យវិនិច្ឆ័យជាមួយនឹងសិស្សដែលបានចុះឈ្មោះចូលរៀនទាំងអស់ ហើយបុគ្គលិកបង្រៀន នឹងសហការគ្នាវិភាគលើលទ្ធផលទន្នន័យរង្វាយតម្លៃ និងធ្វើផែនការបង្រៀនជាយុទ្ធសាស្ត្រដើម្បីដោះស្រាយបញ្ហាខ្វះចន្លោះដែលបានរកឃើញទៅលើជំនាញសិក្សា និងចំណេះដឹង។ បុគ្គលិកបង្រៀន នឹងប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងការសិក្សា (ឧ.ទា. កម្មវិធី Google Classroom កម្មវិធី SeeSaw កម្មវិធីClassdojo) ដើម្បីផ្តល់ឯកសារសិក្សាតាមស្តង់ដា និងការវាយតម្លៃ ទន្ទឹមគ្នាជាមួយនឹងកាផ្តល់ជូនការចូលទៅប្រើប្រាស់កម្មវិធីសិក្សាបង្កើតឡើងដោយមណ្ឌលសិក្សាពេញលេញសម្រាប់សិស្ស និងសំណៅចម្លងជាក់ស្តែងនៃសៀវភៅសិក្សាគោលសម្រាប់សិស្សដែលសិក្សាអំឡុងពេលសិក្សាពីចម្ងាយ។ ការបង្រៀនរវាងគ្រូនិងសិស្សនៅម៉ោងឡាយផ្ទាល់ជាក់ស្តែងក្នុងពេលតែមួយ នឹងផ្តល់ជូនប្រចាំថ្ងៃ។  ការបង្រៀនឡាយផ្ទាល់ នឹងយកគំរូលំនាំតាមថ្នាក់រៀនជាក់ស្តែងតាមដែលអាចធ្វើបាននៅក្នុងក្របខណ្ឌនៃការបង្រៀនពីចម្ងាយ ផ្តល់ឱកាសឲ្យសិស្សសួរសំណួរ និងទទួលបានមតិយោបល់ត្រឡប់ ជំរុញឲ្យសិស្សចូលរួមក្នុងបទពិសោធន៍សិក្សាតាមបែបសហការ ណែនាំសិស្សឲ្យចូលប្រើប្រាស់កម្មវិធីសិក្សានិងការវាយតម្លៃតាមអនឡាញ និងផ្តល់ការគាំទ្រការបង្រៀនជាក្រុម និងការបង្រៀនផ្ទាល់មួយទល់នឹងមួយ។ នៅក្នុងការរៀន-បង្រៀនក្នុងពេលដាច់ដោយឡែកដែលមានសិស្សចូលរួម ពួកគេម្នាក់ៗធ្វើការសិក្សាលើឯកសារតែមួយដូចគ្នា ប៉ុន្តែនៅពេលវេលា/ទីកន្លែងផ្សេងគ្នា ការសិក្សានេះនឹងមានភាពស្របគ្នាទៅតាមការរៀននិងបង្រៀនឡាយផ្ទាល់ ការផ្តល់មតិយោបល់ត្រឡប់របស់គ្រូ ហើយឱកាសក្នុងការផ្តល់សំណួរ នឹងប្រព្រឹតទៅក្នុងការបង្រៀនឡាយផ្ទាល់ ឬតាមរយៈទម្រង់នៃទំនាក់ទំនងពីចម្ងាយ (ឧ.ទា. អ៊ីម៉ែល)  សិស្សអាចមានទំនាក់ទំនងជាមួយខ្លឹមសារសិក្សាទៅតាមកម្រិតនៃការសិក្សារបស់ខ្លួន និងអនុញ្ញាតឲ្យមានភាពបត់បែនច្រើនបន្ថែមទៅក្នុងការកំណត់កាលវិភាគ។ សិស្សនឹងទទួលបានការវាយតម្លៃសិក្សារៀនសូត្រដែលត្រូវបំពេញនៅអំឡុងពេលទំនាក់ទំនងក្នុងម៉ោងឡាយផ្ទាល់ជាក់ស្តែងជាមួយគ្រូរបស់ពួកគេ និងអំឡុងម៉ោងអប់ឡាញ (off-line) ដោយគ្រូបន្តធ្វើការតាមដានកិច្ចការលំហាត់សិស្សនៅក្នុងសៀវភៅកត់ត្រាពិន្ទុ។ ការសិក្សាពីចម្ងាយ នឹងផ្អែកលើកម្មវិធីសិក្សាដែលបានបង្កើតឡើងរបស់មណ្ឌលសិក្សាធិការ SUSD៖ កម្មវិធីសិក្សា Benchmark កម្មវិធីសិក្សា Steps to Advance កម្មវិធីសិក្សា Attainment កម្មវិធីសិក្សា Pearson និងកម្មវិធីសិក្សា iReady Math ដោយមានការចូលទៅប្រើប្រាស់រាល់កម្មវិធីសិក្សាទាំងអស់នេះតាមអនឡាញ។ ការចូលរៀនប្រចាំថ្ងៃ នឹងត្រូវបានគ្រូចុះវត្តមាន ហើយទំនាក់ទំនងក្នុងចំណោមគ្រូ សិស្ស និងឪពុកម្តាយ និង/ឬ អាណាព្យាបាល នឹងនៅតែបន្តអនុវត្តនៅក្នុងការគាំទ្រដល់ការបន្តការបង្រៀនសម្រាប់សិស្ស។ ឧបករណ៍តន្ត្រី ត្រូវសម្អាតអនាម័យ ហើយចែកជូនដល់សិស្សសម្រាប់ត្រីមាស/ឆ្នាំ ទៅតាមការណែនាំសុវត្ថិភាពរបស់មជ្ឈមណ្ឌលគ្រប់គ្រងជំងឺ (Center for Disease Control)។ នៅរដូវផ្ការីក ឆ្នាំ2020 នៅពេលមណ្ឌលសិក្សាធិការបានលើកឡើងជាលើកដំបូងអំពីផលប៉ះពាល់នៃជំងឺ COVID-19 មណ្ឌលសិក្សាធិការ SUSD បានបង្កើត និងផ្តល់ទៅឲ្យបុគ្គលិកនូវផែនការត្រៀមសម្រាប់ការបន្តការអប់រំ ដែលបាន

ផ្តល់មកជាមួយនូវធនធានសម្រាប់ការផ្តល់ជូនការសិក្សាពីចម្ងាយប្រកបដោយគុណភាព និងបានបង្កើតឯកសារណែនាំសម្រាប់គ្រូដែលផ្តោតទៅលើការកំណត់ពេលវេលាបង្រៀនប្រចាំថ្ងៃ របៀបប្រើប្រាស់ធនធាននៃកម្មវិធី Google Classroom កម្មវិធី Google Hangout កម្មវិធី Google Meet និងកម្មវិធី Zoom សម្រាប់គ្រូនិងសិស្ស។ មណ្ឌលសិក្សាធិការ SUSD បានបង្កើតការណែនាំស្តីពីការសិក្សាពីចម្ងាយដែលអាចចូលប្រើប្រាស់បានសម្រាប់ភាគីពាក់ព័ន្ធជាចម្រុះភាសា និងត្រូវបានចែកជូននៅអំឡុងពេលចាប់ផ្តើមនៃការសិក្សាពីចម្ងាយដែលបានផ្តល់ជូនសម្រាប់ឆ្នាំសិក្សា2020-2021។ កម្មវិធីប្រមូលសិស្សចូលរៀន (Back to School Nights) និងបទបង្ហាញរបស់ឪពុកម្តាយលើកម្មវិធី Title 1 ត្រូវបានផ្តល់ជូនតាមរយៈប្រព័ន្ធកម្មវិធីតាមអ៊ីនធឺណិតដែលអនុញ្ញាតឲ្យឪពុកម្តាយចូលរួម និងពិភាក្សាជាមួយបុគ្គលិកសាលាទៅលើចម្ងល់នានា និងផ្នែកនៃការគាំទ្រដែលចាំបាច់ជារួមនៅក្នុងក្របខណ្ឌនៃការសិក្សាពីចម្ងាយ។ ការណែនាំអំពីធនធានបច្ចេកវិទ្យាសម្រាប់ឪពុកម្តាយនិងសិស្ស ត្រូវបានបង្កើតឡើង កំណត់ទីតាំងនៅទំព័រដើមរបស់មណ្ឌលសិក្សាធិការ USD និងរកឃើញភ្លាម នៅពេលអ្នកចុចលើរូបអាយខុនសម្រាប់គ្រួសារ ដែលផ្តល់តំណភ្ជាប់ និងធនធានសម្រាប់ការបណ្តុះបណ្តាលឪពុកម្តាយ/អាណាព្យាបាលឡាយផ្ទាល់ ព័ត៌មានស្តីពីការប្រើប្រាស់កម្មវិធី Google Chrome ធនធានពាក់ព័ន្ធនឹងប្រព័ន្ធគ្រប់គ្រងការសិក្សាផ្សេងៗ (LMS) ដែលកំពុងយកមកប្រើប្រាស់នៅក្នុងក្របខណ្ឌនៃការសិក្សាពីចម្ងាយ ប្រព័ន្ធកម្មវិធីបង្រៀនតាមវីដេអូឡាយផ្ទាល់ កម្មវិធីសិក្សាបង្កើតឡើងដោយមណ្ឌលសិក្សាធិការ កម្មវិធី G Suite តាម Google កម្មវិធី Illuminate និងកម្មវិធី Synergy ធនធានឯកសារបណ្ណាល័យ និងធនធានឯកសារយោងផ្សេងទៀត។

យោងតាមគោលនយោបាយក្រុមប្រឹក្សាភិបាលមណ្ឌលសិក្សាធិការ SUSD លេខ 5121 "កម្រិតថ្នាក់ គួរតែផ្អែកលើការគោរពតាមដោយឥតលម្អៀង និងឥតប្រែប្រួលទៅលើគុណភាពនៃការងាររបស់សិស្ស និងបំណិនប្រសព្វរបស់ពួកគេទៅលើខ្លឹមសារ និងវត្ថុបំណងនៃការវគ្គសិក្សា។ សិស្សគប្បីត្រូវមានឱកាសក្នុងការបង្ហាញអំពីបំណិនប្រសព្វនេះ តាមរយៈវិធីសាស្ត្រផ្សេងៗដូចជាការចូលរួមនៅក្នុងថ្នាក់រៀន កិច្ចការផ្ទះ តេស្ត និងព័ត៌មានផ្សេងៗ។" គោលនយោបាយដាក់ពិន្ទុរបស់មណ្ឌលសិក្ខាធិការ SUSD សម្រាប់ថ្នាក់មត្តេយ្យឆ្លងភូមិសិក្សាដល់ថ្នាក់ទី6 (TK-6) នឹងផ្តោតលើពិន្ទុតាមកម្រិតនិទ្ទេស 1, 2, 3, 4 នៃតារាងប្រត្តិបត្រពិន្ទុ និងថ្នាក់ទី7-ទី12 នឹងទទួលបានលិខិតបញ្ជាក់និទ្ទេស A (90%-100%), B (80%-89%), C (70%- 79%), D (60%-69%) និងគ្មានពិន្ទុ (ជំនួសដោយ F, 0-59%, នឹងមិនប៉ះពាល់ដល់GPA) ទៅលើតារាងប្រតិបត្តិពិន្ទុទេ។ តាមរយៈកម្រិតថ្នាក់ទាំងអស់របស់សិស្សដែលបានចុះឈ្មោះចូលរួមទៅក្នុងកម្មវិធីសិក្សាពីចម្ងាយ កាលវិភាគបង្រៀន បានផ្តល់ផ្តល់ឱកាសឲ្យគំរូនៃការបង្រៀនមានភាពបត់បែនទៅតាមគេហទំព័រសាលារៀន រួមទាំងម៉ោងឈប់សម្រាកផងដែរ និងផ្តល់នូវតុល្យភាពបង្រៀនរវាងការបង្រៀនឡាយផ្ទាល់ និងការសិក្សាស្របទៅតាមសិស្ស រវាងការរៀន-បង្រៀនក្នុងថ្នាក់រៀនទាំងមូល និងជាក្រុមតូចៗ។ ការសិក្សាពីចម្ងាយនៅរដូវផ្ការីកនៃឆ្នាំ2020 គឺជាបទពិសោធន៍សិក្សាសម្រាប់មនុស្សគ្រប់រូបដែលបានចូលរួម និង នៅក្នុងក្របខណ្ឌនៃយោបល់ត្រឡប់ដែលបានវិភាគដោយមណ្ឌលសិក្សាធិការ ការកែសម្រួល និងការកែលម្អនានា ត្រូវបានធ្វើឡើងដើម្បីបង្កើនការទទួលបានការបង្រៀនដោយផ្ទាល់សម្រាប់សិស្សពីគ្រូរបស់ពួកគេ សកម្មភាពចូលរួមនៅក្នុងការសិក្សា ការចូលទៅកាន់ធនធានអនឡាញសម្រាប់ក្រុមគ្រួសារ និងការបណ្តុះបណ្តាលគាំទ្រការសិក្សាពីចម្ងាយ ជាមួយនឹងការផ្តោតទៅលើទំនាក់សិស្សឲ្យបានច្រើន និងឱកាសក្នុងការចូលរួមយ៉ាងសកម្មទៅក្នុងបទពិសោធន៍សិក្សាពីចម្ងាយរបស់ពួកគេ។ មណ្ឌលសិក្សាធិការ បានធានាថា នៅក្នុងក្របខណ្ឌនៃការសិក្សាពីចម្ងាយ គ្រប់សិស្សទាំងអស់បានទទួលយ៉ាងហោចណាស់នូវចំនួននាទីនៃការបង្រៀនអប្បបរមាដែលបានតម្រូវដោយច្បាប់សភា Senate Bill 98៖ ថ្នាក់មត្តេយ្យឆ្លងភូមិសិក្សា (TK) & ថ្នាក់មត្តេយ្យមានចំនួននាទីបង្រៀនប្រចាំថ្ងៃ 180 នាទី ថ្នាក់ទី1-ទី3 មានចំនួននាទីបង្រៀន 240 នាទី។ បន្ទាប់ពីគណនាលើការបង្រៀនផ្សាយផ្ទាល់ប្រចាំថ្ងៃ គ្រូបានរៀបចំរចនាសម្ព័ន្ធជាយុទ្ធសាស្ត្រសម្រាប់ចំនួននាទីបង្រៀនពីចម្ងាយដែលនៅសេសសល់សម្រាប់ការថ្ងៃបង្រៀន។ ការទទួលបាន និងលទ្ធភាពសម្រាប់សិស្សនៅក្នុងការទទួលបានពេញលេញនូវកម្មវិធីសិក្សានេះ ដោយមិនគិតពីលំនាំគំរូនៃការបង្រៀន គឺជាការផ្តោតជាចម្បងរបស់មណ្ឌលសិក្សាធិការ SUSD។ កុំព្យូទ័រយួរដៃ ត្រូវបានប្រគល់ទៅដល់សិស្សគ្រប់រូបដែលត្រូវការការចូលទៅប្រើប្រាស់កុំព្យូទ័រយួរដៃនៅក្នុងទីកន្លែងស្នាក់នៅរបស់ពួកគេ ហើយវ៉ាយហ្វាយហត់ស្ប៉ត (WiFi hot spot) ត្រូវបានផ្តល់ជូនដល់សិស្សគ្រប់រូបដែលត្រូវការការតភ្ជាប់បណ្តាញអ៊ីនធឺណិតនៅក្នុងទីកន្លែងស្នាក់នៅរបស់ពួកគេ។ នៅក្នុងពេលប្រព្រឹតទៅនៃពេលវេលារង់ចាំរបស់មណ្ឌលសិក្សាធិការដែលទទួល ឬដាក់ដំឡើងហ្វីលទ័រចាំបាច់នៅក្នុងវ៉ាយហ្វាយហត់ស្ប៉ត (WiFi hot spot) បុគ្គលិកសាលាបានធ្វើការងាររួមគ្នាជាមួយគ្រួសាររបស់សិស្សដើម្បីផ្តល់នូវជម្រើសសិក្សាឯករាជ្យសម្រាប់សិស្ស និងផ្តល់ឲ្យពួកគេនូវឯកសារជាក់ស្តែងដែលត្រូវការជាចាំបាច់ដើម្បីចូលរួមនៅក្នុងការសិក្សា ខណៈពេលកំពុងរង់ចាំវ៉ាយហ្វាយហត់ស្ប៉តរបស់ពួកគេមកដល់។ លទ្ធភាពរបស់សិស្ស និងក្រុមគ្រួសារក្នុងចូលទៅជួបគ្រូបង្រៀនសម្រាប់ការសួរសំណួរ និងការគាំទ្រ គឺជាបណ្តុំនៃអត្ថបទបង្ហោះតាមអ៊ីនធឺណិតក្នុងក្របខណ្ឌនៃមតិចូលរួមរបស់ភាគីពាក់ព័ន្ធ ហើយប្រព័ន្ធនានា នឹងត្រូវបានដាក់ដំឡើងរួចជាស្រេចនៅតាមគេហទំព័ររបស់សាលា ដើម្បីរក្សាបាននូវឱកាសទំនាក់ទំនងដោយបើកចំហដូចជាម៉ោងធ្វើការតាមពេលវេលាកំណត់ជាដើម ដើម្បីរក្សាស្ថិរភាព និងអភិវឌ្ឍភាពជាដៃគូពេញលេញរវាងបុគ្គលិកសាលា និងក្រុមគ្រួសារ។

## ការទទួលបានឧបករណ៍អេឡិចត្រូនិក និងការតភ្ជាប់បណ្ដាញ

[ការពិពណ៌នាអំពីរបៀបដែលភ្នាក់ងារ LEA នឹងធានានូវការទទួលបានឧបករណ៍អេឡិចត្រូនិក និងការតភ្ជាប់បណ្ដាញសម្រាប់សិស្សគ្រប់រូប ដើម្បីគាំទ្រដល់ការសិក្សាពីចម្ងាយ។]

មណ្ឌលសិក្សាធិការ SUSD នឹងពិនិត្យមើលកុំព្យូទ័រយួរដៃម៉ាក Chromebook សម្រាប់សិស្សដែលបានចុះឈ្មោះចូលរៀន ដែលពួកគេត្រូវការកុំព្យូទ័រដើម្បីចូលរួមក្នុងការសិក្សាពីចម្ងាយ និងបំពេញកិច្ចសាលាដែលបានបានផ្ដល់ជូន។ ដើម្បីធានាថាសិស្សរបស់យើងទទួលបានអ៊ីនធឺណិតប្រើប្រាស់អំឡុងពេលសិក្សាពីចម្ងាយ មណ្ឌលសិក្សាធិការ SUSD ដំបូងបានកំណត់ថា៖ គ្រួសារដែលឪពុកម្ដាយទើបលែងលះ និងសិស្សយុវជននៅក្រោមការគ្រប់គ្រងរបស់ឪពុកម្ដាយចិញ្ចឹម ត្រូវបានផ្ដល់ជូននូវវ៉ាយហ្វាយហត់ស្ប៉ត (WiFi hot spot), គ្រួសារដែលបានបំពេញការស្ទង់មតិដែលបានផ្ដល់យោបល់ថាពួកគេមិនមានអ៊ីនធឺណិតប្រើប្រាស់នៅក្នុងកន្លែងស្នាក់នៅរបស់ពួកគេ និងមិនបានទទួលវ៉ាយហ្វាយហត់ស្ប៉តនៅរដូវផ្ការីកឆ្នាំ2020 ត្រូវបានផ្ដល់ជូនវ៉ាយហ្វាយហត់ស្ប៉ត (WiFi hot spot) ហើយថាអ្នកសិក្សាភាសាអង់គ្លេស និងសិស្សផ្សេងទៀតដែលមានតម្រូវការពិសេស ត្រូវបានផ្ដល់ជូនវ៉ាយហ្វាយហត់ស្ប៉ត (WiFi hot spot) នៅក្នុងកិច្ចដំណើរការនៃមណ្ឌលសិក្សាធិការ SUSD ដែលផ្ដល់ជូនវ៉ាយហ្វាយហត់ស្ប៉ត (WiFi hot spot) យ៉ាងតិចចំនួនមួយសម្រាប់គ្រប់ទីកន្លែងរបស់សិស្សគ្រប់រូប ដើម្បីគាំទ្រដល់ការតភ្ជាប់បណ្ដាញទៅកាន់ការចូលរួមសិក្សាពីចម្ងាយសម្រាប់សិស្ស ហើយនៅពេលណាដែលគេបានបញ្ជាក់ថាសមាជិកគ្រប់រូបបានទទួលវ៉ាយហ្វាយហត់ស្ប៉ត (WiFi hot spot) ពេលនោះមណ្ឌលសិក្សាធិការ SUSD នឹងចាប់ផ្ដើមកិច្ចដំណើរការនៃការធានាសិស្សគ្រប់រូប បានទទួលវ៉ាយហ្វាយហត់ស្ប៉ត (WiFi hot spot), មណ្ឌលសិក្សាធិការ SUSD បានបញ្ជាទិញវ៉ាយហ្វាយហត់ស្ប៉ត (WiFi hot spot) គ្រប់គ្រាន់សម្រាប់ការចែកចាយដោយផ្ទាល់មួយទៅដល់សិស្សដែលបានចុះឈ្មោះទាំងអស់ និងចំនួនបន្ថែមសម្រាប់បុគ្គលិកបង្រៀនទាំងឡាយណាដែលត្រូវការការគាំទ្រការតភ្ជាប់បណ្ដាញ។ មណ្ឌលសិក្សាធិការ SUSD បានផ្ដល់ជូនការស្ទង់មតិលើការតភ្ជាប់បណ្ដាញនៅអំឡុងរដូវផ្ការីកនៃឆ្នាំ2020 នៅអំឡុងរដូវក្ដៅ និងអំឡុងពេលចាប់ផ្ដើមឆ្នាំសិក្សា2020-2021 ដើម្បីកំណត់អត្តសញ្ញាណក្រុមគ្រួសារដែលត្រូវការវ៉ាយហ្វាយហត់ស្ប៉ត (WiFi hot spot) និងកុំព្យូទ័រ, បានផ្ដល់ព័ត៌មានស្ដីពីទីតាំងដែលត្រូវចូលប្រើប្រាស់ដោយឥតគិតថ្លៃ និងមានតម្លៃថោកពីភ្នាក់ងារផ្ដល់សេវារបស់មណ្ឌលសិក្សាធិការ, និងបន្តជាមួយនឹងការគាំទ្របច្ចេកវិទ្យា និងការផ្សព្វផ្សាយលើការវិភាគនិងដោះស្រាយបញ្ហាតាមរយៈនីតិវិធីដែលបានអនុវត្តអំឡុងពេលបិទអគារសិក្សានៅដំណាច់ឆ្នាំសិក្សា 2020 ដោយសារតែជំងឺរាតត្បាត។ ទីតាំងសាលា នឹងមានទំនាក់ទំនងឥតប្រែប្រួលជាមួយសិស្ស និងក្រុមគ្រួសារ ហើយនឹងជួយដល់ក្រុមគ្រួសារឲ្យដោះស្រាយបញ្ហាទទួលបានការតភ្ជាប់បណ្ដាញ តាមរយៈការពិនិត្យមើលបច្ចេកវិទ្យាថ្មីៗសម្រាប់សិស្ស ប្រសិនបើកុំព្យូទ័រខូច ឬដំណើរការខុសប្រក្រតី ដោយជំរុញឲ្យក្រុមការងារបច្ចេកទេសនៅតាមទីតាំងសាលាធ្វើការវិភាគនិងដោះស្រាយបញ្ហាបច្ចេកវិទ្យា ដើម្បីកំណត់ថាតើមានបញ្ហាកំហុសអ្នកប្រើប្រាស់ ឬបញ្ហាបច្ចេកទេសដែរឬអត់ និងធ្វើការងារសហការជាមួយផ្នែកកម្មវិធីសិក្សានិងបច្ចេកវិទ្យាបង្រៀន និងផ្នែកគាំទ្រ

ការបង្រៀន ដើម្បីធានាបំពេញតម្រូវការផ្នែកបច្ចេកវិទ្យាសម្រាប់សិស្ស ស្របគ្នាជាមួយនឹងការប្រើប្រាស់ឧបករណ៍ និងការតភ្ជាប់បណ្ដាញ។ បុគ្គលិកតាមទីតាំងសាលាបានធ្វើការងារដោយរួមសហការជាមួយក្រុមគ្រួសារដើម្បីកំណត់នូវឱកាសសុវត្ថិភាព និងសមស្របសម្រាប់សិស្សដើម្បីទទួលបានការតភ្ជាប់បណ្ដាញអ៊ីនធឺណិត ដើម្បីឲ្យពួកគេអាចចូលរួមនៅក្នុងការសិក្សាពីចម្ងាយ រហូតដល់ពេលការផ្ដល់វ៉ាយហ្វាយហត់ស្ប៉ត (WiFi hot spots) និងហ្វីលទ័រចាំបាច់នានា ត្រូវបានដំឡើង។ ទម្រង់បែបបទ និងកិច្ចដំណើរការចុះហត្ថលេខា ត្រូវបានធ្វើឌីជីថលរូបនីយកម្ម ដើម្បីបង្កើនលទ្ធភាពចូលប្រើប្រាស់ និងប្រព័ន្ធកម្មវិធីដែលសមស្របតាមអ្នកប្រើប្រាស់ ជូនដល់ក្រុមគ្រួសារដើម្បីបំពេញទម្រង់បែបបទដែលបានកំណត់ដោយមណ្ឌលសិក្សាធិការ SUSD សម្រាប់ព័ត៌មានសំខាន់ៗ។ ការចុះតាមផ្ទះ នឹងបន្តអនុវត្តសម្រាប់ការផ្សព្វផ្សាយ និងការគាំទ្រដល់ក្រុមគ្រួសាររបស់សិស្ស ដែលនៅក្នុងនោះ តាមរយៈកិច្ចខិតខំប្រឹងប្រែងគ្រប់បែបយ៉ាង មណ្ឌលសិក្សាធិការ SUSD នៅតែមិនអាចភ្ជាប់ទំនាក់ទំនងទៅកាន់សិស្ស និងសមាជិកគ្រួសារបាន។

## ការចូលរួមរបស់សិស្ស និងវឌ្ឍនភាព

[ការពិពណ៌នាអំពីរបៀបដែលភ្នាក់ងារ LEA នឹងវាយតម្លៃលើវឌ្ឍនភាពរបស់សិស្ស តាមរយៈទំនាក់ទំនងឡាយផ្ទាល់ និងចំនួននាទីបង្រៀនក្នុងពេលតែមួយ និងការពិពណ៌នាអំពីរបៀបដែលភ្នាក់ងារ LEA នឹងវាស់ស្ទង់លើការចូលរួម និងបរិមាណពេលវេលានៃការងាររបស់សិស្ស។]

មណ្ឌលសិក្សាធិការ SUSD បានធានាថាគ្រប់សាលារៀនទាំងអស់ យ៉ាងហោចណាស់កំពុងតែសម្រេចបាននូវចំនួននាទីបង្រៀនអប្បបរមាដូចដែលបានកំណត់ដោយច្បាប់សភា Assembly Bill 77 ដែលសមស្របជាមួយការបង្រៀនឡាយផ្ទាល់ប្រចាំថ្ងៃ និងបទពិសោធន៍សិក្សាពីចម្ងាយ។ ទីតាំងសាលានីមួយៗ បានបង្កើតនូវកាលវិភាគ

ជួងផ្តល់សញ្ញាសម្រាប់ការបង្រៀននិងរៀនពីចម្ងាយ បានចុះវត្តប្រចាំថ្ងៃពាក់ព័ន្ធនឹងទំនាក់ទំនងឡាយផ្ទាល់ និងចំនួននាទីបង្រៀនក្នុងពេលតែមួយ ការសិក្សាក្នុងពេលដាច់ដោយឡែកពីគ្នា និងទម្រង់បែបបទចូលរួមរបស់សិស្សប្រចាំថ្ងៃដែលបានបំពេញ ហើយ អ្នកគ្រប់គ្រងរដ្ឋបាលទីតាំង បានទទួលនូវការចូលត្រួតពិនិត្យតាមប្រព័ន្ធឌីជីថលទៅលើគោលវិធីសិក្សាពីចម្ងាយរបស់គ្រូ ដើម្បីឲ្យដូចគ្នាទៅនឹងការចូលទៅកាន់ថ្នាក់រៀនជាក់ស្តែងនៅតាមទីតាំងធម្មតាដែរ។ រង្វាយតម្លៃដែលធ្វើការវាយតម្លៃលើរបៀបដែលសិស្សកំពុងមានការលូតលាស់នៅក្នុងផ្នែកខ្លឹមសារស្នូលនៃមុខវិជ្ជាអក្សរសាស្រ្តភាសាអង់គ្លេស (ELA) គណិតវិទ្យា និងការអភិវឌ្ឍភាសាអង់គ្លេស (ELD) នឹងប្រព្រឹតទៅនៅក្នុងឆ្នាំសិក្សាទាំងមូល ហើយ បុគ្គលិកបង្រៀន នឹងប្រើប្រាស់ការវាយតម្លៃតាមកម្មវិធីសិក្សា និងការវាយតម្លៃកែលម្អទូទៅ ដើម្បីត្រួតពិនិត្យវឌ្ឍនភាពរបស់សិស្ស និងកែសម្រួលការបង្រៀនដើម្បីបំពេញតាមតម្រូវការបុគ្គលរបស់សិស្ស។ ការបង្រៀនឡាយផ្ទាល់ នឹងត្រូវបានផ្តល់ជូននៅអំឡុងសិក្សាពីចម្ងាយ ដោយមានការរួមបញ្ចូលគ្នាជាយុទ្ធសាស្ត្រនៃសកម្មភាពបង្រៀនក្នុងថ្នាក់រៀនទាំងមូល ក្រុមតូចៗ ផ្ទាល់មួយទល់នឹងមួយ និងសកម្មភាពសិក្សាឯករាជ្យ។  យុទ្ធសាស្ត្របង្រៀនដូចគ្នាជាច្រើនដែលបានប្រើប្រាស់នៅក្នុងក្របខណ្ឌវគ្គបង្រៀនដោយផ្ទាល់ នឹងត្រូវបានប្រើប្រាស់ដើម្បីវាស់ស្ទង់ការចូលរួម ចំនួនពេលវេលាសម្រាប់កិច្ចការសិស្ស ដូចជាការត្រួតពិនិត្យការយល់ដឹង ការដាក់កិច្ចការស្របតាមកម្មវិធីសិក្សា គម្រោងសិក្សា បទបង្ហាញ ការវាយតម្លៃតាមកម្មវិធីសិក្សា ការវាយតម្លៃបញ្ចប់ និងស្នាដៃកិច្ចការសិស្សដូចជាការកត់ត្រា កិច្ចការសរសេរ និងសកម្មភាពដែលគ្រូបានបង្កើតឡើង។ ការអនុវត្តការវាយតម្លៃកែលម្អ នឹងត្រូវបានប្រើប្រាស់ដោយបុគ្គលិក ដើម្បីកំណត់ទៅលើបុគ្គល និងថ្នាក់រៀនទាំងមូល ផ្អែកតាមតម្រូវការរបស់សិស្សនៅក្នុងការសិក្សាតាមស្តង់ដា។ ភាពជាដៃគូរវាងគ្រូ និងឪពុកម្តាយ/អាណាព្យាបាល នឹងបន្តប្រព្រឹតទៅជាមួយនឹងការបង្ហាញប្រាប់អំពីការរំពឹងទុក គោលដៅ និងវឌ្ឍនភាពរបស់សិស្ស។ ប្រព័ន្ធ StudentVue និងប្រព័ន្ធ ParentVue គឺជាធនធានសម្រាប់ក្រុមគ្រួសារ និងសិស្សដើម្បីប្រើប្រាស់ក្នុងការគ្រប់គ្រងវត្តមាន និងពិន្ទុ។ គ្រូនឹងប្រើប្រាស់គំរូនៃការប្រាស្រ័យទាក់ទងផ្សេងៗ ដើម្បីផ្តល់ការផ្សព្វផ្សាយ និងការប្រាស្រ័យទាក់ទងឲ្យបានញឹកញាប់ និងជាបន្តបន្ទាប់ទៅដល់សិស្ស និងក្រុមគ្រួសារនានា ដោយជម្រាបប្រាប់អំពីវឌ្ឍនភាពរបស់សិស្ស ស្របជាមួយនឹងគោលការណ៍ដាក់ពិន្ទុរបស់មណ្ឌលសិក្សាធិការ SUSD ដើម្បីរក្សាបាននូវការតភ្ជាប់ទំនាក់ទំនងផ្ទះ និងសាលារៀន។

សិស្សទាំងអស់ ត្រូវបានរំពឹងថានឹងចូលរួមទៅក្នុងការបង្រៀនឡាយផ្ទាល់តាមអនឡាញរៀងរាល់ថ្ងៃ ហើយសិស្សដែលមិនចូលរួមប្រចាំថ្ងៃនៅក្នុងការសិក្សាពីចម្ងាយ (ក្នុងពេលតែមួយ និង/ឬក្នុងពេលដាច់ដោយឡែក) ត្រូវបានគូសសញ្ញាអវត្តមានសម្រាប់ថ្ងៃសិក្សាសម្រាប់ការមិនចូលរួម ហើយ កិច្ចខិតខំប្រឹងប្រែងពីបុគ្គលិកតាមទីតាំងសាលារៀន នឹងត្រូវបានធ្វើឡើងដើម្បីទំនាក់ទំនងទៅកាន់គ្រួសារ និងសិស្ស និងសាកសួរថាហេតុអ្វីបានជាសិស្សមិនមានវត្តមានសម្រាប់ការសិក្សា ហើយតើសាលាអាចជួយគាំទ្រដល់សិស្សយ៉ាងដូចម្តេចនៅក្នុងការចូលសិក្សាពីចម្ងាយឲ្យបានជាប្រចាំ។ គ្រូនឹងស្រង់វត្តមានបង្រៀនឡាយផ្ទាល់ប្រចាំថ្ងៃ (ក្នុងពេលតែមួយ) ហើយវត្តមានការសិក្សាដែលសិស្សបានចូលរួម (ក្នុងពេលដាច់ដោយឡែក)។ វត្តមានបង្រៀនផ្ទាល់ នឹងផ្អែកលើកវត្តមានសិស្សនៅក្នុងប្រព័ន្ធកម្មវិធីសិក្សាពីចម្ងាយ (ក្នុងពេលដាច់ដោយឡែក) នឹងផ្អែកលើការវាស់ស្ទង់ចម្រុះនៃលទ្ធផលសិក្សារបស់សិស្សដូចជាការរបាយការណ៍ឡុកចូលទៅកាន់ប្រព័ន្ធគ្រប់គ្រងការសិក្សា (កម្មវិធី Google Classroom) កិច្ចការដែលសិស្សបានបំពេញ និងកម្មវិធីតាមអនឡាយផ្សេងទៀតដែលប្រើប្រាស់ដោយគ្រូសម្រាប់សិស្សប្រគល់កិច្ចការដល់គ្រូ។ ការរំពឹងទុកនោះគឺថា រាល់វត្តមាន/ការចូលរួមទាំងអស់ នឹងត្រូវបានចងក្រងទុកជាឯកសារប្រចាំថ្ងៃ ក្នុងប្រព័ន្ធព័ត៌មានរបស់សិស្ស (ហៅថា Synergy) រៀងរាល់ថ្ងៃ ដោយមានកំណត់ត្រាប្រចាំថ្ងៃដែលបានរក្សាទុកពាក់ព័ន្ធនឹងវត្តមាន និងការចូលរួមរបស់សិស្ស ដោយមានទាំងបុគ្គលិកប្រចាំការនៅសាលា ផ្នែកសុខមាលភាពកុមារ និងផ្នែកចូលរៀន ធ្វើការប្រាស្រ័យទាក់ទងជាមួយគ្រួសាររបស់សិស្សដែលអវត្តមាន និង/ឬមិនមានក្នុងឯកសារ សម្រាប់ជាចូលរួមចំណែកក្នុងក្របខណ្ឌនៃឱកាសសិក្សាពីចម្ងាយប្រចាំថ្ងៃ។ គ្រូ នឹងរក្សាទុកកំណត់ត្រាប្រចាំសប្តាហ៍ស្តីពីការចូលរួមរបស់សិស្ស ដោយការចងក្រងឯកសារវត្តមានចូលរួមក្នុងពេលជាមួយគ្នា និងក្នុងពេលដាច់ដោយឡែករបស់សិស្សម្នាក់ៗ សម្រាប់ថ្ងៃសិក្សានីមួយៗ ការបង្ហាញការចូលរួមរបស់សិស្សនៅក្នុងការបង្រៀនប្រចាំថ្ងៃ និងការបំពេញកិច្ចការរបស់សិស្ស។ ក្នុងនាមជាបុគ្គលិកបង្រៀនដែលបានទទួលស្គាល់ គ្រូនឹងកំណត់ចំនួនពេលវេលាកិច្ចការនានាដែលផ្តល់ទៅឲ្យសិស្សនៅក្នុងថ្នាក់/វគ្គសិក្សា ដែលស្របទៅតាមការសិក្សាដែលសិស្សអនុវត្តដោយខ្លួនឯង (ក្នុងពេលដាច់ដោយឡែក)។ គោលវិធីសម្រាប់គ្រូដែលកំណត់ចំនួនពេលវេលាសម្រាប់ការកិច្ចការសិក្សា នឹងអនុញ្ញាតឲ្យមានការបែងចែកភាពខុសគ្នានៅក្នុងការបំពេញតាមគោលវិធីសិក្សាទៅតាមកិច្ចការ និងការបង្រៀនដែលមានការសម្របសម្រួល ស្របគ្នាជាមួយនឹងតម្រូវការពិសេសរបស់សិស្សដែលគាំទ្រដោយការវាយតម្លៃ និងការអង្កេតរបស់គ្រូ។

## ការអភិវឌ្ឍជំនាញវិជ្ជាជីវៈសិក្សាពីចម្ងាយ

[ការពិពណ៌នាអំពីការអភិវឌ្ឍជំនាញវិជ្ជាជីវៈ និងធនធានដែលនឹងត្រូវផ្តល់ទៅដល់បុគ្គលិក ដើម្បីគាំទ្រដល់កម្មវិធីសិក្សាពីចម្ងាយ រួមទាំងការ

គាំទ្រផ្នែកបច្ចេកវិទ្យាផងដែរ។]

ការអភិវឌ្ឍជំនាញវិជ្ជា និងធនធាននានាដែលបានផ្តល់ជូនដល់បុគ្គលិកដើម្បីគាំទ្រដល់កម្មវិធីសិក្សាពីចម្ងាយ គឺជាឱកាសក្នុងពេលតែមួយ និងក្នុងពេលដាច់ដោយឡែកជាបន្តបន្ទាប់ ដែលផ្តោតលើប្រព័ន្ធកម្មវិធីសិក្សាពីចម្ងាយ ការជំរុញឲ្យសិស្សចូលរួមនៅក្នុងមជ្ឈដ្ឋានប្រព័ន្ធអ៊ីនធឺណិត គោលវិធីយល់ដឹងអំពីការប៉ះទង្គិចដើម្បីគាំទ្រដល់សិស្ស មេរៀនសិក្សាលើចិត្តសង្គម ការអនុវត្តការអភិវឌ្ឍភាសាអង់គ្លេស (ELD) ដែលបានកំណត់នឹងរួមបញ្ចូលគ្នានៅក្នុងការសិក្សាពីចម្ងាយ ការទទួលបាន និងការប្រើប្រាស់ធនធានអនឡាញនៃកម្មវិធីសិក្សាតាមស្តង់ដាររបស់មណ្ឌលសិក្សាធិការ និងការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងការសិក្សា (LMS) ដូចជាកម្មវិធី Google Classroom កម្មវិធី Synergy និងកម្មវិធី Illuminate ជាដើម។ មណ្ឌលសិក្សាធិការ SUSD ក៏នឹងផ្តល់ជូនប្រភេទការអភិវឌ្ឍវិជ្ជាជីវៈនានាជាច្រើនដែលមានឈ្មោះថា “Educators Thriving” សម្រាប់អ្នកអប់រំទាំងអស់នៅក្នុងមណ្ឌលសិក្សាធិការ SUSD ដែលផ្តល់ឱកាសសម្រាប់អ្នកដែលបញ្ចប់កម្មវិធីនេះឲ្យទទួលបានមេរៀនសិក្សាចំនួន 3 ពីមហាវិទ្យាល័យគ្រូសានចូឃីន (Teachers College of San Joaquin)។ កម្មវិធីនេះ គឺជាកម្មវិធីអភិវឌ្ឍបុគ្គលផ្អែកតាមការស្រាវជ្រាវដើម្បីជួយឲ្យអ្នកអប់រំទទួលបានសុខុមាលភាព ដែលផ្តល់ជូនពេញលេញតាមអនឡាញ និងដោយមានការចូលរួមនៅក្នុងបទពិសោធន៍សិក្សាក្នុងពេលជាមួយគ្នាជាមួយនឹងក្រុមតូចៗនៃអ្នកអប់រំរួមអាជីព។ មណ្ឌលសិក្សាធិការ SUSD បន្តផ្តល់ជូនប្រភេទការអភិវឌ្ឍវិជ្ជាជីវៈនានាជាច្រើននៅក្នុងពេលវេលាផ្សេងៗនៅទូទាំងឆ្នាំសិក្សា និងខែសិក្សានារដូវក្តៅ ដើម្បីដោះស្រាយបញ្ហាកសាងសមត្ថភាពអប់រំរបស់បុគ្គលិកអប់រំទាំងអស់ ដើម្បីបំពេញតាមតម្រូវការចម្រុះវប្បធម៌និងភាសារបស់សិស្សដែលបានផ្តល់ជូននៅក្នុងមណ្ឌលសិក្សាធិការទាំងមូល។ នាយកដ្ឋានកម្មវិធីសិក្សា និងបច្ចេកវិទ្យាបង្រៀន បានផ្តល់ជូនការបណ្តុះបណ្តាលការអភិវឌ្ឍជំនាញវិជ្ជាជីវៈដល់បុគ្គលិក និងបានបង្កើតធនធានឯកសារកំណត់ត្រាវិជ្ជាជីវៈតាមអ៊ីនធឺណិតនៃម៉ោងសិក្សាដែលបានកត់ត្រា ដោយគ្របដណ្តប់ទៅលើៈ មុខវិជ្ជាវិទ្យាសាស្ត្រ មុខវិជ្ជា ELA ការអភិវឌ្ឍ ELD គណិតវិទ្យា បច្ចេកវិទ្យា 4C កម្មវិធី Starting Off The Year Right ទស្សនៈទូទៅស្តីពីការរចនាប្លង់សកល (Overview of Universal Design For Learning) ការប្រើប្រាស់ការគាំទ្ររូបភាពសម្រាប់រចនាសម្ព័ន្ធ និងការពង្រឹងការអនុវត្តនៅតាមផ្ទះ ( Utilizing Visual Supports for Structure and Reinforcement at Home) គណិតវិទ្យាឌីហ្វែរ៉ងស្យែល/អន្តរាគមន៍តាមអ៊ីនធឺណិត (Virtual Differentiation/Intervention Math) បង្ហាញអំពីស្តង់ដាស្នូលរួមរបស់រដ្ឋ (Common Core State Standards) សកម្មភាព STEM វិទ្យាសាស្ត្រសង្គម(Social Sciences) ការសហការអន្តរបុគ្គល និងការធ្វើការងារជាក្រុមដើម្បីគាំទ្រដល់ការចូលទៅសិក្សាពីចម្ងាយសម្រាប់គោលដៅកម្មវិធី IEP ( Interpersonal Collaboration & Teaming To Support Distance Learning Access to IEP Goals) ការគាំទ្រដែលបានបង្កើតឡើងសម្រាប់ការអប់រំពិសេស (Special Education Designed Supports) ការបង្កើតខ្លឹមសារវីដេអូសម្រាប់ការបង្រៀនតាមអនឡាញ (Creating Video Content for Online Teaching) ការកសាងថ្នាក់រៀនតាមបណ្តាញអ៊ីនធឺណិតកម្រិត A ( Building A Virtual Classroom) ការកសាងចំណេះដឹងនៅផ្នែកវិន័យ (Building Knowledge in the Disciplines) ការណែនាំសម្រាប់អ្នកអប់រំ និងឪពុកម្តាយ (Educator and Parent Coaching)៖ កិច្ចដំណើរការនិងយុទ្ធសាស្ត្រ (Process and Strategies) កម្មវិធី Google Everything ការបង្រៀនបំណិនជីវិតតាមផ្ទះ (Teaching Life Skills At Home) ការប្រើប្រាស់បច្ចេកវិទ្យា (Utilizing Technology) ការគាំទ្រគ្រូថ្មី និងទើបចាប់ផ្តើមបង្រៀន (Supporting New & Beginning Teachers) ការសិក្សាផ្អែកតាមគម្រោងស្រាវជ្រាវ (Project Based Learning) ការដាក់ពិន្ទុឲ្យមានសមភាព (Grading for Equity) យុទ្ធសាស្ត្រតាមអ៊ីនធឺណិតសម្រាប់អ្នករៀនភាសាអង់គ្លេស (English Learner Virtual Strategies) ការកសាងទំនាក់ទំនង វប្បធម៌ និងការគ្រប់គ្រង (Building Rapport, Culture, & Management) និងការបង្រៀនបែបសហការដើម្បីធានាសមភាពសម្រាប់ទាំងអស់គ្នា (Collaborative Teaching To Ensure Equity for All)។ កិច្ចដំណើរការ ត្រូវបានអនុវត្តដើម្បីបណ្តុះបណ្តាលគ្រូបង្រៀនជំនួសនៅលើយុទ្ធសាស្ត្រដែលមានប្រសិទ្ធភាពសម្រាប់ការបង្រៀន និងការជំរុញសិស្សឲ្យចូលរួមក្នុងការសិក្សាពីចម្ងាយ និងរបៀបចូលរួម និងប្រើប្រាស់ឧបករណ៍បង្រៀនក្នុងកម្មវិធី Google Classroom ដែលគ្រូកំពុងយកមកប្រើប្រាស់សម្រាប់ការបង្រៀនឡាយផ្ទាល់ និងការសិក្សាដែលសិស្សអនុវត្តដោយខ្លួនឯង (ក្នុងពេលវេលាដាច់ដោយឡែក)។

ការគាំទ្របច្ចេកវិទ្យា ត្រូវបានផ្តល់ជូនដល់ផ្នែករដ្ឋបាលនៅតាមទីតាំងនិងបុគ្គលិបង្រៀនទាំងអស់ ដោយផ្តល់ទៅឲ្យពួកគេនូវកុំព្យូទ័រយួរដៃ ហើយ សម្រាប់អ្នកដែលបានបំពេញការស្ទង់មតិដោយបង្ហាញពីតម្រូវការសម្រាប់ការគាំទ្រលើការតភ្ជាប់បណ្តាញ និងមិនអាចស្ថិតនៅក្នុងបរិវេណសាលាដើម្បីតភ្ជាប់បណ្តាញវ៉ាយហ្វាយ (WiFi) របស់មណ្ឌលសិក្សាធិការដោយសារហេតុផលមួយចំនួន គឺត្រូវបានផ្តល់ជូនវ៉ាយហ្វាយហត់ស្ប៉ត (WiFi hot spot)។ នាយកដ្ឋានកម្មវិធីសិក្សា និងការបង្រៀន និងសេវាផ្តល់ព័ត៌មាន បានផ្តល់ការគាំទ្របច្ចេកវិទ្យាដោយផ្ទាល់ និងការធ្វើវិភាគនិងដោះស្រាយបញ្ហាកុំព្យូទ័រ និងចូលប្រើប្រាស់ដែលផ្តល់ជូនដល់បុគ្គលិកបង្រៀន។ ឱកាសអភិវឌ្ឍជំនាញវិជ្ជាជីវៈ ត្រូវបានផ្តល់ជូននៅអំឡុងរដូវផ្ការីក រដូវក្តៅទាំងមូល និងត្រូវបានធ្វើផែនការនៅក្នុងឆ្នាំសិក្សាទាំងមូលដើម្បីដោះស្រាយបញ្ហាកសាងសមត្ថភាព ជំនាញ និងចំណេះដឹងពាក់ព័ន្ធនឹងការសិក្សាពីចម្ងាយ ការវិភាគលើទិន្នន័យសិស្ស ការជំរុញសិស្សឲ្យចូលរួមតាមរយៈការបង្រៀនដែលផ្តោតលើគុណភាពខ្ពស់ជាចម្បងតាមស្តង់ដា និងការរួមបញ្ចូលគ្រូពាក់ព័ន្ធនិងឆ្លើយតបតាមវប្បធម៌និងភាសា និងបទពិសោធន៍សិក្សានៅក្នុងការបង្រៀន។

ការអភិវឌ្ឍជំនាញវិជ្ជាជីវៈ និងការគាំទ្រ ត្រូវបានផ្តល់ជូនដល់បុគ្គលិករដ្ឋបាល និងបុគ្គលិកបង្រៀន ស្តីពីរបៀបប្រើប្រាស់ទម្រង់សិក្សាពីចម្ងាយ និងតាមប្រព័ន្ធអ៊ីនធឺណិត ដើម្បីទំនាក់ទំនង និងជំរុញឲ្យឪពុកម្តាយ អាណាព្យាបាល និងក្រុមគ្រួសារចូលរួមជាដៃគូនៅក្នុងការអភិវឌ្ឍការសិក្សា និងចិត្តសង្គមរបស់សិស្សយើង។ ការបណ្តុះបណ្តាលស្តីពីការយល់ដឹងពីការប៉ះទង្គិច និងការប្រតិបត្តិស្តារឡើងវិញ នឹងត្រូវបានផ្តល់ជូនដល់បុគ្គលិកនៅក្នុងមណ្ឌលសិក្សាធិការទាំងមូល និងការសហការនៅជុំវិញការវិភាគលើទិន្នន័យសិស្ស ដើម្បីផ្តល់ដំណឹង និងធ្វើផែនការយុទ្ធសាស្ត្រសម្រាប់បទពិសោធន៍សិក្សានានាដែលគាំទ្រដល់ការអនុវត្តនៃប្រព័ន្ធគាំទ្រច្រើនដំណាក់កាល (Multi-Tiered System of Support) ដែលដោះស្រាយបញ្ហាការសិក្សារៀនសូត្រចម្រុះវប្បធម៌និងភាសា និងតម្រូវការចិត្តសង្គមរបស់សិស្សទាំងអស់។

## តួនាទីបុគ្គលិក និងការទទួលខុសត្រូវ

[ការពិពណ៌នាអំពីតួនាទី និងការទទួលខុសត្រូវថ្មីរបស់បុគ្គលិកដែលរកផលប៉ះពាល់ ដោយសារតែជំងឺ COVID-19។]

ជំងឺរាតត្បាត COVID-19 ការបិទអគារសិក្សា ការផ្លាស់ប្តូរទៅជាការសិក្សាពីចម្ងាយ និងការធ្វើផែនការសម្រាប់គំរូសិក្សាបែបចម្រុះរួមបញ្ចូលគ្នានៃវគ្គបង្រៀនដោយផ្ទាល់ បានមានផលប៉ះពាល់យ៉ាងខ្លាំងទៅលើតួនាទី និងការទទួលខុសត្រូវរបស់បុគ្គលិក និងប្រព័ន្ធដំណើរការរបស់មណ្ឌលសិក្សាធិការ SUSD។ ជាការឆ្លើយតបទៅនឹងជំងឺរាតត្បាត COVID-19 បុគ្គលិកចាំបាច់ត្រូវកែសម្រួល និងផ្លាស់ប្តូរតួនាទី និងការទទួលខុសត្រូវ ហើយប្រព័ន្ធនេះ បានបន្តផ្លាស់ប្តូរចុះឡើង និងបន្តមានភាពបត់បែនដើម្បីដោះស្រាយបញ្ហាតម្រូវការ ស្របគ្នាជាមួយនឹងជំងឺសុខភាព សុវត្ថិភាព និងការសិក្សា។ បុគ្គលិកផ្នែកសុខុមាលភាពកុមារ និងការចូលរៀន និងវគ្គបង្រៀនដោយផ្ទាល់នាពេលអនាគតមួយចំនួន នឹងបន្តរាល់កិច្ចខិតខំប្រឹងប្រែងផ្សព្វផ្សាយ និងសេវាអភិវឌ្ឍរបស់ខ្លួនទាំងអស់ ប៉ុន្តែ តួនាទីជាក់លាក់នៅក្នុងការសិក្សាពីចម្ងាយ ត្រូវបានកែសម្រួលដើម្បីផ្តល់ការគាំទ្រដោយផ្ទាល់ទីតាំងសាលារៀនដែលជួបប្រទះការកើតឡើងនៃអវត្តមានរបស់សិស្ស ដោយសារតែផលប៉ះពាល់នៃជំងឺរាតត្បាត COVID-19។ គ្រូនៅក្នុងគំរូបង្រៀនទាំងអស់ នឹងបន្តស្រង់វត្តមានប្រចាំថ្ងៃ គ្រប់គ្រងការចូលរួមរបស់សិស្សដោយប្រើវិធានការចម្រុះ និងប្រាស្រ័យទាក់ទងជាមួយសិស្ស និងក្រុមគ្រួសារអំពីការចូលរៀនរបស់សិស្ស និងការរំពឹងទុកសម្រាប់ការសិក្សា។ ជាមួយនឹងការសិក្សាពីចម្ងាយ គ្រូកំពុងផ្តល់ជូនការបង្រៀនឡាយផ្ទាល់តាមរយៈបទពិសោធន៍សិក្សាក្នុងពេលតែមួយ និងការគ្រប់គ្រងការសិក្សាដែលសិស្សអនុវត្តដោយខ្លួនឯងក្នុងពេលវេលាដាច់ដោយឡែក តាមរយៈការបំពេញកិច្ចការរបស់សិស្ស សកម្មភាពសិក្សា និងការប្រាស្រ័យទាក់ទងដែលប្រព្រឹត្តទៅក្នុងកម្មវិធី Google Classroom និងប្រព័ន្ធគ្រប់គ្រងការសិក្សារបស់យើង រួមផ្សំជាមួយទម្រង់បែបបទ និងគំរូដែលបានឯកភាពជារួមនៃការទាក់ទងដែលដាក់ឲ្យប្រើប្រាស់នៅទីតាំងសាលា។ នៅក្នុងមណ្ឌលសិក្សាទាំងមូល បុគ្គលិកដែលសេវាកម្មរបស់ពួកគេគាំទ្រដល់សិស្សដែលមានពិការភាព នឹងបន្តនៅក្នុងតួនាទីរបស់ពួកគេដោយផ្តល់ជូនទាំងសេវាកម្មពីចម្ងាយ និងដោយផ្ទាល់សម្រាប់សិស្ស និងក្រុមគ្រួសារ ស្របគ្នាជាមួយនឹងគោលដៅ និងតម្រូវការនៃការវាយតម្លៃ និងសេវាកម្មនៅក្នុងកម្មវិធីអប់រំសម្រាប់បុគ្គល (Individualized Educational Program, IEP) របស់សិស្ស។ បុគ្គលផ្នែកសុខភាព និងសុខុមាលភាព ត្រូវបានចាត់តាំងទៅកាន់ទីតាំងសាលារៀន និងចាំឃ្លាំមើលកិច្ចដំណើរការស្វ័យត្រួតពិនិត្យលើសេវាសុខភាពទៅលើជំងឺ COVID-19 ប្រចាំថ្ងៃ ពិធីសារសុខភាព និងសុវត្ថិភាពដែលកំពុងត្រូវបានអនុវត្តនៅតាមទីតាំងសាលារៀន និងអំឡុងពេលផ្តល់អាហារ និងការជួយទាក់ទងផ្សព្វផ្សាយដល់ក្រុមគ្រួសារ។ ការិយាល័យគ្រប់គ្រងហានិភ័យ បានបំពេញតួនាទីសម្របសម្រួលជាមួយពិធីសារតាមដានការប៉ះពាល់ផ្ទាល់នៃការិយាល័យសុខាភិបាល ស្របគ្នាជាមួយនឹងជំងឺ COVID-19។ មណ្ឌលសិក្សាធិការ SUSD បានជួលអ្នកសម្របសម្រួលផ្នែកជំងឺ COVID-19 ដើម្បីមកជួយសម្រួល និងដឹកនាំប្រព័ន្ធ និងនីតិវិធីផ្សេងៗដែលពាក់ព័ន្ធនឹងការទទួលខុសត្រូវនៅក្នុងការដោះស្រាយផលប៉ះពាល់ផ្នែកសុខភាព និងសុវត្ថិភាពដែលជំងឺរាតត្បាត COVID-19 មានទៅលើមណ្ឌលសិក្សាធិការ SUSD និងសហគមន៍ដែលយើងបម្រើសេវា។

ការកែសម្រួលដែលមាន និងដែលត្រូវធ្វើឡើងទៅលើតួនាទី និងការទទួលខុសត្រូវរបស់បុគ្គលិក ដើម្បីបំពេញតាមតម្រូវការផ្នែកសិក្សារៀនសូត្រ និងផ្នែកចិត្តសង្គមរបស់សិស្ស ទន្ទឹមគ្នានឹងការធានានូវសុខភាព និងសុវត្ថិភាពរបស់បុគ្គលិកនិងសិស្ស មានដូចជា៖

- ម៉ោងធ្វើការ ត្រូវបានកែប្រែ និងកែសម្រួលសម្រាប់មូលហេតុសុខភាព និងសុវត្ថិភាព ក៏ដូចជាការបំពេញតម្រូវការនៃលទ្ធភាពអាចទទួលបានកាន់តែច្រើនឡើងដល់ក្រុមគ្រួសារដែលធ្វើការ។
- គ្រូបង្រៀនដែលកំពុងបង្រៀនពីចម្ងាយ ពីទីកន្លែងស្នាក់នៅរបស់ពួកគេ ឬនៅក្នុងថ្នាក់រៀនរបស់ពួកគេ នៅអំឡុងពេលសិក្សាពីចម្ងាយនៅអំឡុងវគ្គបង្រៀនផ្ទាល់តាមគំរូសិក្សាបែបចម្រុះ នឹងធ្វើការគាំទ្រដល់សិស្ស តាមរយៈការបង្រៀនផ្ទាល់ និងការគាំទ្រការសិក្សាក្នុងពេលដាច់ដោយឡែក។. គ្រូនឹងគាំទ្រសិស្សតាមរយៈការបង្រៀនជាក់លាក់ ការផ្តល់គំរូ និងការពង្រឹងការអនុវត្តបម្រុងប្រយ័ត្នផ្នែកសុខភាព និងបទដ្ឋានសុវត្ថិភាពដោយផ្តោតលើពិធីសារស្វ័យត្រួតពិនិត្យ និង

សិតុណ្ហភាពប្រចាំថ្ងៃ ការស្ថិតនៅក្នុងកន្លែងធ្វើការរបស់ខ្លួន ការប្រើប្រាស់សម្ភារៈរៀងៗខ្លួន ពិធីសាររក្សាគម្លាតឆ្ងាយពីគ្នា ការលាងសម្អាតដៃជាប្រចាំ និងការជៀសវាងការប៉ះពាល់ជាមួយនឹងផ្ទៃវត្ថុដែលប្រើប្រាស់រួមគ្នា នីតិវិធីសម្លាប់មេរោគ និងការទទួលខុសត្រូវផ្សេងទៀតដែលស្របគ្នាទៅនឹងការប្រើប្រាស់ពិធីសារការបង្រៀន និងរៀននៅក្នុងក្របខណ្ឌនៃការរាតត្បាតសុខភាពជាសកល។ គ្រូនឹងភ្ជាប់ទំនាក់ទំនងជាមួយនឹងគ្រួសារ និងផ្តល់ឱកាសសម្រាប់ការចូលរួមរបស់គ្រួសារ នៅក្នុងការសិក្សារបស់កូនពួកគេ ជាបន្តបន្ទាប់ តាមរយៈវគ្គបង្រៀនដោយផ្ទាល់ នៅអំឡុងឆ្នាំសិក្សាទាំងមូល។ គ្រូណែនាំការបង្រៀន នឹងត្រូវបានអញ្ជើញឲ្យចូលកម្មវិធី Google Classrooms នៅក្នុងគំរូណែនាំតាមបែបសហការ ហើយអ្នករដ្ឋបាលតាមទីតាំង និងចូលរួមនៅក្នុងការបង្រៀនឡាយផ្ទាល់ ដើម្បីផ្តល់យោបល់ត្រឡប់បែបស្ថាបនានិងចំគោលដៅ និងការគាំទ្រការបង្រៀន។

- អ្នកជំនាញកម្មវិធី ផ្តល់នូវការគាំទ្រដោយផ្ទាល់ដល់បុគ្គលិកបង្រៀនតាមរយៈផ្នែកឡជីសស្ទិកពាក់ព័ន្ធនឹងការធ្វើផែនការ ការកំណត់ និងការសម្របសម្រួលកិច្ចប្រជុំ IEP ទាំងតាមអ៊ីនធឺណិត និងដោយផ្ទាល់ ដោយធានាថារាល់វិធានការសុខភាព និងសុវត្ថិភាពទាំងអស់ នឹងដាក់ឲ្យដំណើរការ ហើយឪពុកម្តាយ/អាណាព្យាបាល បានទទួលឱកាសធ្វើជាអ្នកចូលរួមយ៉ាងសកម្មនៅក្នុងកិច្ចប្រជុំ ខណៈពេលកំពុងដោះស្រាយរាល់លក្ខខណ្ឌតម្រូវនៃការចងក្រងឯកសារនៅក្នុងកិច្ចប្រជុំ IEP តាមអ៊ីនធឺណិត តាមទូរសព្ទ និងដោយផ្ទាល់។
- ជំនួយការបង្រៀន នឹងផ្តល់ការគាំទ្រជាលក្ខណៈបុគ្គល និងជាក្រុមតូចៗ នៅក្នុងការបង្រៀនឡាយផ្ទាល់ ការសិក្សាក្នុងពេលតែមួយ ហើយនឹងផ្តល់ការគាំទ្រដល់គ្រូដែលជួយសិស្សនៅក្នុងបន្ទប់បំបែកជាក្រុមតូចៗ និងមធ្យោបាយផ្សេងទៀតតាមសមស្រប។
- គ្រូជំនួស ត្រូវបានផ្តល់ជូននៅកាន់ទីតាំងសាលារៀន ដើម្បីផ្តល់ការគាំទ្រការបង្រៀនជាយុទ្ធសាស្ត្រសម្រាប់សិស្សដែលមានតម្រូវការពិសេស នៅក្នុងម៉ោងសិក្សាក្នុងពេលតែមួយ។
- គ្រូធនធាន និងអ្នកជំនាញផ្នែកបរិយាបន្ន នឹងគាំទ្រដល់សេវាកម្មពាក់ព័ន្ធនឹងការសិក្សាពីចម្ងាយ និងវិធានការដែលផ្តោតលើការគោលវិធីខុសៗគ្នានៅក្នុងការដោះស្រាយបញ្ហាតម្រូវការជាយុទ្ធសាស្ត្រ សិស្សដែលមានពិការភាព សកម្មភាព និងសេវាកម្មទាំងនេះ រួមមានការគាំទ្រកិច្ចដំណើរការវាយតម្លៃការសម្របសម្រួលសេវាកម្មដែលស្របជាមួយនឹងកម្មវិធី IEP របស់សិស្ស ដោយមានកាលវិភាគបង្រៀនប្រចាំថ្ងៃរបស់គ្រូបន្ទុកថ្នាក់ ការត្រួតពិនិត្យវឌ្ឍនភាពរបស់សិស្សនៅក្នុងគំរូបង្រៀន និងការសម្របសម្រួលជាមួយជំនួយការបង្រៀន ដើម្បីធានាថាការទទួលបានការគាំទ្រជាយុទ្ធសាស្ត្រដល់សិស្ស ត្រូវបានផ្តល់ជូនជាយុទ្ធសាស្ត្រដល់សិស្ស។
- បុគ្គលិកសេវាសុខភាព ចុះពិនិត្យសុខភាពបុគ្គលិកលើជំងឺ COVID-19 ប្រចាំថ្ងៃ និងសហការគ្នាបង្កើតផែនការដើម្បីដោះស្រាយបញ្ហាឆ្លើយតបទៅនឹងជំងឺរាតត្បាត COVID-19 របស់មណ្ឌលសិក្សាធិការ SUSD ដោយប្រើអនុសាសន៍ពីការិយាល័យអប់រំខោនធីសានចូឃីន (San Joaquin County Office of Education) ផ្នែកសុខភាពសាធារណៈប្រចាំខោនធី (County Public Health) នាយកដ្ឋានសុខភាពរដ្ឋកាលីហ្វ័រញ៉ា (California Department of Health) នាយកដ្ឋានអប់រំរដ្ឋកាលីហ្វ័រញ៉ា (California Department of Education, CDE) និងមជ្ឈមណ្ឌលគ្រប់គ្រងជំងឺ (Centers for Disease Control, CDC)។
- បុគ្គលិកផ្នែកគាំទ្រសិស្ស និងសេវាសុខភាពផ្តល់ការណែនាំដល់ទីតាំងសាលារៀន ដែលដោះស្រាយបញ្ហាក្តីរំពឹងទុកខ្ពស់ជុំវិញបញ្ហាសម្អាត និងសម្លាប់មេរោគនៅផ្ទៃវត្ថុ និងមជ្ឈដ្ឋានការងារ/សិក្សា។
- ក្រៅពីការធានារ៉ាប់រងធម្មតារបស់ពួកគេ អ្នកគ្រប់គ្រងរដ្ឋបាលតាមទីតាំង កំពុងគាំទ្រយ៉ាងសកម្មរាល់វិធានការសុខភាពសាធារណៈដែលចាំបាច់ទាំងអស់ទៅលើបរិវេណសាលា កំពុងរៀបចំផែនការយុទ្ធសាស្ត្រសម្រាប់ផែនការផ្លាស់ប្តូរការសិក្សាពីការសិក្សាពីចម្ងាយទៅជាវគ្គបង្រៀនដោយផ្ទាល់ កំពុងគ្រប់គ្រងបុគ្គលិកដែលស្ថិតនៅក្នុងបរិវេណសាលា និងកំពុងធ្វើការពីចម្ងាយ កំពុងធានាថាបុគ្គលិកបង្រៀនកំពុងផ្តល់ឲ្យសិស្សនូវការបង្រៀនឡាយផ្ទាល់សម្រាប់ការសិក្សាពីចម្ងាយប្រកបដោយគុណភាពខ្ពស់ និងឱកាសសិក្សាក្នុងពេលតែមួយ កំពុងតែជំរុញឲ្យក្រុមគ្រួសារចូលរួម និងកំពុងណែនាំបុគ្គលិកធ្វើការផ្សព្វផ្សាយតាមអ៊ីនធឺណិត និងកំពុងធានាទូទាំងសាលាថា បុគ្គលិកកំពុងតាមដានការចូលរៀនប្រចាំថ្ងៃ និងការចូលរួមរបស់សិស្សទាន់ពេលវេលា និងបានត្រឹមត្រូវ។
- បុគ្គលិកការិយាល័យធ្វើការងាររួមសហការជាមួយអ្នករដ្ឋបាល ដើម្បីគាំទ្រយ៉ាងសកម្ម និងធានាថា រាល់វិធានការសុខភាពសាធារណៈចាំបាច់ទាំងអស់ ត្រូវបានអនុវត្តតាម និងមានរួចជាស្រេច ហើយបុគ្គលិកគាំទ្រ សិស្ស គ្រួសារ និងអ្នកដទៃទៀតដែលមកក្នុងបរិវេណសាលារួមសហការជាមួយបុគ្គលិកសេវាសុខភាពសាលារៀន នៅក្នុងការពាក់ម៉ាស់ និងអនុវត្តតាមពិធីសារសុវត្ថិភាព។
- បុគ្គលិកផ្នែកអាហារូបត្ថម្ភកុមារ និងសេវាចំណីអាហារ គាំទ្ររាល់វិធានការសុខភាពសាធារណៈដែលចាំបាច់ទាំងអស់ ទន្ទឹមគ្នានឹងការអនុវត្តលំហូរបម្លាស់ទីសុវត្ថិភាពរបស់សិស្ស បុគ្គលិក និងក្រុមគ្រួសារតាមរយៈកិច្ចដំណើរផ្តល់អាហារ និងការស្កែនបារកូដ ដើម្បីធានាថាការផ្តល់ចំណីអាហារដល់សិស្ស ត្រូវបានចងក្រងឯកសារទុកយ៉ាងត្រឹមត្រូវសម្រាប់សិស្សដែលបានចុះឈ្មោះចូលរៀន។ នៅក្នុងការរួមសហការជាមួយបុគ្គលិកសេវាសុខភិបាល ពួកគេត្រូវធានាថាកន្លែងការងារ

មានសម្ភារៈការពារបុគ្គលសមស្រប (PPE) និងធនធាន និងសម្ភារៈផ្គត់ផ្គង់សម្រាប់ការសម្អាត/សម្លាប់មេរោគ។
• បុគ្គលិកសេវាសុខភាព ការគ្រប់គ្រងហានិភ័យ និងបុគ្គលិកសេវាគាំទ្រសិស្ស នឹងត្រួតពិនិត្យ និងគាំទ្រយ៉ាងសកម្មទៅលើវិធានការសុខភាពសាធារណៈ ដែលចាំបាច់ទាំងអស់ លក្ខខណ្ឌតម្រូវ និងនីតិវិធីតាមដានការប៉ះពាល់ផ្ទាល់។ បុគ្គលិក នឹងផ្តល់ព័ត៌មានថ្មីៗជាបន្តបន្ទាប់ដល់បុគ្គលិក និងផ្តល់ដំណឹងដល់គ្រួសារ

អំពីនីតិវិធីថ្មីៗ និងការរំពឹងទុកនៃកិច្ចដំណើរការដែលតម្រូវដោយនាយកដ្ឋានសុខាភិបាល ដោយសារតែនីតិវិធីតាមដានការប៉ះពាល់ផ្ទាល់ និងនីតិវិធីស្វ័យត្រួតពិនិត្យសេវាសុខភាពសម្រាប់ជំងឺ COVID-19។
• បុគ្គលិកផ្នែកដឹកជញ្ជូន នឹងត្រួតពិនិត្យ និងគាំទ្ររាល់វិធានការសុខភាពសាធារណៈចាំបាច់ទាំងអស់ ស្របគ្នាជាមួយនឹងនីតិវិធីសម្អាត/សម្លាប់មេរោគទៅលើយានយន្ត ទន្ទឹមគ្នានឹងការធានាបានថា ការរៀបចំកន្លែងអង្គុយដែលរក្សាគម្លាតឆ្ងាយពីគ្នាគ្រប់គ្រាន់ ត្រូវបានជួយសម្រួលក្នុងក្របខណ្ឌសេវាដំណើរការកាដឹកជញ្ជូន។ បុគ្គលិកសេវាដឹកជញ្ជូន និងអ្នកត្រួតពិនិត្យនិងអ្នកផ្តល់ជំនួយក្នុងបរិវេណសាលា (CSMs & CSAs) នៅអំឡុងពេលសិក្សាពីចម្ងាយ បានគាំទ្រដល់ទីតាំងសាលាដែលផ្តល់ជូនចំណីអាហារ តាមរយៈជំនួយឡានដឹកសម្រាប់បម្លាស់ទីចរាចរណ៍ និងទិសដៅរបស់អ្នកមានវត្តមានសម្រាប់ការចែកចំណីអាហារ។ ប្រព័ន្ធមួយ នឹងត្រូវយកមកអនុវត្តដោយរួមសហការជាមួយបុគ្គលិកសេវាសុខភាព នៅក្នុងការធានាថាស្វ័យត្រួតពិនិត្យជំងឺ COVID-19 ប្រចាំថ្ងៃ ត្រូវបានអនុវត្តសម្រាប់សិស្សនៅក្នុងការគាំទ្រកិច្ចដំណើរការការដឹកជញ្ជូនដោយសុវត្ថិភាព និងសុខភាពសម្រាប់អ្នកដែលមានជាប់ពាក់ព័ន្ធ។
• បុគ្គលិកផ្នែកយុវជនក្រោមការគ្រប់គ្រងរបស់ឪពុកម្តាយចិញ្ចឹម និងគ្រួសារទើបលែងថ្មីៗ ធ្វើការត្រួតពិនិត្យ និងគាំទ្រយ៉ាងសកម្មដល់វិធីការសុខភាពសាធារណៈចាំបាច់ទាំងអស់ និងតម្រូវការឡានដឹកស្ទិកពាក់ព័ន្ធនឹងការទទួលបានការសិក្សា ចំណីអាហារ សុខភាពផ្លូវចិត្តនិងសុខុមាលភាព និងសេវាចាំបាច់ផ្សេងៗសម្រាប់សិស្ស និងគ្រួសារ។ ការផ្សព្វផ្សាយ ប្រព្រឹត្តទៅតាមរយៈកិច្ចប្រជុំដោយផ្ទាល់ តាមទូរសព្ទ និងតាមអ៊ីនធឺណិត និងទម្រង់ទំនាក់ទំនងជាមួយនឹងសិស្ស និងក្រុមគ្រួសារ។
• បុគ្គលប្រតិបត្តិការ ថែទាំជួសជុល និងបុគ្គលិកឃ្លាំមើល នឹងគោរពតាមនិងគាំទ្រយ៉ាងសកម្មដល់វិធានការសាធារណៈចាំបាច់ទាំងអស់ ទន្ទឹមគ្នានឹងការថែទាំប្រព័ន្ធសម្អាត និងសម្លាប់មេរោគឲ្យស្អាតជាប្រចាំទៅលើកន្លែងដែលប៉ះពាល់ញឹកញាប់ និងផ្ទៃវត្ថុប្រើប្រាស់រួមជាប្រចាំថ្ងៃ។ បុគ្គលិកក៏នឹងធានាផងដែរថា រាល់ទីតាំងសាលារៀនទាំងអស់ និងអគារសិក្សាមានស្តុកទុកសម្ភារៈ និងធុងសម្ភារៈមានដំណើរការដែលផ្តល់នូវប្រភពសម្រាប់ការលាងសម្អាតដៃ និងសម្អាតអនាម័យដៃ។ បុគ្គលិកក៏នឹងរក្សាសម្ភារការពារផ្ទាល់ខ្លួន (PPE) នៅតាមទីតាំងដែលផ្តល់ជូន និងធានានូវការត្រៀមខ្លួនសម្រាប់ការគោរពតាមវិធានការសុខភាពសាធារណៈទាំងអស់ ទន្ទឹមគ្នានឹងការធ្វើការងារនៅក្នុងនាយកដ្ឋាន និងការបន្តការប្រាស្រ័យទាក់ទងជំវិញពិធីសារ និងនីតិវិធីបញ្ជាទិញ ដើម្បីធានាបានថាសម្ភារៈផ្គត់ផ្គង់បន្ថែម ត្រូវបានបញ្ជាទិញបានទាន់ពេលវេលា ទៅតាមការចង់បាន។

ប្រព័ន្ធផ្តល់សេវាអប់រំ នឹងបន្តកែសម្រួលតួនាទី និងការទទួលខុសត្រូវបុគ្គលិក ដើម្បីដោះស្រាយបញ្ហាតម្រូវការសិក្សារៀនសូត្រ និងតម្រូវការចិត្តសង្គម ទន្ទឹមគ្នានឹងការធានាបានថា រាល់សិស្ស បុគ្គលិក និងក្រុមគ្រួសារទាំងអស់ គឺមានសុវត្ថិភាព និងមានសុខភាពល្អ ហើយថាបុគ្គលិកទាំងអស់នឹងត្រួតពិនិត្យ និងគាំទ្រដល់វិធានការសុខភាពសាធារណៈចាំបាច់ទាំងអស់។ បុគ្គលិកមណ្ឌលសិក្សាធិការ SUSD ត្រូវបានជំរុញឲ្យខិតខំប្រឹងប្រែងគាំទ្រដល់លទ្ធផលសិក្សារបស់សិស្ស ការគាំទ្របរិយាកាសសិក្សាប្រកបដោយសមភាព និងការអភិវឌ្ឍភាពជាដៃគូពេញលេញ ដែលផ្តោតលើការផ្តល់ឲ្យសិស្សគ្រប់រូបនូវការរៀបចំខ្លួនសម្រាប់ការសិក្សានៅមហាវិទ្យាល័យ ជំនាញអាជីព និងសហគមន៍។ ការបិទអគារសិក្សា បានប៉ះពាល់ដល់បុគ្គលិកទាំងអស់ និងបានបង្ហាញពីបញ្ហាប្រឈមផ្នែកដំណើរការដែលមានផលប៉ះពាល់ដោយផ្ទាល់លើតម្រូវការផ្លូវកាយ ផ្លូវចិត្ត មនោសញ្ចេតនា សង្គម និងការអប់រំរបស់សិស្សយើង និងបានបង្កភាពធុញថប់យ៉ាងខ្លាំងទៅលើក្រុមគ្រួសារ និងបុគ្គលិកទាំងអស់។ មណ្ឌលសិក្សាធិការ SUSD នឹងបន្តផ្តល់ឱកាសសម្រាប់យោបល់ត្រឡប់ និងឆ្លើយតបនឹងតម្រូវការរបស់បុគ្គលិក និងធ្វើការងារជាដៃគូជាមួយគ្រប់អ្នកដឹកនាំការងារទាំងអស់ ដើម្បីគាំទ្រដល់សុខុមាលភាពរបស់បុគ្គលិកសំខាន់ៗទាំងអស់។

## ការគាំទ្រសម្រាប់សិស្សដែលមានតម្រូវការពិសេស

[ការពិពណ៌នាអំពីការគាំទ្របន្ថែមដែលភ្នាក់ងារ LEA នឹងផ្តល់ជូន អំឡុងពេលសិក្សាពីចម្ងាយដើម្បីជួយសិស្សដែលមានតម្រូវការពិសេស រួមទាំងអ្នកសិក្សាភាសាអង់គ្លេស សិស្សដែលមានតម្រូវការពិសេសដែលទទួលបានសេវានៅក្នុងការដាក់បញ្ចូលក្នុងការសិក្សាតាមលំដាប់លំដោយពេញលេញ សិស្សស្ថិតក្នុងការមណ្ឌលថែទាំ និងសិស្សដែលកំពុងជួបប្រទះបញ្ហាគ្មានទីជម្រក។]

ការគាំទ្របន្ថែមមួយចំនួនដែលមណ្ឌលសិក្សា SUSD នឹងផ្តល់ជូន នៅអំឡុងការសិក្សាពីចម្ងាយដើម្បីជួយដល់សិស្សដែលមានតម្រូវការពិសេស គឺជាការគាំទ្រការបង្រៀនជាក្រុមតូចៗ និងផ្ទាល់មួយទល់នឹងមួយ ការគាំទ្រការបង្រៀនក្រោយម៉ោងសិក្សានៅសាលា និងកិច្ចការផ្ទះ ការផ្តល់ឲ្យសិស្សនូវវ៉ាយហ្វាយហត់ស្ប៉ត (WiFi hot spot) និងកុំព្យូទ័រយួរដៃដើម្បីធានាដល់ការចូលសិក្សាពីចម្ងាយ ការចូលទៅជួបអ្នកពិគ្រោះយោបល់ និងគ្រូពេទ្យគ្លីនិកសុខភាពផ្លូវចិត្ត និងសុខុមាលភាពចិត្តសង្គម នៅក្នុងមជ្ឈដ្ឋានសិក្សាពីចម្ងាយ។ ការបណ្តុះបណ្តាល នឹងត្រូវផ្តល់ជូនដល់បុគ្គលិកនៅក្នុងការយល់ដឹងពីការប៉ះទង្គិច ការប្រតិបត្តិស្តារឡើងវិញ ភាពលម្អៀងដោយប្រយោល សមភាព និងពិពិធភាព ដើម្បីបង្កើនសមត្ថភាពរបស់បុគ្គលិកនៅក្នុងការបំពេញតាមតម្រូវការចំនួនសិស្សចម្រុះវប្បធម៌និងភាសា ដែលពួកគេបម្រើសេវា។ សៀវភៅណែនាំអំពីការសិក្សាពីចម្ងាយសម្រាប់ឪពុកម្តាយ/អាណាព្យាបាល ត្រូវបានបោះពុម្ពផ្សាយជាចម្រុះភាសា ដោយផ្តល់ធនធាន និងព័ត៌មានស្តីពីការសិក្សាពីចម្ងាយ និងធនធានដែលមានផ្តល់ជូនដល់សិស្ស និងក្រុមគ្រួសារ។ ការគាំទ្រផ្នែកសិក្សារៀនសូត្រដែលបានកំណត់ដើម្បីដោះស្រាយបញ្ហាតម្រូវការរបស់អ្នកសិក្សាភាសាអង់គ្លេស រួមមានការវាយតម្លៃកម្រិតបំណិនសមត្ថភាពភាសាអង់គ្លេស ការគាំទ្រសម្រាប់ការទទួលបានកម្មវិធីសិក្សា លទ្ធភាពក្នុងការចាត់ប្រភេទចំណាត់ថ្នាក់ឡើងវិញជាការគាំទ្រសមត្ថភាពភាសាអង់គ្លេសពេញលេញ និងអាចប្រើប្រាស់បានសម្រាប់ការសិក្សាពីភាសា។ អ្នកសិក្សាភាសាអង់គ្លេសទទួលបានការគាំទ្រលើការសិក្សាពីចម្ងាយ តាមរយៈជំនួយការនិយាយពីភាសា និងជាក្រុមតូចៗដោយផ្តោតលើការអភិវឌ្ឍភាសាអង់គ្លេសដែលបានកំណត់ (ELD)។ អ្នកជំនាញភាសា និងគ្រូណែនាំ ផ្តល់ជូនការបណ្តុះបណ្តាល និងការគាំទ្រដល់បុគ្គលិកបង្រៀន ដោយផ្តោតលើយុទ្ធសាស្ត្រសិក្សាដែលស្របគ្នាជាមួយនឹងការអភិវឌ្ឍភាសាអង់គ្លេស (ELD) រួមបញ្ចូលគ្នានៅក្នុងប្រព័ន្ធកម្មវិធីសិក្សាពីចម្ងាយ។ មណ្ឌលសិក្សាធិការរួបរួមស្តុកថម (Stockton Unified School District) បានផ្តល់ឲ្យគ្រូថ្នាក់មត្តេយ្យដល់ទី12 (K-12) នូវការអភិវឌ្ឍជំនាញវិជ្ជាជីវៈដ៏មានគុណភាពខ្ពស់ និងការណែនាំ ដើម្បីសិក្សាស្វែងយល់ និងបង្កើនចំណេះដឹង និងបំណិនរបស់ពួកគេដើម្បីគាំទ្រយ៉ាងមានប្រសិទ្ធភាពដល់សិស្សសិក្សាភាសាអង់គ្លេស (ELs) ដែលចូលរួមក្នុងការបង្រៀនចម្រុះ និងដែលបានកំណត់ នៅអំឡុងការសិក្សាតាមអ៊ីនធឺណិត។ ការវាយតម្លៃការអភិវឌ្ឍជំនាញវិជ្ជាជីវៈ ត្រូវបានបង្កើតឡើង និងត្រូវបានអនុវត្តដើម្បីផ្តល់ឲ្យគ្រូនូវឱកាសក្នុងការទទួលបានចំណេះដឹងនៃការបង្រៀន អនុសាសន៍ល្អៗពាក់ព័ន្ធនឹងការឧត្តមានុវត្តដែលតាមការសិក្សា ស្រាវជ្រាវ និងរបៀបរួមបញ្ចូលបច្ចេកវិទ្យានៅកនុងការសិក្សាពីចម្ងាយ។ ក្នុងជាមួយគ្នានេះដែរ ការណែនាំការបង្រៀនត្រូវបានផ្តល់ជូនសម្រាប់ជាឱកាសក្នុងការគិតឲ្យស៊ីជម្រៅ និងឆ្លុះបញ្ចាំងទៅលើបទពិសោធន៍របស់ពួកគេសម្រាប់ជាមធ្យោបាយក្នុងការកែលម្អនៅក្នុងការអនុវត្តរបស់ពួកគេ និងផ្តល់ការបង្រៀនពេញលេញ។ លើសពីនេះទៀត គ្រូបានទទួលការគាំទ្រកម្មវិធីសិក្សា និងធនធនាដែលបានគាំទ្រដល់ការសិក្សាតាមអ៊ីនធឺណិតសម្រាប់សិស្ស EL។ ឪពុកម្តាយរបស់សិស្ស EL បានទទួលសេវាបកប្រែឯកសារ និងបកប្រែផ្ទាល់មាត់សម្រាប់ជាមធ្យោបាក្នុងការធានាបាននូវការប្រាស្រ័យទាក់ទងពេញលេញ និងចូលទៅប្រើប្រាស់ដោយស្មើភាពគ្នានៃព័ត៌មានពាក់ព័ន្ធនឹងសាលារៀនដែលពួកគេត្រូវការចំបាច់ដើម្បីធ្វើការសម្រេចចិត្តដោយមានព័ត៌មានគ្រប់គ្រាន់ និងក្លាយជាអ្នកចូលរួមពេញលេញនៅក្នុងការអប់រំរបស់កូនពួកគេក្នុងក្របខណ្ឌនៃការសិក្សាពីចម្ងាយ និងវគ្គសក្សាដោយផ្ទាល់។ ការអភិវឌ្ឍជំនាញវិជ្ជាជីវៈ បានផ្តល់ជូនដល់បុគ្គលិកបង្រៀន ហើយនឹងជាបន្តបន្ទាប់នៅក្នុងឆ្នាំសិក្សាទាំងមូលដោយផ្តោតលើការជំរុញឲ្យអ្នកសិក្សាភាសាអង់គ្លេសចូលរួមតាមរយៈយុទ្ធសាស្ត្របង្រៀនផ្សេងៗគ្នា ការផ្តល់ឲ្យសិស្សនូវមធ្យោបាចម្រុះក្នុងការទទួលបាន និងប្រាស្រ័យទាក់ទងជាមួយខ្លឹមសារសិក្សា យុទ្ធសាស្ត្របង្រៀនបែបទំនាក់ទាក់ទំនងនៅក្នុងការសិក្សាពីចម្ងាយ និងការសិក្សាដោយផ្ទាល់ និងការផ្តល់សកម្មភាពដែលបង្ហាញនូវមធ្យោបាយចម្រុះសម្រាប់ឲ្យសិស្សបង្ហាញនូវការសិក្សា និងការយល់ដឹងរបស់ពួកគេអំពីខ្លឹមសារផ្អែកតាមស្តង់ដា។ សេវាបង្រៀនតាមអនឡាញ នឹងត្រូវបានផ្តល់ជូនដល់សិស្សសិក្សាភាសាអង់គ្លេសដែលមានសិទ្ធិទទួលបាន។

គ្រូអប់រំពិសេស កំពុងរួមសហការធ្វើការងារជាមួយគ្រូបង្រៀនខ្លឹមសារគោលនៅក្នុងប្រព័ន្ធកម្មវិធីតាមអ៊ីនអឺណិតដើម្បីកែសម្រួលបទពិសោធន៍សិក្សាដើម្បីបំពេញតាមតម្រូវការរបស់សិស្សនៅក្នុងមជ្ឈដ្ឋានសិក្សាពីចម្ងាយ។ អន្តរាគមន៍ការបង្រៀន នឹងត្រូវបានប្រើប្រាស់ស្របជាមួយនឹងធនធានបំពេញបន្ថែមដើម្បីធានាថាលក្ខខណ្ឌតម្រូវនៃកម្មវិធីអប់រំសម្រាប់បុគ្គល (IEP) របស់សិស្ស និងគោលដៅសម្រាប់បុគ្គល ត្រូវបានដោះស្រាយ។ ការណែនាំរបស់នាយកដ្ឋានអប់ងរំរដ្ឋកាលីហ្វ័រញ៉ា (California Department of Education, CDE) ដែលដោះស្រាយការរំពឹងទុកនៅក្នុងករណីមានការបិទសាលាជាក់ស្តែង (លើសពីដប់ថ្ងៃ) នឹងណែនាំការកំណត់សេវាកម្មនៅក្នុងករណីមានការផ្លាស់ប្តូរអន្តរកាលនានាដែលប៉ះពាល់ដោយផ្ទាល់ទៅលើកាលវិភាគសាលា ឬជម្រើសនៃការផ្តល់សេវា។ នេះអនុវត្តចំពោះករណីធ្វើចត្តាឡីស័ក និង/ឬការដាកខ្លួនឯងនៅដាច់ដោយឡែក ស្របជាមួនឹងជំងឺរាតត្បាត COVID-19។ នាយកដ្ឋានអប់រំពិសេសរបស់មណ្ឌលសិក្សាធិការ SUSD នឹងបន្តធ្វើការគាំទ្រជាយុទ្ធសាស្ត្រដល់បុគ្គលិកដែលផ្តល់សេវាអប់រំពិសេស ដើម្បីធានាថាសិស្សទាំងអស់ដែលទទួលបានការអប់រំពិសេស ទទួលបាននូវបរិយាបន្ននៅក្នុងវគ្គសិក្សាពីចម្ងាយ និងដោយផ្ទាល់។ បុគ្គលិកអប់រំពិសេស នឹងប្រើប្រាស់នីតិវិធី IEP ជាដៃគូជាមួយក្រុមគ្រួសារដើម្បីបែងចែកភាពខុសគ្នាជាយុទ្ធសាស្ត្រលើបទពិសោធន៍សិក្សា និងគាំទ្រទៅតាមការចាំបាច់ ដើម្បីដោះស្រាយបញ្ហាតម្រូវការផ្នែកសិក្សា និងតម្រូវការចិត្តសង្គមរបស់សិស្ស។ ការវាយតម្លៃដោយផ្ទាល់ និងការគាំទ្រ នឹងត្រូវបានផ្តល់ជូនស្របតាមការណែនាំផ្នែកសុខភាព និងសុវត្ថិភាពដែលបានកំណត់ និងពិធីសាររបស់មណ្ឌលសិក្សាធិការ។ ការបង្រៀនជាក្រុមជាមួយគ្រូអប់រំទូទៅ

ការបង្រៀនជាក្រុមតូចៗ និងការចូលរួមនៅក្នុងកម្មវិធីសិក្សាតាមអ៊ីនធឺណិតរួមគ្នា ទាំងអស់នេះ នឹងត្រូវបានប្រើប្រាស់ដើម្បីធានាថាសិស្សម្នាក់ៗ ត្រូវទទួលបានកម្មវិធីសិក្សាកម្មវិធីសិក្សាស្នូល ជាមួយនឹងគោលបំណងដែលថាសិស្សគ្រប់រូប នឹងស្ថិតលើគន្លងមាគ៌ាឈ្ពោះទៅរកការបញ្ចប់ការសិក្សាពីវិទ្យាល័យ។ មណ្ឌលសិក្សាធិការ SUSD នឹងផ្តល់ជូននូវជម្រើសនៃកិច្ចប្រជុំផែនការ/កម្មវិធីអប់រំសម្រាប់បុគ្គល (IEP) ដែលមានភាពបត់បែន ដូចជាការប្រជុំតាមអ៊ីនធឺណិត ការប្រជុំតាមប្រព័ន្ធទូរគមនាគមន៍ (teleconference) ការប្រជុំនៅតាមទីតាំង ដែលគោរពតាមការណែនាំរបស់ខោនធី និងរដ្ឋ និងការប្រជុំបែបចម្រុះ ដើម្បីបំពេញតាមតម្រូវការរបស់គ្រួសារ។ គ្រូនឹងបង្កើតខ្សែវីដេអូប្រចាំសប្តាហ៍សម្រាប់ឲ្យសិស្សទស្សនានៅលើផ្នែកនៃការបង្រៀន ផ្តល់សកម្មភាពប្រចាំសប្តាហ៍ ពិនិត្យមើលវឌ្ឍនភាពនៃការសិក្សាតាមអនឡាញរបស់សិស្ស និងផ្តល់ឯកសារបន្ថែមតាមការចាំបាច់ និងបង្កើតមេរៀនលក្ខណៈបុគ្គលសម្រាប់សិស្សផ្អែកលើកម្មវិធី IEP របស់ពួកគេ។ អ្នកព្យាបាលសម្តីនិងភាសា នឹងផ្តល់ការណែនាំជាលក្ខណៈបុគ្គលស្របតាមកម្មវិធី IEP របស់សិស្ស រួមមានប្រព័ន្ធកម្មវិធីសិក្សាដែលបានថតទុក ឬតាមអនឡាញ, អ្នកព្យាបាលប្រចាំសាលា នឹងទាក់ទងសិស្សដែលទទួលបានសេវាពិគ្រោះយោបល់សម្រាប់ការអនុវត្តឲ្យចូលរួមក្នុងម៉ោងពិគ្រោះយោបល់តាមអ៊ីនធឺណិត, អ្នកព្យាបាលមុខងារវិជ្ជាជីវៈ និងតាមចលនា នឹងទាក់ទងក្រុមគ្រួសារដើម្បីផ្តល់ការណែនាំសម្រាប់ការអនុវត្តយុទ្ធសាស្រ្តនៅតាមផ្ទះ និងបង្កើតឯកសារនានាដែលអាចអនុវត្តបាននៅតាមផ្ទះ, ហើយអ្នកវិភាគផ្នែកអាកប្បកិរិយាទទួលស្គាល់ដោយក្រុមប្រឹក្សាភិបាល នឹងផ្តល់យុទ្ធសាស្រ្ត និងបច្ចេកទេសគ្រប់គ្រងអាកប្បកិរិយាតាមផ្ទះសម្រាប់គ្រួសារផ្អែកតាមតម្រូវការបុគ្គលរបស់សិស្សម្នាក់ៗ។ សេវាបង្រៀនតាមអនឡាញ នឹងត្រូវបានផ្តល់ជូនដល់សិស្សអប់រំពិសេសដែលមានសិទ្ធិទទួលបាន។

ការគាំទ្រការសិក្សានៅក្នុងការបង្រៀនពីចម្ងាយ/ឆ្ងាយពីគ្នាសម្រាប់សិស្សក្នុងគ្រួសារដែលទើបលែងលះ បានចាប់ផ្តើមជាមួយនឹងការផ្សព្វផ្សាយកាន់តែច្រើនឡើងដល់គ្រួសារ និងសិស្ស ដើម្បីដោះស្រាយបញ្ហាតម្រូវការសុខភាព សុវត្ថិភាព និងការសិក្សាពីចម្ងាយ នៅអំឡុងពេលចាប់ផ្តើមនៃជំងឺរាតត្បាតកាលពីរដូវផ្ការីកកន្លងទៅ។ ការិយាល័យផ្នែកគ្រួសារទើបលែងលះ បានធ្វើការងាររួមសហការជាមួយផ្នែកផ្សេងទៀតរបស់មណ្ឌលសិក្សាធិការ SUSD ដើម្បីធានាថា គ្រួសារទើបលែងលះ និងយុវជនដែលគ្មានអ្នកនៅជាមួយ ត្រូវបានផ្តល់អាទិភាពនៅក្នុងការទទួលបានកុំព្យូទ័រយួរដៃ និងវ៉ាយហ្វាយហត់ស្ប៉ត (WiFi hot spot) ដើម្បីធានាបាននូវការតភ្ជាប់បណ្តាញអ៊ីនធឺណិត និងការចូលទៅកាន់វគ្គសិក្សាពីចម្ងាយ។ ការពិនិត្យផ្ទៀងផ្ទាត់ជាមួយក្រុមគ្រួសារ និងសិស្ស ត្រូវបន្តធ្វើដើម្បីធានាថា ពួកគេចូលរួមក្នុងការសិក្សាពីចម្ងាយ និងវគ្គសុខភាពផ្លូវចិត្ត និងផ្នែកចិត្តសង្គម។ នៅពេលគ្រូរាយការណ៍អំពីកង្វះការចូលរួមរបស់សិស្សនៃគ្រួសារទើបលែងលះ ឬយុវជនគ្មានអ្នកនៅជាមួយនោះ បុគ្គលិកផ្នែកគ្រួសារទើបលែងលះ ត្រូវធ្វើការពិនិត្យផ្ទៀងផ្ទាត់ជាមួយគ្រួសារ និងសិស្សសម្រាប់ការវាយតម្លៃលើតម្រូវការ និងតាមដានជាមួយអ្នកពិគ្រោះយោបល់តាមទីតាំងសាលារៀន ដើម្បីផ្តល់នូវធនធាន និងការគាំទ្រដល់គ្រួសារ និងសិស្ស។ ការសម្របសម្រួល និងការប្រាស្រ័យទាក់ទងតាមទីជម្រកស្នាក់នៅមូលដ្ឋាន និងបុគ្គលិកមណ្ឌលសិក្សាធិការ SUSD ប្រព្រឹតទៅដើម្បីគាំទ្រដល់សិស្សដែលចូលរួមក្នុងការសិក្សាពីចម្ងាយ និងធនធានរួមដែលបានផ្តល់ជូនដោយទីភ្នាក់ងារផ្នែកអ្នកគ្មានទីម្រក ត្រូវបានផ្តល់ជូនដល់ក្រុមគ្រួសារដើម្បីបង្កើនការយល់ដឹងរបស់ពួកគេអំពីសេវាកម្មដែលមានផ្តល់ជូនពួកគេ។ សិស្សយុវជនគ្មានអ្នកនៅជាមួយ និងសិស្សក្នុងគ្រួសារទើបលែងលះ ត្រូវបានផ្តល់ជូនកាបូស្ពាយដែលមានសម្ភារៈសិក្សា ឆ្នាំងសាកថ្មកុំព្យូទ័រយួរដៃដែលអាចយកចុះឡើងបាន និងកាស់ស្តាប់សំឡេងទៅតាមការចាំបាច់ដើម្បីលើកកម្ពស់ការទទួលបានបទពិសោធន៍សិក្សាពីចម្ងាយ។  សេវាបង្រៀនតាមអនឡាញ នឹងត្រូវបានផ្តល់ជូនដល់សិស្សក្នុងគ្រួសារទើបលែងលះដែលមានសិទ្ធិទទួលបាន។

ដាក់ស្តែងតាមតម្រូវការរបស់យុវជនក្រោមគ្រប់គ្រងរបស់ឪពុកម្តាយចិញ្ចឹមនៅក្នុងក្របខណ្ឌការសិក្សាពីចម្ងាយ មណ្ឌលសិក្សាធិការ SUSD ត្រួតពិនិត្យយ៉ាងប្រុងប្រយ័ត្នលើការចូលរៀន និងការចូលរួមរបស់យុវជនក្រោមការគ្រប់គ្រងរបស់ឪពុកម្តាយចិញ្ចឹម ហើយបុគ្គលិកផ្នែកយុវជនក្រោមការគ្រប់គ្រងរបស់ឪពុកម្តាយចិញ្ចឹម ត្រូវប្រាស្រ័យទាក់ទងយ៉ាងជិតស្និទ្ធជាមួយបុគ្គលផ្នែកសុខុមាលភាពកុមារ និងការចូលរៀន (Child Welfare and Attendance) បុគ្គលិកពិគ្រោះយោបល់ និងគ្រូពេទ្យគ្លីនិកផ្នែកសុខភាពផ្លូវចិត្ត ដើម្បីទាក់ទងដោយផ្ទាល់ជាមួយសិស្ស និងផ្តល់ជំនួយចាំបាច់ និងការគាំទ្រឲ្យបានកាន់តែច្រើន។ រាល់បុគ្គលិកផ្នែកយុវជនដែលជាកូនចិញ្ចឹមទាំងអស់ បានទាក់ទងជាមួយយុវជនជាកូនចិញ្ចឹម និង/ឬឪពុកម្តាយ/អាណាព្យាបាលចិញ្ចឹមដើម្បីធានាថាយុវជនដែលជាកូនចិញ្ចឹមនីមួយៗ ទទួលបានកុំព្យូទ័រយួរដៃ និងវ៉ាយហ្វាយហត់ស្ប៉ត (WiFi hot spot)។ បច្ចុប្បន្នភាពសេវាកម្មដែលបានផ្តល់ជូន និងការរំពឹងទុកលើការបង្រៀន បានប្រព្រឹតទៅ ហើយនឹងបន្តប្រព្រឹតទៅពេញមួយឆ្នាំ ដោយបានចែករំលែកប្រាប់ដល់យុវជនជាកូនចិញ្ចឹមអំពីវគ្គបង្រៀន និងការផ្លាស់ប្តូរនានា។ ការពិនិត្យផ្ទៀងផ្ទាត់ជាបន្តបន្ទាប់ដោយបុគ្គលិកជាមួយនឹងយុវជនជាកូនចិញ្ចឹម តាមទូរសព្ទ អ៊ីម៉ែល និងទម្រង់ទំនាក់ទំនងពីចម្ងាយផ្សេងទៀត នឹងប្រព្រឹតទៅពេញមួយឆ្នាំ។ បុគ្គលិកនឹងធ្វើការងារដោយសហការជាមួយផ្នែកមណ្ឌលសិក្សាធិការ SUSD និងទីភ្នាក់ងារខាងក្រៅសម្រាប់ការទទួលបានការគាំទ្រ និងធនធានបន្ថែមតាមត្រូវការ។ សិស្សយុវជនជាកូនចិញ្ចឹម ត្រូវបានផ្តល់ជូនកាបូស្ពាយដែលមានសម្ភារៈសិក្សា ឆ្នាំងសាកថ្មកុំព្យូទ័រយួរដៃដែលអាចយកចុះឡើងបាន និងកាស់ស្តាប់សំឡេង ទៅតាមការចាំបាច់ដើម្បីលើកកម្ពស់ការទទួលបានបទពិសោធន៍សិក្សាពីចម្ងាយ។ សេវាបង្រៀនតាមអនឡាញ នឹងត្រូវបានផ្តល់ជូនដល់

សិស្សយុវជនជាកូនចិញ្ចឹមដែលមានសិទ្ធិទទួលបាន។

មណ្ឌលសិក្សាធិការ SUSD ក្នុងភាពជាដៃគូជាមួយមជ្ឈមណ្ឌលវេជ្ជសាស្ត្រសហគមន៍ (Community Medical Center) បានបើកដំណើរការមជ្ឈមណ្ឌល Sutter Creek Medical នៅក្នុងការអគារចុះឈ្មោះចូលរៀនកណ្តាល (Central Enrollment building) របស់មជ្ឈមណ្ឌលសិក្សាធិការ SUSD នៅថ្ងៃទី4 ខែមីនា។ គ្លីនិកបានផ្តល់ឱកាសដល់អ្នកសិក្សាភាសាអង់គ្លេស យុវជនជាកូនចិញ្ចឹមនិងសិស្សមានប្រាក់ចំណូលទាប ឲ្យទទួលបានធនធានវេជ្ជសាស្ត្រដោយឥតគិតថ្លៃ ការពិនិត្យរាងកាយដើម្បីត្រឡប់ចូលរៀនវិញ ការពិនិត្យរាងកាយសម្រាប់កីឡា និងការចាក់ថ្នាំវ៉ាក់សាំង Tdap និងភាពសុំរាងកាយផ្សេងទៀត។ ទម្រង់វាយតម្លៃហានិភ័យនៃការធ្វើអត្តឃាតពេលសាលាបិទផ្អាកដំណើរការ និងផែនការសុវត្ថិភាព និងសុខុមាលភាព ទាំងជាភាសាអង់គ្លេស និងភាសាអេស្ប៉ាញ ត្រូវបានបង្កើតឡើងដោយនាយកដ្ឋានសេវាកម្មគាំទ្រផ្នែកសុខភាពផ្លូវចិត្ត និងអាកប្បកិរិយា (Mental Health and Behavior Support Service) នៅក្នុងមណ្ឌលសិក្សាធិការ ដើម្បីធានាទាំងការត្រួតពិនិត្យចំនួន និងប្រភេទនៃការវាយតម្លៃដែលកំពុងផ្តល់ជូន ក៏ដូចជាមធ្យោបាយក្នុងការតាមដានបន្ថែមទៀតជាមួយសិស្ស និងក្រុមគ្រួសារតាមការចាំបាច់ បានកំពុងប្រព្រឹតទៅក្នុងក្របខណ្ឌនៃការសិក្សាពីចម្ងាយ និងវគ្គបង្រៀនដោយផ្ទាល់។ ការផ្សព្វផ្សាយពីការចាក់វ៉ាក់សាំង Tdap និងការគាំទ្រត្រូវបានផ្តល់ជូនជាយុទ្ធសាស្ត្រដល់សិស្សថ្នាក់ទី7 ដែលត្រូវការការគាំទ្រក្នុងការទទួលបានការចាក់ថ្នាំបង្ការ ដើម្បីអាចចូលរួមនៅក្នុងការបង្រៀនប្រចាំថ្ងៃ។

សិស្សដែលមានតម្រូវការពិសេស ត្រូវបានផ្តល់ជូននូវប្រតិបត្តិព័ត៌មានតាមកម្រិតថ្នាក់ជាចម្រុះភាសា ដើម្បីតាមដានការចូលរួមជាមួយនឹងខ្លឹមសារតាមកម្រិតថ្នាក់ និងផ្តល់យុទ្ធសាស្ត្រ និងធនធានដល់ឪពុកម្តាយ និងអាណាព្យាបាលដើម្បីគាំទ្រដល់កូនរបស់ពួកគេក្នុងការសិក្សាពីចម្ងាយ។ សិស្ស និងគ្រួសារដែលមានតម្រូវការពិសេស ក៏នឹងចូលទៅកាន់កម្មវិធីDestiny Discover ផងដែរ។ នេះគឺជាកន្លែងដែលមូលដ្ឋានទិន្នន័យឥតគិតថ្លៃ (ProQuest, Britannica, Teachingbooks.net) និងធនធាននានា ត្រូវបានផ្តល់ជូនដោយបណ្ណាល័យរដ្ឋកាលីហ្វ័រញ៉ា (California State Library) ហើយតំណភ្ជាប់ភ្លាមៗសម្រាប់សិស្សមណ្ឌលសិក្សាធិការ SUSD មានទីតាំងស្ថិតនៅ ដើម្បីផ្តល់ការចូលទៅប្រើប្រាស់កាន់ច្រើនឡើងនូវឯកសារអក្សរសាស្ត្រ និងធនធានសិក្សាតាមអនឡាញ។ សិស្សតាមរយៈ SORA ដែលជាប្រភពឯកសារ eBooks និងសៀវភៅអូឌីយ៉ូ ដែលសៀវភៅទាំងនេះមានភាពស្របទៅតាមកម្មវិធីកុំព្យូទ័រ Chromebooks របស់សិស្ស អាចចូលទៅកាន់សៀវភៅ eBook និងសៀវភៅអូឌីយ៉ូចំនួនជាង 300,000 ក្បាល ជាចម្រុះភាសា ដោយឥតគិតថ្លៃផាកពិន័យ។ ក្នុងសប្តាហ៍ដំបូងនៃការសិក្សានៅសាលា អំឡុងពេលសិក្សាពីចម្ងាយ សៀវភៅ eBook ជាង 9000 ក្បាល ត្រូវបានចូលមើលដោយសិស្សដែលបានតម្រូវការពិសេស ហើយសៀវភៅជាង 1,000 ក្បាល ត្រូវបានដាក់ឲ្យស្ថិតក្នុងការរង់ចាំអាន ដោយសារតែភាពពេញនិយមនៃចំណងជើងសៀវភៅដែលធ្វើឲ្យសិស្សចង់អានសៀវភៅនោះ។ រាល់ធនធានទាំងនេះ បានបង្កើតឡើងសម្រាប់ការចុះឈ្មោះមួយលើកយ៉ាងងាយស្រួល នៅក្នុងការចូលទៅប្រើប្រាស់ ដោយប្រើគណនីGoogle សម្រាប់គ្រូនិងសិស្ស ដែលសិស្សអាចឡុកចូលនៅតាមកន្លែងស្នាក់នៅរបស់ពួកគេ និងទទួលបានសៀវភៅអេឡិចត្រូនិក និងសៀវភៅអូឌីយ៉ូជាង 300,000 ក្បាលសម្រាប់ពួកគេក្នុងការជ្រើសរើស។

## វិធានការពាក់ព័ន្ធនឹងកម្មវិធីសិក្សាពីចម្ងាយ [តារាងជួរផ្តេក និងវិធានការបន្ថែម អាចនឹងត្រូវបានដាក់បន្ថែមទៀតទៅតាមការចាំបាច់

| ពិពណ៌នា | មូលនិធិសរុប | ការបែងចែក |
|---|---|---|
| កុំព្យូទ័រយួរដៃដើម្បីបន្តកិច្ចដំណើរការតាមជុំថ្មីៗ និងធានាថា ពួកវាត្រូវបានផ្តល់ជូនដល់សិស្សគ្រប់រូបដែលបានចុះឈ្មោះនៅក្នុងមណ្ឌលសិក្សាធិការ SUSD។ (DLP-1) | $3,007,365 | បាទ/ចាស |
| វ៉ាយហ្វាយហត់ស្ប៉ត (WiFi hot spot) ដែលបានផ្តល់ជូនដល់កន្លែងស្នាក់នៅ/ក្រុមគ្រួសាររបស់សិស្សគ្រប់រូប (វ៉ាយហ្វាយហត់ស្ប៉តចំនួន 37,000) (DLP-2) | $4,531,000 | បាទ/ចាស |
| ធនធានដែលជួយធានា និងគាំទ្រដល់សិស្សដែលប្រើប្រាស់ និងទទួលបានអ៊ីនធឺណិតនិងគេហទំព័រសមស្រប និងមានសុវត្ថិភាព នៅពេលប្រើប្រាស់កុំព្យូទ័រ។ (DLP-3) | $65,000 | បាទ/ចាស |

| | | |
|---|---|---|
| គ្រូជំនួស ដែលបានផ្តល់ជូនដល់ទីតាំងសាលា ដើម្បីគាំទ្រដល់បទសោធន៍សិក្សាពីចម្ងាយក្នុងពេលជាតែមួយសម្រាប់សិស្ស។ (DLP-4) | $2,000,000 | បាទ/ចាស |
| ការបែងចែកថវិកាតាមទីតាំងសាលា ដើម្បីគាំទ្រដល់ការដោះស្រាយបញ្ហាតម្រូវការសិស្ស ការបង្កើតបរិយាកាសសិក្សាប្រកបដោយសុវត្ថិភាព និងសមភាព និងការកសាងភាពជាដៃគូពេញលេញជាមួយឪពុកម្តាយ និងក្រុមគ្រួសារ ដែលពួកគេបម្រើ សេវាជូន។ (DLP-5) | $8,165,760 | បាទ/ចាស |
| កុំព្យូទ័រយួរដៃសម្រាប់បុគ្គលិករដ្ឋបាល គ្រូ និងបុគ្គលិកគាំទ្រការបង្រៀន។ (DLP-6) | $1,390,000 | បាទ/ចាស |
| បច្ចេកវិទ្យាជំនួយសម្រាប់សិស្សដែលមានពិការភាព ដើម្បីចូលសិក្សាតាមអនឡាញពីតាមផ្ទះ។ (DLP-7) | $100,000 | ទេ |

| ពិពណ៌នា | មូលនិធិសរុប | ការបែងចែក |
|---|---|---|
| | | |
| បន្តការផ្តល់បុគ្គលិកគាំទ្រឯកសារបណ្ណាល័យតាមមណ្ឌលសិក្សាកណ្តាល ដើម្បីធានាថាការចូលកាន់សៀវភៅអេឡិចត្រូនិក និងសៀវភៅអូឌីយ៉ូ ត្រូវបានផ្តល់ជូនដល់សិស្ស និងបុគ្គលិកទាំងអស់ ហើយការគាំទ្រដល់ការបណ្តុះបណ្តាលនិងធនធាន ត្រូវបានផ្តល់ជូននៅក្នុងការត្រួតពិនិត្យផ្ទៀងផ្ទាត់ការចេញចូលក្នុងកិច្ចដំណើរការបច្ចេកវិទ្យា និងកម្មវិធីសិក្សានៅក្នុងការសិក្សាពីចម្ងាយ។ (DLP-8) | $194,798 | បាទ/ចាស |
| ការិយាល័យអភិវឌ្ឍភាសាៈ បន្តការផ្តល់ជូនបុគ្គលិកជំនួយការដែលនិយាយពីរភាសា គ្រូណែនាំការអភិវឌ្ឍភាសាអង់គ្លេស (English Language Development, ELD) អ្នកជំនាញផ្នែកអ្នកសិក្សាភាសាអង់គ្លេស អ្នកបកប្រែឯកសារ/ផ្ទាល់មាត់ និងការគាំទ្រដែលដោះស្រាយដាក់លាក់ទៅលើបញ្ហាតម្រូវការអ្នកសិក្សាភាសាអង់គ្លេស រួមទាំងការអនុវត្ត ELD ដែលបានកំណត់/រួមបញ្ចូលគ្នា កម្មវិធីសម្រាប់អ្នកសិក្សាថ្មី និងកម្មវិធីបន្សាំក្នុងភាសា។ (DLP-9) | $1,686,294 | បាទ/ចាស |
| ថ្ងៃអភិវឌ្ឍជំនាញវិជ្ជាជីវៈសម្រាប់ពេលសហការ និងការចូលរួមរបស់គ្រួសារៈ បន្តពេលវេលាប្រចាំខែសម្រាប់ឲ្យគ្រូសហការជាមួយមិត្តរួមថ្នាក់នៅក្នុងគោលវិធីឆ្ពោះទៅរកការកែលម្អលទ្ធផលសិក្សាសិស្ស។ ទន្ទឹមគ្នានឹងការស្ថិតនៅក្នុងគំរូសិក្សាពីចម្ងាយ និង/ឬ គំរូសិក្សាបែបចម្រុះ ការសហការ បានផ្តោតបន្ថែមទៀតទៅលើការវាយតម្លៃ និងការដោះស្រាយបញ្ហាខាតបង់ការសិក្សា និងការឆ្លើយតបទៅនឹងតម្រូវការរបស់សិស្សដែលបានកំណត់ ជាពិសេសអ្នក ជាពិសេសអ្នកដែលងាយរងគ្រោះបំផុតទៅនឹងផលប៉ះពាល់នៃវិសមភាពដោយសារតែជំងឺ COVID និងការជំរុញឲ្យគ្រួសារចូលរួមក្នុងការគាំទ្រក្នុងម៉ោងធ្វើការ និងជំនួបរវាងគ្រួសារនិងគ្រូ។ (DLP-10) | $11,443,348 | បាទ/ចាស |
| មជ្ឈមណ្ឌលចុះឈ្មោះៈ ធានាថា សេវាកម្មជាបន្តដែលពាក់ព័ន្ធនឹងកិច្ចដំណើរការចុះឈ្មោះនៅមណ្ឌលសិក្សាធិការ SUSD និង/ឬកិច្ចដំណើរការផ្ទេរការសិក្សានៅក្នុងមណ្ឌលសិក្សាធិការ ត្រូវបានគាំទ្រដោយការផ្តល់ជូនបុគ្គលិក ដើម្បីឲ្យសិស្សទទួលបានការផ្ទេរការសិក្សាយ៉ាងមានប្រសិទ្ធភាពទៅក្នុងប្រព័ន្ធសាលារៀន និងក្នុងចំណោមទីតាំងសាលារៀន ទន្ទឹមគ្នានឹងការផ្តល់ជូនការចុះឈ្មោះតាមអនឡាញ និងការចុះឈ្មោះដោយផ្ទាល់តាមការណាត់ជួប។ (DLP-11) | $1,101,606 | បាទ/ចាស |
| ការផ្តល់ជូនបុគ្គលិកនៅក្នុងម៉ោងធ្វើការបន្ថែមសម្រាប់គ្រួសារ បានផ្តល់ជូនក្រោយម៉ោងនៅពេលល្ងាច ដើម្បីបង្កើនការចូលប្រើប្រាស់សេវាសម្រាប់ឲ្យក្រុមគ្រួសារ និងសិស្សធ្វើការប្រាស្រ័យទាក់ទងប្រាប់អំពីតម្រូវការ និងការគាទ្រពីបុគ្គលិកប្រចាំការនៅសាលា ស្របគ្នាជាមួយនឹងឡូជីសស្ទិក និងប្រព័ន្ធសិក្សាពីចម្ងាយ។ (DLP-12) | $3,000,000 | បាទ/ចាស |
| ការអភិវឌ្ឍជំនាញវិជ្ជាជីវៈនៅរដូវក្តៅ និងឱកាសសហការដែលបានផ្តល់ជូនដល់បុគ្គលិករដ្ឋបាល និងបុគ្គលិកបង្រៀន បានផ្តោតលើការកសាងសមត្ថភាពនៅក្នុងការផ្តល់ជូនការបង្រៀនផ្តោតលើគុណភាពជាចម្បង និងឱកាសសិក្សាក្នុងម៉ោងដាច់ដោយឡែកនៅក្នុងការសិក្សាពីចម្ងាយ ដែលជំរុញឲ្យសិស្សចូលរួម និងបំពេញតម្រូវការសិក្សាចម្រុះរបស់យុវជនជាកូនចិញ្ចឹម អ្នករៀនភាសាអង់គ្លេស គ្រួសារទើបលែងលះ និងសិស្សដែលមានតម្រូវការពិសេស។ (DLP-13) | $1,800,000 | បាទ/ចាស |
| សៀវភៅណែនាំអំពីការសិក្សាពីចម្ងាយសម្រាប់ឪពុកម្តាយ/អាណាព្យាបាល ដែលបានបោះពុម្ពជាចម្រុះភាសានៅក្នុងការគាំទ្រដល់សេវាកម្ម ព័ត៌មាន និងធនធាននានាដែលកំពុងផ្តល់ជូនដល់ក្រុមគ្រួសារ | $20,000 | បាទ/ចាស |

| | | |
|---|---|---|
| នៅមណ្ឌលសិក្សាធិការ SUSD ទាំងអស់។ (DLP-14) | | |
| អាជ្ញាបណ្ណកម្មវិធី Zoom ដើម្បីធានាដល់សេវាកម្មគាំទ្រដល់អ្នករដ្ឋបាលប្រចាំការ និងសិស្ស ដើម្បីបង្កើតនូវប្រព័ន្ធកម្មវិធីតាមអ៊ីនធឺណិតសម្រាប់ការផ្សព្វផ្សាយ និងសិក្ខាសាលាសម្រាប់ក្រុមគ្រួសារ ដោយគាំទ្រដល់ការកសាងទំនាក់ទំនង ភាពយល់អធ្យាស្រ័យគ្នា និងសមត្ថភាពគ្រួសារក្នុងការជួយឲ្យកុមារចូលទៅប្រើប្រាស់ និងទទួលបានជោគជ័យនៅក្នុងការសិក្សាពីចម្ងាយ។ (DLP-15) | $92,635 | បាទ/ចាស |

## ការបាត់បង់ការសិក្សារបស់សិស្ស

[ការពិពណ៌នាអំពីរបៀបដែលភ្នាក់ងារ LEA នឹងដោះស្រាយបញ្ហាបាត់បង់ការសិក្សារបស់សិស្សដែលបណ្ដាលមកពីជំងឺ COVID-19 នៅអំឡុងឆ្នាំសិក្សា2019–2020 និងឆ្នាំសិក្សា2020–21 រួមទាំងរបៀបដែលទីភ្នាក់ងារ LEA នឹងធ្វើការវាយតម្លៃសិស្សដើម្បីវាស់ស្ទង់លើស្ថានភាពសិក្សា ជាពិសេសនៅក្នុងផ្នែកអក្សរសាស្ត្រភាសាអង់គ្លេស ការអភិវឌ្ឍភាសាអង់គ្លេស និងគណិតវិទ្យា។]

មណ្ឌលសិក្សា SUSD នឹងប្រើប្រាស់ការវាយតម្លៃផ្អែកលើកម្មវិធីសិក្សា ទិន្នន័យសិក្សាគោលរបស់សិស្ស ការវាយតម្លៃកែលម្អទូទៅ ការវាយតម្លៃសរុបបញ្ចប់ និងទិន្នន័យវត្តមាន ដើម្បីគ្រប់គ្រងវឌ្ឍនភាពរបស់សិស្សទៅការរីកចម្រើនផ្អែកតាមស្តង់ដាតាមកម្រិតថ្នាក់ និងដោះស្រាយបញ្ហាជាយុទ្ធសាស្ត្រទៅលើការគាំទ្រតាមកម្រិតផ្អែកលើលទ្ធផលរបស់សិស្ស ស្របជាមួយនឹងគោលវិធីនៃប្រព័ន្ធគាំទ្រច្រើនដំណាក់កាល (Multi-Tiered System of Support)។ គ្រូនឹងផ្តល់ការវាយតម្លៃនៅអំឡុងការសិក្សាពីចម្ងាយ និងវគ្គបង្រៀនដោយផ្ទាល់ ស្របជាមួយនឹងគោលនយោបាយដាក់ពិន្ទុរបស់មណ្ឌលសិក្សា SUSD។ ក្រុមគ្រួសារគួររំពឹងថា កូនៗរបស់ពួកគេនឹងចូលរួមទៅក្នុងការវាយតម្លៃការសិក្សាទៅលើខ្លឹមសារតាមស្តង់ដាកម្រិតថ្នាក់ នៅក្នុងឆ្នាំសិក្សាទាំងមូល ដែលផ្តល់ទិន្នន័យលើវឌ្ឍនភាពសិក្សារបស់សិស្ស និងលទ្ធភាពក្នុងការអនុវត្តជំនាញដែលពួកគេទទួលបានការបង្រៀន។ វដ្តនៃការវាយតម្លៃទាំងនេះ នឹងផ្តល់ទិន្នន័យដែលគ្រូប្រើប្រាស់ដើម្បីផ្តល់ដំណឹងអំពីការការបង្រៀន និងការធ្វើផែនការជាយុទ្ធសាស្ត្ររបស់ពួកគេ ដើម្បីដោះស្រាយបញ្ហាប្រឈមលើការសិក្សា និងការរក្សាបានចំណេះដឹងដែលពាក់ព័ន្ធនឹងផលប៉ះពាល់នៃការបិទអគារសិក្សាដោយសារតែជំងឺរាតត្បាត COVID-19។ ទម្រង់បែបបទវាយតម្លៃទាំងនេះ និងវដ្តនៃការវិភាគទិន្នន័យបែបសហការ និងការធ្វើផែនការយុទ្ធសាស្ត្រ នឹងផ្តោតលើផ្នែកនៃខ្លឹមសារបង្រៀនមុខវិជ្ជាអក្សរសាស្ត្រភាសាអង់គ្លេស (ELA) ការអភិវឌ្ឍភាសាអង់គ្លេស (ELD) និងគណិតវិទ្យា។

អំឡុងរដូវផ្ការីកឆ្នាំ2020 មណ្ឌលសិក្សាធិការរួបរួមស្តុកថម (Stockton Unified School District, SUSD) បានដោះស្រាយបញ្ហាប្រឈមនៃការសិក្សារបស់សិស្ស តាមរយៈការផ្តល់នូវការចូលប្រើប្រាស់សៀវភៅអេឡិចត្រូនិក និងសៀវភៅអូឌីយ៉ូច្រើនជាងមុន ការបើកទូលាយឱកាសបង្រៀន AVID ដល់សិស្សវិទ្យាល័យទាំងអស់ ការផ្តល់ការបង្រៀននិងកិច្ចការលំហាត់ផ្ទះ ការផ្តល់ការគាំទ្រការបង្រៀននិងកិច្ចការលំហាត់ផ្ទះតាមរយៈប្រព័ន្ធកម្មវិធីតាមកុំព្យូទ័រ ការផ្តល់កម្មវិធីសិក្សាបំពេញក្រេឌីតតាមកុំព្យូទ័រដល់សិស្សវិទ្យាល័យ ការបង្កើនការចូលពិនិត្យផ្ទៀងផ្ទាត់របស់អ្នកពិគ្រោះយោបល់ជាមួយនឹងសិស្ស ដើម្បីផ្តល់ការណែនាំសិក្សារៀនសូត្រ និងការគាំទ្រចិត្តសង្គម និងការផ្តល់បទពិសោធន៍សិក្សាពីចម្ងាយតាមសាលានៅរដូវក្តៅដល់សិស្ស។ អំឡុងពេលចាប់ផ្តើមឆ្នាំសិក្សា2020-2021 ក្នុងក្របខណ្ឌការសិក្សាពីចម្ងាយគ្រប់ទីតាំងសាលារៀនទាំងអស់ បានចាត់ចែងការវាយតម្លៃដំណាក់កាលដំបូង ដោយប្រើការវាយតម្លៃដែលមណ្ឌលសិក្សាធិការបានអនុម័ត ដើម្បីប្រមូលយកទិន្នន័យគោលដែលជាការគាំទ្រដល់គ្រូក្នុងការកំណត់តម្រូវការសិក្សារបស់សិស្សយ៉ាងមានប្រសិទ្ធភាពនៅក្នុងថ្នាក់រៀនរបស់ពួកគេ ពេលវេលាសហការតាមកម្រិតថ្នាក់សម្រាប់គ្រូក្នុងការធ្វើការងារជាយុទ្ធសាស្ត្ររួមគ្នា ដើម្បីធ្វើផែនការមេរៀនផ្សេងៗគ្នានៅក្នុងផ្នែកខ្លឹមសារនានានៃមុខវិជ្ជា ELA ការអភិវឌ្ឍ ELD និងគណិតវិទ្យា ផ្តល់ការផ្សព្វផ្សាយដល់ក្រុមគ្រួសារដោយបង្ហាញប្រាប់អំពីការរំពឹងទុកនៃការសិក្សាពីចម្ងាយតាមរយៈការប្រាស្រ័យទាក់ទងជាបន្តបន្ទាប់ និងការធ្វើបទបង្ហាញដែលបានចែករំលែកអំឡុងពេលយុទ្ធនាការប្រមូលសិស្សចូលរៀនវិញ (Back to School Nights) តាមអ៊ីនធឺណិត និងយុទ្ធនាការ Title 1 Parent Night និងការកសាងសហគមន៍ថ្នាក់រៀនតាមរយៈការរួមបញ្ចូលការសិក្សាផ្អែកចិត្តសង្គម និងអន្តរាគមន៍និងការគាំទ្រអាកប្បកិរិយាវិជ្ជមាន (Positive Behavior Interventions and Supports, PBIS) ដើម្បីបង្កើតបរិយាកាសសិក្សាបែបសមធម៌ដោយមានការរួមបញ្ចូលគ្រប់សិស្សទាំងអស់គ្នា។ នៅក្នុងឆ្នាំសិក្សា2020-2021 ទាំងមូល បុគ្គលិកបង្រៀន នឹងប្រើប្រាស់ការវាយតម្លៃកែលម្អ និងផ្អែកតាមកម្មវិធីសិក្សា ដើម្បីពិនិត្យមើលការយល់ដឹងនៅអំឡុងម៉ោងសិក្សាក្នុងពេលជាមួយគ្នា ប្រើប្រាស់កិច្ចការអនុវត្តដូចជាគម្រោងសិក្សាបង្កើតឡើងដោយសិស្សជាដើម វីដេអូ និងទម្រង់ច្នៃប្រឌិតផ្សេងៗរបស់សិស្ស ដែលបង្ហាញ និងអនុវត្តជាក់ស្តែង

លើអ្វីដែលពួកគេបានបានសិក្សា ហើយ ការវាយតម្លៃសរុបបញ្ចប់តាមស្តង់ដា នឹងត្រូវបានប្រើប្រាស់ប្រកបដោយភាពស៊ីចង្វាក់គ្នានៅក្នុងទីតាំងសាលារៀនទាំងមូល ដើម្បីអនុញ្ញាតឲ្យមានការពិភាក្សាអំពីសហគមន៍សិក្សាជំនាញវិជ្ជាជីវៈ (Professional Learning Community, PLC) និងវិធានសម្រាប់ការរីកលូតលាស់ទូទៅ។ វិធានការ និងសេវាកម្មច្រើនជាងមុននៅក្នុងផ្នែកមុខវិជ្ជា ELA ការអភិវឌ្ឍ ELD និងគណិតវិទ្យា នឹងប្រព្រឹត្តទៅនៅអំឡុងឆ្នាំសិក្សានេះ ដែលបានផ្តោតលើឱកាសសម្រាប់សិស្ស និងក្រុមគ្រួសារចូលជួបបុគ្គលិកបង្រៀនច្រើនជាងមុន ទទួលបានម៉ោងបង្រៀន ឱកាសនិងធនធានជំនួយកិច្ចការលំហាត់ផ្ទះ និងម៉ោងអភិវឌ្ឍជំនាញវិជ្ជាជីវៈ។

បុគ្គលិកសេវាគាំទ្រសម្រាប់សិស្ស បន្តដោះស្រាយបញ្ហាប្រឈមនៃការសិក្សាតាមរយៈគោលវិធីដែលមានច្រើនដំណាក់កាល។ សេវាកម្មបំពេញបន្ថែមដំណាក់កាលទីពីរ បន្តអនុវត្ត ទន្ទឹមគ្នានឹងពេលដែលសិស្សចូលរៀននៅក្នុងការសិក្សាពីចម្ងាយ។ អ្នកពិគ្រោះយល់បល់សាលា បង្កើត និងប្រើប្រាស់អន្តរាគមន៍ឆ្លើយតបដូចជាផែនការសុវត្ថិភាពសិស្ស យុទ្ធសាស្ត្រដំណោះស្រាយសម្រាប់បុគ្គល ការពិនិត្យផ្ទៀងផ្ទាត់ចេញចូល ការគាំទ្រមិត្ត គោលវិធីយល់ដឹងពីការប៉ះទង្គិច និងគោលវិធីយុទ្ធសាស្ត្រគាំទ្រផ្សេង ទៀត។ ទម្រង់បែបបទយល់ព្រមដោយមានព័ត៌មានគ្រប់គ្រាន់ពីចម្ងាយ បានត្រូវបង្កើតឡើងពីសេវាកម្មទាំងនេះ។ ការបកប្រែនៃទម្រង់បែបបទនេះជាភាសាអេស្ប៉ាញ កំពុងតែប្រព្រឹតទៅ។ អ្នកពិគ្រោះយោបល់សាលា ផ្តល់ជូនការពិគ្រោះយោបល់ផ្នែកចិត្តវិទ្យាអប់រំលក្ខណៈបុគ្គល/ជាក្រុមតូចៗ ដើម្បីដោះស្រាយបញ្ហាតម្រូវការបានមកពីទិន្នន័យ អភិវឌ្ឍជំនាញ និងបង្កើតការផ្សារភ្ជាប់ទំនាក់ទំនងសាលារៀន និងមិត្តរួមថ្នាក់។ អ្នកពិគ្រោះយោបល់សាលា សហការជាមួយអ្នកផ្តល់សេវាគាំទ្រ (ឧ.ទា. គីលានុប្បដ្ឋាក អ្នកចិត្តសាស្ត្រប្រចាំសាលា/បុគ្គលិកសង្គមកិច្ច និងគ្រូពេទ្យគ្លីនិក) ដើម្បីគាំទ្រតម្រូវការសិស្ស។ ម្យ៉ាងទៀត អ្នកពិគ្រោះយោបល់សាលា គ្រប់គ្រងលើវឌ្ឍនភាពរបស់សិស្សនៅអំឡុងពេល និងក្រោយពេលអន្តរាគមន៍ និងបញ្ជូនបន្តទៅកាន់ធនធានខាងក្រៅ។ សេវាកម្មបន្ទាន់ដំណាក់កាលទីពីរ ក៏បន្តអនុវត្តផងដែរ ទន្ទឹមគ្នានឹងពេលដែលសិស្សចូលរៀននៅក្នុងការសិក្សាពីចម្ងាយ។ អ្នកពីគ្រោះយោបល់សាលា ផ្តល់ការពិគ្រោះយោបល់អំពីវិបត្តិ និងការពិគ្រោះបល់ជាលក្ខណៈបុគ្គលផ្តោតលើដំណោះស្រាយរយៈពេលខ្លី ទន្ទឹមគ្នានឹងការអនុវត្ត (ឬការពង្រឹងការអនុវត្ត) ការពិគ្រោះយោបល់ស្តាឡើងវិញនិងយល់ដឹងពីការប៉ះពាល់។ ពួកគេបញ្ជូនសិស្សបន្តទៅកាន់គ្រូពេទ្យគ្លីនិកផ្នែកសុខភាពផ្លូវចិត្តតាមសាលារៀន ឬដៃគូភ្នាក់ងារសហគមន៍ សម្រាប់បញ្ហាពាក់ព័ន្ធនឹងសុខភាពផ្នែកផ្លូវចិត្ត/អាកប្បកិរិយារ៉ាំរ៉ៃ និងត្រួតពិនិត្យវឌ្ឍនភាពរបស់សិស្សនៅអំឡុងពេលសេវាអន្តរាគមន៍ និងសេវាក្រោយអន្តរាគមន៍។

## យុទ្ធសាស្ត្រអំពីការបាត់បង់ការសិក្សារបស់សិស្ស

[ការពិព៌ណនាអំពីវិធានការ និងយុទ្ធសាស្ត្រ ដែលទីភ្នាក់ងារ LEA នឹងប្រើប្រាស់ដើម្បីដោះស្រាយបញ្ហាបាត់បង់ការសិក្សា និងបង្កើនវឌ្ឍនភាពសិក្សាសម្រាប់សិស្សតាមតម្រូវការ រួមទាំងរបៀបដែលយុទ្ធសាស្ត្រទាំងនេះមានភាពខុសគ្នាសម្រាប់សិស្សដែលជាអ្នកសិក្សាភាសាអង់គ្លេស អ្នកមានប្រាក់ចំណូលទាប យុវជនជាកូនចិញ្ចឹម សិស្សដែលមានតម្រូវការពិសេស និងសិស្សដែលជួបប្រទះបញ្ហាគ្មានទីជម្រក។]

ការសិក្សាក្នុងពេលជាមួយគ្នា ការបង្រៀនផ្ទាល់ នឹងក្លាយជាការផ្តោតជាចម្បងនៃការដោះស្រាយបញ្ហាប្រឈមនៃការសិក្សានិងតម្រូវការសម្រាប់ការបង្កើនវឌ្ឍនភាព ដោយមានការផ្តល់ជូនការអភិវឌ្ឍជំនាញវិជ្ជាជីវៈជាបន្តបន្ទាប់ដោយផ្តោតលើការផ្តល់ការបង្រៀនដែលផ្តោតលើគុណភាពខ្ពស់ជាចម្បងនៅក្នុងការសិក្សាពីចម្ងាយ និងវគ្គបង្រៀនដោយផ្ទាល់។ គ្រប់សិស្សទាំងអស់ នឹងទទួលបានការបង្រៀនដោយផ្ទាល់តាមស្តង់ដា គាំទ្រដោយសកម្មភាពសិក្សាដែលផ្តោតលើកម្មវិធីសិក្សា ផ្តោតលើការចេះស្ទាត់ជំនាញលើខ្លឹមសារតាមកម្រិតថ្នាក់។ ការបង្រៀនដែលផ្តោតលើគុណភាពខ្ពស់ជាចម្បង នឹងផ្តល់ឲ្យសិស្សនូវការបង្រៀនដោយផ្ទាល់ ឧទាហរណ៍ដែលគ្រូបានផ្តល់ជាគំរូ និងឱកាសសម្រាប់សិស្សក្នុងការចូលរួមជាមួយនឹងជំនាញផ្អែកតាមស្តង់ដាកម្រិតថ្នាក់ ទស្សនាទាន និងវាក្យសព្ទដែលពាក់ព័ន្ធនឹងផ្នែកខ្លឹមសារស្នូលនៃការសិក្សាទាំងអស់។ ឱកាសគាំទ្រការសិក្សានៅសាលានារដូវក្តៅ ត្រូវបានផ្តល់ជូនដល់យុវជនជាកូនចិញ្ចឹម ក្រុមគ្រួសារទើបលែងលះអ្នកសិក្សាភាសាអង់គ្លេស អ្នកមានចំណូលទាប និងសិស្សដែលមានតម្រូវការពិសេស។ ម៉ោងការងារដែលគ្រូបានសម្របសម្រួល ត្រូវបានផ្តល់ជូនសម្រាប់ការចូលប្រើប្រាស់របស់សិស្ស ដើម្បីទទួលបានការគាំទ្រការបង្រៀន និងជំនួយកិច្ចការលំហាត់ផ្ទះ។ ឱកាសជំនួយសម្រាប់ការបង្រៀន និងកិច្ចការលំហាត់ផ្ទះ ត្រូវបានផ្តល់ជូនដល់យុវជនជាកូនចិញ្ចឹម គ្រួសារទើបលែងលះ អ្នកសិក្សាភាសាអង់គ្លេស អ្នកមានចំណូលទាប និងសិស្សដែលមានតម្រូវការពិសេស។ កម្មវិធីក្រោយការសិក្សានៅសាលា ក៏បានបំពេញតម្រូវការរបស់សិស្សទាំងនេះផងដែរ ដោយផ្តល់ជូនបទពិសោធន៍ការជួបទំនាក់ទំនងសង្គម ជំនួយកិច្ចការលំហាត់ផ្ទះ ការបង្រៀន និងបទពិសោធន៍នៃការពង្រឹងសមត្ថភាព។ ការចូលទៅកាន់កម្មវិធី Rosetta Stone ត្រូវបានផ្តល់ជូនអ្នកសិក្សាភាសាអង់គ្លេស ដើម្បីគាំទ្រដល់ការទទួលបានចំណេះដឹងភាសាអង់គ្លេស និងការពង្រីកសកម្មភាពវាក្យសព្ទ។. គ្រប់ទីតាំងសាលារៀនទាំងអស់ដែលបានផ្តល់សេវាកម្មដល់សិស្សថ្នាក់ពីមត្តេយ្យឆ្លងភូមិសិក្សាដល់ថ្នាក់ទី8 (TK-8) ត្រូវបានផ្តល់ជូនគ្រូចូលបងៀនជំនួសប្រចាំថ្ងៃម្នាក់ ហើយនៅវិទ្យាល័យ ត្រូវបានផ្តល់ជូនគ្រូចូលបង្រៀនជំនួសពីរនាក់ ដែលប្រព្រឹត្តទៅជាយុទ្ធសាស្ត្រនៅក្នុងការសិក្សាពីចម្ងាយក្នុងថ្នាក់រៀនកំណត់ដែលបានបម្រើសេវាដល់យុវជនជាកូនចិញ្ចឹម គ្រួសារទើបលែងលះអ្នកសិក្សាភាសាអង់គ្លេស

អ្នកមានចំណូលទាប និងសិស្សដែលមានតម្រូវការពិសេស ដើម្បីបង្កើតការគាំទ្រការបង្រៀន ការគាំត្រការសិក្សាជាក្រុមតូចៗ និងការសិក្សាផ្ទាល់មួយទល់នឹងមួយ ដែលបានផ្តល់ជូនដល់សិស្សនៅក្នុងបទពិសោធន៍សិក្សាក្នុងពេលជាមួយគ្នា ឬក្នុងពេលដាច់ដោយឡែក។ កម្មវិធីបំពេញក្រេឌីតឬបំប៉នអ្នកបោះបង់ការសិក្សា ត្រូវបានប្រើប្រាស់នៅកម្រិតថ្នាក់វិទ្យាល័យ ដើម្បីផ្តល់នូវការគាំទ្របន្ថែមទៀតដល់ក្រុមសិស្សដែលបានកំណត់ ដោយផ្តល់ឱកាសក្នុងការរៀនបំពេញក្រេឌីត ទទួលបានស្តង់ដាតាមកម្រិតថ្នាក់ និងទទួលបានក្រេឌីតដើម្បីស្ថិតនៅតាមគន្លងមាគ៌ាឆ្ពោះទៅរកការបញ្ចប់ការសិក្សា ស្របជាមួយនឹងការបញ្ចប់វគ្គសិក្សា A-G។ កម្មវិធីត្រូវបានអនុវត្តនៅក្នុងគំរូសិក្សាពីចម្ងាយពេញលេញ ហើយ គ្រូបានគាំទ្រដល់សិស្សក្នុងកិច្ចដំណើរការបំពេញក្រេឌីត ដោយមានការជួយគាំទ្រអន្តរាគមន៍បង្រៀនច្រើនជាងមុន។ អ្នកជំនាញផ្នែកបរិយាបន្ន នឹងគាំទ្រដល់សិស្សដែលមានតម្រូវការពិសេស ជាពិសេសសិស្សដែលមានជំងឺអូទីស៊ុម តាមរយៈការផ្តល់សេវាពិគ្រោះយោបល់ដល់គ្រូបង្រៀន អ្នកគ្រប់គ្រងរដ្ឋបាលប្រចាំទីតាំង និងបុគ្គលិកគាំទ្រនៅក្នុងកិច្ចដំណើរការកំណត់ប្រព័ន្ធ និងការអនុវត្តយុទ្ធសាស្ត្រដើម្បីបង្កើនសមត្ថភាពសម្រាប់សិស្សដែលមានពិការភាពឲ្យទទួលបាន និងចូលរួមទៅក្នុងការសិក្សាពីចម្ងាយ និងផ្ទេរការសិក្សាដោយជោគជ័យចូលទៅក្នុងវគ្គសិក្សាដោយផ្ទាល់។ គ្រូនៅក្នុងការផ្តល់ការគាំទ្រការបង្រៀនជាក្រុមតូចៗជូនដល់យុវជនជាកូនចិញ្ចឹម គ្រួសារទើបលែងលះ អ្នកសិក្សាភាសាអង់គ្លេស អ្នកមានចំណូលទាប និងសិស្សដែលមានតម្រូវការពិសេស នឹងផ្តោតទៅលើការបង្កើនចំណេះដឹងស៊ីជម្រៅ និងសមត្ថភាពរបស់សិស្សនៅក្នុងការអនុវត្តជាក់ស្តែងលើជំនាញផ្អែកតាមស្តង់ដាកម្រិតខ្ពស់ ដែលត្រូវការជាចាំបាច់សម្រាប់ភាពជោគជ័យលើការសិក្សានៅក្នុងកម្រិតថ្នាក់សិក្សានិងវគ្គសិក្សា A-G នាពេលអនាគត ដែលត្រូវការជាចាំបាច់ដើម្បីឲ្យសិស្សបញ្ចប់ការសិក្សាពីវិទ្យាល័យត្រៀមខ្លួនសម្រាប់ការចូលរៀននៅមហាវិទ្យាល័យ និងជំនាញអាជីពនានា។ សិស្សដែលមានតម្រូវការពិសេស នឹងទទួលបានការចូលទៅកាន់កម្មវិធីអន្តរាគមន៍អំណានមួយដែលបានផ្តល់ជូនស្របតាមតម្រូវការបំណិនអំណានជាលក្ខណៈបុគ្គលជាក់លាក់ និងផ្តល់ជូនការត្រួតពិនិត្យវឌ្ឍនភាព និងការវាយតម្លៃតាមជំនាញជាបន្តបន្ទាប់ ដើម្បីបង្កើនសមត្ថភាពរបស់សិស្សក្នុងការរីកចម្រើនទៅមុខ និងទទួលបានសមត្ថភាព និងបំណិនអំណានតាមកម្រិតថ្នាក់។ ការប្រាស្រ័យទាក់ទងជាបន្តបន្ទាប់រវាងគ្រូ និងក្រុមគ្រួសារ នឹងប្រព្រឹតទៅដោយបង្ហាញប្រាប់ពីគោលដៅសិក្សា វឌ្ឍនភាពសិក្សា យុទ្ធសាស្ត្រ និងជំនាញដែលត្រូវធ្វើការ និងផ្តោតការយកចិត្តទុកដាក់ ខ្លឹមសារដែលបានបង្រៀន ធនធានតាមអនឡាញ និងតាមកម្មវិធីសិក្សាដែលត្រូវប្រើប្រាស់ដើម្បីគាំទ្រដល់ការសិក្សាសិស្សបន្ថែមពីលើថ្ងៃសិក្សានៅសាលា និងរៀបរាប់លម្អិតអំពីកិច្ចការលំហាត់ និងរបៀបប្រើប្រាស់កម្មវិធី ParentVue ដើម្បីគ្រប់គ្រងពិន្ទុសិស្ស។ ការអភិវឌ្ឍជំនាញវិជ្ជាជីវៈ និងការគាំទ្រការសិក្សា នឹងប្រព្រឹតទៅជាបន្តបន្ទាប់សម្រាប់បុគ្គលិកបង្រៀនក្នុងការគាំទ្រដល់កិច្ចដំណើរការដោះស្រាយបញ្ហាប្រឈមនឹងការសិក្សា និងបង្កើនវឌ្ឍនភាពសិក្សាសម្រាប់សិស្សទាំងអស់ ជាមួយនឹងគោលវិធីជាយុទ្ធសាស្ត្រតាមដំណាក់កាល ដែលដឹកនាំជាចម្បងឆ្ពោះទៅរកការបំពេញតម្រូវការយុវជនជាកូនចិញ្ចឹម គ្រួសារទើបលែងលះ អ្នកមានចំណូលទាប និងសិស្សដែលមានតម្រូវការពិសេស។ នៅក្នុងការដោះស្រាយបញ្ហាបង្កើនការសិក្សារបស់សិស្ស បុគ្គលិកបង្រៀន នឹងចូលរួមយ៉ាងហោចណាស់ពីរដងក្នុងមួយខែទៅក្នុងពេលវេលាកំណត់តាមកម្រិតថ្នាក់បែបសហការសម្រាប់សហគមន៍សិក្សាជំនាញវិជ្ជាជីវៈ (Professional Learning Community, PLC) ដែលនៅក្នុងនោះរួមមាន៖ វដ្តទិន្នន័យនៃការវិភាគទិន្នន័យសិស្ស ការកំណត់ជំនាញនិងចំណេះដឹងសំខាន់ៗដែលមានពីមុនមកនៅក្នុងផ្នែកសិក្សាខ្លឹមសារស្នូល ការធ្វើផែនការយុទ្ធសាស្ត្រដែលផ្តោតលើការត្រួតពិនិត្យវឌ្ឍនភាពសិក្សាសិស្ស នៅក្នុងផ្នែកមុខវិជ្ជាអក្សរសាស្ត្រភាសាអង់គ្លេស (English Language Arts, ELA) ការអភិវឌ្ឍភាសាអង់គ្លេស (English Language Development, ELD) និងគណិតវិទ្យា ការកំណត់តម្រូវការសិក្សាផ្សេងៗគ្នាសម្រាប់ការគាំទ្រស្របជាមួយនឹងវិសាលភាព និងកម្រិតលំដាប់លំដោយផ្អែកតាមកម្មវិធីសិក្សាដែលបានអនុម័ត ទន្ទឹមគ្នានឹងការអភិវឌ្ឍការវាយតម្លៃកែលម្អជារួម ដើម្បីផ្តល់ដំណឹងអំពីការអនុវត្តការបង្រៀន។ អ្នកណែនាំការបង្រៀន នឹងផ្តល់ការគាំទ្រការបង្រៀនតាមទីតាំងជាបន្តបន្ទាប់ដែលផ្តោតលើការដោះស្រាយបញ្ហាយុទ្ធសាស្ត្រផ្សេងៗគ្នា និងការរួមបញ្ចូលគ្នានៃធនធានផ្អែកតាមកម្មវិធីសិក្សាដើម្បីគាំទ្រដោយការដោះស្រាយបញ្ហាខ្វះចន្លោះផ្នែកសិក្សា និងការបង្កើនតម្រូវការរបស់សិស្ស ដោយសារតែផលប៉ះពាល់នៃជំងឺ COVID-19 លើសេវាកម្មបង្រៀនដែលផ្តល់ជូននៅអំឡុងពេលបិទអគារសិក្សាទាំងមូល និងអំឡុងពេលវគ្គបង្រៀនដោយផ្ទាល់។

ការសិក្សាពីចម្ងាយ តម្រូវឲ្យមានការភ្ជាប់ទៅកាន់អ៊ីនធឺណិត ក៏ដូចជាឧបករណ៍ណាមួយ ដើម្បីចូលទៅកាន់ការបង្រៀន។ ដើម្បីជួយធានាបានថាសិស្សគ្រប់រូបមានឧបករណ៍ប្រើប្រាស់ អ្នកពិគ្រោះយោបល់តាមសាលា បានជួយជំរុញឲ្យទីតាំងរបស់ពួកគេចែកចាយកុំព្យូទ័រ Chromebooks និងបានគាំទ្រឲ្យមានវ៉ាយហ្វាយហត់ស្ប៉ត (WiFi hot spot) ដោយសារតែក្រុមគ្រួសារទាំងអស់មិនមានអ៊ីនធឺណិតប្រើប្រាស់។ អ្នកពិគ្រោះយោបល់សាលា ក៏ឆ្លើយតបទៅកាន់សំណូមពររបស់ឪពុកម្តាយ និងអាណាព្យាបាលផងដែរ សម្រាប់ការគាំទ្រទៅលើការប្រើប្រាស់បច្ចេកវិទ្យា។ នៅក្នុងរដូវផ្ការីក អ្នកពិគ្រោះយោបល់សាលា បានប្រើប្រាស់មធ្យោបាយនានាតាមអ៊ីនធឺណិត (រួមមានការស្ទង់មតិតាម Google) សម្រាប់ឲ្យគ្រូបង្រៀនបញ្ជូនបន្តសិស្សដែលមិនបានចូលរួមក្នុងការសិក្សាពីចម្ងាយ ឬឈប់ចូលរួមក្នុងពេលណាមួយ។ អ្នកពិគ្រោះយោបល់ បានខិតខំប្រឹងប្រែងគ្រប់បែបយ៉ាងដើម្បីទាក់ទងទៅកាន់គ្រួសារសិស្សដែលមិនបានចូលរួម ដើម្បីជួយគាំទ្រពួកគេ និងកំណត់ពីតម្រូវការរបស់ពួកគេ (ឧ.ទា. ឧកបរណ៍មានដំណើរការល្អ ការតភ្ជាប់ទៅកាន់អ៊ីនធឺណិត មិនមានលទ្ធភាពក្នុងការភ្ជាប់ទៅកាន់កម្មវិធី Google Classroom ជាដើម)។ អ្នកពិគ្រោះយោបល់សាលា បានប្រើប្រាស់យុទ្ធសាស្ត្រទំនាក់ទំនងផ្សេងៗដើម្បីទាក់ទង និងភ្ជាប់ទំនាក់ទំនងជាមួយសិស្ស។ អ្នកពិគ្រោះយោបល់សាលា

ផ្ញើអ៊ីម៉ែលនិងវីដេអូប្រចាំសប្ដាហ៍ បានរៀបចំជំនួបពេលអាហារថ្ងៃត្រង់តាមអ៊ីនធឺណិតដើម្បីរក្សាការភ្ជាប់បណ្ដាញនិងទំនាក់ទំនង និងបានខិតខំប្រឹងប្រែងបន្ថែមទៀតដើម្បីភ្ជាប់ទំនាក់ទំនងជាមួយសិស្សដែលមិនចូលរៀន/ចូលរួម ដូចជាការភ្ជាប់ទំនាក់ទំនងតាមបណ្ដាញព័ត៌មានសង្គម និងការគាំទ្រមិត្ត បន្ថែមពីលើការទាក់ទងជាមួយគ្រួសារ។ អ្នកពិគ្រោះយោបល់សាលា និងអ្នកជំនាញកម្មវិធីអ្នកពិគ្រោះយោលប់សាលា (School Counselor Program Specialist) បានរួមបញ្ចូលនូវធនធានសិក្សាជាច្រើននៅក្នុងគេហទំព័រសាលា និងគេហទំព័រមណ្ឌលសិក្សាធិការ ដើម្បីផ្ដល់ជូនការគាំទ្របន្ថែម ដល់សិស្សលើមុខវិជ្ជាគណិតវិទ្យា អំណាន និងមុខវិជ្ជាច្រើនផ្សេងទៀត។

## ប្រសិទ្ធភាពនៃយុទ្ធសាស្រ្តអំពីការបាត់បង់ការសិក្សារបស់សិស្ស

[ការពិពណ៌នាពីកម្រិតប្រសិទ្ធភាពនៃសេវាកម្ម ឬការគាំទ្រដែលបានផ្ដល់ជូនដើម្បីដោះស្រាយបញ្ហាបាត់បង់ការសិក្សា នឹងត្រូវបានវាស់ស្ទង់។]

ប្រសិទ្ធភាពនៃសេវាកម្ម និងការគាំទ្រដែលបានផ្ដល់ជូនដើម្បីដោះស្រាយបញ្ហាប្រឈមនៃការសិក្សា នឹងត្រូវបានវាស់ស្ទង់តាមរយៈការវាយតម្លៃជាបន្តបន្ទាប់លើវឌ្ឍនភាពរបស់សិស្ស ទិន្នន័យការចូលរួមរបស់សិស្ស និងទិន្នន័យវត្តមានរបស់សិស្ស។ ទម្រង់បែបបទនៃការវាយតម្លៃជាបន្តបន្ទាប់ទាំងនេះ រួមមានការវាយតម្លៃកែលម្អរួមទូទៅ ការវាយតម្លៃតាមកម្មវិធីសិក្សានិងការវាយតម្លៃបណ្ដោះអាសន្ន និងចំណុចគោលសម្រាប់មុខវិជ្ជា ELA ការអភិវឌ្ឍ ELD និងគណិតវិទ្យា ដែលបានគ្រប់គ្រងលើវគ្គសិក្សានៃឆ្នាំសិក្សា2020-2021។ ទិន្នន័យស្ទង់មតិលើបរិយាកាសសាលា ក៏នឹងយកមកពិចារណាផងដែរនៅក្នុងការវាស់ស្ទង់ប្រសិទ្ធភាពនៃសេវាកម្ម និងការគាំទ្រដែលផ្ដល់ជូនដល់សិស្ស។

## វិធានការដើម្បីដោះស្រាយបញ្ហាការបាត់បង់ការសិក្សារបស់សិស្ស [តារាងជួរផ្ដេក និងវិធានការបន្ថែម អាចនឹងត្រូវបានដាក់បន្ថែមទៀត ទៅតាមការចាំបាច់]

| ពិពណ៌នា | មូលនិធិសរុប | ការបែងចែក |
|---|---|---|
| ការបង្រៀនក្រោយម៉ោងសិក្សា ជំនួយកិច្ចការលំហាត់ផ្ទះ និងសកម្មភាពពង្រឹងសមត្ថភាពដែលបានផ្ដល់ជូនតាមរយៈប្រព័ន្ធកម្មវិធីសិក្សាពីចម្ងាយ (PLL-1) | $2,222,825 | បាទ/ចាស |
| កម្មវិធីអន្តរាគមន៍អំណាន មានឈ្មោះថា Read 180 បានផ្ដល់ជូនដល់សិស្សដែលមានតម្រូវការពិសេស ដើម្បីដោះស្រាយបញ្ហាតម្រូវការសម្រាប់ការទទួលបានចំណេះដឹងអក្ខរកម្ម និងបំណិនសំណេរតាមដំណាក់កាល (PLL-2) | $115,248 | បាទ/ចាស |
| កម្មវិធីបំពេញក្រេឌីតនិងបប៉ិនអ្នកបោះបង់ការសិក្សានៅវិទ្យាល័យ បានផ្ដល់ជូនដល់សិស្សវិទ្យាល័យគ្រប់រូបទាំងអស់ ជាមួយនឹងការផ្ដោតលើសិស្សថ្នាក់ទីដប់មួយ និងសិស្សថ្នាក់ទីដប់ពីរ ដែលត្រូវការទទួលបានឱកាសបំពេញក្រេឌីត។ (PLL-3) | $885,732 | បាទ/ចាស |
| កម្មវិធីសិក្សាតាមអ៊ីនធឺណិតសិក្សានៅរដូវក្ដៅ ដំណើការដោយទីតាំងសាលារៀននៅក្នុងមណ្ឌលសិក្សាធិការ SUSD ទាំងមូល។ (PLL-4) | $485,168 | បាទ/ចាស |

| ពិពណ៌នា | មូលនិធិសរុប | ការបែងចែក |
|---|---|---|
| គ្រូណែនាំការបង្រៀនដើម្បីគាំទ្រដល់ការរួមបញ្ចូលនៃការគាំទ្រផ្អែកតាមការសិក្សាស្រាវជ្រាវក្នុងការផ្តល់ជូនការបង្រៀនដែលផ្តោតលើគុណភាពខ្ពស់ជាចម្បង អំឡុងការសិក្សាពីចម្ងាយ និងវគ្គបង្រៀនដោយផ្ទាល់។ (PLL-5) | $6,960,631 | បាទ/ចាស |
| រក្សាស្ថិរភាពកម្មវិធីលើកកម្ពស់ការរីកចម្រើនតាមរយៈការកំណត់លើបុគ្គល (Advancement via Individual Determination, AVID) នៅក្នុងការគាំទ្រដល់ការផ្តល់កម្មវិធីផ្អែកលើការស្រាវជ្រាវ ដែលរួមបញ្ចូលនូវគំរូប្រព័ន្ធ វប្បធម៌ ការបង្រៀន និងទំនាក់ទំនងសម្រាប់គ្រូនិងសិស្សក្នុងការចូលរួមក្នុងជំនាញនៃការសរសេរ សំណួរ កិច្ចសហការ ការរៀបចំ និងការអាន ដែលផ្តោតលើការរៀបចំសិស្សជំនាន់ទីមួយនៅក្នុងគ្រួសាររបស់ពួកគេដើម្បីបញ្ចប់ការសិក្សាពីវិទ្យាល័យ និងចូលរៀននៅមហាវិទ្យាល័យ។ (PLL-6) | $700,000 | ទេ |

# សុខភាពផ្លូវចិត្ត និងសុខមាលភាពសង្គម និងអារម្មណ៍

[ពិពណ៌នាអំពីរបៀបដែលទីភ្នាក់ងារអប់រំក្នុងមូលដ្ឋាន នឹងត្រួតពិនិត្យ និងទ្រទ្រង់សុខភាពផ្លូវចិត្ត និងសុខមាលភាពសង្គម និងអារម្មណ៍របស់សិស្ស និងបុគ្គលិក ក្នុងអំឡុងពេលនៃឆ្នាំសិក្សា ដោយរួមបញ្ចូលទាំងការអភិវឌ្ឍវិជ្ជាជីវៈ និងធនធានដែលត្រូវបានផ្តល់ជូនដល់សិស្ស និងបុគ្គលិកដើម្បី ប្រឈម ដោះស្រាយសេចក្តី ភ័យរន្ធត់តក់ស្លុត និងឥទ្ធិពលដទៃផ្សេងទៀតរបស់ជំងឺ COVID-19 ទៅលើសហគមន៍សាលារៀន]

រាល់ជំនួយគាំទ្រ និងសេវាសុខភាពផ្លូវចិត្ត និងសុខមាលភាពសង្គម និងអារម្មណ៍ទាំងអស់ ដែលត្រូវបានផ្តល់ជូនសិស្ស គ្រួសារ និងបុគ្គលិក ត្រូវបាន ផ្តល់ជូនដោយផ្ទាល់ដោយមានវត្តមានអ្នកទាំងនោះ និងត្រូវបានផ្តល់ជូនពីចម្ងាយ (ការថែទាំសុខភាពពីចម្ងាយ)។ ជំនួយគាំទ្រ ត្រូវបានផ្តល់ តាមរយៈប្រព័ន្ធដែលមានច្រើនជាន់ថ្នាក់ ដែលមានចាប់តាំងពីជំនួយគាំទ្រទូទៅដែលសិស្សទាំងអស់អាចទទួលផលប្រយោជន៍បានពីជំនួយគាំទ្របែបនោះ រហូតទៅដល់ជំនួយគាំទ្រខ្លាំង ក្លាដែលមានលក្ខណៈបុគ្គល និងមានលក្ខណៈពិសេសដាច់ដោយឡែកសម្រាប់សិស្ស និងត្រូវបានបង្កើតឡើងសម្រាប់តម្រូវការជាក់លាក់។ ការស្ទង់មតិត្រូវបាន ធ្វើឡើងចំពោះសិស្ស បុគ្គលិក និងគ្រួសាររបស់ពួកគេ ដើម្បីកំណត់នូវតម្រូវការផ្នែកសុខមាលភាពរបស់ពួក គេដែលត្រូវបានបន្សីជាមួយ សុខភាពផ្លូវចិត្ត។ ការទំនាក់ទំនងរបស់ថ្នាក់ដឹកនាំ នឹងត្រូវធ្វើឡើងជាមួយនាយកដ្ឋាន ផ្សេងៗគ្នាជាច្រើន និងក្នុងវិស័យផ្សេងៗជាច្រើនដើម្បីត្រួតពិនិត្យ និងសម្របសម្រួលការ សិក្សាផ្នែកសង្គម និងអារម្មណ៍ សុខភាពផ្លូវចិត្ត និងធនធាន និងជំនួយគាំទ្រផ្នែកអាកប្បកិរិយា។ កិច្ចអន្តរាគមន៍ និងជំនួយគាំទ្រដែល ធ្វើឲ្យមានអាកប្បកិរិយា វិជ្ជមាន (PBIS) ត្រូវបានផ្តល់ជូនទីតាំងសាលារៀនតាមរយៈមេរៀនស្តីពីការសិក្សាផ្នែក សង្គម និងអារម្មណ៍ ការយល់ដឹងអំពីសុខភាព ផ្លូវចិត្ត គ្រូបណ្តុះបណ្តាល អំពីកិច្ចអន្តរាគមន៍ និងជំនួយគាំទ្រដែលធ្វើឲ្យមានអាកប្បកិរិយាវិជ្ជមាន ត្រូវបានចាត់តាំងឲ្យមានវត្តមាននៅតាមសាលារៀនដើម្បី ជួយតម្រង់ទិសដៅ និងត្រួត ពិនិត្យជំនួយគាំទ្រនានា និងផ្តល់ការបណ្តុះបណ្តាលស្តីពីការបង្កើតវប្បធម៌សាលារៀននៅក្នុងបរិបទនៃការសិក្សាពីចម្ងាយ ដែល វប្បធម៌នេះនឹងបណ្តុះ និងពង្រឹង នូវទំនាក់ទំនងជាមួយសិស្សទាំងអស់ ព្រមទាំងបង្កើតបរិយាកាសមួយដែលមានសុវត្ថិភាព និងពោរពេញដោយក្តីគោរព សម្រាប់សិស្សទាំងអស់ ដោយទន្ទឹមគ្នា នោះធ្វើការវាយតម្លៃជាប្រចាំអំពីជំនួយគាំទ្រដែលគេត្រូវការ។ គ្រូពេទ្យឯកទេស សុខភាពផ្លូវចិត្ត និងមនុស្សបង្គោល ដែលផ្តល់ជំនួយគាំទ្រផ្នែកអាកប្បកិរិយា ត្រូវ បានចាត់តាំងឲ្យបំពេញការងារនៅតាមទីតាំងសាលារៀននីមួយៗ ដើម្បីជួយត្រួតពិនិត្យ និងតម្រង់ទិសដៅនៃ ជំនួយគាំទ្រសុខភាពផ្លូវចិត្ត។ ពិធីសារស្តីពីវិបត្តិសុខភាពផ្លូវចិត្តនៅទូទាំងស្រុក ត្រូវបានបង្កើតឡើងដើម្បីផ្តល់ការបណ្តុះបណ្តាល  ស្តីពីពិធីសារឆ្លើយតប ចំពោះវិបត្តិសុខភាពផ្លូវចិត្ត ជូនដល់ប្រធានទីតាំងអ្នកគ្រប់គ្រង និងបុគ្គលិកផ្តល់សេវាសិស្ស។ បុគ្គលិកផ្នែកសុខភាពផ្លូវចិត្ត និងផ្តល់ជំនួយគាំទ្រផ្នែក អាកប្បកិរិយា តាមរយៈការពិគ្រោះយោបល់ និងការសហការបាន ផ្តល់ការណែនាំដល់ទីតាំងសាលារៀននានាពាក់ព័ន្ធនឹងប្រព័ន្ធសុខភាពផ្លូវចិត្ត និងប្រព័ន្ធ គាំទ្រអាកប្បកិរិយាដែលមានស្រាប់ ដើម្បីធ្វើការឆ្លើយតបផ្នែកថែទាំ សុខភាពដែលមានការយល់ដឹងអំពីសេចក្តីភ័យរន្ធត់តក់ស្លុត សម្រាប់សិស្ស បុគ្គលិក និងគ្រួសារ ព្រមទាំងបានចូលរួមក្នុងប្រព័ន្ធត្រួតពិនិត្យ ការចុះឈ្មោះចូល និងការចុះឈ្មោះចេញរបស់ទីតាំងសាលារៀន និងបានត្រួតពិនិត្យយ៉ាងសកម្មនូវ ទំនាក់ទំនងទាំងនេះជាមួយ សិស្សដើម្បីស្វែងយល់អំពីតម្រូវការបន្ថែមទៀត និងការព្រួយបារម្ភដែលមានសក្តានុពលនានា ដើម្បីផ្តល់ឱកាសអន្តរាគមន៍ បន្ថែមទៀត។ ការវាយតម្លៃសុខភាពផ្លូវចិត្ត និងអាកប្បកិរិយារបស់សិស្សម្នាក់ៗ ត្រូវបានធ្វើឡើង កិច្ចប្រជុំស្តីពីការកំណត់អាទិភាពនៃការព្យាបាលជាមួយ ក្រុមសិស្សដើម្បី វាយតម្លៃអំពីប្រសិទ្ធភាពនៃការអន្តរាគមន៍ និងពិនិត្យវាយតម្លៃឡើងវិញនូវ តម្រូវការជំនួយគាំទ្របន្ថែមសម្រាប់សិស្ស ត្រូវបានរៀបចំឡើង ហើយសេវាផ្ទាល់ត្រូវបានផ្តល់ជូនតាមរយៈការព្យាបាលជាលក្ខណៈបុគ្គល និងជាក្រុម ហើយសេវាកែលម្អអាកប្បកិរិយាដ៏ខ្លាំងក្លា ដែលជួយគាំទ្រគ្រួសារ សិស្ស និងទីតាំងសិក្សាក្នុងអំឡុងពេលបញ្ចប់ឆ្នាំសិក្សា2019-2020 ពេញមួយអំឡុងពេលនៃរដូវ ក្តៅ ហើយនឹងបន្តក្នុងអំឡុងពេលនៃឆ្នាំសិក្សា2020-2021។
ពេញមួយអំឡុងពេលនៃឆ្នាំសិក្សា សេវាផ្ទាល់ ការទទួលបានការព្យាបាលជាលក្ខណៈបុគ្គល និងជា ក្រុម ព័ត៌មានសម្រាប់ធ្វើការទំនាក់ទំនង និងការហៅទូរសព្ទដើម្បីសាកសួរទៅកាន់សិស្ស បុគ្គលិក និងគ្រួសារ ធនធាន សិក្ខាសាលាសម្រាប់គ្រួសារ សិក្ខាសាលា និងវគ្គបណ្តុះបណ្តាលផ្តល់ធនធានដែលមានឈ្មោះថា ‘Insta-Coffee Chats’  ដែលត្រូវបានថតទុក ការវាយតម្លៃ ការសម្របសម្រួលជាមួយទីភ្នាក់ងារខាងក្រៅ ការត្រួត ពិនិត្យជាប្រចាំអំពីតម្រូវការផ្នែកសុខភាពផ្លូវចិត្ត ការផ្សព្វផ្សាយជាមុនទៅកាន់សហគមន៍ និងការឆ្លើយតបចំពោះវិបត្តិសុខភាពផ្លូវចិត្ត នឹងត្រូវផ្តល់ជូន ទៅ ដល់សិស្ស គ្រួសារ និងបុគ្គលិក។ នាយកដ្ឋានសុខភាពផ្លូវចិត្ត និងទ្រទ្រង់អាកប្បកិរិយា បន្តផ្តោតការយកចិត្តទុកដាក់ទៅលើការពង្រឹងសុខភាព ផ្លូវចិត្ត និងលើកកម្ពស់ការយល់ដឹងផ្នែកសង្គម និងអារម្មណ៍ និងពង្រឹងសុខុមាលភាពផ្នែកអារម្មណ៍របស់បុគ្គលិកស្រុក។ ការអភិវឌ្ឍវិជ្ជាជីវៈ ការ បណ្តុះបណ្តាល និងធនធាន

ត្រូវបានផ្តល់ជូន និងនៅតែបន្តផ្តល់ជូនពេញមួយអំឡុងពេលនៃឆ្នាំនោះ។ ឱកាសអភិវឌ្ឍវិជ្ជាជីវៈ ត្រូវបានកែសម្រួល និងអាចត្រូវកែសម្រួលដើម្បីគ្របដណ្តប់លើគ្រប់ទិដ្ឋភាពទាំងអស់នៃតម្រូវការរបស់បុគ្គលិក សិស្ស និងគ្រួសារ ដែលពាក់ព័ន្ធនឹងការបង្រៀនដែល សិស្សមានវត្តមានផ្ទាល់ ការសិក្សាពីចម្ងាយ និងការសិក្សា តាមរបៀបចម្រុះលាយបញ្ចូលគ្នា។ ការអភិវឌ្ឍវិជ្ជាជីវៈដែលត្រូវបានផ្តល់ជូន មានដូចជា ការបណ្តុះបណ្តាលស្តីពីថ្នាក់រៀនដែលឆ្លើយតបចំពោះសេចក្តីភ័យរន្ធត់តក់ស្លុត យុទ្ធសាស្ត្រ ជាក់ស្តែងដើម្បីប្រឈមដោះស្រាយចំពោះរោគសញ្ញា សុខភាពផ្លូវចិត្តទូទៅនៅក្នុងថ្នាក់រៀន ការអន្តរាគមន៍ព្យាបាល ការគ្រប់គ្រងវិបត្តិ និងគំរូនៃអារម្មណ៍តានតឹង ព្រឹត្តិបត្រព័ត៌មានសុខភាពផ្លូវចិត្តប្រចាំ ខែ មូលដ្ឋានគ្រឹះនៃការអប់រំដែលមានការយល់ដឹងអំពីសេចក្តីភ័យរន្ធត់តក់ស្លុត ការសិក្សាផ្នែកសង្គម និងអារម្មណ៍ និងការគ្រប់គ្រងខ្លួនឯងសម្រាប់ គ្រូមត្តេយ្យ ការបណ្តុះបណ្តាលដែលមានការយល់ដឹងអំពីសេចក្តីភ័យរន្ធត់តក់ស្លុត សម្រាប់អ្នកសម្របសម្រួល កម្មវិធីក្រោយពេលចេញពីសាលា រៀន និងការសង្គ្រោះបឋមផ្នែកសុខភាពផ្លូវចិត្តសម្រាប់យុវជន។ ឱកាសនៃការអភិវឌ្ឍវិជ្ជាជីវៈដែលនឹងត្រូវផ្តល់ជូន មានដូចជា ព្រឹត្តិបត្រព័ត៌មាន សុខភាពផ្លូវចិត្តប្រចាំខែ មូលដ្ឋានគ្រឹះនៃការអប់រំដែលមានការយល់ដឹងអំពីសេចក្តីភ័យរន្ធត់តក់ស្លុត កាបណ្តុះបណ្តាលដែលមានការយល់ដឹង អំពី សេចក្តីភ័យរន្ធត់តក់ស្លុត សម្រាប់គ្រួសារដែលកំពុងផ្លាស់ប្តូរ និងបុគ្គលិកផ្នែកយុវជនដែលរស់នៅក្នុងមណ្ឌលកុមារកំព្រា ថ្ងៃចន្ទយល់ដឹងការវិល ត្រលប់មកកាន់សាលារៀនដោយមានការយល់ដឹងអំពីសេចក្តីភ័យរន្ធត់តក់ស្លុត វីដេអូនៅលើប៉ុស្តិ៍យូធូបសម្រាប់ភាគីពាក់ព័ន្ធចូលទស្សនានៅពេល ណាក៏ដោយ ការបណ្តុះបណ្តាលអំពីបំណិនគ្រប់គ្រងអារម្មណ៍ សេចក្តីគោរពផ្នែកវប្បធម៌ដោយមានការយល់ដឹងខាងផ្នែកវេជ្ជសាស្ត្រ ម៉ោងបំពេញ ការងារសម្រាប់ភាគីពាក់ព័ន្ធជួបពិភាក្សាជាមួយគ្រូពេទ្យដោយផ្ទាល់ និងទទួលបានចម្លើយចំពោះសំណួររបស់ពួកគេ និងការបង្ហាញជាក់លាក់នៃ ទីតាំងសាលារៀន ដែលឆ្លើយតបទៅនឹងចំនួនសិស្សដែលកំពុងទទួលសេវានៅនឹងទីតាំងសាលារៀននោះ។

អ្នកផ្តល់ប្រឹក្សាយោបល់របស់សាលារៀន ដោះស្រាយបញ្ហាសុខមាលភាពសង្គម និងអារម្មណ៍របស់សិស្ស ដោយដឹកនាំការបង្រៀន (តាមបែបទូរ និម្មិត្ត និងដោយផ្សាយផ្ទាល់) ដោយគ្របដណ្តប់ទៅលើប្រធានបទផ្សេងៗជាច្រើន ដែលត្រូវបានរៀបចំឲ្យមាននៅពេញមួយអំឡុងពេលនៃឆ្នាំសិក្សា។ កម្មវិធីជំនួយគាំទ្រដែលមានច្រើនជាន់ថ្នាក់សម្រាប់សិស្ស (SAP) គឺជាប្រព័ន្ធដែលអ្នកប្រឹក្សាយោបល់របស់សាលាប្រើប្រាស់ដើម្បីត្រួតពិនិត្យមើលតម្រូវ ការរបស់សិស្ស ដោយរួមទាំងសុខមាលភាពសង្គម និងអារម្មណ៍របស់ពួកគេផងដែរ។ កម្រិតជាន់ថ្នាក់របស់កម្មវិធី SAP ដែលមានការបញ្ជូនបន្ត និងការ ប្រឹក្សាយោបល់ការព្រួយបារម្ភ ការវាយតម្លៃ ការឆ្លើយតប ក្រុមវាយតម្លៃ និងក្រុមជួយគាំទ្រសិស្ស នឹងបន្តអនុវត្ត ក្នុងអំឡុងពេលនៃការសិក្សាពីចម្ងាយ ដើម្បីអនុញ្ញាតឲ្យគ្រូអាចបន្តផ្តល់ព័ត៌មានអំពីការព្រួយបារម្ភរបស់ពួកគេទៅដល់អ្នកប្រឹក្សាយោបល់របស់សាលា ដើម្បីឲ្យការអន្តរាគមន៍/ជំនួយគាំទ្រអាចត្រូវផ្តល់ជូនសិស្សទាំងនោះ។ ក្នុងអំឡុងពេលនៃការសិក្សាពីចម្ងាយ សកម្មភាព របស់សិស្សនៅលើបណ្តាញអ៊ីនធឺណិត ត្រូវបានត្រួតពិនិត្យដោយ ស្រុក ហើយនៅពេលដែលប្រព័ន្ធអេឡិចត្រូនិក រកឃើញនូវសញ្ញានៃបញ្ហាអ្នកប្រឹក្សាយោបល់ របស់សាលា នឹងត្រូវផ្តល់ដំណឹងជូន ហើយពួកគេធ្វើការទំនាក់ទំនងជាមួយសិស្ស និងគ្រួសារដើម្បីធ្វើការត្រួតពិនិត្យ ដោយផ្តល់ជំនួយគាំទ្រផ្នែកគ្រប់គ្រងអារម្មណ៍តានតឹង ការដោះស្រាយជម្លោះ ការស៊ើបអង្កេតអំពីការគំរាមកំហែង ឬកិច្ចអន្តរាគមន៍បង្ការអត្តឃាត ប្រសិនបើចាំបាច់។ អ្នកប្រឹក្សាយោបល់របស់សាលាផ្តល់ជូន នូវម៉ោងញ៉ាំកាហ្វេជាមួយមាតាបិតា (តាមបែបទូរនិម្មិត្ត និងដោយផ្សាយផ្ទាល់) ដើម្បីជួយគាំទ្រមាតាបិតា និងផ្តល់ឱកាសឲ្យមាតាបិតា បញ្ចេញមតិយោបល់ និងដើម្បីផ្តល់ជំនួយគាំទ្រដល់មាតាបិតា ដែលមានការព្រួយបារម្ភចំពោះកូនៗរបស់ពួកគេ។ អ្នកប្រឹក្សាយោបល់របស់សាលាចូលរួមក្នុងកិច្ចប្រជុំនៅនឹងទីតាំង និងត្រូវបានលើកទឹកចិត្តឲ្យផ្តល់ជូនដល់បុគ្គលិកនូវយុទ្ធសាស្ត្រថែទាំខ្លួនឯង។ យើងនឹងបន្តត្រួតពិនិត្យ ទិន្នន័យនៃការស្ទង់មតិអំពីបរិយាកាសសាលារៀនដែលមានឈ្មោះថា មិត្តភក្តិបង្រួបបង្រួមសិស្ស និងការស្ទង់មតិស្តីពីកុមារដែលមានសុខភាពល្អ ហើយនឹងផ្តល់ជូននូវការវាយតម្លៃអំពីតម្រូវការជូនទៅដល់សិស្ស និងបុគ្គលិកជាទៀងទាត់។ អ្នកប្រឹក្សាយោបល់របស់សាលានឹងបន្តផ្តល់ការអភិវឌ្ឍវិជ្ជាជីវៈជូនដល់បុគ្គលិក ស្តីពីប្រធានបទសង្គម និងអារម្មណ៍ដែលរួមបញ្ចូលការបង្រៀនដែលមានការយល់ដឹងអំពីសេចក្តីភ័យរន្ធត់តក់ស្លុត និងយុទ្ធសាស្ត្រគ្រប់គ្រងថ្នាក់រៀន ការអនុវត្តពង្រឹង កម្លាំងចិត្តឡើងវិញ និងការថែទាំខ្លួនឯង។ អ្នកប្រឹក្សាយោបល់ របស់សាលា នឹងបន្តផ្តល់ជំនួយគាំទ្រចំពោះសុខមាលភាពរបស់បុគ្គលិករបស់យើង តាមរយៈវិធីសាស្ត្រដូចខាងក្រោម៖ ការវាយតម្លៃអំពីតម្រូវការរបស់បុគ្គលិក កញ្ចប់ស្វាគមន៍ការត្រឡប់មកវិញ សកម្មភាពកសាងបរិយាកាសបុគ្គលិក និងកសាងសហគមន៍ ព្រមទាំងផ្តល់នូវការអភិវឌ្ឍបុគ្គលិក។ ប្រក្រតិទិននៃព្រឹត្តិការណ៍នៃការបង្ការ និងការយល់ដឹងរបស់អ្នកប្រឹក្សាយោបល់របស់ សាលា និងកម្មវិធីមិត្តភក្តិបង្រួបបង្រួមសិស្ស ក៏រួមបញ្ចូលនូវជំនួយគាំទ្រផ្នែកសង្គម និងអារម្មណ៍ជាច្រើនដូចជា៖ ចរិតលក្ខណៈប្រចាំខែ ខែស្តីពីការ យល់ដឹង និងវត្តមាន ខែបង្ការអត្តឃាត ខែប្រឆាំងការសម្លុតគម្រាម និងទិវាសាមគ្គីភាព ទិវាពុំមានអ្នកណាម្នាក់ញ៉ាំអាហារម្នាក់ឯង និងព្រឹត្តិការណ៍បង្ការទប់ស្កាត់ការប្រើប្រាស់គ្រឿងស្រវឹង ថ្នាំជក់ និងគ្រឿងញៀនដទៃទៀត។ ព្រឹត្តិការណ៍ទាំងនេះផ្តល់ជូននូវវិធីសាស្ត្រដែល ផ្តោតលើសាលា ទាំងមូល និងកុមារទាំងមូលសម្រាប់ពង្រឹងសុខមាលភាព និងការកសាងបរិយាកាសសាលារៀនដែលមានលក្ខណៈវិជ្ជមាន។ ព្រឹត្តិការណ៍បង្ការ ទប់ស្កាត់

និងលើកកម្ពស់ការយល់ដឹងទាំងនេះ នឹងបន្ត តាមបែបទូរនិម្មិត្តតាមរយៈយុទ្ធនាការតាមបណ្តាញសង្គម មេរៀនដែលត្រូវបានថតសកម្មភាព ទូរនិម្មិត និងតាមរយៈយន្តការបែបឆ្នៃប្រឌិតដទៃទៀត។ កម្មវិធីមិត្តភក្តិបង្រួបបង្រួមសិស្ស (PLUS) ដំណើរការដោយផ្អែកលើមូលដ្ឋានដែលថា នៅពេលសិស្សមានអារម្មណ៍ថាខ្លួនគឺជាផ្នែកមួយនៃសាលារៀន មានអារម្មណ៍រីករាយនៅពេលពួកគេស្ថិតនៅក្នុងសាលារៀន មានអារម្មណ៍ថាជាផ្នែកមួយនៃសហគមន៍សាលារៀន មាន អារម្មណ៍ថាត្រូវបានអ្នកដទៃប្រព្រឹត្តចំពោះខ្លួនប្រកបដោយយុត្តិធម៌ និងមានអារម្មណ៍ថាមានសុវត្ថិភាព ទំនាក់ទំនងជាមួយសាលាដែលមានលក្ខណៈវិជ្ជមានទាំងនេះ គឺជាកត្តាបង្ការការពារមួយចំពោះការព្រួយបារម្ភផ្នែកសង្គម និងអារម្មណ៍។ កម្មវិធី PLUS ប្រើប្រាស់សិស្សដែលជាអ្នកដឹកនាំចំនួន 1300នាក់ ដែលត្រូវបានបណ្តុះបណ្តាល ដើម្បីជួយវាយតម្លៃអំពីទំនាក់ទំនងជាមួយសាលារៀន និងបរិយាកាសនៃអារម្មណ៍របស់មិត្តរបស់ពួកគេ។ កម្មវិធីសិក្សា PLUS និងកម្មវិធីសិក្សាតស៊ូមតិរបស់មិត្ត ដែលក្រុម PLUS របស់យើង ប្រើប្រាស់ដើម្បីពង្រឹងលើកកម្ពស់សមត្ថភាពផ្នែកសង្គម និងអារម្មណ៍ ការអនុវត្តដែលមានការយល់ដឹងអំពីសេចក្តីភ័យរន្ធត់តក់ស្លុត ការអនុវត្តនៃការពង្រឹងកម្លាំងចិត្តឡើងវិញ និងវិធីសាស្រ្តបែបផ្លាស់ប្តូរចំពោះការអប់រំ។ កម្មវិធី PLUS ប្រើប្រាស់ ការស្ទង់មតិអំពីបរិយាកាស សាលារៀនបីដងក្នុងមួយឆ្នាំសម្រាប់ សិស្សថ្នាក់ទី4 រហូតដល់ថ្នាក់ទី12 ទាំងអស់ ដើម្បីវាស់វែងតាមបែបបរិមាណវិស័យនូវបទពិសោធន៍របស់សិស្សពាក់ព័ន្ធនឹង អារម្មណ៍ជិតស្និទជា មួយសាលារៀន សុវត្ថិភាពរបស់សាលារៀន និងទិដ្ឋភាពផ្នែកអារម្មណ៍ផ្សេងៗទៀតចំពោះសាលារៀន។ ការស្ទង់មតិទាំងនេះ នឹងត្រូវកែសម្រួលសម្រាប់ ការសិក្សាពីចម្ងាយ និងបរិវេណសាលាទូរនិម្មិត ដើម្បីរួមបញ្ចូលសំណួរស្តីពីបទពិសោធន៍របស់ពួកគេនៅលើបណ្តាញអ៊ីនធឺណិត ទំនាក់ទំនងរបស់ ពួកគេជាមួយមិត្តភក្តិ និងបុគ្គលិកនៅលើបណ្តាញអ៊ីនធឺណិត និងកត្តាដែលពាក់ព័ន្ធនឹងផ្ទះផ្សេងៗទៀតដែលមានផលប៉ះពាល់ទៅលើជោគជ័យផ្នែក សង្គម និងអារម្មណ៍ និងជោគជ័យផ្នែកសិក្សា។ ការស្ទង់មតិ PLUS មិនត្រឹមតែត្រូវបានប្រើប្រាស់ដោយក្រុម PLUS តែប៉ុណ្ណោះទេ តែត្រូវបានប្រើ ប្រាស់ផងដែរដោយក្រុមថ្នាក់ដឹកនាំទីតាំង និងស្រុក ដើម្បីវាយតម្លៃអំពីតម្រូវការរបស់សិស្ស។ ការស្ទង់មតិទាំងនេះ នឹងត្រូវវិភាគតាមបែបយុទ្ធសាស្រ្ត ដោយផ្តោតលើពូជសាសន៍/ជាតិពន្ធុ ស្ថានភាពរស់នៅ ភាសា ភេទ និងកម្រិតថ្នាក់ ដើម្បីកំណត់អំពីតម្រូវការរបស់សិស្សពិសេសរបស់យើង និង ដើម្បីផ្តល់ជូននូវជំនួយគាំទ្រដែលកាន់តែចំគោលដៅជាងមុន។ ក្រុមការងារ PLUS ក៏ប្រើប្រាស់ផងដែរនូវវេទិកា PLUS ធ្វើជាយន្តការមួយសម្រាប់ កសាងសហគមន៍ បង្កើនការជួយគាំទ្ររវាងមិត្តភក្តិ និងប្រមូលទិន្នន័យបែបគុណវិស័យអំពីមតិយោបល់របស់សិស្ស។ ក្រុមរបស់ PLUS ដឹកនាំ មិត្តភក្តិរបស់ពួកគេតាមរយៈកិច្ចដំណើរការពង្រឹងកម្លាំងចិត្តឡើងវិញនៃការកសាងសហគមន៍ ដោយកំណត់អត្តសញ្ញាណបញ្ហាសំខាន់ៗ និងបង្កើត ដំណោះស្រាយដែលដឹកនាំដោយសិស្សសម្រាប់ដោះស្រាយបញ្ហារបស់សិស្ស។ ឱកាសពង្រឹងកម្លាំងចិត្តឡើងវិញទាំងនេះ នឹងបន្តអនុវត្តតាមបែប ទូរនិម្មិត្ត ហើយក្រុម PLUS នឹងបន្តប្រើប្រាស់ទិន្នន័យបែបគុណវិស័យ និងបរិមាណវិស័យ ដើម្បីអនុវត្តសកម្មភាពដែលមានអត្ថន័យដែលអាចដោះ ស្រាយបញ្ហារបស់សិស្ស។ ក្នុងនាមជាអ្នកតស៊ូមតិ និងជាអ្នកអប់រំមិត្ត សិស្សក៏ប្រើប្រាស់ផងដែនូវទម្រង់នៃបណ្តាញសង្គមនានាដើម្បីលើកកម្ពស់ សុខុមាលភាព ការបង្ការទប់ស្កាត់អត្តឃាត ការបង្ការទប់ស្កាត់ការប្រើប្រាស់គ្រឿងស្រវឹង ថ្នាំជក់ និងគ្រឿងញៀនដទៃទៀត ព្រមទាំងដើម្បីកសាង សហគមន៍លើបណ្តាញអ៊ីនធឺណិតដែលពួកគេជាសមាជិករបស់សហគមន៍នោះ។ ក្រុម PLUS គឺជាអ្នកឆ្លើយតបបែបឌីជីថលដំបូង នៅក្នុងបរិវេណសាលាទូរនិម្មិតរបស់យើង។ ពួកគេដឹងអំពីរបៀបស្វែងរក និងរាយការណ៍អំពីបញ្ហាដែលនឹងប៉ះពាល់ដល់សុខុមាលភាពផ្នែកសង្គម និងអារម្មណ៍។ ដើម្បីប្រឈមដោះស្រាយផលប៉ះពាល់របស់ជំងឺ COVID-19 មកលើបុគ្គលិក សិស្ស និងសហគមន៍សាលារៀន នាយកដ្ឋានសេវាទ្រទ្រង់ សិស្សបាន ខិតខំបំពេញការងារដើម្បីធានាថាគេហទំព័ររបស់ស្រុក និងសាលារៀនមានព័ត៌មានថ្មីៗ និងពាក់ព័ន្ធ ដើម្បីជួយសិស្ស គ្រួសារ និងបុគ្គលិក។ សេវាប្រឹក្សាយោបល់ដូចជាការជួបប្រជុំជាក្រុមតូចៗ និងការជួបប្រជុំត្រួតពិនិត្យសុខភាពផ្លូវចិត្ត ព្រមទាំងការបង្រៀនតាមបណ្តាញអ៊ីនធឺណិត ត្រូវ បានបង្កើតឡើង និងដាក់បង្ហាញ សម្រាប់សិស្ស និងគ្រួសារចូលទៅទស្សនា។ បន្ទប់រម្ងាប់អារម្មណ៍តាមបែបទូរនិម្មិត ត្រូវបានបង្កើតឡើងសម្រាប់អ្នកណាក៏ដោយដែលកំពុងត្រូវការទីកន្លែងដែលមានការយល់ដឹងអំពីសេចក្តីភ័យរន្ធត់តក់ស្លុតតាមបែបទូរនិម្មិត។ សេវានានាត្រូវបានកែសម្រួលដើម្បីធានាថាធនធាន អាចនឹងត្រូវទទួលបានដើម្បីបំពេញតាមតម្រូវការរបស់គ្រួសារក្នុងអំឡុងពេលនៃការសិក្សាពីចម្ងាយ និងធានាថា សិស្សទាំងឡាយទទួលបានជំនួយគាំទ្រផ្នែកសង្គម និងអារម្មណ៍ដែលចាំបាច់នៅក្នុងអំឡុងពេលនៃភាពឯកោ និងពេលដ៏លំបាកនេះ។ នាយកដ្ឋានទ្រទ្រង់សិស្សបានបង្កើតគេហទំព័រមួយ និងលេខទូរសព្ទផ្តល់ជំនួយមួយ ដើម្បីផ្តល់ភាពងាយស្រួលក្នុងការទទួលបានធនធានរបស់សាលារៀន និងសហគមន៍សម្រាប់បំពេញសេចក្តីត្រូវការជាមូលដ្ឋាននានា ជំនួយគាំទ្រផ្នែកសិក្សា និងសុខភាពផ្លូវចិត្ត ជាពិសេសចម្លើយតបបន្ទាន់ និងទាន់ពេលវេលាដែលចាំបាច់នៅពេលសិស្សបង្ហាញថាពួកគេកំពុងមានវិបត្តិ និងបានបំពេញការងារដើម្បីទំនាក់ទំនងទៅកាន់សិស្សដែលមិនបានចូលរួមជាមួយការសិក្សាពីចម្ងាយដោយសារហេតុផលជាច្រើន។ លេខទូរសព្ទផ្តល់ជំនួយដែលត្រូវបានបង្កើតឡើងដោយស្រុក ដើម្បីជួយឲ្យមាតាបិតាអាចជួបពិភាក្សាជាមួយអ្នក ផ្តល់ប្រឹក្សាយោបល់របស់សាលា និងគ្រូពេទ្យសុខភាពផ្លូវចិត្ត ព្រមទាំងទទួលបានជំនួយគាំទ្រផ្នែកបច្ចេកទេស ពិតជាមានប្រសិទ្ធភាពយ៉ាងខ្លាំង

ដោយមាតាបិតាជាច្រើនបានទូរសព្ទចូលមកក្នុងមួយថ្ងៃៗដើម្បីស្វែងរកជំនួយគាំទ្រដែលពួកគេត្រូវការ។ អ្នកផ្តល់ប្រឹក្សាយោបល់របស់សាលាក៏បានខិតខំប្រឹងប្រែងបំពេញការងារដើម្បីបង្កើតធនធាននៅលើបណ្តាញអ៊ីនធឺណិត ដោយបានធ្វើបច្ចុប្បន្នភាពទំព័រប្រឹក្សាយោបល់ និងធនធាននៅលើគេហទំព័ររបស់សាលារៀន ដោយបង្កើត ឬធ្វើបច្ចុប្បន្នភាពថ្នាក់រៀនហ្គូគហ្គល (Google Classrooms) និងបង្កើតលេខទូរសព្ទ ឬម៉ោងការងារ ឬប្រព័ន្ធផ្សេងទៀត ដើម្បីផ្តល់ឱកាសឲ្យមាតាបិតា និងសិស្សអាចទទួលបានជំនួយគាំទ្រ។ ជាញឹកញាប់អ្នកផ្តល់ប្រឹក្សាយោបល់របស់សាលារៀនដើរតួជាមជ្ឈមណ្ឌលធនធានតែមួយសម្រាប់មាតាបិតា ដោយផ្តល់ជំនួយគាំទ្រគ្រប់យ៉ាងទាំងអស់ដល់គ្រួសារ ដោយរាប់ចាប់តាំងពីអាហារថ្ងៃត្រង់នៅសាលារៀន រហូតដល់បច្ចេកវិទ្យាធនធានសុខាភិបាល និងសុវត្ថិភាព បន្ថែមទៅលើជំនួយគាំទ្រផ្នែកសិក្សា និងសង្គម។ អ្នកផ្តល់ប្រឹក្សាយោបល់របស់សាលា ក៏ឆ្លើយតបផងដែរចំពោះសញ្ញាព្រមានបែបឌីជីថល និងធ្វើការទំនាក់ទំនងដើម្បីត្រួតពិនិត្យជាមួយសិស្ស និងគ្រួសារ ដោយរួមទាំងការហៅទូរសព្ទដើម្បីពិនិត្យផ្ទៀងផ្ទាត់ការជួយគាំទ្រលើការគ្រប់គ្រងអារម្មណ៍តានតឹង ការដោះស្រាយជម្លោះ ការស៊ើបអង្កេតអំពីការ គំរាមកំហែង និងការអន្តរាគមន៍បង្ការអត្តឃាត។ ក្នុងអំឡុងពេលនៃការសិក្សាពីចម្ងាយ អ្នកផ្តល់ប្រឹក្សាយោបល់របស់សាលា បន្តផានាឲ្យមានជំនួយ គាំទ្រដល់សិស្ស និងទីតាំងពាក់ព័ន្ធនឹងការសិក្សាផ្នែកសង្គម និងអារម្មណ៍ជោគជ័យផ្នែកសិក្សា និងការអភិវឌ្ឍនៅមហាវិទ្យាល័យ/ការអភិវឌ្ឍអាជីព និងភាពត្រៀមខ្លួនសម្រាប់អភិវឌ្ឍផ្នត់គំនិត និងអាកប្បកិរិយាដែលសិស្សត្រូវការដើម្បីសម្រេចជោគជ័យ។ អ្នកផ្តល់ប្រឹក្សាយោបល់របស់សាលាបានចូលរួមជាមួយគ្រូដើម្បីធ្វើបទបង្ហាញមេរៀនស្តីពីការគ្រប់គ្រងអារម្មណ៍តានតឹង និងការថែទាំខ្លួនឯង បង្កើតសកម្មភាព "ក្រុមអាហារថ្ងៃត្រង់" នៅលើបណ្តាញអ៊ីនធឺណិត ដើម្បីផ្តល់នូវការទំនាក់ទំនងសង្គមដែលគេត្រូវការយ៉ាងខ្លាំង និងសម្របសម្រួលម៉ោងពិសាកាហ្វេជាមួយមាតាបិតាតាមបែបទូរនិម្មិតដើម្បីផ្តល់ជំនួយគាំទ្រដល់មាតាបិតាផងដែរ។ អ្នកផ្តល់ប្រឹក្សាយោបល់របស់សាលា បានចាប់ដៃគូនៅទូទាំងស្រុកដើម្បីបង្កើតមេរៀនជាវីដេអូស្តីពីការថែទាំខ្លួនឯង សម្រាប់ការសិក្សានៅតាមផ្ទះ និងការត្រៀមខ្លួនសម្រាប់ចូលមហាវិទ្យាល័យ។ អ្នកផ្តល់ប្រឹក្សាយោបល់បានធ្វើកិច្ចការជាមួយសិស្សដែលនឹងបញ្ចប់ការសិក្សាស្តីពីការបញ្ចប់ជំនួយហិរញ្ញវត្ថុ និងលក្ខខណ្ឌតម្រូវសម្រាប់ចូលរៀននៅមហាវិទ្យាល័យ និងការត្រៀមខ្លួនសម្រាប់ការចូលទៅកាន់មហាវិទ្យាល័យ។ អ្នកផ្តល់ប្រឹក្សាយោបល់របស់សាលាបានធ្វើការជាមួយក្រុមការងាររបស់សាលារៀន ដើម្បីបង្កើតពិធីទូរនិម្មិតដើម្បី ទទួលស្គាល់និងអបអរសិស្សមត្តេយ្យ សិស្សថ្នាក់ទី8 និងការចាប់ផ្តើមថ្នាក់វិទ្យាល័យ និងការបញ្ចប់ការសិក្សានៅដំណាច់ឆ្នាំសិក្សា2019-2020 និងបន្តធ្វើផែនការយុទ្ធសាស្ត្រក្នុងការបង្កើតព្រឹត្តិការណ៍សង្គមពាក់ព័ន្ធនឹងសុខុមាលភាពសម្រាប់សិស្សនៅក្នុងឆ្នាំសិក្សា2020-2021។

# ការចូលរួមរបស់សិស្ស និងការផ្តល់សេវាទៅដល់សហគមន៍

[ពិពណ៌នាអំពីការចូលរួមរបស់សិស្ស និងការផ្តល់សេវាទៅដល់សហគមន៍ ដោយរួមទាំងនិតិវិធីស្តីពីយុទ្ធសាស្ត្រដែលមានច្រើនជាន់ថ្នាក់ដើម្បីធ្វើឲ្យមានការចូលរួមឡើងវិញសម្រាប់សិស្សដែលមិនមានវត្តមានក្នុងការសិក្សាពីចម្ងាយ និងរបៀបដែលទីភ្នាក់ងារអប់រំក្នុងមូលដ្ឋាន នឹងផ្តល់សេវាទៅដល់សហគមន៍ជូនដល់សិស្ស និងមាតាបិតា ឬអាណាព្យាបាលរបស់ពួកគេ ដោយធ្វើឡើងជាភាសាដទៃផ្សេងទៀតក្រៅពីភាសាអង់គ្លេស នៅពេលដែលសិស្សមិនអាចបំពេញតាមលក្ខខណ្ឌតម្រូវផ្នែកអប់រំ ឬប្រសិនបើទីភ្នាក់ងារអប់រំក្នុងមូលដ្ឋានកំណត់ថាសិស្សទាំងនោះមិនបានចូលរួមក្នុងការសិក្សា និងកំពុងមានហានិភ័យក្នុងការបាត់បង់ការសិក្សា។]

ការចូលរួមរបស់សិស្ស និងការផ្តល់សេវាទៅដល់សហគមន៍របស់ SUSD ជាលក្ខណៈយុទ្ធសាស្ត្រ បានរួមបញ្ចូលនូវអនុសាសន៍ និងការណែនាំរបស់ ការិយាល័យអប់រំ និងសុខាភិបាលសាធារណៈរបស់សហព័ន្ធ រដ្ឋ និងតំបន់ ដោយអនុលោមតាមច្បាប់លេខ77 របស់សភារដ្ឋ និងច្បាប់លេខ98 របស់ព្រឹទ្ធសភា។ វិធានការស្តីពីការចូលរួមរបស់សិស្ស និងការផ្តល់សេវាទៅដល់សហគមន៍ ផ្តោតទៅលើការបំពេញតាមសេចក្តីត្រូវការផ្សេងៗគ្នាដែលមានលក្ខណៈបុគ្គលរបស់យុវជនដែលរស់នៅក្នុងមណ្ឌលកុមារកំព្រា គ្រួសារដែលកំពុងផ្លាស់ប្តូរ គ្រួសារដែលមានប្រាក់ចំណូលទាប អ្នកសិក្សាភាសា អង់គ្លេស និងសិស្សដែលមានតម្រូវការពិសេស តាមរយៈវិធីសាស្ត្រមួយដែលប្រកបដោយសមធម៌ និងដែលផ្តោតលើដំណោះស្រាយ ក្នុងការកសាង ភាពជាដៃគូជាមួយសិស្ស និងគ្រួសារ ដែលផ្តោតលើការសម្រេចបាននូវសេចក្តីរំពឹងដែលថាយើងចង់បាន និងត្រូវការឲ្យសិស្សមានវត្តមាន និងចូលរួមក្នុងការសិក្សារៀនសូត្រជារៀងរាល់ថ្ងៃ។ សេចក្តីរំពឹងទុកទាំងនេះ ត្រូវបានផ្សព្វផ្សាយតាមបែបមជ្ឈការដោយថ្នាក់ដឹកនាំកណ្តាលរបស់ SUSD និងថ្នាក់ដឹកនាំរបស់ទីតាំងសាលា ដោយវត្តមាន និងការចូលរួមប្រចាំថ្ងៃរបស់សិស្ស និងគ្រួសាររបស់ពួកគេ ត្រូវបានរាយការណ៍សម្រាប់ការចូលរួម

របស់សិស្សទាំងនៅក្នុងការសិក្សាទន្ទឹមពេលជាមួយគ្នា និងខុសពេលគ្នា។ គ្រូកត់ត្រាវត្តមានប្រចាំថ្ងៃ និងការចូលរួមនៅរៀងរាល់ថ្ងៃសិក្សាសម្រាប់រយៈពេលសិក្សាដែលត្រូវបានកំណត់នីមួយៗ នៅក្នុងទម្រង់គំរូសិក្សាដែលត្រូវបានអនុវត្តក្នុងអំឡុងពេលពេញមួយឆ្នាំសិក្សា2020-2021។ ប្រសិនបើសិស្សណាម្នាក់មិនមានវត្តមាននៅក្នុងពេលសិក្សាណាមួយ ការហៅទូរសព្ទដោយស្វ័យប្រវត្តចំនួនពីរដងនឹងត្រូវធ្វើឡើងទៅកាន់លេខទូរសព្ទដែលត្រូវបានកត់ត្រាទុកសម្រាប់សិស្សរូបនោះ ដោយការហៅទូរសព្ទម្តងត្រូវបានធ្វើឡើងនៅពេលព្រឹក និងការហៅទូរសព្ទម្តងទៀតនៅពេលរសៀល ដើម្បីជូនដំណឹងដល់មាតាបិតា ឬអាណាព្យាបាលថាសិស្សរូបនោះមិនមិនវត្តមាននៅក្នុងថ្នាក់រៀន ហើយបុគ្គលិកម្នាក់របស់សាលានឹងទៅជួបជាមួយគ្រួសារផងដែរដើម្បីស្វែងរកហេតុផលនៃអវត្តមាននោះ និងដើម្បីស្វែងយល់ថាតើសាលាអាចផ្តល់ជំនួយគាំទ្របែបណាដល់គ្រួសារទាំងនោះដើម្បីធានាថាសិស្សរូបនោះនឹងអាចចូលសិក្សារៀនសូត្រជារៀងរាល់ថ្ងៃ។ សៀវភៅណែនាំស្តីពីការសិក្សាពីចម្ងាយសម្រាប់គ្រួសារ ត្រូវបានបង្កើតឡើង និងផ្តល់ជូនដល់គ្រួសារទាំងឡាយជាភាសាផ្សេងៗគ្នាជាច្រើន។ ការចូលរួមរបស់សិស្ស និងការផ្តល់សេវាទៅដល់សហគមន៍ ត្រូវបានចាត់ទុកថាជា ទំនួលខុសត្រូវរួមពីព្រោះគ្រប់សិស្ស SUSD ដែលត្រូវបានចុះឈ្មោះទាំងអស់ ត្រូវបានចាត់ទុកថាជាបញ្ញាវន្តវ័យក្មេងដ៏មានតម្លៃនៅក្នុងប្រព័ន្ធអប់រំ របស់យើង។ ការផ្តល់សេវាទៅដល់សហគមន៍ជូនដល់គ្រួសារដើម្បីធានានូវការចូលរួមរបស់សិស្សក្នុងការសិក្សាប្រចាំថ្ងៃ និងយុទ្ធសាស្ត្រដើម្បីដោះស្រាយបញ្ហាប្រឈមនៃការសិក្សា ត្រូវបានផ្តល់ជូនដោយគ្រូប្រចាំថ្នាក់រៀន បុគ្គលិកទីតាំងសាលា អ្នកគ្រប់គ្រងទីតាំង និងបុគ្គលិកនៅទូទាំងស្រុក ដោយផ្តោតទៅលើការជំរុញការចូលរួមរបស់សិស្សទាំងអស់នៅក្នុងបរិយាកាសសិក្សាមួយដែលប្រកបដោយសមធម៌ ហើយការផ្សព្វផ្សាយព័ត៌មានទៅដល់សហគមន៍ ត្រូវបានធ្វើឡើងជាច្រើនភាសាផ្សេងៗគ្នា។ សិស្សដែលត្រូវបានកាត់ផ្តាច់ការទំនាក់ទំនង ឬមិនអាចទាក់ទងបាន ត្រូវបានផ្តល់ជូននូវការគាំទ្របែបយុទ្ធសាស្ត្រដែលមានច្រើនជាន់ថ្នាក់ ដែលមានដូចជា ការធ្វើទស្សនកិច្ចទៅកាន់ផ្ទះរបស់ពួកគេ ការបង្កើនការផ្តល់សេវាទៅដល់ សហគមន៍ ការផ្តល់សេវាសម្រាប់កុមារ និងយុវជនដែលមានហានិភ័យខ្ពស់ និងចម្លើយតបនៃជំនួយគាំទ្រដែលមានការយល់ដឹងអំពីសេចក្តីភ័យរន្ធត់ តក់ស្លុត ដើម្បីផ្តល់ជូនដល់សិស្ស និងសមាជិកគ្រួសាររបស់ពួកគេនូវការគាំទ្រពេញលេញដែលចាំបាច់ដើម្បីធានាថាសិស្សរូបនោះ នឹងអាចចូលសិក្សា រៀនសូត្រជារៀងរាល់ថ្ងៃ ហើយតម្រូវការផ្នែកសុខុមាលភាពសង្គម និងអារម្មណ៍របស់ពួកគេត្រូវបានបំពេញនៅក្នុងកិច្ចដំណើរការនេះ។ យុទ្ធសាស្ត្រ ទ្រទ្រង់ និងអន្តរាគមន៍ផ្នែកអាកប្បកិរិយាវិជ្ជមាន ត្រូវបានអនុវត្តនៅទូទាំងស្រុក ដោយផ្តោតទៅលើការអភិវឌ្ឍវប្បធម៌សាលារៀនដែលមានលក្ខណៈ វិជ្ជមាន និងមានលក្ខណៈបរិយាប័ន្ន បរិយាកាសសិក្សាកក់ក្តៅ និងប្រកបដោយសមធម៌ បរិយាកាសសាលារៀនដែលជំរុញការចូលរួម និងបទពិសោធន៍សិក្សាដែលមានលក្ខណៈឆ្លើយតបទាំងផ្នែកវប្បធម៌ និងភាសា។ ការទំនាក់ទំនងជាប្រចាំ ត្រូវបានធ្វើឡើងរវាងសាលារៀន និងគ្រួសារ តាមរយៈការ ហៅទូរសព្ទ ការផ្ញើអ៊ីម៉ែល ការទំនាក់ទំនងតាមបណ្តាញសង្គម អ្នកបញ្ជូនសំបុត្រ វគ្គបណ្តុះបណ្តាល និងសិក្ខាសាលា កិច្ចប្រជុំ និងជំនួយគាំទ្រដែលត្រូវបានផ្តល់ជូនដោយការិយាល័យសុខុមាលភាពកុមារ និងវត្តមានការិយាល័យការចូលរួមរបស់គ្រួសារ និងការិយាល័យអភិវឌ្ឍការអប់រំ និងភាសា។

ការសិក្សាពីចម្ងាយ តម្រូវឲ្យមានការភ្ជាប់បណ្តាញអ៊ីនធឺណិត ព្រមទាំងឧបករណ៍ដើម្បីទទួលបានការបង្រៀន។ ដើម្បីធានាថាសិស្សទាំងអស់ មាន ឧបករណ៍នោះ អ្នកផ្តល់ប្រឹក្សាយោបល់របស់សាលាបានជួយទីតាំងរបស់ពួកគេក្នុងការចែកចាយកុំព្យូទ័រក្រូមប៊ុក និងបានតស៊ូមតិដើម្បីទាមទារឲ្យមានទីតាំងផ្តល់សេវាវ៉ាយហ្វាយហតស្ប៉ត (WiFi hot spots) ពីព្រោះគ្រួសារទាំងអស់ពុំមានភ្ជាប់បណ្តាញអ៊ីនធឺណិតនោះឡើយ។ អ្នកផ្តល់ប្រឹក្សាយោបល់របស់សាលា ក៏បានឆ្លើយតបចំពោះសំណើរាប់មិនអស់របស់មាតាបិតាដែលស្នើសុំជំនួយគាំទ្រពាក់ព័ន្ធនឹងការប្រើប្រាស់បច្ចេកវិទ្យា។ នៅក្នុងនិទាឃរដូវ អ្នកផ្តល់ប្រឹក្សាយោបល់របស់សាលា បានប្រើប្រាស់ឧបករណ៍ទូរនិម្មិត្ត (ដោយរួមទាំងការស្ទង់មតិហ្គូគហ្គល (Goggle surveys)) ដើម្បីអនុញ្ញាតឲ្យគ្រូបង្រៀនបញ្ជូនបន្តនូវសិស្សដែលមិនចូលរួមក្នុងការសិក្សាពីចម្ងាយ ឬដែលឈប់ចូលរួមនៅពេលណាមួយ។ អ្នកផ្តល់ប្រឹក្សាយោបល់ខិតខំប្រឹងប្រែងគ្រប់បែបយ៉ាងដើម្បីធ្វើការទំនាក់ទំនងទៅកាន់គ្រួសាររបស់សិស្សដែលមិនចូលរួម ដើម្បីជួយគាំទ្រពួកគេ និងស្វែងយល់អំពីតម្រូវការរបស់ពួកគេ ដោយធ្វើការជាមួយអ្នកបកប្រែភាសា ដើម្បីជួយគាំទ្រដល់ការទំនាក់ទំនងជាមួយគ្រួសាររបស់ពួកគេ ជាភាសាដែលត្រូវបានប្រើប្រាស់នៅក្នុងផ្ទះរបស់ពួកគេ (ឧ. ឧបករណ៍ដែលដំណើរការសមស្រប ការភ្ជាប់បណ្តាញអ៊ីនធឺណិត ការមិនអាចភ្ជាប់ជាមួយថ្នាក់រៀនហ្គូគហ្គល (Google Classroom) ។ល។)។ អ្នកផ្តល់ប្រឹក្សាយោបល់របស់សាលា បានប្រើប្រាស់យុទ្ធសាស្ត្រផ្សេងៗគ្នាជាច្រើនដើម្បីធ្វើការទំនាក់ទំនងជាមួយ សិស្ស។ អ្នកផ្តល់ប្រឹក្សាយោបល់របស់សាលាផ្ញើអ៊ីម៉ែល និងវីដេអូរៀងរាល់សប្តាហ៍ រៀបចំការញ៉ាំអាហារថ្ងៃត្រង់បែបទូរនិម្មិតដើម្បីធ្វើឲ្យការទាក់ទង និងទំនាក់ទំនងមាននិរន្តរភាព និងខិតខំបន្ថែមទៀតដើម្បីភ្ជាប់ទំនាក់ទំនងជាមួយសិស្សដែលមិនបានចូលរួម ដូចជាធ្វើការទាក់ទងតាមរយៈបណ្តាញ សង្គម និងការជួយគាំទ្រមិត្តភក្តិ បន្ថែមទៅលើការទាក់ទងទៅកាន់គ្រួសារ។ អ្នកផ្តល់ប្រឹក្សាយោបល់របស់សាលា និងអ្នកជំនាញកម្មវិធីអ្នកផ្តល់ប្រឹក្សា យោបល់របស់សាលាបានរួមបញ្ចូលនូវធនធានសិក្សាមួយចំនួននៅលើគេហទំព័ររបស់សាលា និងស្រុក ដើម្បីផ្តល់ការគាំទ្របន្ថែមដល់សិស្សលើមុខ វិជ្ជាគណិត អំណាន

និងមុខវិជ្ជាដទៃផ្សេងទៀត។

កម្មវិធី PLUS ផ្តោតទៅលើទំនាក់ទំនងជិតស្និទជាមួយសាលារៀន ដែលត្រូវបានចាត់ទុកថាជាកត្តាការពារដ៏សំខាន់មួយមិនត្រឹមតែសម្រាប់សុខុមាលភាព សង្គម និងអារម្មណ៍តែប៉ុណ្ណោះទេ តែវាថែមទាំងជួយលើកកម្ពស់ការចូលរួមវិជ្ជមាន និងបង្កើនវត្តមានផងដែរ។ ដើម្បីជួយគាំទ្រការបង្កើនទំនាក់ទំនងជិតស្និទរបស់សិស្សកាលពីឆ្នាំកន្លងទៅ ក្រុមការងារ PLUS បានចាប់ផ្តើមទាក់ទងទៅមិត្តភក្តិរបស់ពួកគេតាមរយៈគណនីបណ្តាញសង្គម កិច្ចប្រជុំទូរនិម្មិតតាមកម្រិតថ្នាក់ និងតាមរយៈអ៊ីម៉ែល ដោយរៀបរាប់លម្អិតអំពីធនធានដែលពួកគេអាចស្វែងរកបាន។ ក្រុមការងារ PLUS កំពុងបន្តអនុវត្តកិច្ចខិតខំប្រឹងប្រែងទាំងនេះ នៅក្នុងឆ្នាំសិក្សា2020-2021 និងកំពុងដោះស្រាយបញ្ហាប្រឈមនានាដើម្បីស្វែងយល់ថាហេតុអ្វីមិត្តភក្តិរបស់ពួកគេជ្រើសរើសមិនបើករូបភាពវីដេអូរបស់ពួកគេក្នុងអំឡុងម៉ោងសិក្សារបស់ពួកគេ។ ពួកគេយល់ដឹងថា បទពិសោធស្តីពីសេចក្តីភ័យរន្ធត់តក់ស្លុតបង្ហាញ ថា មានហេតុផលសង្គម/អារម្មណ៍ជាច្រើនដែលនាំឲ្យសិស្សមិនបើកវីដេអូរបស់ពួកគេ ហើយថ្នាក់ដឹកនាំ PLUS បានចាប់ផ្តើមបង្កើតវិធីសាស្ត្រជាច្រើន ដើម្បីធ្វើឲ្យសិស្សមានអារម្មណ៍ថាមានសុវត្ថិភាពគ្រប់គ្រាន់នៅក្នុងថ្នាក់រៀនទូរនិម្មិតរបស់ពួកគេដើម្បីធ្វើឲ្យពួកគេបើកវីដេអូរបស់ពួកគេ។ ពួកគេបានធ្វើយុទ្ធនាការបង្កើតរូបភាពនៅផ្ទៃខាងក្រោយទូរនិម្មិត រូបភាពតំណាងឲ្យអារម្មណ៍ដែលត្រូវបង្កើតឡើងដោយសិស្សខ្លួនឯង និងវិធីសាស្ត្របែបរីករាយផ្សេងៗទៀតដើម្បជំរុញឲ្យមានការចូលរួមទោះបីជាពួកគេបើក ឬមិនបើកវីដេអូក៏ដោយ។ ព្រឹត្តិការណ៍ដែលមានឈ្មោះថា **យុវជននិយាយ** និងវេទិកា របស់ PLUS គឺជាវិធីសាស្ត្រផ្សេងទៀតដែលសិស្សកំពុងចូលរួមក្នុងការកសាងការទំនាក់ទំនងជាមួយសាលារៀនដែលមានលក្ខណៈវិជ្ជមាន។ ការផ្តល់ជូននូវសកម្មភាពប្រកបដោយអត្ថប្រយោជន៍ នៅមុនពេល អំឡុងពេល និងក្រោយពេល សិក្សានៅសាលារៀន គឺជាវិធីសាស្ត្រមួយផ្សេងទៀតដែល PLUS ផ្សព្វផ្សាយទៅដល់សហគមន៍ ដើម្បីជំរុញការចូលរួមរបស់សិស្សនៅក្នុងសាលារៀន។ PLUS នឹងរៀបចំផងដែរនូវព្រឹត្តិការណ៍រាត្រីគ្រួសារ/មាតាបិតាបែបទូរនិម្មិតជាច្រើនដែលនៅក្នុងព្រឹត្តិការណ៍នោះមាតាបិតា អាចចូលរួមផងដែរក្នុងសកម្មភាពប្រកដោយអត្ថន័យដែលនឹងពង្រឹងការភ្ជាប់ទំនាក់ទំនងរវាងផ្ទះ និងសាលារៀន ព្រមទាំងពង្រឹងលើកកម្ពស់វេទិកាពិភាក្សារបស់សិស្សដែលនៅក្នុងវេទិកាទាំងនោះ សេវាបកប្រែនឹងត្រូវផ្តល់ជូនជាភាសាផ្សេងៗគ្នាជាច្រើន។

សេវាទ្រទ្រង់សិស្ស បានបង្កើតកម្មវិធីប្រឹក្សាយោបល់ពេញលេញរបស់សាលារៀននៅទូទាំងស្រុក។ នាយក និងអ្នកជំនាញឯកទេសកម្មវិធីប្រឹក្សាយោបល់របស់សាលារៀន បានបំពេញការងារជាមួយអ្នកពិគ្រោះយោបល់ដែលមានការទទួលស្គាល់ថ្នាក់ជាតិ និងក្រុមការងាររបស់គាត់ ដើម្បីធ្វើ ការបណ្តុះបណ្តាល និងផ្តល់រចនាសម្ព័ន្ធ និងជំនួយគាំទ្រ ដើម្បីពង្រឹងលើកកម្ពស់ប្រសិទ្ធភាពនៃកម្មវិធីរបស់យើងដើម្បីបន្សុីជាមួយស្តង់ដាប្រឹក្សា យោបល់របស់ជាតិ និងរដ្ឋ។ ដើម្បីដាក់ឲ្យដំណើរការនូវកម្មវិធីប្រឹក្សាយោបល់សាលារៀនដែលមានលក្ខណៈពេញលេញ យើងបានប្រើប្រាស់ទិន្នន័យ និងសមត្ថភាព និងស្តង់ដាររបស់សមាគមអ្នកផ្តល់ប្រឹក្សាយោបល់សាលារៀនអាមេរិក (ASCA) ដើម្បីបន្សុីជាមួយគោលដៅបេសកកម្ម និងទស្សនវិស័យរបស់ស្រុកដើម្បីវាយតម្លៃអំពីតម្រូវការរបស់សិស្ស ដើម្បីបង្កើតយុទ្ធសាស្ត្រផ្តល់សេវាបន្ថែម និងចាំបាច់នានា និងការគាំទ្របន្ថែម និងចាំបាច់នានាដល់សិស្សជាអាទិភាពរបស់យើង។ អ្នកផ្តល់ប្រឹក្សាយោបល់របស់សាលាទាំងអស់ បានទទួលការបណ្តុះបណ្តាលស្តីពីការអនុវត្តនៃការពង្រឹងកម្លាំងចិត្តឡើងវិញ និងបរិយាកាសសាលារៀនដែលមានលក្ខណៈវិជ្ជមាន។ ពួកគេភាគច្រើនក៏ទទួលបានការបណ្តុះបណ្តាលស្តីពីការអនុវត្តដែលមានការយល់ដឹងអំពីសេចក្តីភ័យរន្ធត់តក់ស្លុតផងដែរ។ ការបណ្តុះបណ្តាលនាពេលអនាគត កំពុងត្រូវបានរៀបចំដោយសារតែការបិទសាលារៀន ប៉ុន្តែនឹងត្រូវរៀបចំអនុវត្តនៅពេលស្តង់ដានៃការរៀបចំត្រូវបានបង្កើតឡើង។ ដើម្បីធានាថាសិស្សរបស់យើងកំពុងទទួលបានសេវាប្រកបដោយសមធម៌ យើងបានអនុវត្តប្រព័ន្ធ MTDSS ដើម្បីផ្តល់សេវាទៅដល់គ្រប់សិស្សទាំងអស់។ តាមការពិត គំរូរបស់សមាគមអ្នកផ្តល់ប្រឹក្សាយោបល់សាលារៀន អាមេរិក (ASCA) គឺពឹងផ្អែកជាចម្បងទៅលើការអនុវត្តនៃការពង្រឹងកម្លាំងចិត្តឡើងវិញដែលមានការយល់ដឹងអំពីសេចក្តីភ័យរន្ធត់តក់ស្លុត និងគំរូពេញលេញមួយដែលផ្តល់សេវាទៅដល់សិស្សរបស់យើងទាំងអស់ និងគ្រួសាររបស់ពួកគេ។ អ្នកផ្តល់ប្រឹក្សាយោបល់របស់សាលារៀន សម្របសម្រួល កម្មវិធី SAP ដែលមានច្រើនជាន់ថ្នាក់ ដើម្បីកំណត់ជាមុននូវអត្តសញ្ញាណសិស្សដែលមានការលំបាកក្នុងការចូលសិក្សារៀងរាល់ថ្ងៃ និងមានការលំបាកក្នុងការបំពេញតាមសេចក្តីរំពឹងទុកនៃកម្រិតថ្នាក់របស់ពួកគេ ព្រមទាំងរៀបចំផ្តល់ការត្រួតពិនិត្យ និងវាស់វែងផលប៉ះពាល់នៃការអន្តរាគមន៍ និងសេវា និងធានាឲ្យបាននូវការបែងចែកជំនួយគាំទ្រដោយសមធម៌។ អ្នកផ្តល់ប្រឹក្សាយោបល់របស់សាលានីមួយៗ ទទួលខុសត្រូវក្នុងការផ្តល់ការអភិវឌ្ឍវិជ្ជាជីវៈដល់បុគ្គលិក ដោយគ្របដណ្តប់លើប្រធានបទដែលពាក់ព័ន្ធនឹងតម្រូវការផ្នែកសង្គម និងអារម្មណ៍ តម្រូវការផ្នែកសិក្សា តម្រូវការផ្នែកមហាវិទ្យាល័យ និងអាជីពរបស់សិស្សរបស់យើង ដូចជាការគ្រប់គ្រងខ្លួនឯង ការផ្តោតលើគោលដៅ ទោះបីមានឧបសគ្គ ការចៀសវាងការរំខាន ព្រមទាំងកិច្ចដំណើរការ និងវិធីសាស្ត្រជួយគាំទ្រការគិត ការចងចាំ ឬការសិក្សា និងការផ្តោតអារម្មណ៍ទៅលើបំណិនដែលបង្កើនទំនាក់ទំនងសង្គម

និងការកំណត់អាទិភាពនៃគោលដៅខ្ពស់ជាងមុននៅក្នុងជីវិត។ អ្នកផ្តល់ប្រឹក្សាយោបល់របស់សាលារៀន ផ្តល់ការប្រឹក្សាយោបល់ និងការអភិវឌ្ឍវិជ្ជាជីវៈ ទៅដល់គ្រូ និងក្រុមការងារសាលារៀន ស្តីពីយុទ្ធសាស្ត្រសម្រាប់ជួយគាំទ្រកុមារពេញលេញ ដោយរួមទាំងយុទ្ធសាស្ត្រដែលមានការយល់ដឹងអំពី សេចក្តីភ័យរន្ធត់ ការអភិវឌ្ឍកុមារ ការសិក្សាផ្នែកសង្គម និងអារម្មណ៍ យុទ្ធសាស្ត្រឆ្លើយតបផ្នែកវប្បធម៌ និងភាសា ការកសាងសហគមន៍ និងទំនាក់ ទំនង និង ការអនុវត្តនៃការពង្រឹងកម្លាំងចិត្តឡើងវិញ។ អ្នកផ្តល់ប្រឹក្សាយោបល់របស់សាលារៀន ពិគ្រោះយោបល់ជាមួយគ្រូបង្រៀនស្តីពីសិស្សដែល រស់នៅក្នុងមណ្ឌលកុមារកំព្រា/គ្រួសារកំពុងផ្លាស់ប្តូរ/អ្នកសិក្សាភាសាអង់គ្លេស/សិស្សដែលទទួលការអប់រំពិសេស ស្តីពីការស្វែងយល់អំពីតម្រូវការ និងការផ្តល់យុទ្ធសាស្ត្រ និងជំនួយគាំទ្រ។ អ្នកផ្តល់ប្រឹក្សាយោបល់របស់សាលារៀន ក៏ផ្តល់ជូនផងដែរនូវជំនួយគាំទ្រដែលមានច្រើនជាន់ថ្នាក់ដល់ គ្រូបង្រៀនតាមរយៈការផ្តល់ជូននូវយុទ្ធសាស្ត្រដើម្បីជំរុញឲ្យមានការចូលរួមពីគ្រួសារ និងចាប់ដៃគូជាមួយគ្រួសារ។

# អាហាររូបត្ថម្ភនៅក្នុងសាលារៀន

[ពិពណ៌នាអំពីរបៀបដែលទីភ្នាក់ងារអប់រំក្នុងមូលដ្ឋាន នឹងផ្តល់អាហារគ្រប់គ្រាន់ដែលមានអាហាររូបត្ថម្ភជូនដល់សិស្សទាំងអស់ ដោយរួមទាំងសិស្ស ដែលមានសិទ្ធិទទួលបានអាហារដោយឥតគិតថ្លៃ ឬអាហារដែលត្រូវបានបញ្ចុះថ្លៃ នៅពេលសិស្សទាំងនោះកំពុងចូលរួមក្នុងការសិក្សាដែលសិស្ស ត្រូវមានវត្តមានផ្ទាល់ និងការសិក្សាពីចម្ងាយ។]

នាយកដ្ឋានសេវាអាហារ និងអាហាររូបត្ថម្ភសម្រាប់កុមារ បានបន្តបម្រើ និងចែកចាយអាហារដល់សិស្ស និងគ្រួសាររបស់ពួកគេចាប់តាំងពីពេលដែល SUSD បានបិទទ្វារសាលារៀនដោយសារតែជំងឺរាតត្បាត COVID-19។ នៅក្នុងខែទាំងឡាយនៃនិទាឃរដូវ និងរដូវក្តៅ ស្រុកអាចផ្តល់អាហារជូនកុមារណាក៏ដោយដែលមានអាយុក្រោម 18ឆ្នាំ មិនថាពួកគេ គឺជាសិស្សរបស់ SUSD ដែលត្រូវបានចុះឈ្មោះ ឬមិនមែនជាសិស្សរបស់ SUSD ក៏ដោយ។ សម្រាប់ឆ្នាំសិក្សា2020-2021 ដោយមានការផ្លាស់ប្តូរវិធានច្បាប់ និងការរំពឹងទុកការចែកអាហារ ត្រូវផ្តោតលើការផ្តល់អាហារទៅដល់សិស្សដែលបានចុះឈ្មោះនៅក្នុង SUSD តែប៉ុណ្ណោះ។ អាហារ ត្រូវចែកបីដងក្នុងមួយសប្តាហ៍ ពោលគឺ អាហារពេលព្រឹក ថ្ងៃត្រង់ និងពេលយប់ សម្រាប់រយៈពេល ពីរថ្ងៃ។ អាហារនឹងត្រូវចែកជូននៅថ្ងៃចែកអាហារនីមួយៗ ពោលគឺថ្ងៃចន្ទ ថ្ងៃពុធ និងថ្ងៃសុក្រ នៅតាមទីតាំងសាលារៀនចំនួន 28 ដែលមានទីតាំងនៅពេញទូទាំងព្រំប្រទល់របស់ SUSD។ ទីតាំងបោះជំរំពេលថ្ងៃរបស់កុមារដែលផ្តល់ជូនការគ្រប់គ្រងលើកុមារប្រចាំថ្ងៃសម្រាប់បុគ្គលិកសំខាន់ៗរបស់ SUSD ត្រូវបានដាក់ឲ្យស្ថិតនៅទីតាំងចែកចាយអាហារ ដើម្បីផ្តល់លទ្ធភាពឲ្យកុមារដែលចូលរួមក្នុងការបោះជំរំនៅពេលថ្ងៃរបស់កុមារ ទទួលបានអាហារពេលព្រឹក ពេលថ្ងៃ ពេលយប់ និងអាហារសម្រន់ ខណៈពេលពួកគេចូលរួមក្នុងការបោះជំរំនាពេលថ្ងៃរបស់កុមារ។

សូលុយស្យុងសម្លាប់មេរោគ ស្រោមដៃ និងម៉ាស់ ត្រូវបានរៀបចំដើម្បីធានាថាសម្លៀកបំពាក់ និងឧបករណ៍ការពារខ្លួន មានគ្រប់គ្រាន់សម្រាប់បុគ្គលិកទាំងអស់ដែលចូលរួមក្នុងការចែកអាហារ។ ក្នុងអំឡុងពេលនៃការរៀបចំអាហារ បុគ្គលិកទាំងអស់រក្សាគម្លាតសង្គម ដោយបំពេញការងារយ៉ាងហោចណាស់ក្នុងចម្ងាយ 6ហ្វីតពីគ្នា បុគ្គលិកពាក់ស្រោមដៃ និងម៉ាស់ពេញមួយអំឡុងពេលនៃវេនបំពេញការងាររបស់ពួកគេ ហើយបុគ្គលិកត្រូវបានលើកទឹកចិត្តឲ្យលាងដៃរបស់ពួកគេ និងផ្លាស់ប្តូរស្រោមដៃរបស់ពួកគេជាទៀងទាត់។ អ្នកគ្រប់គ្រងទីតាំង និងបុគ្គលិកសេវាសុខាភិបាល មានវត្តមាននៅទីតាំងចែកចាយអាហារ ដើម្បីត្រួតពិនិត្យមើលការរក្សាគម្លាតសង្គម និងផ្តល់ការក្រើនរម្លឹក និងការណែនាំ ដែលចាំបាច់។ ការទំនាក់ទំនងតាមទូរសព្ទ អ៊ីម៉ែល សំបុត្រ ទៅដល់ទីកន្លែងរស់នៅរបស់សិស្ស និងគេហទំព័រផ្តល់ព័ត៌មាន ត្រូវបានបង្កើតឡើងដើម្បីផ្តល់ព័ត៌មានយ៉ាងច្បាស់លាស់ជូនដល់ សិស្ស និងគ្រួសាររបស់ពួកគេអំពីទីកន្លែងដែលអាចទទួលយកអាហារ ពិធីសារស្តីពីសុវត្ថិភាពនៅពេលទទួលយកអាហារ និងលេខទូរសព្ទមួយដើម្បី ហៅទូរសព្ទទៅរក ប្រសិនបើដោយសារហេតុផលណាមួយ ឬគ្រួសារណាមួយមិនអាចរៀបចំការធ្វើដំណើរទៅដល់ទីតាំងសាលារៀនដែលផ្តល់អាហារ ដើម្បីអនុញ្ញាតឲ្យបុគ្គលិករបស់ស្រុកអាចទាក់ទងទៅគ្រួសារទាំងនេះ និងរៀបចំឲ្យគ្រួសារទាំងនោះអាចទទួលយកអាហារ។ និតិវិធីចែកចាយអាហារដូចខាងក្រោម ត្រូវបានដាក់ឲ្យអនុវត្តៈ បុគ្គលិកម្នាក់នឹងសួរអំពីចំនួនកុមារដែលមនុស្សពេញវ័យកំពុងទទួលយកអាហារទៅឲ្យបុគ្គលិកនឹងស្កេនអក្សរសម្ងាត់នៅលើប័ណ្ណអាហាររបស់សិស្ស ដែលមនុស្សពេញវ័យកំពុងរក្សាទុក បុគ្គលិកនឹងដាក់អាហារនៅខាងចុងតុ ឬរទេះ ក្រោយពេលបុគ្គលិកទៅចុងម្ខាងទៀតនៃតុ ឬរទេះ មាតាបិតា/អាណាព្យាបាល អាចចូលទៅកាន់តុ ឬរទេះនោះ ដើម្បីទទួលយកអាហារ មាតាបិតា/អាណាព្យាបាលត្រូវបានណែនាំមិនឲ្យប៉ះពាល់តុនោះឡើយ។ បុគ្គលិកទាំងអស់ដែលផ្តល់អាហារត្រូវបានផ្តល់ជូននូវ និងត្រូវបានណែនាំឲ្យស្លៀកពាក់សម្លៀកបំពាក់ និងឧបករណ៍ការពារខ្លួន ហើយព័ត៌មាននេះត្រូវបានចែករំលែកទៅដល់គ្រួសារទាំងឡាយ ដែលត្រូវបានធ្វើឲ្យស៊ីសង្វាក់ជាមួយនឹងសេចក្តីណែនាំ របស់ទីភ្នាក់ងារសុខាភិបាលនានា ដោយនិតិវិធី និងសេចក្តីណែនាំទាំងនេះរំពឹងថានិងកោតសរសើរចំពោះមាតាបិតា/អាណាព្យាបាលដែលពាក់ម៉ាស់ ឬឧបករណ៍សម្រាប់គ្របលើមាត់ និងច្រមុះនៅពេលទទួលយកអាហារ ដោយគោរពតាមគោលការណ៍ណែនាំឲ្យរក្សាគម្លាតសង្គមចម្ងាយ 6ហ្វីត របស់មជ្ឈមណ្ឌលបង្ការនិងទប់ស្កាត់ជំងឺឆ្លង។ នាយកទីតាំងសាលារៀន សហការជាមួយគ្នា ដើម្បីជួយគាំទ្រដល់ការចែកចាយអាហារ និងដោយសហការជាមួយនាយកដ្ឋានអាហាររូបត្ថម្ភកុមារ និងសេវាអាហារ ដើម្បីធានាថាទីតាំងចែកចាយអាហារ មានបុគ្គលិកគ្រប់គ្រាន់ដើម្បីគោរពតាមការណែនាំស្តីពីការរក្សាគម្លាតសង្គម និងដើម្បីផ្តល់ជំនួយគាំទ្រសមស្របក្នុងការចែកចាយអាហារ។ ការិយាល័យទំនាក់ទំនងសាធារណៈ ការអប់រំគ្រួសារ និងការចូលរួមរបស់គ្រួសារ និងអភិវឌ្ឍភាសា និងនាយកដ្ឋានសុខុមាលភាពកុមារ និងវត្តមានកុមារ និងបុគ្គលិកទីតាំងសាលារៀន ចែករំលែកព័ត៌មានទាំងនេះ និងផ្តល់ជូនគ្រួសារទាំងឡាយនូវជំនួយគាំទ្រក្នុងការទទួលបានផលប្រយោជន៍ផ្នែកអាហារបន្ថែមទៀត ដែលត្រូវបានហៅថា EBT ឬ P-EBT ដែលជួយ

# សកម្មភាពបន្ថែមដើម្បីអនុវត្តផែនការនិរន្តរភាពនៃការសិក្សា (ជួរដេកនិងសកម្មភាពបន្ថែម ទៀត អាចនឹងត្រូវដាក់ចូលបន្ថែម ប្រសិនបើចាំបាច់)

| ផ្នែក | ពិពណ៌នា | មូលនិធិសរុប | ដែលរួមចំណែក |
|---|---|---|---|
| កម្មវិធីសិក្សាពីចម្ងាយ (និរន្តរភាពនៃការបង្រៀន) | ការផ្តល់ការបោះជំរំនាពេលថ្ងៃរបស់កុមារ សម្រាប់បុគ្គលិកស្រុក ដែលមានបញ្ហាប្រឈម និងការលំបាកដែលពាក់ព័ន្ធនឹងជំងឺរាតត្បាត COVID-19។ (AA-1) | 1,050,000 ដុល្លារ | ទេ |
| អាហាររូបត្ថម្ភនៅក្នុងសាលារៀន | គ្រឿងបរិក្ខា និងសម្ភារៈនៃអាហាររូបត្ថម្ភកុមារ និងសេវាអាហារ ដែលគេត្រូវការជាចាំបាច់សម្រាប់ការផ្តល់ អាហារ ក្នុងអំឡុងពេលនៃការបិទសាលារៀន ខណៈពេល ដែលសេវានេះនឹងនៅតែបន្ត នៅពេលការផ្តល់ជូនដោយមាន វត្តមានមនុស្សផ្ទាល់ អាចត្រូវអនុញ្ញាត ដោយគោរពតាម គោលការណ៍ណែនាំសុខាភិបាលសាធារណៈ (សិស្សអាច ស្កែនប័ណ្ណរបស់ពួកគេ តង់ដែលត្រូវបានតម្លើងដើម្បីយកម្លប់ សម្លៀកបំពាក់ការពារផ្ទាល់ខ្លួន សម្ភារៈបរិក្ខារក្សាអនាម័យ សម្ភារៈបរិក្ខាសម្រាប់សម្លាប់មេរោគ ឧបករណ៍ និងសម្ភារៈ បរិក្ខាសម្រាប់ផ្តល់សេវាអាហារបន្ថែម និងសម្ភារៈបរិក្ខាដទៃ ទៀត ដែលគេត្រូវការជាចាំបាច់សម្រាប់ផ្តល់សេវាចែកចាយ អាហារនៅក្នុងអំឡុងពេលនៃជំងឺរាតត្បាត COVID-19។ (AA-2) | 32 000 ដុល្លារ | ទេ |
| សុខភាពផ្លូវចិត្ត និងសុខុមាលភាពសង្គម និងអារម្មណ៍ | គ្រូពេទ្យសុខភាពផ្លូវចិត្ត ផ្តល់ជំនួយគាំទ្រផ្ទាល់ដល់ទីតាំងសាលារៀននីមួយៗក្នុងការដោះស្រាយផលប៉ះពាល់នៃសេចក្តីភ័យរន្ធត់តក់ស្លុត និងសេចក្តីភ័យបារម្ភពាក់ព័ន្ធនឹងការរស់នៅដាច់ដោយឡែកតែឯងដែលត្រូវពន្យារពេលកាន់តែយូរ ការបាត់បង់ជីវិតនៅក្នុងគ្រួសារ និងការបន្តស្នាក់នៅក្នុងទីកន្លែងដែលមានបទពិសោធន៍ពាក់ព័ន្ធនឹងផលប៉ះពាល់នៃជំងឺ COVID-19។ សិក្ខាសាលា ការបណ្តុះបណ្តាល ការព្យាបាលជាលក្ខណៈបុគ្គល ជាក្រុម និងជាលក្ខណៈគ្រួសារ ដែលផ្តោតលើការអនុវត្តដែលមានការយល់ដឹងអំពីសេចក្តីភ័យរន្ធត់តក់ស្លុត និងតម្រូវការផ្នែកសង្គម និងអារម្មណ៍ និងផ្នែកសុខុមាលភាព ហើយសេវាប្រកបដោយការយកចិត្តទុកដាក់ ត្រូវបានផ្តល់ជូនរួមជាមួយនឹងធនធាន និងសេវាដទៃៗទៀតដែលត្រូវបានផ្តល់ជូនដោយ នាយកដ្ឋានសុខភាពផ្លូវចិត្តនិងអាកប្បកិរិយារបស់ | 4 620 000 ដុល្លារ | បាទ/ចាស |

| | | | |
|---|---|---|---|
| | សិស្ស។ (AA-3) | | |
| សុខភាពផ្លូវចិត្ត និងសុខុមាលភាពសង្គម និងអារម្មណ៍ | អ្នកប្រឹក្សាយោបល់ផ្តល់ជំនួយគាំទ្រផ្ទាល់ ជូនដល់ទីតាំងសាលា នីមួយៗ ក្នុងការអនុវត្តការណែនាំផ្នែកសិក្សា និងការគាំទ្រការ សិក្សាផ្នែកសង្គមនិងអារម្មណ៍សម្រាប់ប្រឈមដោះស្រាយផល ប៉ះពាល់នៃសេចក្តីភ័យរន្ធត់តក់ស្លុត និងសេចក្តី ភ័យបារម្ភ ដែលពាក់ព័ន្ធនឹងការរស់នៅដាច់ដោយឡែកតែឯង ដែលត្រូវ ពន្យារពេលកាន់តែយូរ ការបាត់បង់ជីវិតនៅក្នុង គ្រួសារ និង ការបន្តស្នាក់នៅក្នុងទីកន្លែងដែលមានបទ ពិសោធន៍ពាក់ព័ន្ធ នឹងផលប៉ះពាល់នៃជំងឺ COVID-19 និងកត្តា រួមផ្សំផ្សេងទៀត ដល់សុខមាលភាពសង្គមនិងអារម្មណ៍របស់សិស្ស។ (AA-4) | 10 198 220 ដុល្លារ | បាទ/ចាស |
| ការចូលរួមរបស់សិស្ស និងការ ផ្តល់សេវាទៅដល់សហគមន៍ | ការថែទាំដែលមានការយល់ដឹងអំពីសេចក្តីភ័យរន្ធត់តក់ស្លុត និងការបណ្តុះបណ្តាលសាលារៀនបែបឆ្លើយតបសម្រាប់ បុគ្គលិក SUSD ក្នុងការដោះស្រាយតម្រូវការផ្សេងៗគ្នារបស់ សិស្ស បុគ្គលិក និងគ្រួសារ ពាក់ព័ន្ធនឹងផលប៉ះពាល់នៃការ ដោះស្រាយផលប៉ះពាល់នៃសេចក្តីភ័យរន្ធត់តក់ស្លុត និងសេចក្តី ភ័យបារម្ភ ដែលពាក់ព័ន្ធនឹងការរស់នៅដាច់ដោយឡែកតែឯង ដែលត្រូវពន្យារពេលកាន់តែយូរ ការបាត់បង់ជីវិតនៅក្នុងគ្រួសារ និងការបន្តស្នាក់នៅក្នុងទីកន្លែងដែលមានបទពិសោធន៍ ពាក់ព័ន្ធនឹងផលប៉ះពាល់នៃជំងឺ COVID-19 និងកត្តា រួមផ្សំ ផ្សេងទៀត ដែលស៊ីសង្វាក់ជាមួយនឹងតម្រូវការសម្រាប់ការ អនុវត្តដែលមានការយល់ដឹងអំពីសេចក្តីភ័យរន្ធត់តក់ស្លុត។ (AA-5) | 150 000 ដុល្លារ | បាទ/ចាស |
| ការចូលរួមរបស់សិស្ស និងការ ផ្តល់សេវាទៅដល់សហគមន៍ | ការបណ្តុះបណ្តាល និងឯកសារស្តីពីការអនុវត្តការពង្រឹង កម្លាំង ចិត្តឡើងវិញ ដើម្បីបំពេញតាមសេចក្តីត្រូវការផ្នែក អាកប្បកិរិយា និងសេចក្តីត្រូវការផ្នែកសុខុមាលភាពសង្គម និងអារម្មណ៍ ដែលពាក់ព័ន្ធនឹងសិស្សដែលចូលរៀនទាំងនៅ ក្នុងទម្រង់សិក្សាពីចម្ងាយនិងទម្រង់សិក្សាដោយមានវត្តមានផ្ទា ល់នៅក្នុងឆ្នាំសិក្សាមួយក្នុងអំឡុងពេលមានការរីករាតត្បាតនៃ ជំងឺនៅទូទាំងពិភពលោក។ (AA-6) | 150 000 ដុល្លារ | បាទ/ចាស |
| ការចូលរួមរបស់សិស្ស និងការ ផ្តល់សេវាទៅដល់សហគមន៍ | ការផ្តល់ជូនមាតបិតា អាណាព្យាបាល និងគ្រួសារ នូវធនធាន និងព័ត៌មានចាំបាច់ ដើម្បីកែលម្អភាពជាដៃគូនៅក្នុងគំរូសិក្សា ពីចម្ងាយ និងនៅពេលផ្លាស់ប្តូរទៅកាន់ទម្រង់សិក្សាដែល សិស្សត្រូវមានវត្តមានផ្ទាល់ តាមរយៈការផ្តល់ជំនួយគាំទ្រ និង សេវាផ្ទាល់ តាមរយៈសិស្ស គ្រួសារ និងការទំនាក់ទំនងរបស់ បុគ្គលិកជាមួយគ្រួសារ អ្នកគ្រប់គ្រងសេវាសង្គម និងយុវជន ដែលគ្មានផ្ទះសម្បែងដែលមិនមានអ្នករស់នៅជាមួយ និងការ ទំនាក់ទំនងជាមួយយុវជនដែលរស់នៅក្នុងមណ្ឌលកុមារកំព្រា | 1 624 705 ដុល្លារ | បាទ/ចាស |

| | | | |
|---|---|---|---|
| | និងធនធានសម្រាប់យុវជនដែលរស់នៅក្នុងមណ្ឌលកុមារកំព្រា។ (AA-7) | | |
| ការចូលរួមរបស់សិស្ស និងការ ផ្តល់សេវាទៅដល់សហគមន៍ | បុគ្គលិកទទួលបន្ទុកវត្តមានរបស់សិស្ស និងគណនីយភាព ដែលរួមមាន ជំនួយការការិយាល័យ បុគ្គលិកសុខុមាលភាពកុមារ និងវត្តមាន បុគ្គលិកទំនាក់ទំនងទៅសិស្សដែលមិនចូលរៀន និងអ្នកជំនាញផ្នែកវត្តមាន បានធ្វើដំណើរទៅជួប និងទាក់ទងទៅគ្រួសាររបស់ពួកគេ ជាប្រចាំដើម្បីពង្រឹងលើកកម្ពស់សារៈសំខាន់នៃវត្តមានប្រចាំថ្ងៃរបស់សិស្ស និងដើម្បីកសាងទំនាក់ទំនងរវាងគ្រួសារជាមួយនឹង SUSD។ (AA-8) | 2 312 745 ដុល្លារ | បាទ/ចាស |
| កម្មវិធីសិក្សាពិចម្ងាយ (ជំនួយគាំទ្រសម្រាប់សិស្សដែលមានតម្រូវការពិសេសដោយឡែក) | ការដាក់អ្នកជំនាញផ្នែកបរិយាប័ន្នឲ្យបំពេញការងារ ដើម្បីគាំទ្រការរួមបញ្ចូលពេញលេញនូវសិស្សដែលមានតម្រូវការពិសេសទៅក្នុងការផ្តល់ការសិក្សាពីចម្ងាយ និងការសិក្សាដោយមានវត្តមានសិស្សដោយផ្ទាល់ និងធ្វើការបណ្តុះបណ្តាល/សិក្ខាសាលាជូនអ្នកគ្រប់គ្រង គ្រូចំណេះទូទៅ និងបុគ្គលិកទ្រទ្រង់ស្តីពីសិស្សដែលមានជំងឺអូទីសឹម និងការអនុវត្តដែលផ្អែកលើភស្តុតាង ដើម្បីជួយគាំទ្រការផ្លាស់ប្តូររបស់សិស្សចូលទៅក្នុងទម្រង់សិក្សាពីចម្ងាយពេញលេញ ការសិក្សាដែលសិស្សត្រូវមានវត្តមាន និងការសិក្សាចំណេះទូទៅ។ (AA-9) | 345 427 ដុល្លារ | បាទ/ចាស |
| ការចូលរួមរបស់សិស្ស និងការ ផ្តល់សេវាទៅដល់សហគមន៍ | ការធ្វើឲ្យមាននិរន្តរភាពនូវធនធាន និងកម្មវិធីនៃការត្រៀមខ្លួន សម្រាប់មហាវិទ្យាល័យ និងអាជីព សិស្សអាចទទួលបានកម្ម វិធី កុំព្យូទ័រសម្រាប់ស្រាវជ្រាវរុករកអាជីពការងារ និង របាយការណ៍សិក្សាប្រចាំត្រីមាស សម្រាប់សិស្សវិទ្យាល័យ ដែលអ្នកផ្តល់ប្រឹក្សាយោបល់ផ្តល់ជូនសិស្សដែលបានចុះឈ្មោះនៅវិទ្យាល័យម្នាក់ៗ ប្រើប្រាស់សម្រាប់កិច្ចសន្ទនាស្តី ពីការណែនាំផ្នែកសិក្សា និងចែករំលែកព័ត៌មានជាមួយ គ្រួសារស្តីពីក្រេឌីត នៅកម្រិតវិទ្យាល័យដែលទទួលបានវគ្គ សិក្សា A-G ដែលគេត្រូវការចំណាត់ថ្នាក់ដែលមានលក្ខណៈ ប្រកួតប្រជែងបច្ចុប្បន្ន របស់សិស្សដែលមានវគ្គសិក្សា និង ទិន្នន័យសិក្សាសម្រាប់ការអនុញ្ញាតឲ្យចូលរៀននៅក្នុងសាកលវិទ្យាល័យកាលីហ្វ័រញ៉ា និងឬ សាកលវិទ្យាល័យរដ្ឋ កាលីហ្វ័រញ៉ា និងវិថីនៃអាជីពដែល ពាក់ព័ន្ធនឹងវគ្គសិក្សាដែល និស្សិតបានរៀននិងទិន្នន័យស្តីពី ចំណង់ចំណូលចិត្តផ្ទាល់ខ្លួនដែលត្រូវបានវិភាគចេញពីកម្មវិធី កុំព្យូទ័រស្រាវជ្រាវរុករកអាជីព។ (AA-10) | 319 868 ដុល្លារ | បាទ/ចាស |
| សុខភាពផ្លូវចិត្ត និងសុខុមាលភាពសង្គម និងអារម្មណ៍ | ការបង្កើតក្រុមការងារអន្តរាគមន៍ផ្នែកអាកប្បកិរិយានិងសេវាផ្ទាល់ដែលត្រូវបានផ្តល់ជូនបុគ្គលិក ទីតាំងសាលារៀន និង គ្រួសារ ដែលផ្តោតលើសេវាផ្នែកអាកប្បកិរិយា និងការប្រមូល | 2 462 742 ដុល្លារ | បាទ/ចាស |

| | | | |
|---|---|---|---|
| | ទិន្នន័យយុទ្ធសាស្ត្រក្នុងការជួយគាំទ្រ យុវជនដែលរស់នៅក្នុងមណ្ឌលកុមារកំព្រា គ្រួសារដែលកំពុងផ្លាស់ប្តូរ អ្នកសិក្សាភាសាអង់គ្លេស អ្នកមានចំណូលទាប និងសិស្សដែលមានតម្រូវការពិសេស ការទទួលបានការសិក្សារៀនសូត្រ និងការបង្រៀនដោយគ្រូផ្ទាល់តាមរយៈប្រព័ន្ធអនុវត្តការគ្រប់គ្រងអាកប្បកិរិយា ដែលត្រូវបានបង្កើតឡើងដើម្បីបំពេញតាមសេចក្តីត្រូវការផ្នែកសង្គមនិងអារម្មណ៍របស់សិស្ស ក្នុងភាពជាដៃគូជាមួយបុគ្គលិកបង្រៀននិងគ្រួសារនៅក្នុងការសិក្សាពីចម្ងាយ និងការសិក្សាដោយមានវត្តមានផ្ទាល់។ (AA-11) | | |
| ការចូលរួមរបស់សិស្ស និងការ<br>ផ្តល់សេវាទៅដល់សហគមន៍ | ដោយត្រូវបានសម្របសម្រួលដោយប្រធានសមធម៌ ការបណ្តុះបណ្តាលទូទាំងស្រុកសម្រាប់បុគ្គលិក ផ្តោតទៅលើភាពលម្អៀងដោយប្រយោល ភាពចម្រុះ និងការរួមបញ្ចូល និងយុទ្ធសាស្ត្រឆ្លើយតបផ្នែកវប្បធម៌ និងភាសា ក្នុងការគាំទ្រការបង្កើត និងការរក្សានិរន្តរភាពនៃបរិយាកាសសិក្សាប្រកបដោយ សមធម៌។ (AA-12) | 479 499 ដុល្លារ | បាទ/ចាស |
| ការចូលរួមរបស់សិស្ស និងការ<br>ផ្តល់សេវាទៅដល់សហគមន៍ | ធ្វើឲ្យមាននិរន្តរភាពនូវការទំនាក់ទំនងជាមួយមាតាបិតា អ្នកជំនាញស្តីពីការចូលរួម សិក្ខាសាលា ការបណ្តុះបណ្តាល និងវគ្គសិក្សាភាសាអង់គ្លេសជាភាសាទីពីរ ដើម្បីបន្តគាំទ្រតម្រូវការរបស់គ្រួសារ និងផ្តល់ឱកាសសម្រាប់ការកសាងសមត្ថភាពនៃគ្រួសារក្នុងនាមជាដៃគូក្នុងការសិក្សារបស់សិស្សទាំងនៅក្នុងការសិក្សាពីចម្ងាយនិងការសិក្សាដោយមានវត្តមានផ្ទាល់ ដោយផ្តោតជាចម្បងទៅលើការបង្កើនអត្រាវត្តមានប្រចាំថ្ងៃរបស់យុវជនដែលរស់នៅក្នុងមណ្ឌលកុមារកំព្រា អ្នកសិក្សាភាសាអង់គ្លេស អ្នកមានចំណូលទាប គ្រួសារដែលកំពុងផ្លាស់ ប្តូរ និងសិស្សដែលមានតម្រូវការពិសេស។ (AA-13) | 809 767 ដុល្លារ | បាទ/ចាស |
| ការចូលរួមរបស់សិស្ស និងការ<br>ផ្តល់សេវាទៅដល់សហគមន៍ | ធ្វើឲ្យមាននិរន្តរភាព បង្កើន និងសម្រួលការចូលរួមរបស់សិស្ស និងឱកាសដឹកនាំសម្រាប់យុវជនដែលរស់នៅក្នុងមណ្ឌលកុមារកំព្រា អ្នកសិក្សាភាសាអង់គ្លេស គ្រួសារដែលកំពុងផ្លាស់ប្តូរ អ្នកមានចំណូលទាប និងសិស្សដែលមានតម្រូវការពិសេស ក្នុងការចូលរួមក្នុងក្លឹប សកម្មភាពកីឡា និងសិក្សា កម្មវិធី និងបទពិសោធន៍ភាពជាអ្នកដឹកនាំ នៅក្នុងការសិក្សាពីចម្ងាយ និងការសិក្សាដែលមានវត្តមានផ្ទាល់។ (AA-14) | 2 264 242 ដុល្លារ | បាទ/ចាស |
| ការចូលរួមរបស់សិស្ស និងការ<br>ផ្តល់សេវាទៅដល់សហគមន៍ | រង្វាន់លើកទឹកចិត្តសម្រាប់ការចូលរួមរបស់សិស្សដែលត្រូវបានផ្តល់ជូនសាលារៀនដោយផ្តោតលើការបង្កើនការចូលរួមរបស់សិស្សក្នុងការសិក្សាពីចម្ងាយ និងការសិក្សាដោយមានវត្តមាន ផ្ទាល់ និងការកំណត់គោលដៅសម្រាប់សិស្សជាមួយនឹងវិធីសាស្ត្រដែលមានច្រើនជាន់ថ្នាក់ ដែលផ្តោតលើការបង្កើន | 400 000 ដុល្លារ | បាទ/ចាស |

| | | | |
|---|---|---|---|
| | វត្តមាន និងការចូលរួមសម្រាប់យុវជនដែលរស់នៅក្នុង មណ្ឌលកុមារកំព្រា គ្រួសារដែលកំពុងផ្លាស់ប្តូរ អ្នកសិក្សាភាសាអង់គ្លេស និងសិស្សដែលមានតម្រូវការពិសេស និងក្រុមសិស្សដទៃផ្សេងទៀតដែលត្រូវបានគាំទ្រដោយទិន្នន័យពាក់ព័ន្ធនឹងតម្រូវការនូវជំនួយគាំទ្រដែលកាន់តែកើនឡើងនិងត្រូវបានកែលម្អពាក់ព័ន្ធនឹងការចូលរួមរបស់សិស្សក្នុងការសិក្សាប្រចាំថ្ងៃ។ (AA-15) | | |
| កម្មវិធីសិក្សាពីចម្ងាយ (ជំនួយគាំទ្រសម្រាប់សិស្សដែលមានតម្រូវការពិសេសដោយឡែក) | ដើម្បីគាំទ្រ និងពង្រឹងការប្តេជ្ញាចិត្តរបស់យើង GreatSchools នឹងផ្តល់ជូនមាតាបិតានូវព្រឹត្តិបត្រព័ត៌មានតាមកម្រិតថ្នាក់ ដើម្បីតាមដានការចូលរួមដោយមានខ្លឹមសារមេរៀន និងដើម្បីវាស់វែងផលប៉ះពាល់ទៅលើឥរិយាបថ និងអាកប្បកិរិយារបស់មាតាបិតា។ ព្រឹត្តិបត្រព័តមាន នឹងចេញផ្សាយជាភាសាអង់គ្លេស និងភាសាអេស្ប៉ាញ។ លទ្ធផលនៃព្រឹត្តិបត្រព័ត៌មានតាមកម្រិតថ្នាក់ ពិតជាមានឥទ្ធិពលយ៉ាងខ្លាំងជាពិសេសសម្រាប់មាតាបិតាដែលមានប្រាក់ចំណូលទាប និងមាតាបិតា អ្នកសិក្សាភាសាអង់គ្លេស។ របាយការណ៍ឆ្លុះបង្ហាញថាព្រឹត្តិបត្រព័ត៌មានបានជះឥទ្ធិពល ឬនឹងជះឥទ្ធិពលទៅលើទស្សនៈ និងអាកប្បកិរិយារបស់ពួកគេ ហើយ 85% ភាគរយនៃមាតាបិតាបានចាត់វិធានការផ្អែកលើព័ត៌មានទាំងនេះរួចទៅហើយ។ (AA-16) | 23 000 ដុល្លារ | ទេ |
| ការចូលរួមរបស់សិស្ស និងការ ផ្តល់សេវាទៅដល់សហគមន៍ | ធ្វើឲ្យសេវាសុខាភិបាលមាននិរន្តរភាព ដោយជ្រើសរើសបុគ្គលិកឲ្យបំពេញការងារ ដែលជា គិលានុបដ្ឋាកដែលមានអាជ្ញាប័ណ្ណ អ្នកជំនួយការថែទាំសុខភាព អ្នកសម្របសម្រួលការចាប់ផ្តើមដែលមានសុខភាពល្អ អ្នកសម្របសម្រួលកម្មវិធីទំនាក់ទំនងធនធានសហគមន៍ អ្នកប្រកបវិជ្ជាជីវៈជាគិលានុបដ្ឋាកប្រចាំគ្រួសារ និងដាក់បុគ្គលិកឲ្យបម្រើការងារសម្រាប់មជ្ឈមណ្ឌលសុខុមាលភាព ដើម្បីធានាថាសេវាសុខាភិបាល និងការគ្រប់គ្រងការឆ្លើយតបផ្នែកសុខាភិបាលដែលមិនស្មុគស្មាញ ត្រូវបានបន្តផ្តល់ជូនសិស្ស និងគ្រួសារក្នុងអំឡុងពេលនៃការសិក្សាពីចម្ងាយ និងការសិក្សាដោយមានវត្តមានផ្ទាល់ ដោយជួយដោះស្រាយតម្រូវការផ្នែកសុខាភិបាល និងសុខុមាលភាពរបស់ពួកគេ។ (AA-17) | 2 826 619 ដុល្លារ | បាទ/ចាស |
| ការចូលរួមរបស់សិស្ស និងការ ផ្តល់សេវាទៅដល់សហគមន៍ | ឱកាសបណ្តុះបណ្តាល និងធនធានដែលត្រូវបានផ្តល់ជូនដល់បុគ្គលិកការិយាល័យយុវជនដែលរស់នៅក្នុងមណ្ឌលកុមារកំព្រា ដើម្បីដោះស្រាយតម្រូវការនៃការចូលរួមរបស់យុវជនដែលរស់នៅក្នុងមណ្ឌលកុមារកំព្រា និងការផ្តល់សេវាដល់សហគមន៍ ក្នុងអំឡុងពេលនៃការសិក្សាពីចម្ងាយ និងការ | 14 300 ដុល្លារ | បាទ/ចាស |

| | | | |
|---|---|---|---|
| | សិក្សាដោយមានវត្តមានផ្ទាល់ តាមរយៈការផ្តល់ជូនសម្ភារៈសិក្សារៀនសូត្រ បង្កើនសេវាបកប្រែ បុគ្គលិកទទួលបានការបណ្តុះបណ្តាលស្តីពីយុវជនដែលរស់នៅក្នុងមណ្ឌលកុមារកំព្រា និងធនធានផ្សេងទៀត ដែលគេត្រូវការជាចាំបាច់ដើម្បីបង្កើនការចូលរួមរបស់យុវជនដែលរស់នៅក្នុងមណ្ឌលកុមារកំព្រា ក្នុងការសិក្សារៀនសូត្រ និងកែលម្អទម្រង់នៃការផ្តល់សេវាទៅដល់សហគមន៍ ទៅដល់យុវជនដែលរស់នៅក្នុងមណ្ឌលកុមារកំព្រា និងមាតាបិតា អាណាព្យាបាល និងគ្រួសារដែលផ្តល់ជំនួយគាំទ្រដល់យុវជនដែលរស់នៅក្នុងមណ្ឌលកុមារកំព្រា។ (AA-18) | | |

# បង្កើន ឬកែលម្អសេវាកម្មសម្រាប់យុវជនងាយរងគ្រោះ សិស្សរៀនភាសាអង់គ្លេស និងសិស្សដែលមានចំណូលទាប

| ភាគរយតែត្រូវបង្កើន ឬកែលម្អសេវាកម្ម | បង្កើនការបែងចែកចំនួនសិស្ស ផ្អែកលើការចុះឈ្មោះរបស់យុវជនងាយរងគ្រោះ សិស្សរៀនភាសាអង់គ្លេស និងសិស្សដែលមានចំណូលទាប |
|---|---|
| 29.35% | $82,814,898 |

## សេចក្តីពិពណ៌នាសំខាន់ៗ

[ចំពោះសកម្មភាពដែលត្រូវបានផ្តល់ជូនទូទាំងសាលារៀន ឬក៏នៅទូទាំងសង្កាត់ (district) ឬក៏ការិយាល័យអប់រំខោនធី (COE) សេចក្តីពន្យល់អំពី (1) តើតំរូវការរបស់យុវជនងាយរងគ្រោះ សិស្សរៀនភាសាអង់គ្លេស និងសិស្សដែលមានចំណូលទាបត្រូវបានគេពិចារណាមុនគេយ៉ាងដូចម្តេច និង (2) តើសកម្មភាពទាំងនេះមានប្រសិទ្ធភាពត្រឹមកម្រិតណា ដើម្បីបំពេញសេចក្តីត្រូវការរបស់សិស្សទាំងនោះ។]

បុគ្គលិកសង្កាត់ (district) បានសហការគ្នារៀបចំផែនការបែងចែក និងកំណត់ចំនួនកុំព្យូទ័រយួរដៃ ឧបករណ៍បញ្ចូលភ្លើង និងវ៉ាយហ្វាយ ប្រកបដោយយុទ្ធសាស្ត្រដែលជាសេចក្តីត្រូវការរបស់យុវជនងាយរងគ្រោះ សិស្សរៀនភាសាអង់គ្លេស និងសិស្សដែលមានចំណូលទាប ដើម្បីធានាថា ការចូលប្រើអ៊ីនធឺណិត និងការតភ្ជាប់អ៊ីនធឺណិតត្រូវបានផ្តល់ជូនគ្រួសារសិស្ស។ សិស្សដែលត្រូវការកុំព្យូទ័រយួរដៃទាំងអស់ត្រូវទទួលបានកុំព្យូទ័រយួរដៃមួយគ្រឿង ក្នុងឆ្នាំសិក្សា2020-2021 ព្រមទាំងវ៉ាយហ្វាយ។ ការសម្រេចនូវគោលដៅ និងជំនួយផ្នែកបច្ចេកវិទ្យា ត្រូវបានសម្របសម្រួលរវាងការិយាល័យទទួលបន្ទុកគ្រួសារសិស្សក្នុងពេលអន្តរកាល និងយុវជនងាយរងគ្រោះ (Families in Transition and Foster Youth office)  ផ្នែកទទួលបន្ទុកផ្តល់សេវាជំនួយដល់សិស្ស (Student Support Services department) និងផ្នែកទទួលបន្ទុកផ្តល់សេវាអប់រំ (Ed Services department)។ ចំពោះសិស្សមិនមានការតភ្ជាប់ប្រព័ន្ធអ៊ីនធឺណិតដោយសារតែរង់ចាំវ៉ាយហ្វាយមកដល់សង្កាត់ (district) បុគ្គលិកសិក្សា សហការជាមួយគ្រួសារនៃយុវជន ងាយរងគ្រោះ សិស្សរៀនភាសាអង់គ្លេស និងសិស្សដែលមានចំណូលទាប ដើម្បីអភិវឌ្ឍកម្មវិធីសិក្សាឯករាជ្យប្រចាំសប្តាហ៍ ដែលមានផ្តល់ជូននូវ សម្ភារៈសិក្សា ដោយមានជំនួយ និងការណែនាំពីលោកគ្រូ អ្នកគ្រូ និងមន្ត្រីពិគ្រោះយោបល់ ដើម្បីធានាបាននូវការទទួលបានខ្លឹមសារសិក្សាតាម កម្រិតសិក្សា។ វិធានការណ៍ទាំងនេះមានប្រសិទ្ធភាព

ដោយបានបំពេញនូវសេចក្តីត្រូវការនៃការចូលប្រើអ៊ីនធឺណិត និងការតភ្ជាប់ប្រព័ន្ធអ៊ីនធឺណិត ក្នុងការសិក្សាពីចម្ងាយ និងការសិក្សាដោយផ្ទាល់។ Netops ត្រូវបានគេប្រើដើម្បីផ្តល់ជូនលោកគ្រូ អ្នកគ្រូនូវសមត្ថភាពតាមដានសកម្មភាពសិក្សារបស់សិស្សនៅលើ Chromebook និង Windows ដើម្បីធានាឲ្យបាននូវការប្រើប្រាស់ត្រឹមត្រូវ និងការឆ្លើយតបទាន់ពេលវេលាដល់សិស្សក្នុងអំឡុង ពេលបង្រៀន ក៏ដូចជាតាមដានវឌ្ឍនភាពនៃកិច្ចការរបស់សិស្ស។ Software នេះផ្តល់ជូនការចូលរៀន និងជម្រើសសម្រាប់លោកគ្រូ អ្នកគ្រូ ដើម្បី បង្ហាញខ្លឹមសារបង្រៀនដល់សិស្សមើលនៅលើអេក្រង់ និងបង្ហាញខ្លឹមសាររបស់សិស្សម្នាក់ៗជូនសិស្សទាំងអស់មើលនៅលើអេក្រង់ តាមរយៈឧបករណ៍បញ្ចាំងស្លាយដ៍ (projector) ឧបករណ៍បង្រៀនផ្ទាល់ (lock devices) ព្រមទាំងកំណត់កម្មវិធី និងគេហទំព័រជាយុទ្ធសាស្ត្រសម្រាប់សិស្សឱ្យចូលប្រើក្នុងម៉ោងបង្រៀនក្នុងថ្នាក់ ដើម្បីបង្កើនសកម្មភាពសិក្សាពីចម្ងាយ និងសកម្មភាពបង្រៀនដោយផ្ទាល់។

Stockton Unified School District បានផ្តល់ជូនលោកគ្រូ អ្នកគ្រូ K-12 នូវការអភិវឌ្ឍវិជ្ជាជីវៈ និងការបង្ហាត់បង្ហាញប្រកបដោយគុណភាពខ្ពស់ ទាំងការរៀនកសាងចំណេះដឹង និងជំនាញរបស់ពួកគេ ដើម្បីជួយដល់សិស្សរៀនអង់គ្លេសចូលរួមក្នុងការបង្រៀនដែលមានលក្ខណៈរួមបញ្ចូល និង ពិសេស ក្នុងម៉ោងសិក្សាតាមអ៊ីនធឺណិត។ វគ្គបណ្តុះបណ្តាលអំពីជំនាញវិជ្ជាជីវៈត្រូវបានបង្កើត និងអនុវត្តឡើង ដើម្បីផ្តល់ជូនលោកគ្រូ អ្នកគ្រូនូវឱកាសទទួលបានចំណេះដឹងអំពីគរុកោសល្យ  អនុសាសន៍ល្អៗទាក់ទងនឹងឧត្តមានុវត្តដែលផ្អែកលើការសិក្សាស្រាវជ្រាវ និងវិធីសាស្ត្រនៃការបញ្ចូល បច្ចេកវិទ្យា ទៅក្នុងការសិក្សាពីចម្ងាយ។ ជាមួយគ្នានេះដែរ  ការបង្ហាត់បង្ហាញត្រូវបានផ្តល់ឱកាសគិតឲ្យបានស៊ីជម្រៅ និងឆ្លុះបញ្ចាំងអំពីបទពិសោធន៍ របស់ពួកគេ ដែលជាមធ្យោបាយមួយសម្រាប់កែលម្អការអនុវត្តរបស់ពួកគេ និងផ្តល់នូវការបង្រៀនប្រកបដោយអត្ថន័យ។ លើសពីនេះទៀត លោកគ្រូ អ្នកគ្រូ ទទួលបាននូវជំនួយកម្មវិធីសិក្សា និងធនធានដែលជួយដល់ការសិក្សាភាសាអង់គ្លេស។ មាតាបិតាសិស្សទទួលបាននូវសេវាបកប្រែ ដើម្បីធានា បាននូវការប្រាស្រ័យទាក់ទងប្រកបដោយអត្ថន័យ និងមានសិទ្ធិទទួលបានព័ត៌មានទាក់ទងនឹងសាលារៀន ដើម្បីធ្វើសេចក្តីសម្រេចចិត្តផ្អែកលើ ព័ត៌មានដែលមាន និងចូលរួមអប់រំកូនៗរបស់ពួកគេ។

អ្នកគ្រប់គ្រងសង្កាត់ (district)ទទួលបន្ទុកសេវាសង្គមកិច្ច និងមន្ត្រីទំនាក់ទំនងគ្មានផ្ទះសម្បែងត្រូវទាក់ទងទៅកាន់សិស្ស ដោយហៅទូរសព្ទ ផ្ញើអ៊ីម៉ែល និងជួបជាមួយក្រុមគ្រួសាដែលស្ថិតក្នុងអន្តរកាលនៅទីលំនៅដែលពួកគេស្គាល់ និងទៅជួបសិស្ស និងគ្រួសាររបស់ពួកគេ ដោយរក្សានូវគម្លាតសង្គម ដើម្បីជួយដល់គ្រួសារដែលត្រូវការជំនួយ ទទួលបានធនធានសិក្សា ហើយសិស្សយល់អំពីរបៀបចូលរួម និងឧបសគ្គដែលកើតមានចំពោះពួកគេក្នុងការសិក្សាពីចម្ងាយ។ បុគ្គលិកសង្កាត់ (district) បានធ្វើការជាមួយបុគ្គលិកសង្គម អង្គការមិនរកប្រាក់ចំណេញក្នុងមូលដ្ឋាន សិស្សានុសិស្ស និងមាតាបិតាសិស្ស/អាណាព្យាបាលសិស្ស ដើម្បីធានាថា យុវជនមានសិទ្ធិទទួលបានទំនាក់ទំនងជាប្រចាំជាមួយលោកគ្រូ អ្នកគ្រូ មន្ត្រីប្រឹក្សាយោបល់ និង/ឬ ពេទ្យសុខភាពផ្លូវចិត្ត ក្នុងជំនួយដល់ឱកាសសិក្សាអំពីសង្គម និងអារម្មណ៍ កុំព្យូទ័រយួរដៃ និងវ៉ាយហ្វាយសម្រាប់ភ្ជាប់ប្រព័ន្ធអ៊ីនធឺណិត ចូលរួមសិក្សា ពីចម្ងាយដែលសង្កាត់ (district) បានផ្តល់ជូន។

ការយកចិត្តទុកដាក់លើជំងឺប៉ះទង្គិចផ្លូវចិត្ត ការអនុវត្តការស្តារឡើងវិញ និងការបណ្តុះបណ្តាលអំពីអន្តរាគមន៍ និងជំនួយដើម្បីទទួលបានអាកប្ប កិរិយាវិជ្ជមាន (PBIS) ត្រូវបានផ្តល់ជូន ដោយផ្តោតលើដំណោះស្រាយនូវផលប៉ះពាល់នៃជម្ងឺ COVID-19 ទៅលើយុវជនងាយរងគ្រោះ សិស្សរៀនភាសាអង់គ្លេស និងសិស្សដែលមានចំណូលទាប។ ឱកាសអភិវឌ្ឍវិជ្ជាជីវៈផ្តោតលើការផ្តល់ការសិក្សាពីចម្ងាយដែលមានគុណភាពខ្ពស់ ការចូលអានលក្ខណៈពិសេសនៃក្រុមប្រឹក្សាភិបាល Stockton Unified School District លើប្រព័ន្ធអ៊ីនធឺណិត ត្រូវបានអនុម័ត កម្មវិធីសិក្សាស្តង់ដារ ការផ្តល់ជំនួយផ្នែកសង្គម និងអារម្មណ៍ដល់ការសិក្សាដល់សិស្ស ប្រើប្រាស់វេទិកាតាមអ៊ីនធឺណិតដើម្បីបង្រៀន និងទាក់ទងជាមួយអ្នកដទៃ ដោយស្មើភាព ហើយប្រធានបទសិក្សាពីចម្ងាយផ្សេងទៀត ត្រូវបានផ្តល់ជូនបុគ្គលិកសិក្សា និងបុគ្គលិកសង្កាត់ (district) តាមរយៈកម្មវិធីវីដេអូលើប្រព័ន្ធអ៊ីនធឺណិតរៀងរាល់សប្តាហ៍។ ការបង្រៀន និងសិក្ខាសាលាតាមប្រព័ន្ធអ៊ីនធឺណិតត្រូវបានផ្តល់ជូនមាតាបិតា និងអាណាព្យាបាល ផ្តោតលើការជួយបង្កើនការយល់ ដឹងអំពីរបៀបប្រើ និងស្វែងរកកម្មវិធីសិក្សាពីចម្ងាយ ធនធានកម្មវិធីសិក្សាលើប្រព័ន្ធអ៊ីនធឺណិត និងកម្មវិធីធ្វើសន្និសីទវីដេអូ ដែលត្រូវបានប្រើសម្រាប់ ការបង្រៀនផ្ទាល់ និងការសិក្សាស្របតាមស្តង់ដា។

មានមន្ត្រីប្រឹក្សាយោបល់ម្នាក់យ៉ាងតិចត្រូវបានចាត់តាំងឲ្យជួយដល់កន្លែងសិក្សាថ្នាក់ទី8 ប្រាំថ្ងៃក្នុងមួយសប្តាហ៍ និងមន្ត្រីប្រឹក្សាយោបល់ជាច្រើននាក់ដែលជាបុគ្គលិកវិទ្យាល័យ ដើម្បីធ្វើការណែនាំអំពីការសិក្សា និងតម្រូវការខាងអារម្មណ៍ និងសង្គមរបស់សិស្ស។ មន្ត្រីប្រឹក្សាយោបល់បានបង្កើតមេរៀនអំពីអារម្មណ៍ និងសង្គម ដើម្បីបញ្ចូលទៅក្នុងបទពិសោធន៍សិក្សាពីចម្ងាយដែលលើកឡើងអំពីផលប៉ះពាល់នៃការប៉ះទង្គិចផ្លូវចិត្ត និងភាពឯកោ ដោយសារជម្ងឺ COVID-19

ទៅលើយុវជនងាយរងគ្រោះ សិស្សរៀនភាសាអង់គ្លេស និងសិស្សដែលមានចំណូលទាប។ រង្វង់ស្ការ និងយុទ្ធសាស្ត្រជួបជុំគ្នាក្នុងថ្នាក់រៀនត្រូវបានបង្កើតឡើង ដើម្បីអនុវត្ត នៅក្នុងការសិក្សាពីចម្ងាយ ដើម្បីផ្តល់ឱកាសដល់សិស្ស ក្នុងការចែករំលែកអារម្មណ៍របស់ពួក គេ និងទំនាក់ទំនងជាមួយមិត្តភក្តិរបស់ពួកគេ នៅក្នុងកម្មវិធីសិក្សាពីចម្ងាយ។ មន្ត្រីប្រឹក្សាយោបល់ប្រចាំវិទ្យាល័យបានជួយដល់លោកគ្រូ អ្នកគ្រូ យុវជនងាយរងគ្រោះ សិស្សរៀនភាសាអង់គ្លេស និងសិស្សដែលមានចំណូលទាប ក្នុងការបង្កើតប្រព័ន្ធគ្រប់គ្រងពេលវេលា ដើម្បីគាំទ្រដល់ភាព ជោគជ័យ ទាំងការបង្រៀនពីចម្ងាយ និងការសិក្សាក្នុងថ្នាក់។ មន្ត្រីប្រឹក្សាយោបល់ជួយពង្រឹង និងរៀបចំប្រព័ន្ធសម្រាប់សិស្សកំណត់គោលដៅឲ្យបានត្រឹមត្រូវ កំណត់អាទិភាពកិច្ចការប្រចាំសប្តាហ៍ កំណត់ថេរវេលាដែលត្រូវបំពេញភារកិច្ច កែលម្អពេញមួយថ្ងៃ យុទ្ធសាស្ត្ររៀបចំលំហការងារ រៀបចំផែនការទុកជាមុន ដើម្បីដោះស្រាយបញ្ហាប្រឈមដែលអាចកើតឡើង។

បុគ្គលិកពេទ្យផ្នែកសុខភាពផ្លូវចិត្ត និងសមាជិកក្រុមអន្តរាគមន៍អាកប្បកិរិយា ត្រូវផ្តល់ជំនួយផ្នែកសុខភាពផ្លូវចិត្ត និងអាកប្បកិរិយា នៅតាមសាលារៀននីមួយៗ ទូទាំង Stockton Unified School District។ បុគ្គលិកពេទ្យផ្នែកសុខភាពផ្លូវចិត្ត និងបុគ្គលិកក្រុមអន្តរាគមន៍អាកប្បកិរិយា ត្រូវលើកកម្ពស់ការអភិវឌ្ឍផ្នែកសង្គម និងអារម្មណ៍ដើម្បីឲ្យសិស្សទាំងអស់គ្នាមានសុខភាពល្អ និងដោះស្រាយជាចម្បងនូវតម្រូវការទាក់ទងទៅនឹងការប៉ះទង្គិចផ្លូវ ចិត្ត និងឧបសគ្គទាក់ទងនឹងសុខភាពផ្លូវចិត្ត ដែលយុវជនងាយរងគ្រោះជាច្រើននាក់ សិស្សរៀនអង់គ្លេស និងសិស្សមានចំណូលទាបបានជួបប្រទះក្នុងការសិក្សាពីចម្ងាយ។ បុគ្គលិកជាសមាជិកផ្តល់នូវសេវាពិគ្រោះយោបល់ ដើម្បីដោះស្រាយនូវតម្រូវការរបស់យុវជនងាយរងគ្រោះ សិស្សរៀនភាសាអង់គ្លេស និងសិស្សដែលមានចំណូលទាប ក្នុងម៉ោងព្យាបាលបុគ្គល ក្រុម និងគ្រួសារ។ ក្នុងពេលសិក្សាពីចម្ងាយ ខ្សែអាត់វីដេអូដែលចែកចាយ អំពីយុទ្ធសាស្ត្រចងចាំរបស់សិស្ស គ្រួសារ និងបុគ្គលិក ដែលមានចំណងជើងថា Mindful Mondays ត្រូវបានបង្កើត និងផ្តល់ជូនជាច្រើនភាសា។

ផ្នែកសុខភាពផ្លូវចិត្ត និងសេវាកម្ម បានផ្តល់ជូនមាតាបិតា អាណាព្យាបាល គ្រួសារ និងបុគ្គលិកនូវធនធានសិក្សាពីចម្ងាយ ដែលរួមមាន insta-coffee talks (ការបណ្តុះបណ្តាលដែលថតទុកជាមុនអំពីប្រធានបទផ្សេងៗ) យុទ្ធសាស្ត្រគ្រប់គ្រងអាកប្បកិរិយានៅពេលសិក្សាពីចម្ងាយ ការយកចិត្តទុកដាក់ លើការរងរបួស ការអប់រំ និងជំបូន្មានភ្លាមៗ អន្តរាគមន៍ និងជំនួយអាកប្បកិរិយាវិជ្ជមាន (PBIS) នៅក្នុងការសិក្សាពីចម្ងាយ និងការសិក្សានៅតាមផ្ទះ និងយុទ្ធសាស្ត្រអប់រំដែលទាក់ទងនឹងរបួស។ ប្រធានបទនៃសិក្ខាសាលាដែលផ្តល់ជូនគ្រួសារ និងបុគ្គលិក រួមមាន៖ ការដោះស្រាយអំពីការភ័យខ្លាច និងការថប់បារម្ភអំពីការវិលត្រឡប់ទៅសាលារៀនវិញ ការកសាងទំនាក់ទំនង និងការឆ្លើយតបទៅនឹងកង្វល់របស់សិស្ស ការគ្រប់គ្រងស្ត្រេសសម្រាប់ មន្ត្រីសិក្សាកិច្ចស្វាគមន៍សិស្ស ការបង្កើតនូវលំហការងារ វិធីជំរុញទឹកចិត្តក្នុងការសិក្សា យុទ្ធសាស្ត្រគ្រប់គ្រងអាកប្បកិរិយា ដែលមានការលំបាក និង រៀបចំកាលវិភាគ។ បុគ្គលិកពេទ្យផ្នែកសុខភាពផ្លូវចិត្ត និងបុគ្គលិកគ្រប់គ្រងអាកប្បកិរិយា មានប្រសិទ្ធភាពបំពេញសេចក្តីត្រូវការរបស់សិស្ស បង្កើនការសិក្សាពីចម្ងាយ ដោយរួមបញ្ចូលការអនុវត្ត ដែលមានការប៉ះទង្គិចផ្លូវចិត្ត និងអន្តរាគមន៍ និងជំនួយអាកប្បកិរិយាវិជ្ជមាន (PBIS)  ទៅក្នុង វប្បធម៌ថ្នាក់រៀន ដើម្បីជួយអភិវឌ្ឍបទពិសោធន៍សិក្សាពីចម្ងាយប្រកបដោយភាពរាក់ទាក់ សុវត្ថិភាព និងសុខភាពល្អសម្រាប់សិស្ស និងបុគ្គលិក។

យុវជនងាយរងគ្រោះ សិស្សរៀនភាសាអង់គ្លេស និងសិស្សដែលមានចំណូលទាប ត្រូវទទួលបានសម្ភារៈសិក្សាដើម្បីជួយឲ្យជួយដល់ពួកគេក្នុងការ សិក្សាពីចម្ងាយ។ សាលារៀន និងគ្រួសារដែលស្ថិតក្នុងអន្តរកាល និងយុវជនងាយរងគ្រោះត្រូវទទួលបាននូវហ្វឹតហាយឡៃ ដីស សៀវភៅកត់ត្រា និងសម្ភារៈផ្សេងៗទៀតសម្រាប់ប្រើប្រាស់ក្នុងលំនៅដ្ឋានរបស់ពួកគេ ក្នុងពេលសិក្សាពីចម្ងាយ។ Stockton Unified School District បានបញ្ជាឱ្យមានផ្តល់ជូននូវសម្ភារៈជាលក្ខណៈបុគ្គលដល់យុវជនងាយរងគ្រោះ សិស្សរៀនភាសាអង់គ្លេស និងសិស្សដែលមានចំណូលទាប នៅពេលការសិក្សាដោយផ្ទាល់ត្រូវបានអនុញ្ញាត។ សកម្មភាពនិងសេវាកម្មទាំងនេះមានប្រសិទ្ធភាពដល់ការចូលរួមយ៉ាងសកម្មរបស់សិស្ស និងបង្កើនការទទួលបានជំនួយដើម្បីឱ្យសិស្សមានធនធានដែលពួកគេត្រូវការ ទាំងក្នុងលំនៅដ្ឋាន និងក្នុងថ្នាក់រៀន ដើម្បីចូលរួមដោយផ្ទាល់ក្នុងការសិក្សា។

មន្ត្រីពិគ្រោះយោបល់ប្រចាំសាលារៀនទាក់ទងជាមួយយុវជនងាយរងគ្រោះ និងសិស្សសាលាក្នុងពេលអន្តរកាល ដើម្បីធានាថា ពួកគេអាចចូលរួមក្នុងការសិក្សាពីចម្ងាយ និងអាចបំពេញតាមតម្រូវការមូលដ្ឋានរបស់ពួកគេ។ មន្ត្រីពិគ្រោះយោបល់ប្រចាំសាលាសហការជាមួយគ្រួសារសិស្ស ដើម្បីពង្រឹងទំនាក់ទំនងរវាងផ្ទះនិងសាលារៀន។ យុវជនងាយរងគ្រោះ/គ្រួសារក្នុងពេលអន្តរកាល/សិស្សរៀនភាសាអង់គ្លេសត្រូវបានបង្រៀនអំពីជំនាញសិក្សាក្នុងសង្គម តាមរយៈមេរៀនក្នុងថ្នាក់ (រួមទាំងកម្មវិធីសិក្សាជំហានទី 2) ដោយមន្ត្រីប្រឹក្សាយោបល់ប្រចាំសាលាដែលផ្តល់ការត្រួតពិនិត្យម្តងមួយៗ និងជំនួយជាក្រុម។ មន្ត្រីពិគ្រោះយោបល់ប្រចាំសាលាសហការជាមួយផ្នែកអភិវឌ្ឍន៍ភាសា ជាពិសេសជាមួយលោកគ្រូ អ្នកគ្រូបង្រៀនភាសាអង់គ្លេសដើម្បីធានាថា សិស្សរៀនភាសាអង់គ្លេស ទទួលបានជំនួយផ្នែកអារម្មណ៍និងសង្គម និងជំនួយការសិក្សាក្នុងថ្នាក់របស់ពួកគេ។ មន្ត្រីប្រឹក្សាយោបល់ប្រចាំសាលាសហការជាមួយក្រសួងអប់រំពិសេស

ដើម្បីជួយសិស្សក្នុងកម្មវិធីអប់រំពិសេស ដើម្បីបំពេញសេចក្តីត្រូវការខាងអារម្មណ៍ និងសង្គម។ មន្ត្រីពិគ្រោះយោបល់ប្រចាំសាលាសហការជាមួយលោកគ្រូ អ្នកគ្រូ អប់រំពិសេស អ្នកគ្រប់គ្រងសំណុំរឿង ជំនាញការផ្នែកកម្មវិធី ចិត្តវិទូ ប្រចាំសាលា និងមន្ត្រីជំនាញខាងព្យាបាលការនិយាយ ដើម្បីតាមដានការរីកចម្រើនរបស់សិស្ស និងសុខុមាលភាពសង្គម។ ដើម្បីផ្តល់ជំនួយដល់ក្រុម សិស្សបន្ថែមទៀត (យុវជនងាយរងគ្រោះ និងយុវជនអនាថា ការសិក្សាភាសាអង់គ្លេស និងការអប់រំពិសេស) គឺជាចំណុចដែលត្រូវសុំជំនួយនៅតាមសាលារៀនគេរៀងៗខ្លួន និងសហការជាមួយគ្រួសារដែលស្ថិតក្នុងអន្តរកាល ការអប់រំពិសេស និងក្រុមភាសាអង់គ្លេស ដើម្បីធានាថា សិស្សយើងទទួលបានជំនួយ និងធនធានសិក្សា អាជីព អារម្មណ៍និងសង្គម។

ក្នុងឆ្នាំសិក្សា ការិយាល័យអភិវឌ្ឍន៍ភាសា (LDO) នឹងផ្តល់ការបណ្តុះបណ្តាល និងសិក្ខាសាលាជាបន្តបន្ទាប់។ ការិយាល័យអភិវឌ្ឍន៍ភាសា (LDO) នឹងផ្តល់ឱកាស និងពេលវេលាជូនលោកគ្រូ អ្នកគ្រូ និងជំនួយការដែលចេះពីរភាសា ដើម្បីចូលរួមក្នុងវិទ្យាស្ថាន ELD និងសិក្ខាសាលាដែលកំពុង បន្ត។ ការិយាល័យអភិវឌ្ឍន៍ភាសា (LDO) នឹងផ្តល់នូវវគ្គបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈចម្រុះនិងចំពោះ សហការជាមួយគ្រឹះស្ថានបោះពុម្ពផ្សាយក្នុងការបញ្ចូលកម្មវិធីរបស់ការិយាល័យអភិវឌ្ឍន៍ភាសា (LDO) ផ្តោតលើការបណ្តុះបណ្តាលអំពីកម្មវិធីសិក្សារបស់គ្រឹះស្ថានបោះពុម្ពផ្សាយ។ លោកគ្រូ អ្នកគ្រូថ្មីនឹងទទួលបាននូវវគ្គសិក្សាជំនាញវិជ្ជាជីវៈ (ELD) ដែលមានលក្ខណៈរួមបញ្ចូលនិងចំពោះ។ ការិយាល័យអភិវឌ្ឍន៍ភាសា (LDO) នឹងធ្វើការបង្រៀនបណ្តុះបណ្តាល និងសិក្ខាសាលា ដើម្បីធានាថា លោកគ្រូ អ្នកគ្រូ អាចផ្តល់កម្មវិធីសិក្សាស្នូលដែលរឹងមាំនិងបំពេញតាមតម្រូវការរបស់សិស្សរៀនភាសាអង់គ្លេស តាមរយៈការសិក្សាពីចម្ងាយ និងការសិក្សាក្នុងថ្នាក់។ សង្កាត់ (district) រៀបចំកិច្ចប្រជុំសម្របសម្រួលសិស្សរៀន ភាសាអង់គ្លេសប្រចាំត្រីមាស (ELP) ដែលកម្មវិធីនេះយកគំរូតាមវិធីសាស្ត្រស្រាវជ្រាវដែលមានប្រសិទ្ធិភាព ដើម្បីធានាថា មន្ត្រីសម្របសម្រួលប្រចាំ សាលាបង្រៀនភាសាអង់គ្លេស ពាំនាំវិធីសាស្ត្របង្រៀនត្រឡប់មកសាលារៀនរបស់ពួកគេវិញដើម្បីបន្តកែលម្អការសិក្សាអង់គ្លេសក្នុងពេលការ អភិវឌ្ឍភាសាអង់គ្លេស ដែលមានលក្ខណៈរួមបញ្ចូលនិងចំពោះ។ វគ្គបណ្តុះបណ្តាលត្រូវបានផ្តល់ជូន ក្នុងពេលប្រជុំគណៈកម្មាធិការពិគ្រោះយោបល់ ជាមួយមាតាបិតាសិស្សរៀន ភាសាអង់គ្លេស (ELAC) និងជួយដល់ការកសាងសមត្ថភាពរបស់គណៈកម្មាធិការពិគ្រោះយោបល់ជាមួយមាតាបិតាសិស្ស រៀនភាសាអង់គ្លេស (ELAC) ដើម្បីចូលរួមជាមួយសិស្ស កម្មវិធី និងតម្រូវការថវិកា។ សេវាបកប្រែត្រូវបានផ្តល់ជូនបុគ្គលិក គ្រួសារ និង សមាជិក សហគមន៍ នៅតាមសាលារៀន ការប្រជុំគ្រួសារ វគ្គបណ្តុះបណ្តាល សិក្ខាសាលា និងកិច្ចប្រជុំប្រចាំសង្កាត់ (district)។ ការបកប្រែដោយសរសេរ និងនិយាយត្រូវបានផ្តល់ជូន ដើម្បីជួយដល់កិច្ចប្រជុំគ្រួសារ ឯកសារ បទបង្ហាញ កិច្ចប្រជុំកម្មវិធីអប់រំលក្ខណៈបុគ្គល (IEPs) និងទំនាក់ទំនងដល់សង្កាត់ (district)។

នៅទូទាំងសង្កាត់ (district) គ្រប់សាលារៀនទាំងអស់ត្រូវបានគេផ្តល់ជូនរយៈពេល 1 ម៉ោងកន្លះរៀងរាល់សប្តាហ៍ សម្រាប់លោកគ្រូ អ្នកគ្រូសហការ គ្នាអភិវឌ្ឍ ការបង្រៀនដំបូងប្រកបដោយគុណភាពខ្ពស់ ឆ្លើយតបទៅនឹងតម្រូវការសិក្សាអារម្មណ៍និងសង្គមរបស់សិស្សទាំងអស់ ទាំងការសិក្សាពីចម្ងាយ និងការបង្រៀនផ្ទាល់ ដោយផ្តោតជាយុទ្ធសាស្ត្រលើបទពិសោធន៍បង្រៀនផ្អែកលើការសិក្សាស្រាវជ្រាវ ប្រកបដោយប្រសិទ្ធភាព ដើម្បីបង្កើន សមិទ្ធិកម្មសិក្សារបស់យុវជនដែលមានចំណូលទាប យុវជនងាយរងគ្រោះ និងសិស្សរៀនអង់គ្លេស តាមរយៈការធ្វើផែនការយុទ្ធសាស្ត្រ និងបទពិសោធន៍ សិក្សាខុសៗគ្នា។ សាលារៀនបានបង្កើតកាលវិភាគសហការប្រចាំឆ្នាំ និងភាពជាអ្នកដឹកនាំសាលា បានសហការជាមួយសហគមន៍សិក្សាវិជ្ជាជីវៈ (PLCs) ដើម្បី កំណត់ជំនាញ និងការអភិវឌ្ឍរបស់បុគ្គលិកដែលត្រូវបំពេញបន្ថែម។ លោកគ្រូ អ្នកគ្រូបានផ្តល់ឱកាសដល់គ្រួសារសិស្សម្នាក់ៗដើម្បីចូលរួមក្នុងកិច្ចប្រជុំ រវាងលោកគ្រូ អ្នកគ្រូ មាតាបិតាសិស្ស/អាណាព្យាបាលសិស្ស/គ្រួសារសិស្ស។ សកម្មភាពចូលរួមរបស់គ្រួសារសិស្សត្រូវបានរៀបចំ និងប្រព្រឹត្តទៅនៅគ្រប់សាលារៀន គ្រប់ពេលវេលា ពេញមួយឆ្នាំសិក្សា។

សិស្សវិទ្យាល័យត្រូវបានផ្តល់ឱកាសចូលរួមក្នុងកម្មវិធីស្តារឥណទានសិក្សានិងបោះបង់ការសិក្សា (Credit and Dropout Recovery Program) នៅគ្រប់វិទ្យាល័យ ទាំងអស់។ លោកគ្រូ អ្នកគ្រូបានផ្តល់ជំនួយច្រើនទាំងមុនពេល ក្នុងអំឡុងពេល និងបន្ទាប់ពីឱកាសសិក្សានៅសាលារៀន ដើម្បីទទួលបាន កម្មវិធីស្តារឥណទានសិក្សា ដូចជា APEX និង Cyber High ដើម្បីជួយដល់សិស្សានុសិស្សដែលកំពុងតែឈានទៅបញ្ចប់ការសិក្សាថ្នាក់វិទ្យាល័យ។ នៅរដូវផ្ការីកឆ្នាំ2020 វគ្គបណ្តុះបណ្តាលអំពី APEX ចំនួន 1,503 វគ្គ ត្រូវបានបញ្ចប់ ហើយវគ្គបណ្តុះបណ្តាលអំពី Cyber High ចំនួន 120 វគ្គត្រូវបានបញ្ចប់ដើម្បីស្តារឥណទាន ឡើងវិញ។ យុវជនងាយរងគ្រោះ សិស្សរៀនអង់គ្លេស និងសិស្សមានចំណូលទាបត្រូវទទួលបាននូវកម្មវិធីស្តារឥណទាន និងជំនួយពីលោកគ្រូ អ្នកគ្រូ ក្នុងការឆ្លើយសំណួរសិស្ស និងផ្តល់ជំនួយបង្ហាត់បង្រៀនមួយកម្រិតទៀត ក្នុងការសិក្សាពីចម្ងាយ និងការផ្តល់ជំនួយបង្ហាត់បង្រៀនដោយផ្ទាល់ ដើម្បីទទួលបានការស្តារឥណទានឡើងវិញ និងការចូលរៀនវគ្គសិក្សា A-G ដល់សិស្សដែលត្រូវការការស្តារឥណទាន ឡើងវិញ។ មន្ត្រីពិគ្រោះយោបល់ប្រចាំសាលា និងអ្នកបច្ចេកទេសណែនាំនឹងផ្តល់ជូនការណែនាំអំពីការសិក្សា និងកិច្ចប្រជុំធ្វើផែនការនិងកំណត់គោលដៅឥណទានជាមួយយុវជនងាយរងគ្រោះ

សិស្សរៀនភាសាអង់គ្លេស និងសិស្សដែលមានចំណូលទាប ពេញមួយឆ្នាំដើម្បីជួយសិស្សដែលកំពុងតែឈានទៅបញ្ចប់ការសិក្សាថ្នាក់វិទ្យាល័យ។

ជំនាញការផ្នែកបរិយាប័ន្ន (Inclusion Specialists) គាំទ្រដល់សិស្សពិការ ជាពិសេសសិស្សដែលមានជម្ងឺអូឌីសឹម ដោយផ្តល់សេវាពិគ្រោះយោបល់ដល់លោកគ្រូ អ្នកគ្រូ មន្ត្រីរដ្ឋបាល និងមន្ត្រីជំនួយអំពីការអនុវត្តផ្អែកលើលទ្ធផលស្រាវជ្រាវ។ ជំនាញការផ្នែកបរិយាប័ន្ន គឺជាមន្ត្រីពិគ្រោះយោបល់អំពី ការអនុវត្តប្រកបដោយបរិយាប័ន្ន ដើម្បីជួយដល់លោកគ្រូ អ្នកគ្រូដែលបង្រៀនថ្នាក់អប់រំចំណេះទូទៅ លោកគ្រូ អ្នកគ្រូដែលបង្រៀនថ្នាក់អប់រំ ពិសេស មន្ត្រីរដ្ឋបាល និងបុគ្គលិកជំនួយ ក្នុងការធានាឱ្យសិស្សពិការទទួលបាននូវឱកាសដាក់បញ្ចូលក្នុងថ្នាក់រៀនចំណេះទូទៅ ទាំងការសិក្សាពី ចម្ងាយ និងការសិក្សាដោយផ្ទាល់។ ពួកគេជួយដល់ការផ្លាស់ប្តូរពីសាលាមត្តេយ្យទៅសិស្សថ្នាក់ទី 8 នៅពេលដែលពួកគេផ្លាស់ប្តូរទៅការអប់រំចំណេះ ទូទៅ ដោយផ្តល់ថ្នាក់អប់រំចំណេះទូទៅនូវការអនុវត្ត និងចំណេះដឹង ដែលនាំឱ្យសិស្សផ្លាស់ប្តូរយ៉ាងរលូនទៅកាន់បរិយាកាសសិក្សាដែលមិនសូវមាន ការរឹតត្បិតនៅក្នុងរង្វង់ឆ្នាំនេះ ដោយជួយដល់គ្រួសារ និងបុគ្គលិកផ្លាស់ប្តូរសិស្សដោយជោគជ័យ ក្នុងការសិក្សាពីចម្ងាយ និងការសិក្សាក្នុងថ្នាក់ ខណៈពេលជួយរៀបចំកាលវិភាគម៉ោងចេញលេង និងប្រព័ន្ធគ្រប់គ្រងអាកប្បកិរិយា ដើម្បីកាត់បន្ថយការថប់បារម្ភ និងការខកចិត្តរបស់សិស្ស។ ជំនួយអាចជាជំនាញមុខងារប្រតិបត្តិ បទពិសោធន៍បង្រៀនផ្អែកលើលទ្ធផលស្រាវជ្រាវ ការតស៊ូមតិដើម្បីអនុវត្តគោលវិធីបន្ថែមអំពីការសិក្សាដោយ ការយល់តាមរយៈការអភិវឌ្ឍកម្មវិធីសិក្សា (UDL) នៅក្នុងថ្នាក់រៀន ការកែប្រែអាកប្បកិរិយា ការចូលរួមក្នុងកិច្ចប្រជុំស្តីពីកម្មវិធីអប់រំសម្រាប់សិស្ស ម្នាក់ៗ និងសម្របសម្រួល ដំណើរទេសចរណ៍សម្រាប់សិស្សវិទ្យាល័យនិងគ្រួសាររបស់គេ ខណៈពេលដែលជួយដល់ជំនាញបណ្តោះអាសន្នពីថ្នាក់ទី 8 ដល់ទី 9។ ជំនាញការផ្នែកបរិយាប័ន្ន ជួយមាតាបិតាសិស្ស ដោយផ្តល់ការបណ្តុះបណ្តាលអំពីការផ្លាស់ប្តូរទៅកាន់បរិយាកាសក្នុងថ្នាក់រៀន ទម្លាប់ និងបទពិសោធន៍អប់រំ ដើម្បីបញ្ចូលទៅក្នុងបរិយាកាសនៅគេហដ្ឋាន ក៏ដូចជាបទពិសោធន៍ផ្អែកលើលទ្ធផលស្រាវជ្រាវ ដើម្បីបង្កើនភាពជោគជ័យ ក្នុងការសិក្សា និងអភិវឌ្ឍទំនាក់ទំនងក្នុងសង្គម។ លើសពីនេះទៀត ជំនាញការផ្នែកបរិយាប័ន្នបានផ្តល់ការបណ្តុះបណ្តាល/សិក្ខាសាលាដល់មន្ត្រី រដ្ឋបាល លោកគ្រូ អ្នកគ្រូ ដែលបង្រៀននៅថ្នាក់ អប់រំចំណេះទូទៅ និងបុគ្គលិកជំនួយ អំពីសិស្សដែលមានជម្ងឺអូឌីសឹម និងបទពិសោធន៍ផ្អែកលើ លទ្ធផលស្រាវជ្រាវ ដើម្បីគាំទ្រដល់ការផ្លាស់ប្តូររបស់ពួកគេ ទៅកាន់អប់រំចំណេះទូទៅតាមរយៈការសិក្សាពីចម្ងាយ និងការសិក្សាក្នុងថ្នាក់។

គ្រូបណ្តុះបណ្តាលបានជួយដល់លោកគ្រូ អ្នកគ្រូក្នុងការអនុវត្តកម្មវិធីសិក្សាថ្មី និងធ្វើឲ្យបទពិសោធន៍បង្រៀនខុសៗគ្នា ដើម្បីបំពេញតំរូវការផ្សេងៗរបស់ សិស្សគ្រប់កម្រិត។ គ្រូបណ្តុះបណ្តាលបានប្រើគំរូបង្រៀនពុទ្ធិ ដោយផ្តោតលើលោកគ្រូ អ្នកគ្រូដែលផ្តល់ការបង្រៀនដំបូងប្រកបដោយគុណភាព ខ្ពស់ដល់សិស្សដែលមានវប្បធម៌ និងភាសាខុសៗគ្នា ក្នុងកម្រិតសមត្ថភាពសិក្សាបច្ចុប្បន្ន។ គ្រូបណ្តុះបណ្តាលត្រូវបានផ្តល់ការបណ្តុះបណ្តាលផ្អែក លើកម្មវិធីសិក្សាដែលគ្រឹះស្ថានបោះពុម្ពផ្សាយ និងការបណ្តុះបណ្តាលអំពីការបង្រៀន និងការសិក្សាភាសា និងវប្បធម៌។ សាលាទាំងអស់ត្រូវទទួល ជំនួយពីគ្រូបណ្តុះបណ្តាលដែលផ្តោតលើវិធីសាស្ត្រ ដើម្បីជួយដល់លោកគ្រូ អ្នកគ្រូ កសាងសមត្ថភាពបង្ហាត់បង្រៀន ដើម្បីបែងចែកមេរៀនឲ្យខុស ពីគ្នា ដើម្បីធានាបាននូវការយល់ដឹងអំពីមេរៀនស្តង់ដារ សម្រាប់សិស្សទាំងអស់ ក្នុងការសិក្សាពីចម្ងាយ និងការសិក្សាក្នុងថ្នាក់។ ជំនួយត្រូវបានផ្តល់ជូនដោយផ្តោតលើ ការបំពេញតំរូវការរបស់សិស្សរៀនភាសាអង់គ្លេសក្នុងកម្មវិធីអភិវឌ្ឍភាសាអង់គ្លេសដែលមានលក្ខណៈរួមបញ្ចូល (ELD)។ វគ្គនៃការបណ្តុះបណ្តាលក្នុងថ្នាក់ ធានាបាននូវការបង្រៀនបែបអន្តរកម្មដោយផ្ទាល់ សំណួរកម្រិតខ្ពស់ ការចូលរួមរបស់សិស្ស ភ័ស្តុតាង ដែលប្រើប្រាស់វិធីសាស្ត្រវាយតំលៃ ដើម្បីតាមដាន ប្រសិទ្ធភាពនៃការណែនាំ ការអភិវឌ្ឍ និងការវិភាគអំពីវិធីសាស្ត្រវាយតម្លៃក្នុងថ្នាក់រៀន និងកិច្ចតែងការមេរៀនរួម ដើម្បីធានាថា គោលដៅដែលអាច វាស់វែងបានត្រូវបានកំណត់ ហើយមេរៀនត្រូវបានធ្វើឲ្យខុសគ្នា ដើម្បីឆ្លើយតបនឹងតម្រូវការសិក្សាជាក់លាក់របស់យុវជនងាយរងគ្រោះ សិស្សរៀនអង់គ្លេស និងសិស្សដែលមានចំណូលទាប។ គ្រូបណ្តុះបណ្តាលបានចូលរួមក្នុងបទពិសោធន៍ សិក្សាប្រកបដោយវិជ្ជាជីវៈក្នុងឆ្នាំសិក្សា2019-2020 និង ក្លាយជាគ្រូបណ្តុះបណ្តាលអំពីការអនុវត្តកម្មវិធីសិក្សាក្នុងឆ្នាំសិក្សា2020-2021។

សាលារៀនទាំងអស់បានទទួលការបែងចែកថវិកា ផ្អែកលើចំនួនសិស្ស មូលដ្ឋានទិន្នន័យអប់រំមូលដ្ឋានរដ្ឋកាលីហ្វ័រញ៉ា (CBED) និងភាគរយនៃយុវជន ងាយរងគ្រោះ សិស្សរៀនភាសាអង់គ្លេស និងសិស្សដែលមានចំណូលទាបដែលបានចូលរៀន ដើម្បីឆ្លើយតបនឹងតម្រូវការ បង្កើន ឬក៏កែលម្អ សេវាកម្មដែលត្រូវបានផ្តល់ជូននៅសាលារៀន នៅពេលប្រជុំរៀបចំផែនការយុទ្ធសាស្ត្រជាមួយសាលា និងថ្នាក់ដឹកនាំសង្កាត់ (district) ដោយផ្តោតលើ ការសម្រេចចិត្តផ្អែកលើទិន្នន័យ និងការវិភាគអំពីមូលហេតុ។ ដំណើរការនេះត្រូវបានអនុញ្ញាតឲ្យមានការសម្រេចចិត្តថ្នាក់សាលារៀន ដោយសហការជាមួយ ក្រុមប្រឹក្សាសាលា (School Site Council) និងការពិគ្រោះយោបល់ និងអនុសាសន៍របស់គណៈកម្មាធិការប្រឹក្សាយោបល់អំពីសិស្សរៀនភាសាអង់គ្លេស ដែលត្រូវស្របទៅនឹងផែនការត្រួតពិនិត្យនិងគណនេយ្យភាពថ្នាក់មូលដ្ឋាននៃសង្កាត់ (district) (LCAP) និងផែនការសាលារៀនសម្រាប់សមិទ្ធិកម្មសិស្ស (SPSA)

ដែលឆ្ពោះទៅរកការបង្កើន និងកែលំអសេវាកម្មដែលផ្តល់ជូនដល់យុវជនសិស្សរៀនភាសាអង់គ្លេស សិស្សពិការ និងក្រុមសិស្សដែលមានចំណូលទាប ក្នុងអំឡុងពេលសិក្សាពីចម្ងាយ និងការសិក្សាក្នុងថ្នាក់។ សាលារៀនបានប្រើថវិកាបម្រុងទុកដើម្បីបង្កើនជំនួយដល់មន្ត្រីពិគ្រោះយោបល់ ជំនួយការបណ្ណាល័យផ្នែកប្រព័ន្ធផ្សព្វផ្សាយ ធនធានបង្រៀនបន្ថែម ជំនួយការដែលចេះពីរភាសា ជំនួយការផ្នែកបង្រៀន មន្ត្រីទំនាក់ទំនង ជាមួយមាតាបិតាសិស្ស ជំនួយការសហគមន៍ ជំនួយការនាយកសាលាបន្ថែម ជំនាញការផ្នែកកម្មវិធី ដំណើរកំសាន្ត វត្តមាន និងការ លើកទឹកចិត្តលើការសិក្សា បន្ទាប់ពីការបង្រៀននៅសាលា ព្រឹត្តិការណ៍ចូលរួមរបស់គ្រួសារ និងធនធានផ្នែកលើភ័ស្តុតាងផ្សេងទៀត ដើម្បីបង្កើន និងធ្វើឱ្យប្រសើរឡើង នូវការរីកចម្រើនលើការសិក្សា និងការអភិវឌ្ឍសង្គមនិងអារម្មណ៍ ដល់ក្រុមសិស្សបង្គោល ដែលក្នុងនោះទិន្នន័យបន្តបង្ហាញ អំពីការកើនឡើងនូវសេវាកម្ម និងជំនួយដែលត្រូវផ្តល់ជូនដើម្បីធានាដល់ការរីកចម្រើនលើការសិក្សា និងការអភិវឌ្ឍផ្នែកសង្គមនិងអារម្មណ៍ ដែល ជួយសិស្សដែលបញ្ចប់ថ្នាក់វិទ្យាល័យ បានត្រៀមខ្លួនសម្រាប់មហាវិទ្យាល័យ អាជីព និងការត្រៀមខ្លួនរបស់សហគមន៍។
ផ្តោតលើការបំពេញតំរូវការរបស់យុវជនជម្រុញអ្នកសិក្សាភាសាអង់គ្លេសនិងសិស្សមានប្រាក់ចំណូលទាបដែលមានកម្មវិធី IEP នៅវិទ្យាល័យកម្មវិធីអន្តរាគមន៍ការអានត្រូវបានផ្តល់ដើម្បីបង្កើននិងកែលំអសមត្ថភាពរបស់សិស្សទាំងនេះក្នុងការទទួលបានការគាំទ្រអន្តរាគមន៍ ពីការអានដែលផ្អែកលើការស្រាវជ្រាវនិងអាចចូលដំណើរការបានយ៉ាងងាយស្រួល។ តាមរយៈការសិក្សាពីចម្ងាយ។ កម្មវិធីអន្តរាគមន៍នៃការអានត្រូវបានគាំទ្រដោយគ្រូនិងរបាយការណ៍ទិន្នន័យអំពីវឌ្ឍនភាពត្រូវបានផ្តល់ជូនដល់សិស្សនិងក្រុមគ្រួសារ។ អន្តរាគមន៍នៃការអានគឺជាការគាំទ្របន្ថែមនិងផ្តោតជាចម្បងលើការបំពេញតំរូវការអក្ខរកម្មរបស់សិស្សជាមួយកម្មវិធី IEP ដែលជាយុវជនចិញ្ចឹមសិស្សភាសាអង់គ្លេសឬសិស្សមានប្រាក់ចំណូលទាប។

[សេចក្តីពិពណ៌នាអំពីរបៀបបង្កើន ឬកែលម្អភាគរយនៃសេវាកម្មដែលយុវជនងាយរងគ្រោះ សិស្សរៀនភាសាអង់គ្លេស និងសិស្សដែលមានចំណូលទាបត្រូវការ។]

ការផ្លាស់ប្តូរទៅកាន់ការសិក្សាពីចម្ងាយបានផ្តល់នូវឱកាសពិសេសមួយដើម្បីដោះស្រាយបញ្ហាគម្លាតបច្ចេកវិទ្យា និងការតភ្ជាប់ដែលជះឥទ្ធិពលដោយផ្ទាល់ដល់ការកើនឡើង និងការធ្វើឱ្យប្រសើរឡើងនូវការចូលរួមទៅកាន់ភាគីពាក់ព័ន្ធ ការសិក្សា សុខភាពផ្លូវចិត្ត និងសុខុមាលភាពអារម្មណ៍ មុនពេល និងក្នុងពេលនៃការរីករាលដាលនៃជម្ងឺរាតត្បាត COVID-19។ តំរូវការដែលស្របនឹងការសិក្សាពីចម្ងាយបានផ្តល់ឱកាសបន្ទាន់ថ្មីមួយ ដែលធានាឲ្យយុវជនទាំងអស់ សិស្សរៀនភាសាអង់គ្លេស និងសិស្សដែលមានចំណូលទាប មានលទ្ធភាពប្រើប្រាស់កុំព្យូទ័រយួរដៃ និងអ៊ីនធឺណិតនៅលំនៅដ្ឋានរបស់ពួកគេ។ ដោយពិនិត្យឡើងវិញលើសេវាកម្ម ធនធាន និងក្របខ័ណ្ឌដែលផ្តល់ជូនសិស្ស ទស្សនវិស័យថ្មី ទាក់ទងនឹងការចូលមើល ធនធានសិក្សា និងធនធានវីដេអូបាន កើតឡើង ហេតុដូច្នេះការយល់ដឹងទូលំទូលាយអំពីវិធីបង្កើន និងកែលម្អសេវាកម្មអាចត្រូវបានផ្តល់ជូនក្នុង ទម្រង់សមកាលកម្ម និងអសមកាល ក្នុងការផ្តល់ជូននូវការសិក្សា សុខភាព និងសេវាកម្មសុខុមាលភាពដល់សិស្ស គ្រួសារ និងបុគ្គលិក។ SUSD បានទិញ និងបែងចែកកុំព្យូទ័រយួរដៃ និងវ៉ាយហ្វាយ ដើម្បីជំរុញយុវជនងាយរងគ្រោះ សិស្សរៀនភាសាអង់គ្លេស និងសិស្សដែលមានចំណូលទាប ដើម្បីបង្កើន និងកែលម្អលទ្ធភាពទទួលបានការសិក្សា ធនធានសិក្សា អារម្មណ៍ និងសង្គម និងឧបករណ៍នានា នៅសាលារៀន និងនៅផ្ទះ ដែលគាំ ទ្រដល់ការបង្កើនជំនាញបច្ចេកទេស ដែលអាចអនុវត្តបាន និងត្រូវការ ដើម្បីបញ្ចប់ថ្នាក់វិទ្យាល័យ ថ្នាក់មហាវិទ្យាល័យ អាជីព និងការត្រៀមខ្លួនរបស់ សហគមន៍។ ចំពោះសិស្សដែលមានចំណូលទាប សិស្សរៀនភាសាអង់គ្លេស និងសិស្សយុវជនងាយរងគ្រោះដែលចូលប្រើអ៊ីនធឺណិតដែលត្រូវបានផ្ញើទៅពួកគេ គឺជាបទពិសោធន៍ថ្មី នៅកន្លែងស្នាក់នៅរបស់ពួកគេ។ នៅពេលដែល គោលការណ៍ណែនាំស្តីពីសុខភាពនិងសុវត្ថិភាពសាធារណៈ អនុញ្ញាតឱ្យមានការផ្តល់ជូនដោយផ្ទាល់ យុវជនងាយគ្រោះ សិស្សរៀនភាសាអង់គ្លេស និងសិស្សដែលមានចំណូលទាប នឹងអាចបន្តទទួលបានកុំព្យូទ័រយួរដៃ និងសេវាអ៊ីនធឺណិតនៅលំនៅដ្ឋានរបស់ពួកគេ។

យុវជនងាយរងគ្រោះ សិស្សរៀនភាសាអង់គ្លេស និងសិស្សមានចំណូលទាបទទួលបានអាហារពេលព្រឹក អាហារថ្ងៃត្រង់ និងអាហារពេលល្ងាច ចំនួន 5ថ្ងៃ។ សិស្សមានសិទ្ធិទទួលបានមន្ត្រីពិគ្រោះយោបល់ ដើម្បីបំពេញសេចក្តីត្រូវការខាងសុខុមាលភាព សង្គម និងជំនួយសិក្សា និងតំរូវការក្នុងការកំណត់គោលដៅ។ នៅតាមសាលារៀនទាំងអស់ សេវាសុខភាពផ្លូវចិត្តក្នុងទម្រង់ជាបុគ្គល ជាក្រុម និងជាគ្រួសារ ត្រូវបានផ្តល់ជូនដើម្បីផ្តល់សេវាសុខភាព ផ្លូវចិត្តតាមកម្រិតនីមួយៗ។ យុវជនងាយរងគ្រោះ សិស្សរៀនភាសាអង់គ្លេស និងសិស្សដែលមានប្រាក់ចំណូលទាប ទទួលបាននូវឯកសារណែនាំ ដើម្បីជាជំនួយដល់ការចូលរួមរបស់សិស្ស ក្នុងពេលសិក្សាពីចម្ងាយ និងទទួលបាននូវសម្ភារៈសិក្សា នៅពេលដែលមានការផ្តល់ជូនការណែ នាំដោយផ្ទាល់។ សៀវភៅមគ្គុទេសក៍អំពីការសិក្សាពីចម្ងាយត្រូវបានបកប្រែជាច្រើនភាសា ដើម្បីបង្កើនភាពងាយស្រួលដល់យុវជនងាយរងគ្រោះ សិស្សរៀនភាសាអង់គ្លេស និងគ្រួសារដែលមានចំណូលទាប ដើម្បីស្វែងយល់កាន់តែស៊ីជម្រៅអំពីការរំពឹងទុក និងធនធានដែលមាន ក្នុងការសិក្សា ពីចម្ងាយ។ កម្មវិធីផ្តល់ប្រាក់កម្ចីត្រូវបានផ្តល់ជូនដល់យុវជនងាយរងគ្រោះ សិស្សរៀនភាសាអង់គ្លេស និងសិស្សដែលមានចំណូលទាប ដោយមាន ជំនួយពីលោកគ្រូ

អ្នកគ្រូដោយផ្ទាល់ ដែលជួយសិស្សស្តារគណនេយ្យនៅក្នុងការសិក្សាពីចម្ងាយ។ ខ្សែសាកថ្មសម្រាប់បញ្ចូលថ្មកុំព្យូទ័រយួរដៃត្រូវបានទិញជូនយុវជនងាយរងគ្រោះ គ្រួសារដែលស្ថិតក្នុងអន្តរកាល និងយុវជនដែលគ្មានជំនួយ ដើម្បីបង្កើនសមត្ថភាពរក្សាឧបករណ៍របស់ពួកគេ ទទួលបានការសិក្សាពីចម្ងាយ និងធនធានតាមអ៊ីនធឺណិត។ យុវជនស្ម័គ្រចិត្ត និងគ្រួសារដែលស្ថិតក្នុងអន្តរកាល នឹងទទួលបានការបណ្តុះបណ្តាលបន្ថែមទៀតនៅឆ្នាំនេះ ដើម្បីជួយកែលំអសេវាកម្ម និងជំនួយដែលយើងផ្តល់ជូនដល់យុវជនក្នុងការបណ្តុះបណ្តាលនៅទូទាំង SUSD។

ចំពោះសិស្សរៀនភាសាអង់គ្លេស ការប្រាស្រ័យទាក់ទងប្រចាំថ្ងៃ និងការរំពឹងទុកអំពីការការប្រាស្រ័យទាក់ទងនេះ ដែលកើតមាននៅក្នុងថ្ងៃសិក្សាគឺជាចំណុចនៃការអភិវឌ្ឍ និងសេវាបកប្រែភាសា។ ក្នុងការសិក្សាពីចម្ងាយ ឱកាសចូលរួមក្នុងការសន្ទនា និងចូលរួមជាមួយមិត្តភក្តិ ក្នុងពេលឆ្លងកាត់ការឈប់សម្រាក ពេលសំរាក អាហារថ្ងៃត្រង់ និងបទពិសោធន៍នៅក្នុងថ្នាក់រៀន និងជុំវិញបរិវេណសាលាមិនមានភាពងាយស្រួលដល់សិស្សរៀនភាសាអង់គ្លេសទេ។ ការិយាល័យអភិវឌ្ឍន៍ភាសា និងសាលារៀនកំពុងបង្កើតអាហារថ្ងៃត្រង់ តាមអ៊ីនធឺណិត ឱកាសបង្កើនសមត្ថភាពសិស្ស ការ ប្រមូលផ្តុំសិស្សនៅក្នុងវេទិកាសិក្សាពីចម្ងាយ ដើម្បីផ្តល់ជូននូវលំហអ៊ីនធឺណិតមួយដែលវិជ្ជមាន និងសុវត្ថិភាព សម្រាប់អន្តរកម្មតាមប្រព័ន្ធអ៊ីនធឺណិត និងបទពិសោធន៍អំពីសង្គមឧបនីយកម្ម ដែលកើតឡើងរវាងសិស្សនិងបុគ្គលិក។ មុនពេលសិក្សាពីចម្ងាយ ឧបសគ្គផ្សេងៗ ដូចជាការដឹកជញ្ជូនកីឡា ម៉ោងសិក្សាជាន់គ្នា បានធ្វើឲ្យយុវជនងាយរងគ្រោះ សិស្សរៀនភាសាអង់គ្លេស និងសិស្សដែលមានចំណូលទាប មិនអាចចូលក្លឹបនានា មុនពេល និងក្រោយពេលសិក្សា និងការផ្តល់ជំនួយសិក្សា។ ឥឡូវនេះ ចំពោះសិស្សទាំងអស់ដែលទទួលបាននូវកុំព្យូទ័រយួរដៃ និងសេវាវ៉ាយហ្វាយពី SUSD សកម្មភាពចូលក្លឹប សកម្មភាពកំសាន្ត ម៉ោងរៀនតាមផ្ទះ និងជំនួយកិច្ចការផ្ទះ បានកើនឡើង និងប្រសើរឡើង តាមរយៈការផ្តល់ការតភ្ជាប់ដល់សិស្ស។ ឥឡូវនេះ យុវជនងាយរងគ្រោះ សិស្សរៀនភាសាអង់គ្លេស និងសិស្សដែលមានចំណូលទាប អាចទទួលបានជំនួយសិក្សា វគ្គសិក្សាអំពីសុខភាព ផ្លូវចិត្ត ឱកាសសុខមាលភាពសង្គម និងបទពិសោធន៍សប្បាយក្នុងសង្គម។ ការិយាល័យអភិវឌ្ឍន៍ភាសា (LDO) ប្តេជ្ញាបម្រើសេចក្តីត្រូវការរបស់សិស្ស រៀនភាសាអង់គ្លេស និងផ្តល់ជំនួយលើការសិក្សាពីចម្ងាយ និងការសិក្សាក្នុងថ្នាក់ជាប្រចាំ ដើម្បីធានាថា សិស្សរៀនភាសាអង់គ្លេស (ELs) ទទួលបានបង្រៀនដំបូង និងបទពិសោធន៍ប្រកបដោយគុណភាពខ្ពស់ ដើម្បីគាំទ្រដល់សិស្សរៀនភាសាអង់គ្លេស (ELs) ដែលទទួលបានជំនាញភាសា អង់គ្លេស ជំនាញសិក្សា និងវាក្យសព្ទតាមស្តង់ដារនៃកម្រិតសមិទ្ធិកម្មសិក្សា។ ការឈានទៅដល់ការទំនាក់ទំនង និងជំនួយបន្ថែមត្រូវបានផ្តល់ដោយបុគ្គលិកនៃការិយាល័យអភិវឌ្ឍន៍ភាសា (LDO) សហការជាមួយ SUSD និងទីភ្នាក់ងារខាងក្រៅ ដើម្បីធានាបាននូវសេវាកម្មបន្ទាប់បន្សំ ដើម្បី ដោះស្រាយបញ្ហា និងឧបសគ្គរបស់សិស្ស និងគ្រួសារសិស្ស តាមរយៈគោលវិធីព្យាបាលជម្ងឺប៉ះទង្គិចផ្លូវចិត្តរបស់កុមារ។

ការដោះស្រាយតម្រូវការផ្សេងៗគ្នារបស់សិស្សដែលមានចំណូលទាប សេវាកម្មត្រូវបានបង្កើន និងកែលម្អ នៅក្នុងវិស័យសុខភាពផ្លូវចិត្ត បទពិសោធន៍ស្តារយុត្តិធម៌ឡើងវិញ ការទទួលបានការថែទាំ សេវាកម្មពីមណ្ឌលសុខភាព បទពិសោធន៍ស្តារឡើងវិញ និងការអភិវឌ្ឍនៃវិជ្ជាជីវៈអំពី បទពិសោធន៍ អំពីជម្ងឺប៉ះទង្គិចផ្លូវចិត្តសម្រាប់បុគ្គលិក និងសិក្ខាសាលាអំពីការសិក្សាអំពីផ្លូវចិត្ត សង្គម និងសុខុមាលភាព ដែលផ្តោតលើយុទ្ធសាស្រ្តសម្រាប់បុគ្គលិកបញ្ចូលការសិក្សាពីចម្ងាយ និងការបង្រៀនដោយផ្ទាល់ សេវាថែទាំសុខភាព ធនធានសិក្សានិងជំនួយដល់ការសិក្សា និងជំនួយលើការគ្រប់គ្រងអាកប្បកិរិយាដល់សិស្ស គ្រួសារ និងបុគ្គលិក។ សេវាអប់រំបច្ចេកទេសអាជីព (CTE) និងសេវាសិល្បៈទស្សនានិងសំដែង (VAPA) និងកម្មវិធីតម្រង់ទិសសម្រាប់វិទ្យាល័យឆ្ពោះទៅរកការឆ្លើយតបទៅនឹងតម្រូវការរបស់អ្នកមានចំណូលទាប យុវជនងាយរងគ្រោះ និងសិស្សរៀនអង់គ្លេស ព្រោះពួកគេផ្តល់ជូនម៉ូដខែល ដែលការសិក្សានៅមហាវិទ្យាល័យមានភាពបត់បែននិងលឿនដើម្បីអាជីព ហើយដែលផ្តល់នូវវេទិកាសិក្សាពីចម្ងាយ និងការ សិក្សាក្នុងថ្នាក់ដែលជួយធ្វើឱ្យសិស្សប្រឈមនឹងបញ្ហាសង្គម និងការសិក្សាផ្សេងៗគ្នា និងនៅលើផ្លូវឆ្ពោះទៅរកភាពជោគជ័យ នៅក្នុងមហាវិទ្យាល័យ ការអភិវឌ្ឍអាជីព និងជំនាញចាំបាច់សម្រាប់សិស្ស ដើម្បីឆ្ពោះទៅមុខក្នុងជីវិតជាអ្នកដឹកនាំនៅក្នុងសហគមន៍របស់ពួកគេ។ ការអភិវឌ្ឍវិជ្ជាជីវៈផ្តោត លើភាពលំអៀងជាក់ស្តែង ភាពចម្រុះ និងការដាក់បញ្ចូលការបង្រៀននិងការសិក្សាអំពីវប្បធម៌និងភាសា សមធម៌ និងការផ្តល់ការណែនាំដំបូងដែលមានគុណភាពខ្ពស់នឹងបន្តក្នុងពេលសិក្សាពីចម្ងាយ ហើយនៅពេលដែលការផ្លាស់ប្តូរទៅកាន់ការសិក្សាក្នុងថ្នាក់អាចអនុញ្ញាតបាន។ សិស្សនិងគ្រួសារដែលស្ថិតនៅក្នុងអន្តរកាល យុវជនងាយរងគ្រោះ សិស្សរៀនភាសាអង់គ្លេស សិស្សដែលមានតម្រូវការពិសេស និងសិស្សមានចំណូលទាបនឹងបន្តទទួលបានជំនួយពីការិយាល័យអប់រំនឹងបន្តទទួលបានជំនួយពីការិយាល័យអប់រំនិងការចូលរួម (Family Education and Engagement Office) ការិយាល័យគ្រួសារដែលស្ថិតក្នុងអន្តរកាលនិងយុវជនងាយរងគ្រោះ (Families In Transition and Foster Youth Office) ការិយាល័យអភិវឌ្ឍន៍ភាសា (Language Development Office) និងបុគ្គលិកទទួលបន្ទុកសុខុមាលភាពកុមារនិងវត្តមាន (Child Welfare and Attendance staff) ដើម្បីធានាថា សិស្សទទួលបានបទពិសោធន៍អប់រំប្រកបដោយគុណភាពនៅក្នុងការសិក្សាពីចម្ងាយមានការតភ្ជាប់ប្រព័ន្ធអ៊ីនធឺណិតដើម្បីទទួលបានការសិក្សាពីចម្ងាយ ដឹង និងជួយដល់ការទទួលបានធនធាន ដែលផ្តល់ជូននៅសង្កាត់ (district) និងក្រុង ហើយបន្តផ្តល់ធនធាន ដូចជា សិក្ខាសាលា និងការបណ្តុះ បណ្តាលអំពីការត្រៀមខ្លួនសម្រាប់ការងារ សេវាសុខមាលភាពគ្លីនិក ឡានក្រុង អាហារ ការផ្គត់ផ្គង់ដល់ការសិក្សា ជំនួយចូលទៅកាន់លំនៅដ្ឋាន សេវាបកប្រែ

និងសេវាចាំបាច់ផ្សេងទៀត ក្នុងការសិក្សាពីចម្ងាយ និងការសិក្សាក្នុងថ្នាក់។

ការរីកចម្រើនថ្មីមួយទៀតដែលស្របជាមួយនឹងការតភ្ជាប់ និងការបែងចែកបច្ចេកវិទ្យានៅលំនៅដ្ឋានរបស់សិស្សដែលបានចុះឈ្មោះគឺសម្រាប់យុវជន ងាយរងគ្រោះ សិស្សរៀនភាសាអង់គ្លេស និងគ្រួសារដែលមានចំណូលទាប អាចទទួលបានវេទិកាតាមអ៊ីនធឺណិត សម្រាប់ការប្រជុំសិក្ខាសាលារបស់សង្កាត់ (district) និងព្រឹត្តិការណ៍នានាដែលអនុញ្ញាតការចូលរួមឱ្យកាន់តែច្រើន ពីគ្រួសារដែលដោយសារតែឧបសគ្គមួយ ឬក៏ អថេរមួយផ្សេងទៀត មិនអាចចូលរួមព្រឹត្តិការណ៍ ឬក៏ផ្តល់ជូនដោយផ្ទាល់របស់សង្កាត់ (district)។ SUSD ក៏បានបង្កើតគេហទំព័រធនធានដែលអាចចូលទៅមើល ដោយចុចលើរូបដៃ ដែលរកឃើញនៅលើគេហទំព័រគ្រួសារ គេហទំព័រដើមរបស់ SUSD និងគេហទំព័ររបស់សាលាទាំងអស់ដែលផ្តល់នូវបណ្ណាល័យធនធាននិង ព័ត៌មានសម្រាប់គ្រួសារប្រើប្រាស់។ ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់យុវជនងាយរងគ្រោះ សិស្សរៀនភាសាអង់គ្លេស និងគ្រួសារ ដែលមានប្រាក់ចំណូលទាប SUSD បានបង្កើតបណ្ណាល័យវីដេអូ សិក្ខាសាលា ការបណ្តុះបណ្តាល និងការផ្តល់ជូនការអភិវឌ្ឍជំនាញជាច្រើនភាសា ដើម្បីឱ្យគ្រួសារ សិស្ស និងបុគ្គលិកអាចទទួលបានធនធាន និងចូលមើលព័ត៌មានឡើងវិញដែលបានចែករំលែកនៅពេលដែលត្រូវនឹងកាលវិភាគ របស់ពួកគេ។ មាតាបិតាសិស្ស និងអាណាព្យាបាលមានលទ្ធភាពចូលរួមការប្រជុំពីទីតាំងដែលងាយស្រួលសម្រាប់ពួកគេ និងបង្កើនការចូលរួម បន្ថែមសម្លេងរបស់ពួកគេនៅក្នុង ដំណើរការរៀបចំផែនការសាលារៀន និងតម្រូវការដែលត្រូវគ្នាជាមួយកូនៗរបស់គេ។ បន្ទប់បង្រៀននិម្មិត ជំនួយ ដល់លំហាត់ធ្វើនៅផ្ទះ និងកន្លែងសម្រាកលំហែអារម្មណ៍ស្ថិតក្នុងចំណោមការផ្តល់តាមអ៊ីនធឺណិតមួយចំនួនដែលត្រូវបានផ្តល់ជូនដល់សិស្ស គ្រួសារ និងបុគ្គលិកដែលតំណាងឱ្យសេវាកាន់តែប្រសើរឡើង ដែលបង្កើនលទ្ធភាពទទួលបានការសិក្សារីកចម្រើន និងសេវាអភិវឌ្ឍន៍អារម្មណ៍និងសង្គម។ ម៉ោងធ្វើការរបស់សាលាធ្វើនៅពេលល្ងាច ដើម្បី ផ្តល់ឱកាសដល់យុវជនងាយរងគ្រោះ សិស្សរៀនភាសាអង់គ្លេស និងគ្រួសារដែលមានចំណូលទាប ដើម្បីសួរសំណួរ ទទួលជំនួយ និងត្រូវបាន ផ្តល់ព័ត៌មានអំពីវិធីទទួលបានធនធានដែលផ្តល់ដោយបុគ្គលិក និងរដ្ឋបាលនៅសាលារៀននៅទូទាំងសង្កាត់ (district) ផ្តោតលើសមធម៌ និង លទ្ធភាពទទួលបាន។

ការលើកទឹកចិត្តក្នុងការចូលរួម និងប្រព័ន្ធប្រចាំថ្ងៃ ប្រចាំសប្តាហ៍ និងប្រចាំខែសម្រាប់យុវជនងាយរងគ្រោះ សិស្សរៀនភាសាអង់គ្លេស និងសិស្ស ដែលមានចំណូលទាប ដើម្បីជួយពង្រឹងអំពីភាពចាំបាច់របស់សិស្សក្នុងការចូលរួមក្នុងការសិក្សាពីចម្ងាយ និងចូលរួមក្នុងការសិក្សាសមកាលកម្ម និង អសមកាល គ្នាជារៀងរាល់ថ្ងៃ។ ជាយុទ្ធសាស្ត្រ បុគ្គលិក នឹងជួយដល់គ្រួសារដើម្បីធានាថា សិស្សកំពុងសិក្សាពីចម្ងាយ និងការផ្តល់ការសិក្សាដោយ ផ្ទាល់ បុគ្គលិកបង្រៀន នឹងរក្សាកំណត់ត្រាអំពីការចូលរួមប្រចាំសប្តាហ៍ដើម្បីឲ្យសិស្សម្នាក់ៗធ្វើឯកសារដែលមានលក្ខណៈស៊ីចង្វាក់គ្នា និងអចិន្ត្រៃយ៍ សម្រាប់ ការសិក្សាពីចម្ងាយទាំងមូល ឬដោយផ្នែក ផ្ទៀងផ្ទាត់វត្តមាន និងតាមដានកិច្ចការរបស់សិស្ស។ ដំណើរការនេះនឹងជួយគាំទ្រដល់ការតាម ដានវឌ្ឍនភាព របស់ក្រុមសិស្សបង្គោល និងផ្តល់នូវការរួមបញ្ចូលគ្នានៃជំនួយជាក្រុមដើម្បីដោះស្រាយឧបសគ្គនានាចំពោះការសិក្សាប្រចាំថ្ងៃរបស់សិស្ស និងការទទួល បានបទពិសោធន៍សិក្សា។ សេវាប្រឹក្សាយោបល់ និងសេវាណែនាំ ត្រូវបានផ្តល់ជូនដល់យុវជនងាយរងគ្រោះ សិស្សរៀនភាសាអង់គ្លេស និងសិស្សដែល មានចំណូលទាប ផ្តល់ជំនួយអារម្មណ៍សង្គមនិងអារម្មណ៍ សំដៅជួយសិស្ស និងដោះស្រាយបញ្ហាប្រឈមនានាអំពីវត្តមានប្រចាំថ្ងៃ តាមរយៈ ការបង្កើត នូវសេវាកម្មសិស្សគ្រប់ជ្រុងជ្រោយ ដោយបង្កើតទំនាក់ទំនងប្រកបដោយភាពជឿជាក់ និងការទុកចិត្តគ្នា។ ខណៈពេលដែលធានាថា តម្រូវការរបស់ សិស្សត្រូវបានបំពេញទាំងនៅក្នុងថ្នាក់រៀន និងក្រៅថ្នាក់រៀន។ ការដោះស្រាយតម្រូវការរបស់ក្រុមសិស្សមានវិសាលភាពទូលំទូលាយ និងជួយដល់ ភាពជោគជ័យរបស់សិស្ស វត្តមានរបស់សិស្សនិន្នាការអាកប្បកិរិយាវិជ្ជមាន ការកំណត់គោលដៅសិក្សា និងការសិក្សារីកចម្រើន និងការបញ្ចប់ ការសិក្សា។